

# ធម៌នមស្ការ និង ធម្មបទ

ភិក្ខុ សីលសំវរោ ឯក សំ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# “ធម៌នមស្ការ និងគាថាធម្មបទ”

រៀបរៀងដោយ

**ភិក្ខុ សីលសំវរោ ឯក សំ**

សម្រាប់ចែកផ្សាយជាធម្មទាន

រក្សាសិទ្ធិគ្រប់បែបយ៉ាង

ព.ស.២៥៦៩ គ.ស.២០២៥

# ប្រារព្ធកថា

## "ពុទ្ធាយនមោ នមេ សទ្ធម៉ាយ សង្ឃាយ ទធ្មេ សានរមិ"

"សូមថ្វាយបង្គំចំពោះព្រះមហាបុរសដោយសេចក្តីគោរព"

ដោយសេចក្តីសោមនស្សជ្រះថ្លាយ៉ាងជ្រាលជ្រៅ រកអ្វីប្រៀបផ្ទឹមពុំបាន ចំពោះពុទ្ធោវាទ ព្រមទាំងធម្មគុណ និងសង្ឃគុណ ដែលជាត្រៃសរណគមន៍ដ៏ខ្ពង់ខ្ពស់បំផុត និងចំពោះធម្មទស្សន៍ទាំងឡាយដែលព្រះសម្មាសម្ពុទ្ធជាអង្គម្ចាស់ ទ្រង់បានសម្តែងទុកដើម្បីជាប្រយោជន៍ដល់វេនេយ្យសត្វលោកក្នុងត្រៃភព។ ព្រះសម្ពុទ្ធទាំងឡាយ ព្រះអង្គជាបិតានិរោធ ទ្រង់បានបំពេញនូវបារមីធម៌ អស់រយៈពេលយ៉ាងយូរអង្វែងដោយសទ្ធាធិក វិរិយាធិក ឬបញ្ញាធិក ដើម្បីបានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញាណ។ ព្រះអង្គទ្រង់ប្រកបដោយមហាករុណាទិគុណ និងមហាព្រហ្មវិហារធម៌ ចំពោះសត្វលោកទាំងឡាយ។ ការសម្តែងនូវ "ធម្មយាន" របស់ព្រះអង្គ ដើម្បីសង្គ្រោះមនុស្សលោក ទេវលោក មារ និងព្រហ្មលោក ឱ្យបានរួចផុតចាកទុក្ខ និងញ៉ាំងសព្វសត្វដែលមានឧបនិស្ស័យឱ្យបានសម្រេចមគ្គផល ពោលគឺជាបេសកកម្មដ៏ឧត្តមដែលព្រះបរមសាស្តាបានបំពេញយ៉ាងសកម្មពេញមួយព្រះជន្ម៤៥ព្រះ វស្សា។ ព្រះធម៌ក្តី ព្រះវិន័យក្តី និងធម្មាបដិបត្តិក្តី ដែលព្រះអង្គបានបតិស្ឋានទុកជាមរតកដ៏ថ្លៃថ្លានេះ សុទ្ធតែ

ជាយាន សម្រាប់ពុទ្ធបរិស័ទគ្រប់ៗរូប យកមកសិក្សា រៀនសូត្រ និងប្រតិបត្តិក្នុងជីវិតប្រចាំថ្ងៃ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីចម្រើន និងសេចក្តីសុខ ក្នុងលោកនេះ និងបរលោកខាងនាយ។

ដោយសារបុព្វហេតុនៃឧបនិស្ស័យ និងការបានសាងផ្នួសក្នុងសំណាក់ព្រះពុទ្ធសាសនានេះហើយ ទើបជាហេតុនាំឱ្យខ្ញុំព្រះករុណា អាត្មាភាព បានសិក្សាឈ្វេងយល់នូវពុទ្ធវចនរបស់ព្រះជិនស្រី និងបានយល់ច្បាស់ពីគុណូបការនៃព្រះធម៌ដ៏បរិសុទ្ធនេះ។ អាស្រ័យហេតុនេះ ទើបខ្ញុំព្រះករុណា អាត្មាភាព មានការព្យាយាមរៀបរៀង និងចងក្រងសៀវភៅ "ធម៌នមស្សការ និងធម្មបទគាថា" នេះឡើង ដើម្បីទុកជាប្រទីបបំភ្លឺ ភាពងងឹតសូន្យឈឹងរបស់សត្វលោក ដែលកំពុងស្វែងរកជម្រាបជិបត្តិសម្រាប់ដឹកនាំជីវិត។ ដោយអំណាចនៃបុញ្ញកម្ម និងកុសលចេតនានៃការរៀបរៀងសៀវភៅនេះ សូមឱ្យសព្វសត្វទាំងឡាយបានប្រកបដោយឧបនិស្ស័យបានសិក្សា និងយល់ច្បាស់ក្នុងអរិយសច្ចធម៌ ហើយបានជាបច្ច័យនាំឱ្យរួចផុតចាកទុក្ខគ្រប់ៗគ្នា។

**"នត្ថិ បញ្ញា សមា អាភា"**

(គ្មានពន្លឺអ្វីស្មើនឹងពន្លឺបញ្ញាឡើយ)

ថ្ងៃចន្ទ ១១កើត ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៦៩

**ភិក្ខុ សីលសំវរោ ឯក សំ**

# គុណកថា

ព្រះពុទ្ធសាសនា គឺជាមជ្ឈមណ្ឌលក្នុងការបណ្តុះបណ្តាលនូវគុណធម៌ សីលធម៌ សុជីវធម៌ និងជាប្រភពនៃការសាងឧបនិស្ស័យ ឱ្យមនុស្សគ្រប់រូបប្រកបដោយសុចរិតភាព និងគុណតម្លៃក្នុងសង្គម។ ខ្ញុំព្រះករុណា អាត្មាភាព មានភព្វសំណាងដែលបានមកជ្រកកោនក្រោមម្លប់ និងបានសាងផ្នួសក្នុងព្រះពុទ្ធសាសនា ព្រមទាំងបានសិក្សាឈ្វេងយល់នូវធម្មរសដ៏បរិសុទ្ធរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ដែលនេះពិតជាឱកាសដ៏ក្រៃលែងនិងកម្ររកបានជាទីបំផុត។ ដោយអំណាចនៃបុញ្ញកម្មនេះសូមឱ្យបានជាគ្រឹះយ៉ាងរឹងមាំក្នុងការទ្រទ្រង់ និងលើកស្ទួយផ្សព្វផ្សាយព្រះពុទ្ធសាសនាឱ្យកាន់តែមានការរីកចម្រើន រុងរឿង និងស្ថិតស្ថេរចីរកាលដុះដាលជានិច្ច ជានិរន្តរ៍។ម្យ៉ាងវិញទៀត អាស្រ័យដោយបុព្វេកតបុញ្ញកុសលដែលបានសាងពីអតីតជាតិ និងដោយគុណូបការធម៌ ពីលោកអ្នកមានគុណទាំងទ្វេ គឺ លោកពុក **សួស សុខ** និង អ្នកម្តាយ **ខាត់ ឃឿន** ដែលជាអ្នកផ្តល់កំណើត បីបាច់ថែរក្សា ទំនុកបម្រុង និងអប់រំទូន្មានខ្ញុំព្រះករុណា អាត្មាភាព ដោយក្តីស្រឡាញ់យ៉ាងជ្រាលជ្រៅបំផុត។ លើសពីនេះ លោកទាំងពីរព្រមទាំងបានអនុញ្ញាតឱ្យខ្ញុំព្រះករុណា អាត្មាភាពបានសាងផ្នួសដើម្បីបន្តការសិក្សារៀនសូត្រទាំងផ្លូវលោក និងផ្លូវធម៌ រហូតមក

ដល់ពេលនេះៗ គុណូបការដ៏មហិមារនេះពិតជាមិនអាចតបស្នង គុណនេះបានឡើយ។ ម្យ៉ាងទៀតការបួសនិងការសិក្សារៀន សូត្ររបស់អាត្មាភាពបានមកដល់ចំណុចនេះ គឺដោយសារការ ឧបត្ថម្ភ និងទំនុកបម្រុងពីសម្នាក់ញាតិញោមគ្រប់ទិសទីទាំងអស់ សូមឲ្យបុញ្ញកម្មនេះបានសម្រេចជាឧត្តមប្រយោជន៍ដល់ញាតិញោម គ្រប់ៗគ្នាកុំបីខានៗ ជាពិសេសសូមបុញ្ញកុសលនេះបានសម្រេច ដល់ញោមឧបាសិកា ខៀវ មូលី ដែលញោមជានិច្ចកាលបានផ្ដល់ គំនិត បណ្ដុះនូវគំនិតនិងថវិកាសម្រាប់ការសិក្សារៀនសូត្រតាំង ពីដើមរហូតមក។

"ការដឹងគុណ ជាមូលដ្ឋានបណ្ដុះឧត្តមភាពជីវិត"

# ឧទ្ទិសកថា

កុសលទាំងឡាយឯណា ដែលកើតឡើងហើយចេញពីសេចក្ដីព្យាយាមទាំងឡាយនៃខ្ញុំ ខ្ញុំសូមថ្វាយកុសលទាំងឡាយនោះ ចំពោះអង្គព្រះមហាក្សត្រខ្មែរគ្រប់ជំនាន់ដែលទ្រង់ដឹកនាំជាតិប្រកបដោយទសពិធរាជធម៌។ បុរសឯណាមួយដែលមានស្មារតីភក្ដីចំពោះជាតិ មានភាពក្លាហានក្នុងសន្ដាន លះភាពសុខសប្បាយដេកត្រាំដោយទឹកសន្សើម និងភក់ រាងកាយប្រលាក់ដោយឈាមនៃបច្ចាមិត្ត ខ្ញុំសូមឧទ្ទិសកុសលនេះជូនចំពោះបុរសទាំងឡាយនោះ។ អ្នកប្រាជ្ញ ជាសមណក្ដី ជាគ្រហស្ថក្ដី ដែលបានលះបង់ហើយ នូវសេចក្ដីលោភៈ លះពេលនូវកាលពីព្រះសុរិយាគោចរហូតអស់រាត្រីទាំងឡាយ ដើម្បីសិក្សានូវចំណេះដឹងបដិបត្តិអង្គនៃបណ្ឌិតរក្សានូវភាពជាបុគ្គលថ្លៃថ្នូរ បដិបត្តិនូវឱវាទនៃព្រះមហាបុរស ខ្ញុំសូមឧទ្ទិសកុសលនេះជូនចំពោះលោកទាំងឡាយនោះ។ សូមឧទ្ទិសជូនចំពោះញាតិទាំងឡាយនៃខ្ញុំក្នុងវដ្ត...។

**- ឆ ឃាំ សារៈ រៀបរៀងនេះ រមណ្ដេ -**

**(បាឌ្ញមិនអាស្រ័យនៅក្នុងព្រៃស្មសាន)**

# សារបណ្ណ

អារម្ភកថា ———— ក
គុណកថា ———— គ
ឧទ្ទិសកថា ———— ឃ
១.ពុទ្ធុប្បត្តិសង្ខេប ———— ១
២.ធម៌ធម៌នមស្សការព្រះរតនត្រ័យ ———— ៩
៣.វិធីសមាទានសីល ———— ៨៥
៤.ធម្មបទគាថា ———— ១១៣
គន្ថនិទ្ទេស ———— ២០០

**អ្នករៀបរៀង និងចងក្រង**

ភិក្ខុ សីលសំវរោ **ឯក សំ**

**គណៈកម្មការបច្ចេកទេស**

សមណនិស្សិត **រុន វ៉ាណា (អមរិន្ទ)**

**គណៈកម្មត្រួតពិនិត្យអក្ខរាវិរុទ្ធ**

**ក្រុមអ្នកនិពន្ធកម្ពុជា**

**គណៈកម្មការរចនាបថក្របរឹង និងសោភ័ណភាព**

សមណនិស្សិត **រុន វ៉ាណា (អមរិន្ទ)**

# ពុទ្ធប្បវត្តិសង្ខេប

## ១-សន្តុសិតទេវបុត្រច្យុតិចាកទេវលោក

ក្រោយពីព្រះពោធិសត្វលោកបានបំពេញទានបារមីក្នុងអត្តភាពជាព្រះវេស្សន្តររួចមក ព្រះអង្គបានចុតិយាងទៅចាប់បដិសន្ធិក្នុងស្ថានតុសិត ព្រះនាមថា “សន្តុសិតទេវបុត្រ”។ លុះដល់កាលគួរ ទេវតាទាំងឡាយក្នុងមួយសែនចក្រវាឡ បានជ្រាបថា សន្តុសិតទេវបុត្រនឹងត្រូវត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធក្នុងលោក ទើបនាំគ្នាចូលទៅអារាធនាព្រះអង្គ ឱ្យយាងចុះមកចាប់បដិសន្ធិក្នុងមនុស្សលោក។ មុននឹងទទួលពាក្យអារាធនា ព្រះពោធិសត្វទ្រង់បានពិចារណាមើលយ៉ាងល្អិតល្អន់នូវ មហាវិលោកនៈទាំង៥ប្រការដែលរួមមាន៖

**កាល** (អាយុកាល)៖ ជាធម្មតា ព្រះពុទ្ធទាំងឡាយទ្រង់មិនត្រាស់ដឹងក្នុងយុគសម័យដែលមនុស្សមានអាយុលើសពី ១សែនឆ្នាំ ឬតិចជាង ១រយឆ្នាំឡើយ។ ព្រះពោធិសត្វតែងយាងមកត្រាស់ដឹង ក្នុងចន្លោះពេលដែលមនុស្សមានអាយុពី ១រយឆ្នាំ ទៅ ១សែនឆ្នាំ។

**ទ្វីប** (ទីតាំង)៖ ព្រះពុទ្ធទាំងឡាយ ទ្រង់ត្រាស់ដឹងតែក្នុងជម្ពូទ្វីបមួយប៉ុណ្ណោះ។

**បទេស** (តំបន់)៖ ព្រះពុទ្ធទាំងឡាយ ទ្រង់ត្រាស់ដឹងតែក្នុងមជ្ឈិមប្រទេសប៉ុណ្ណោះ។

**គោត្រត្រកូល** (វណ្ណៈ)៖ ព្រះពុទ្ធទាំងឡាយ ទ្រង់មិនបដិសន្ធិក្នុងត្រកូលវេស្សៈ (អ្នកជំនួញ) និងសូទ្រៈ (អ្នកបម្រើ) ឡើយ ពោលគឺទ្រង់ជ្រើសរើសតែត្រកូលក្សត្រ ឬត្រកូលព្រាហ្មណ៍ប៉ុណ្ណោះ។

**មាតា**៖ ពុទ្ធមាតា ត្រូវតែជាស្ត្រីបរិសុទ្ធ មិនមានសភាពល្បះល្បោះ មិនសេពសុរា ជាស្ត្រីដែលបានសាងបារមីធម៌រាប់សែនកប្បមកហើយ ព្រមទាំងមានសីល ៥ ស្អាតបរិសុទ្ធជានិច្ច។

បន្ទាប់ពីទ្រង់បានពិចារណាមើលមហាវិលោកនៈទាំង៥រួចរាល់ ព្រះពោធិសត្វទ្រង់ទតឃើញថា ជម្ពូទ្វីបជា**មណ្ឌលចក្រវាល** មាននគរកបិលពស្តុស្ថិតក្នុងមជ្ឈិមប្រទេស មានត្រកូលក្សត្រដ៏ប្រសើរ និងមានព្រះមាតាដ៏បវរ ទើបទ្រង់បង្អោនព្រះទ័យយាងចុះមកបដិសន្ធិក្នុងត្រកូលក្សត្រ នៃព្រះបាទសុទ្ធោទនៈ និងព្រះនាងសិរិមហាមាយា ក្នុងគោតមគោត្រ។

ព្រះពោធិសត្វទ្រង់យាងចុះចាប់បដិសន្ធិក្នុងព្រះគភ៌ព្រះនាងសិរិមហាមាយា នៅថ្ងៃព្រហស្បតិ៍ ១៥កើត ពេញបូណ៌មី ខែអាសាឍ មុនពុទ្ធសករាជ ៨០ឆ្នាំ និង ១០ខែ។ ក្នុងខណៈនោះ លោកធាតុទាំង ១ សែនចក្រវាល ក៏កក្រើកញាប់ញ័ររំពើកឡើង ព្រមទាំងមានបុព្វនិមិត្តអស្ចារ្យ ៣២ ប្រការ កើតឡើងប្រាកដក្នុងខណៈនោះរួមមាន៖ ពន្លឺ

ភ្លឺស្វាងរកប្រមាណមិនបានផ្សាយពេញសព្វទិសទី១ មនុស្សខ្វាក់អាចមើលឃើញ១ មនុស្សថ្លង់អាចស្តាប់ឮ១ មនុស្សគអាចនិយាយបាន១ មនុស្សគមអាចឈរខ្លួនត្រង់១ មនុស្សខ្វិនអាចដើរបាន១ សត្វជាប់ចំណងត្រូវបានរួចខ្លួន១ ភ្លើងនរកត្រូវរលត់១ សត្វលោកបាត់បង់សេចក្តីស្រេកឃ្លាន១ សត្វតិរច្ឆានលែងភ័យខ្លាចគ្នា១ រាល់ជំងឺសព្វសត្វត្រូវបានសះស្បើយ១ មនុស្សម្នានិយាយរកគ្នាដោយសេចក្តីមេត្តា១ សេះនិងដំរីបញ្ចេញសម្រែកយ៉ាងពីរោះ១ តន្ត្រីគ្រប់ប្រភេទបន្លឺសំឡេងឡើងដោយឯងៗ១ កងដៃមនុស្សប៉ះទង្គិចគ្នាឮសូររណ្តំ១ គ្រប់ទិសទីមានសភាពស្រឡះល្អ១ ខ្យល់ត្រជាក់បក់នាំមកនូវសេចក្តីសុខ១ ភ្លៀងធ្លាក់ខុសរដូវកាល១ ទឹកផុសចេញពីដែនដី១ សត្វបក្សីឈប់ហើរ១ ទឹកស្ទឹងឈប់ហូរ១ ទឹកសមុទ្រប្រែក្លាយជារសផ្អែម១ ផ្កាឈូក ៥ប្រភេទនិងផ្កាឈើគ្រប់មុខរីកស្គុសស្គាយគ្រប់ទីកន្លែង ទម្លុះសូម្បីតែផ្ទៃសិលា១ មានភ្លៀងផ្កាធ្លាក់ពីលើអាកាស និងមានសំឡេងទិព្វតន្ត្រីបន្លឺឡើងយ៉ាងពីរោះរណ្តំ១។

សម័យនោះ នគរកបិលពស្តុមានប្រារព្ធពិធីបុណ្យនក្ខត្តឫក្សខែអាសាឍយ៉ាងគគ្រឹកគគ្រេង។ ព្រះនាងមហាមាយាទេវី បានចូលរួមពិធីនេះតាំងពី ៧ថ្ងៃមុន តែលុះដល់ថ្ងៃពេញបូណ៌មី ព្រះនាងក៏ទ្រង់ស្រង់ទឹកក្រអូប លះបង់ព្រះរាជទ្រព្យ ៤សែនកហាបណៈធ្វើ

ជាទាន និងទ្រង់សមាទានឧបោសថសីលរួច ទើបយាងចូលព្រះក្រឡាបន្ទំ ផ្ទំលើព្រះសិរិសេយ្យាសនា។ នារាត្រីនោះ ព្រះនាងទ្រង់យល់ព្រះសុបិននិមិត្តដ៏អស្ចារ្យថា៖

មហារាជទាំង៤ បានមកលើកព្រះនាងព្រមទាំងសេយ្យាសនា នាំឆ្ពោះទៅកាន់ព្រៃហេមពាន្ត ដាក់លើផ្ទៃមនោសិលាក្រោមដើមសាលព្រឹក្សដ៏ធំ។ លំដាប់នោះ ព្រះមហេសីនៃមហារាជទាំង៤ បានយាងព្រះនាងចុះទៅស្រង់ទឹកក្នុងស្រះអនោតត្តដើម្បីជម្រះមន្ទិលទាំងពួង រួចថ្វាយសំពត់ទិព្វ លាបស្រឡាបគ្រឿងក្រអូប និងប្រដាប់ដោយផ្កាឈើទិព្វ។ បន្ទាប់មក ទេវតាបាននាំព្រះនាងទៅកាន់វិមានមាស លើកូនភ្នំប្រាក់ ទ្រង់ផ្ទំបែរព្រះសិរិសាទៅទិសខាងកើត។ គ្រានោះ មានសេតដំរី (ដំរីស) ដ៏ប្រសើរមួយ យាងចុះពីភ្នំមាស ឡើងមកកាន់ភ្នំប្រាក់ ដោយយកប្រមោយចាប់កាន់ផ្កាឈូកស បន្លឺសំឡេងកោញ្ចនាទ ដើរចូលទៅប្រទក្សិណព្រះនាង៣ជុំ រួចហាក់បីដូចជាយាងជ្រែកចូលតាមផ្ទៃព្រះឧទរខាងស្តាំនៃព្រះនាង។

លុះព្រឹកឡើង ព្រះនាងបានក្រាបទូលព្រះសុបិននេះថ្វាយព្រះបាទសុទ្ធោទនៈ។ ព្រាហ្មណ៍បុរោហិតទាំងឡាយបានទស្សន៍ទាយថា ព្រះនាងនឹងប្រសូតបានព្រះរាជបុត្រាជាអ្នកមានបុណ្យបារមីដ៏អស្ចារ្យបំផុតក្នុងលោក។ ក្នុងកំឡុងពេលព្រះពោធិសត្វគង់ក្នុងព្រះ

គតិ ទេវមហារាជទាំង៤ (ព្រះបាទធតរដ្ឋ វិរុឡ្ហកៈ វិរូបក្ខៈ និងកុវេរៈ) តែង យាងមកថែរក្សាការពារព្រះគភ៌ជានិច្ច។

ការយាងចុះចាប់បដិសន្ធិនៃព្រះពោធិសត្វ តែងប្រព្រឹត្តទៅ តាមធម្មនិយាម ដ៏អស្ចារ្យជាប្រក្រតីដូចតទៅ៖

១-ព្រះពោធិសត្វច្យុតចាកស្ថានតុសិត យាងចុះកាន់ព្រះគភ៌ ព្រះមាតា ដោយមានសតិសម្បជញ្ញៈពេញបរិបូរណ៍។

២-ក្នុងខណៈនោះ ពន្លឺដ៏ភ្លឺស្វាងរកប្រមាណមិនបាន បាន កើតឡើងសព្វលោកធាតុ គ្របសង្កត់ពន្លឺទេវតាទាំងឡាយ បំភ្លឺសូម្បីតែទីងងឹតអន្ធការដែលពន្លឺព្រះអាទិត្យនិងព្រះច័ន្ទចាំងទៅមិន ដល់ (លោកន្តរនរក)។

៣-ទេវបុត្រទាំង ៤អង្គ តែងយាងមកថែរក្សាក្នុងទិសទាំង ៤ ដើម្បីការពារកុំឱ្យមានសត្រូវ ឬអមនុស្សណាមកបៀតបៀនព្រះ ពោធិសត្វ និងព្រះមាតាបានឡើយ។

៤-ព្រះមាតានៃព្រះពោធិសត្វ ក្លាយជាស្ត្រីប្រកបដោយ សីល៥ បរិសុទ្ធដោយឯកឯង។

៥-ព្រះមាតា ពុំមានសេចក្តីត្រេកត្រអាលក្នុងកាមគុណចំពោះ បុរសណាមួយឡើយ ហើយក៏គ្មានបុរសណាម្នាក់អាចប្រព្រឹត្តកន្លង លើព្រះនាងបានដែរ។

៦-ព្រះមាតា តែងបរិបូរណ៍ដោយកាមគុណទាំង៥ (រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ) ជាទីស្កប់ស្កល់ និងមានអ្នកផ្គាប់បម្រើយ៉ាងល្អខ្លោះ។

៧-ព្រះមាតា ពុំមានរោគាពាធណាមួយបៀតបៀនឡើយ ទ្រង់មានតែសេចក្តីសុខស្រួលក្នុងព្រះកាយជានិច្ច។ អស្ចារ្យបំផុតនោះគឺ ព្រះមាតាអាចទតឃើញព្រះពោធិសត្វគង់ក្នុងព្រះគភ៌ហាក់បីដូចជាស្ថិតនៅខាងក្រៅ ដោយមានអវយវៈតូចធំ និងឥន្ទ្រិយពេញបរិបូរណ៍ច្បាស់លាស់។

**២-អំពីទ្រង់ប្រសូត**

ព្រះមហាបុរសទ្រង់យាងចុះចាប់បដិសន្ធិនៅថ្ងៃព្រហស្បតិ៍ ១៥កើត ពេញបូណ៌មី ខែអាសាឍ ឆ្នាំរកា។ ព្រះអង្គគឺជាព្រះរាជបុត្រនៃព្រះបាទសុទ្ធោទនៈនិងព្រះនាងសិរិមហាមាយាទេវី ជារាជទាយាទនៃសក្យវង្ស ដែលគ្រងរាជសម្បត្តិនៅក្រុងកបិលពស្តុ ដែនសក្កៈ(ស្ថិតក្នុងប្រទេសនេប៉ាល់បច្ចុប្បន្ន)។

ព្រឹត្តិការណ៍ទ្រង់ប្រសូតបានកើតឡើង ក្នុងខណៈដែលព្រះវរមាតា ព្រះនាងមាយាទេវី ទ្រង់យាងអមដោយព្រះរាជបរិពារចេញពីរាជធានីកបិលពស្តុ ឆ្ពោះទៅកាន់ក្រុងទេវទហៈ ដែលជារាជធានីនៃព្រះរាជបិតារបស់ព្រះនាង (តាមទំនៀមស្ត្រីនៃទេវទហៈត្រូវទៅប្រសូតបុត្រនៅខាងខ្លួន)។ លុះយាងមកដល់ព្រំប្រទល់

រវាងក្រុងទាំងពីរ ត្រង់ឧទ្យានលុម្ពិនីវ័ន វេលាថ្ងៃត្រង់ជាក់ ព្រះនាង ក៏បានប្រសូតព្រះរាជបុត្រាដ៏ពិសិដ្ឋ ក្រោមដើមសាលព្រឹក្ស នៅ ថ្ងៃសុក្រ ១៥កើត ពេញបូណ៌មី ខែពិសាខ ឆ្នាំច ដោយថ្វាយព្រះ នាមថា ព្រះសិទ្ធត្ថកុមារ។

(លុះដល់ពុទ្ធសករាជ២៩៣ (មុនគ្រិស្តសករាជ ២៥០ ឆ្នាំ) ព្រះបាទអសោកមហារាជនៃប្រទេសឥណ្ឌា បានយាងមកកាន់លុម្ពិនីវ័ ន ហើយទ្រង់បានបញ្ជាឱ្យកសាងសសរថ្មមួយដើមកម្ពស់ប្រមាណ១០ ម៉ែត្រ ដើម្បីទុកជាទីសម្គាល់នៃការប្រសូតរបស់ព្រះសក្យមុនី សម្មាសម្ពុទ្ធ ដែលទីនេះចាត់ទុកជាពុទ្ធបូជនីយដ្ឋានទី១សម្រាប់ពុទ្ធ បរិស័ទគ្រប់ទិសទីមកគោរពបូជា។)

## ៣-ព្រះពុទ្ធត្រាស់ដឹង

កាលព្រះរាជកុមារសិទ្ធត្ថចម្រើនវ័យ ទ្រង់បានសិក្សាវិជ្ជាអក្សរ សាស្រ្ត និងយុទ្ធសាស្រ្តក្នុងសំណាក់សាស្រ្តាចារ្យ «វិស្វាមិត្រ»។ លុះព្រះជន្ម ១៦ ព្រះវស្សា ទ្រង់ទ្រង់អភិសេកជាមួយព្រះនាង យសោធរា (ពិម្ពា) ដែលមានព្រះជន្មស្រករគ្នា និងទ្រង់បានឡើង សោយរាជ្យជាធំលើសក្យវង្ស តំណាងព្រះរាជបិតា នៅថ្ងៃអាទិត្យ ពេញបូណ៌មី ខែកត្តិក ឆ្នាំឆ្លូវ។

ក្រោយសោយរាជ្យបាន ១៣ឆ្នាំ លុះព្រះជន្ម ២៩ ព្រះ វស្សា និងទទួលបានព្រះរាជបុត្រមួយព្រះអង្គព្រះនាម «រាហុល»

ព្រះអង្គក៏សម្រេចព្រះទ័យយាងចេញសាងព្រះផ្នួស នៅថ្ងៃព្រហស្បតិ៍ ពេញបូណ៌មី ខែអសាឍ ឆ្នាំថោះ នាឆ្នេរស្ទឹងអនោមា។ ក្រោយពីទ្រង់ព្រះផ្នួស ព្រះអង្គបានខិតខំស្វែងរកមោក្ខធម៌ ដោយការប្រព្រឹត្តទុក្ករកិរិយា (អត្តកិលមថានុយោគ) អស់រយៈពេល ៦ ឆ្នាំ នាឧរុវេលានិគម ដែនមគធៈ។ លុះទ្រង់លះបង់ការប្រព្រឹត្តដ៏តឹងរ៉ឹងនេះ ហើយងាកមកប្រតិបត្តិតាមផ្លូវកណ្តាល (មជ្ឈិមាបដិបទា) ទ្រង់ក៏បានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធប្រាកដឡើងក្នុងលោក នៅថ្ងៃពុធ១៥កើត ពេញបូណ៌មី ខែពិសាខ ឆ្នាំរកា(មុនពុទ្ធសករាជ៤៥ឆ្នាំ) ក្រោមពោធិព្រឹក្សនាត្រើយខាងលិចស្ទឹងនេរញ្ជរា ក្នុងមណ្ឌលគយា។

ទីនេះត្រូវបានហៅថា “ពុទ្ធគយា” ចាត់ជា ពុទ្ធបូជនីយដ្ឋានទី២ (ស្ថិតក្នុងរដ្ឋបិហារ ប្រទេសឥណ្ឌា) ដែលពិភពលោកស្គាល់ច្បាស់តាមរយៈមហាចេតិយពុទ្ធគយា សាងដោយព្រះបាទអសោកមហារាជ។ សព្វថ្ងៃ នៅសល់ព្រះវិហារមួយដែលមានតម្កល់ព្រះពុទ្ធរូប “មារវិជ័យ” ដ៏ធំលាបទឹកមាស ទ្រង់ព្រះភ្នែន ព្រះហស្តស្តាំចង្អុលផែនដី ជាភស្តុតាងនៃការផ្ចាញ់មារ និងដើមពោធិ៍ថ្មីមួយដើមដុះចេញពីឫសដើមពោធិ៍ដើម។ ទីនេះក៏ជាទីស្នាក់ការនៃគណៈកម្មការទីប្រឹក្សាព្រះពុទ្ធសាសនាពិភពលោក ដែលប្រទេសកម្ពុជាយើងក៏មានប្រតិភូចូលរួមផងដែរ។

### ៨-ទ្រង់សម្តែងព្រះធម្មចក្រ (មិគទាយវ័ន)

បន្ទាប់ពីបានត្រាស់ដឹង ព្រះបរមសាស្តាទ្រង់បានគង់សោយវិមុត្តិសុខ និងពិចារណាអនុត្តរធម៌នៅសត្តមហាឋាន(ទីទាំង៧) អស់រយៈពេល៧សប្តាហ៍ (៤៩ថ្ងៃ)។ បន្ទាប់មកព្រះអង្គបានយាងទៅសម្តែងធម្មចក្កប្បវត្តនសូត្រជាបឋមទេសនា ពណ៌នាអំពីទុក្ខទាំង១៣កង ហេតុដែលនាំឱ្យកើតទុក្ខ(តណ្ហា) ការរលត់ទុក្ខ(ព្រះនិព្វាន)និងមធ្យោបាយរំលត់ទុក្ខគឺមគ្គមានអង្គ ៨(ចតុរារិយសច្ច)។ ការសម្តែងនេះធ្វើឡើងដើម្បីប្រោសបញ្ចវគ្គិយ៍ទាំង៥រូប នៅថ្ងៃសៅរ៍ ១៥កើត ពេញបូណ៌មី ខែអាសាឍ ឆ្នាំវក នាឥសិបតនមិគទាយវ៉ន (សព្វថ្ងៃហៅថា សារនាថជិតក្រុងពារាណសី)។ ទីនេះចាត់ជា ពុទ្ធបូជនីយដ្ឋានទី៣។ សព្វថ្ងៃ គេឃើញមាន «ចៅខណ្ឌីស្តូប» ជាទីដែលព្រះពុទ្ធជួបបញ្ចវគ្គិយ៍ និង «ធម្មេខស្តូប» ជាទីដែលទ្រង់សម្តែងធម៌ កសាងដោយព្រះបាទអសោក។ ព្រះបាទអសោកក៏បានកសាងសសរថ្មមានរូបសិង្ហមុខ ៤ឈរទល់ខ្នងគ្នា និងមានរូបកង់ធម្មចក្រពីក្រោម ដែលសព្វថ្ងៃរដ្ឋាភិបាលឥណ្ឌាបានចម្លងយកធ្វើជារូបសញ្ញាត្រាជាតិ និងទង់ជាតិ ដើម្បីបង្ហាញថាសន្តិភាពឥណ្ឌាផ្អែកលើគោលធម៌ព្រះពុទ្ធសាសនា។

### ៩-ទ្រង់ចូលបរិនិព្វាន (កុសិនារា)

ចាប់តាំងពីការសម្តែងព្រះធម្មចក្រមក ព្រះសម្មាសម្ពុទ្ធតែងយាងត្រាច់ចរប្រកាសធម៌ ដើម្បីប្រោសវេនេយ្យសត្វដោយ

ទ្រង់បំពេញពុទ្ធកិច្ច ៥ យ៉ាងជាប្រក្រតីគឺ៖

១-ពេលព្រឹក៖ ទ្រង់ត្រាច់បិណ្ឌបាត

២-ពេលរសៀល៖ ទ្រង់សម្តែងធម៌ប្រោសពុទ្ធបរិស័ទ

៣-ពេលព្រលប់៖ ទ្រង់ប្រទានឱវាទដល់ភិក្ខុសង្ឃ

៤-ពេលអធ្រាត្រ៖ ទ្រង់ដោះស្រាយប្រស្នាទេវតា

៥-ពេលបច្ចូស៖ ទ្រង់ប្រមើលមើលឧបនិស្ស័យសត្វដើម្បីយាងទៅប្រោស។

ព្រះអង្គទ្រង់បំពេញពុទ្ធកិច្ចនេះនៅក្នុងមជ្ឈិមប្រទេស អស់រយៈពេល ៤៥ ព្រះវស្សា ទាល់តែមានពុទ្ធបរិស័ទទាំង ៤ (ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា) យ៉ាងរឹងមាំ ទើបទ្រង់សម្រេចព្រះទ័យយាងចូលព្រះបរិនិព្វាន នៅថ្ងៃអង្គារ ១៥កើត ពេញបូណ៌មី ខែពិសាខ ឆ្នាំម្សាញ់ (មុនពុទ្ធសករាជ ១ថ្ងៃ) ក្រោមចន្លោះសាលព្រឹក្សទាំងគូ នៅត្រើយខាងលិចក្រុងកុសិនារា។ ទីនេះចាត់ជា ពុទ្ធបូជនីយដ្ឋានទី៤។

លុះដល់ថ្ងៃពុធ ៨រោច ខែពិសាខ ឆ្នាំម្សាញ់ ពុទ្ធបរិស័ទបានរៀបចំពិធីថ្វាយព្រះអគ្គីព្រះបរមសព នៅមកុដពន្ធនចេតិយភាគខាងកើតក្រុងកុសិនារា រួចបែងចែកព្រះបរមសារីរិកធាតុជា ៨ ចំណែកថ្វាយដល់ព្រះរាជា ៨ នគរ។ បច្ចុប្បន្ន ទីក្រុងនេះបន្សល់ទុកនូវ «មហាបរិនិព្វានស្តូប» និងព្រះវិហារមួយដែល

តម្កល់ព្រះពុទ្ធរូបទ្រង់ផ្ទំចូលបរិនិព្វានដ៏ធំមួយព្រះអង្គ សម្រាប់ពុទ្ធបរិស័ទគោរពបូជាជារៀងរហូតមក។

**“យោ វោ អានន្ទ មយា ធម្មោ ច វិនយោ ច**
**ទេសិតោ បញ្ញត្តោ សោ វោ មមច្ចយេន សត្ថា”**

ម្នាលអានន្ទ ធម៌ណាក្តី វិន័យណាក្តី ដែលតថាគតសម្តែងហើយ បញ្ញត្តិហើយដល់អ្នកទាំងឡាយ លុះអំណេះឥតអំពីតថាគតទៅ ធម៌និងវិន័យនោះជាគ្រូរបស់អ្នកទាំងឡាយ។

# “ធម៌
# នមស្ការ”

# បទសរភញ្ញ

(ព្រះរាជនិពន្ធ សម្តេចព្រះសង្ឃរាជ ជួន ណាត)

សូមថ្វាយបង្គំព្រះសម្ពុទ្ធ ប្រសើរបំផុតក្នុងលោកា
ជាគ្រូនៃមនុស្សនិងទេវតា ទ្រង់ត្រាស់ទេសនាប្រដៅសត្វ។
ចង្អុលឲ្យដើរផ្លូវកណ្តាល មាគ៌ាត្រកាលអាចកម្ចាត់
ទុក្ខភ័យចង្រៃឲ្យខ្ចាយបាត់ អាចកាត់សង្សារៈទុក្ខបាន ។
សាសនាព្រះអង្គនៅសព្វថ្ងៃ សត្វមាននិស្ស័យពីបុរាណ
ប្រឹងរៀនប្រឹងស្តាប់ចេះចាំបាន កាន់តាមលំអានបានក្តីសុខ ។
ឥតមានសុខណាស្មើក្តីស្ងប់ បញ្ចប់ត្រឹមសុខឃ្លាតចាកទុក្ខ
តាំងពីលោកនេះតទៅមុខ ក្តីសុខនឹងមានព្រោះធម៌ស្ងប់ ។
ខ្ញុំសូមបង្គំផ្ចាះព្រះធម៌ ព្រះសង្ឃបវរទាំងគ្រប់សព្វ
រួមជាត្រៃរ័ត្នគួរគោរព ជាម្លប់ត្រជាក់នៃលោកា ។
ព្រះរូបព្រះធាតុនៃព្រះពុទ្ធ វិសុទ្ធតាងអង្គព្រះសាស្តា
សូមគុណត្រៃរ័ត្នជួយខេមរា ឲ្យបានសុខាតរៀងទៅ។

(ក្រាបថ្វាយបង្គំម្តង)

# បទុមថ្វាយផ្កា

បទុមក្រពុំរីក មានចិត្តត្រេកកាច់មកថ្វាយ
បទុមក្រពុំថ្វាយ បង្អាច់កាយកបកេសរ។
លុតលើកទាំងទសករ ប្រណម្យដោមដាក់លើសិរសី
ខ្ញុំក្រាបក្រោមព្រះបាទ អភិវាទវរវន្ទា។
ថ្វាត់ថ្វាយទៅព្រះស្រី- រ័ត្នដ៏ថ្លៃស្រីកាឡា
ក្បូរក្បាច់រចនា បរិបូរណ៍បួនដណ្តប់ហាត្ថ។
ព្រះអង្គភគវា ស្តេចគង់នាបល្ល័ង្ករ័ត្ន
ផ្ទះយល់កំណើតសត្វ សត្វអមរនិករកាយ។
ឆ្លោមស្លឹក-ស្លឹកត្រសុំ ត្រសាយព្រមនូវមែកមាស
បពិត្រវីសំណូម ខ្ញុំសាងសូមប្រាថ្នាកាត់
សូមធុតចំហុតថ្វាត់ សត្វរៀងដល់និព្វានហោង៕

# ថ្វាយបង្គំព្រះពោធិសត្វ

គោមិយោ ពោធិសត្តោ ឆាម ភគវា ចិត្តំ
ទតកំ អារម្មណំ តុំ បិ ពុទ្ធោ មេ ភវិស្សតិ
កុសលធម្មេ សម្មាសម្ពុទ្ធោ ឥតិបិសោ ភគវា។
មហាជនកោ ពោធិសត្តោច ឆាម ភគវា ចិត្តំ

វតកំ អារម្មណំ ត្វំ បិ ពុទ្ធោ មេ ភវិស្សតិ
កុសលធម្មេ សម្មាសម្ពុទ្ធោ ឥតិបិសោ ភគវា ។
សុវណ្ណសាមោ ពោធិសត្តោ ញាម ភគវា ជិត្តំ
វតកំ អារម្មណំ ត្វំ បិ ពុទ្ធោ មេ ភវិស្សតិ
កុសលធម្មេ សម្មាសម្ពុទ្ធោ ឥតិបិសោ ភគវា ។
នេមិរាជានោ ពោធិសត្តោ ញាម ភគវា ជិត្តំ
វតកំ អារម្មណំ ត្វំ បិ ពុទ្ធោ មេ ភវិស្សតិ
កុសលធម្មេ សម្មាសម្ពុទ្ធោ ឥតិបិសោ ភគវា ។
មហោសថោ ពោធិសត្តោ ញាម ភគវា ជិត្តំ
វតកំ អារម្មណំ ត្វំ បិ ពុទ្ធោ មេ ភវិស្សតិ
កុសលធម្មេ សម្មាសម្ពុទ្ធោ ឥតិបិសោ ភគវា ។
ភូរិទត្តោ ពោធិសត្តោ ញាម ភគវា ជិត្តំ
វតកំ អារម្មណំ ត្វំ បិ ពុទ្ធោ មេ ភវិស្សតិ
កុសលធម្មេ សម្មាសម្ពុទ្ធោ ឥតិបិសោ ភគវា ។
ចន្ទកុមារោ ពោធិសត្តោ ញាម ភគវា ជិត្តំ
វតកំ អារម្មណំ ត្វំ បិ ពុទ្ធោ មេ ភវិស្សតិ
កុសលធម្មេ សម្មាសម្ពុទ្ធោ ឥតិបិសោ ភគវា ។
ព្រហ្មនារទោ ពោធិសត្តោ ញាម ភគវា ជិត្តំ
វតកំ អារម្មណំ ត្វំ បិ ពុទ្ធោ មេ ភវិស្សតិ

កុសលធម្មេ សម្មាសម្ពុទ្ធោ    ឥតិបិសោ ភគវា។
វិធូរោ ពោធិសត្តោ    នាម ភគវា ចិត្តំ
វតកំ អារម្មណំ តុំ បិ    ពុទ្ធោ មេ ភវិស្សតិ
កុសលធម្មេ សម្មាសម្ពុទ្ធោ    ឥតិបិសោ ភគវា។
វេស្សន្តរោ ពោធិសត្តោ    នាម ភគវា ចិត្តំ
វតកំ អារម្មណំ តុំ បិ    ពុទ្ធោ មេ ភវិស្សតិ
កុសលធម្មេ សម្មាសម្ពុទ្ធោ    ឥតិបិសោ ភគវា។
សិទ្ធត្ថោ ជាតិ នាម បរិយន្តំ    ពុទ្ធំ សរណំ គច្ឆាមិ
ធម្មំ សរណំ គច្ឆាមិ    សង្ឃំ សរណំ គច្ឆាមិ
នសជាតោ    និដ្ឋិតោ។

# សុខាភិយាចនគាថា

បសន្នា ហោន្តុ សព្វេបិ    បាណិនោ ពុទ្ធសាសនេ
សម្មា ធារំ បវេច្ឆន្តោ ច    កាលេ ទេវោ បវស្សតុ
វុឌ្ឍិភាវាយ សត្តានំ    សមិទ្ធំ នេតុ មេទនី។
សត្តមំ សិរិទេវិញ្ញ    និច្ចំ រក្ខន្តិ បុត្តកំ
ឯវំ ធម្មេន រាជានោ    បជំ រក្ខន្តុ សព្វទា៕

# បទថ្វាយផ្កា

*យើងខ្ញុំ មានចិត្តត្រេក    អរពន់ពេក កើតជ្រះថ្លា*

នាំគ្នា បូជាផ្កា ថ្វាយសាស្ដា ដោយគោរព។
ដើម្បី យកជល្លា និងលោះលា ខ្លួនចាកភព
ចាកភ័យ ចាកឧបទ្រព្យ ដោយសារម្លប់ បុណ្យសាសនា។
ទើបបេះ យកផ្កាឈើ មកក្រងធ្វើ ភួងមាលា
មានពណ៌ ក្លិនជ្រេងគ្នា សូមបូជា ថ្វាយព្រះពុទ្ធ។
ព្រះធម៌ និងព្រះសង្ឃ ប្រសើរអង្គ សីលបរិសុទ្ធ
ត្រ័យរតន៍ បីខ្ពស់ផុត ដែលជាបុណ្យ លោកទាំងបី។
ខ្ញុំម្ចាស់ ទាំងអស់គ្នា តែងកំព្រា ទាំងប្រុសស្រី
ព្រាត់ប្រាស់ ក្នុងលោកីយ៍ ព្រាត់ស្វាមី ព្រាត់ភរិយា។
តែងជួប និងឈឺចាប់ និងក្ដីស្លាប់ ជាធម្មតា
មានក្ដី ទុក្ខក្ដៅជ្រា រកនរណា ជួយពុំបាន។
ដោយតេ-ជះបូជា ភួងមាលា ល្អកល្យាណ
ត្រ័យរតន៍ ទាំងបីឋាន សូមឲ្យបាន ផុតទោសទុក្ខ។
ផុតចាស់ ផុតឈឺចាប់ ផុតក្ដីស្លាប់ តទៅមុខ
សូមឲ្យខ្ញុំបានសុខ ក្នុងសម្បត្តិ ព្រះនិព្វន។
ពាក្យពោល ប៉ងប្រាថ្នា ធ្វើសច្ចា ប្រណិធាន
សូមមគ្គ ផលនិព្វន ឲ្យខ្ញុំបានប្រាកដហោង៕

(ក្រាបថ្វាយបង្គំម្ដង)

# ថ្វាយបង្គំព្រះពុទ្ធ៥អង្គ

១-ខ្ញុំសូមវន្ទា នូវព្រះឈ្នះមារ ទាំងប្រាំព្រះអង្គ
សូមឃាំងបារមី ម្ចាស់ថ្លៃមកគង់ នៅនាកំឡុង
ទីឋាននេះណា។

២-ព្រះកុក្កុសន្ធោ ព្រះកោនាគមនោ ព្រះកស្សបោ
ព្រះសមណគោត្តម បរមពុទ្ធោ ព្រះមេត្តេយ្យោ
ពោធិសត្វថ្លៃ។

៣-ព្រមទាំងព្រះធម៌ ជ្រាលជ្រៅបវរ ល្អប្រសើរក្រៃ
ប្រាំបីម៉ឺនបួនពាន់ ធម្មក្ខន្ធនេះនៃ របស់ជិនស្រី
ទីទៃរាល់អង្គ។

៤-ព្រមទាំងព្រះសង្ឃ ប្រសើរសីលទ្រង់ ជាបុត្រព្រះពុទ្ធ
លះកាត់តណ្ហា ប្រសើរបំផុត ខ្ញុំសូមលំអុត
កាយវាចាចិត្ត។

៥-ដោយតេជៈខ្ញុំ លើកហត្ថប្រណម្យ ដាក់លើសិរសា
សូមកំចាត់បង់ សត្រូវនានា ទុក្ខសោករោគា
វិនាសទៅហោង។

(ក្រាបថ្វាយបង្គំម្តង)

ព្រះពុទ្ធោវាទ “សត្ថុនោ វចនោ វាទំ ករោតិយេវ ខន្តិកោ បរមាយ ច បូជាយ ជិនំ បូជេតិ ខន្តិកោ”។ សេចក្តីប្រែ “អ្នកអត់ធន់ ឈ្មោះថាធ្វើតាម នូវព្រះពុទ្ធដីកាជាឱវាទ នៃព្រះសាស្តាមែនពិត អ្នកអត់ធន់ ឈ្មោះថាបូជា នូវព្រះវិជិតមារ ដោយការបូជាដ៏ឧត្តម”។

# ពុទ្ធកិច្ច៥ប្រការ

បុព្វណ្ហេ បិណ្ឌបាតញ្ច សាយណ្ហេ ធម្មទេសនំ បទោសេ ភិក្ខុ ឱវាទំ អឌ្ឍរត្តេ ទេវបញ្ហនំ បច្ចូសេវ គតេ កាលេ ភព្វាភព្វេ វិលោកនំ ឯតេ បញ្ច វិធេ កិច្ចេ វិសោធេតិ មុនិ បុង្គវោតិ។

ព្រះសម្មាសម្ពុទ្ធ ជាចម្បងជាងអស់អ្នកប្រាជ្ញ ទ្រង់ជម្រះនូវពុទ្ធកិច្ចទាំងឡាយ៥ប្រការនេះ គឺក្នុងពេលព្រឹកទ្រង់ស្តេចទៅបិណ្ឌបាត១ ក្នុងពេលល្ងាច ទ្រង់សម្តែងធម៌ទេសនា១ ក្នុងពេលព្រលប់ទ្រង់ប្រទានឱវាទដល់ពួកភិក្ខុ១ ក្នុងពេលអធ្រាត្រ ទ្រង់ដោះប្រស្នានៃទេវតា១ ក្នុងពេលជិតភ្លឺ ទ្រង់ប្រមើលនូវសត្វលោកដែលគួរត្រាស់ដឹង និងមិនគួរត្រាស់ដឹង១។

# នមស្ការគារវវត្ថុ៥ប្រការ

និព្វុតេ លោកនាថម្ហិ សម្ពុទ្ធេ អគ្គបុគ្គលេ បដិមា ពោធិរុក្ខា ច ថូបា ច ជិនធាតុយោ ចតុរាសីតិសហស្សា ធម្មក្ខន្ធា សុទេសិតា អគ្គប្បវត្តនដ្ឋានេ ឋបិតា ហោន្តិ តាណិនំ។

កាលព្រះសម្មាសម្ពុទ្ធ ជាអគ្គបុគ្គល ជាទីពឹងនៃសត្វលោកបរិនិព្វានទៅហើយ ព្រះបដិមាផង ពោធិព្រឹក្សផង ព្រះស្តូបផង ព្រះជិនធាតុផង ព្រះធម៌៨ហ្មឺន ៤ពាន់ធម្មក្ខន្ធ ដែលព្រះអង្គទ្រង់សម្តែងហើយ ដោយប្រពៃផង ជាវត្ថុគឺ ព្រះសម្មាសម្ពុទ្ធទ្រង់

ប្រតិស្ឋានទុក ក្នុងស្ថានដ៏ប្រព្រឹត្តទៅ ដើម្បីជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វទាំងឡាយ។

(ក្រាបថ្វាយបង្គំម្តង)

## នមស្ការព្រះបរមសារីរិកធាតុ

**មាឃវស្សានិ សម្ពុទ្ធោ ភគវា យោ តថាគតោ សមសីត្យាយុគកាលេ បរិនិព្វាយិ សោ មុនិ តស្ស សារីរិកធាតុ អម្ហាកំ បមុខេ ឋិតា ឥធាគតោ ច សោ សត្ថា ធរមានោវ តិដ្ឋតិ សក្ការេហាភិបូជេម តំ នមស្សាម សាធុនំ សាធុនោ ភគវា ណាថោ សព្វញ្ញូ សន្តិនាយកោ ឥមេ ឧលិន្ទសក្ការេ អនុកម្បាយ គណ្ហាតុ ទីឃរត្តំ ហិតាយេវ សុខា យម្ហាក សព្វទា ។**

ព្រះតថាគតមុនីអង្គណា ទ្រង់បានត្រាស់ជាព្រះពុទ្ធទ្រង់ញាណ ហើយទ្រង់ទេសនាធម៌ប្រោសប្រទាន សព្វសត្វដែលមាននិស្ស័យវាសនាអស់៤៥វស្សាប្រាកដព្រះជន្មកំណត់ ៨០វស្សាទ្រង់ចូលនិព្វាន ជាន័យថ្លៃថ្លា ក្សេមក្សាន្តសុខា ឥតអ្វីផ្ទឹមបាន ឥឡូវព្រះសារីរិកធាតុ នៃព្រះលោកនាថប្រតិស្ឋាន ក្នុងទីចំពោះមុខជាប្រធានយើងខ្ញុំដូចបានឃើញព្រះអង្គនោះ ស្តេចយាងមកគង់ ក្នុងទីនេះឯងយើងខ្ញុំចាត់ចែង បូជាចំពោះ ព្រះអង្គដោយក្តី គោរពយ៉ាងស្មោះសូមព្រះអង្គនោះ មេត្តាកំណត់ ទទួលនូវគ្រឿង បូជាទាំងឡាយ

ដែលជាតង្វាយ នៃមនុស្សទុគិត ដោយក្តីអនុគ្រោះ យើងខ្ញុំកំសត់សូមសុខប្រាកដ អស់កាលអង្វែង។

## អារក្ខកម្មដ្ឋាន

**វន្ទាមិ ពុទ្ធំ គុណសាគរន្តំ សត្តា សទា ហោន្តុ សុខី អវេរា កាយោ ជិឃច្ឆោ សកលោ ទុគន្ធោ គច្ឆន្តិ សព្វេ មរណំ តថាហំ។**

ខ្ញុំសូមថ្វាយបង្គំចំពោះព្រះសម្ពុទ្ធ ទ្រង់មានព្រះគុណដល់ធំធេងដូចសាគរ សូមសត្វទាំងឡាយមានតែសេចក្តីសុខ មិនមានពៀរនឹងគ្នាសព្វកាល រាងកាយទាំងមូលនេះ មានក្លិនអាក្រក់គួរខ្ពើមរអើមក្រៃពេកណាស់សព្វសត្វទាំងអស់រមែងដល់នៅសេចក្តីស្លាប់ទាំងខ្លួនអាត្មាអញក៏ដូច្នោះដែរ។

**វន្ទាមិ ធម្មំ សុគតេន ទុត្តំ សត្តា សទា ហោន្តុ សុខី អវេរា កាយោ ជិឃច្ឆោ សកលោ ទុគន្ធោ គច្ឆន្តិ សព្វេ មរណំ តថាហំ។**

ខ្ញុំសូមថ្វាយបង្គំចំពោះព្រះធម៌ ដែលព្រះសុគតទ្រង់សម្តែងហើយ សូមសត្វទាំងឡាយ មានតែសេចក្តីសុខ មិនមានពៀរនឹងគ្នាសព្វកាល រាងកាយទាំងមូលនេះ មានក្លិនអាក្រក់គួរខ្ពើមរអើមក្រៃពេកណាស់សព្វសត្វទាំងអស់រមែងដល់នៅសេចក្តីស្លាប់ទាំងខ្លួនអាត្មាអញក៏ដូច្នោះដែរ។

**វន្ទាមិ សង្ឃំ មុនិរាជបុត្តំ សត្តា សទា ហោន្តុ សុខី អវេរា កាយោ ជិឃច្ឆោ សកលោ ទុគន្ធោ គច្ឆន្តិ សព្វេ មរណំ តថាហំ។** ខ្ញុំសូម

ថ្វាយបង្គំចំពោះព្រះសង្ឃដែលជាបុត្តនៃព្រះសម្ពុទ្ធ ជាស្តេចនៃអ្នកប្រាជ្ញ សូមសត្វទាំងឡាយ មានតែសេចក្តីសុខ មិនមានពៀរនឹងគ្នាសព្វកាល រាងកាយទាំងមូលនេះមានក្លិនអាក្រក់គួរខ្ពើមរអើមក្រៃពេកណាស់សព្វសត្វទាំងអស់រមែងដល់នៅសេចក្តីស្លាប់ទាំងខ្លួនអាត្មាអញក៏ដូច្នោះដែរ។

## រតនបូជា

**ឥមេហិ ទីបធូបាទិសក្ការេហិ ពុទ្ធំ ធម្មំ សង្ឃំ អភិបូជយាមិ មាតាបិតាទីនំ គុណវន្តានញ្ច មយ្ហញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ។**

ខ្ញុំព្រះករុណាសូមបូជាចំពោះនូវ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាម្ចាស់ ដោយគ្រឿងសក្ការៈទាំងឡាយ មានទៀន និងធូបជាដើមនេះ ដើម្បីសេក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់អ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់ខ្ញុំព្រះករុណាផង អស់កាលជាអង្វែងទៅហោង។

## នមស្សការ

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។**

រីកិរិយានមស្ការថ្វាយបង្គំ នៃខ្ញុំព្រះករុណា ចូលមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ។

## តិសរណគមន៍

**ពុទ្ធំ សរណំ គច្ឆាមិ**

ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹងទីរឭក។

**ធម្មំ សរណំ គច្ឆាមិ**

ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីពឹងទីរឭក។

**សង្ឃំ សរណំ គច្ឆាមិ**

ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីពឹងទីរឭក។

**ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹងទីរឭក ជាគម្រប់ពីរដងផង។

**ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីពឹងទីរឭក ជាគម្រប់ពីរដងផង។

**ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីពឹងទីរឭក ជាគម្រប់ពីរដងផង។

**តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹងទីរឭក ជាគម្រប់បីដងផង។

**តតិយម្បិ ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីពឹងទីរឭក ជាគម្រប់បីដងផង។

**តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីពឹងទីរឭក ជាគម្រប់បីដងផង។

# នមស្ការព្រះសម្ពុទ្ធទាំងឡាយ

**សម្ពុទ្ធេ អដ្ឋវីសញ្ច ទ្វាទសញ្ច សហស្សកេ បញ្ចសតសហស្សានិ នមាមិ សិរសា អហំ។** ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវ

ព្រះសម្មាសម្ពុទ្ធ ទាំងឡាយ២៨ព្រះអង្គផង ១ម៉ឺន ២ពាន់ព្រះអង្គផង ៥សែនព្រះអង្គផង ដោយត្បូងរបស់ខ្ញុំព្រះករុណា។

**តេសំ ធម្មញ្ច សង្ឃញ្ច អាទរេន នមាមិហំ។** ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវ ព្រះធម៌ផង នូវព្រះសង្ឃផង របស់ព្រះសម្មាសម្ពុទ្ធទាំងឡាយនោះដោយគោរព។

**នមក្ការានុភាវេន ហន្ត្វា សព្វេ ឧបទ្ទវេ អនេកា អន្តរាយាបិ វិនស្សន្តុ អសេសតោ។** ដោយអានុភាព នៃកិរិយានមស្ការថ្វាយបង្គំ សូមឱ្យកំចាត់បង់នូវឧបទ្រពទាំងឡាយទាំងពួងទាំងសេចក្តីអន្តរាយទាំងឡាយជាអនេក ក៏ចូលឱ្យវិនាស កុំបីមានសេសសល់ឡើយ ។

**សម្ពុទ្ធេ បញ្ចបញ្ញាសញ្ច ចតុវីសតិសហស្សកេ ទសសតសហស្សានិ នមាមិ សិរសា អហំ។** ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធ ទាំងឡាយ ៥៥ព្រះអង្គផង ២ម៉ឺន ៤ពាន់ព្រះអង្គផង ១លានព្រះអង្គផង ដោយត្បូងរបស់ខ្ញុំព្រះករុណា។

**តេសំ ធម្មញ្ច សង្ឃញ្ច អាទរេន នមាមិហំ។** ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវ ព្រះធម៌ផង នូវព្រះសង្ឃផង របស់ព្រះសម្មាសម្ពុទ្ធទាំងឡាយនោះដោយគោរព។

**នមក្ការានុភាវេន ហន្ត្វា សព្វេ ឧបទ្ទវេ អនេកា អន្តរាយាបិវិនស្សន្តុអសេសតោ។** ដោយអានុភាព នៃកិរិយានមស្ការថ្វាយបង្គំ

សូមឱ្យកំចាត់បង់នូវឧបទ្រពទាំងឡាយទាំងពួងទាំងសេចក្តីអន្តរាយទាំងឡាយជាអនេក ក៏ចូលឱ្យវិនាស កុំបីមានសេសសល់ឡើយ ។

**សម្ពុទ្ធេ អដ្ឋវីសញ្ច ទ្វាទសញ្ច សហស្សកេ បញ្ចសតសហស្សានិ នមាមិ សិរសា អហំ។** ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធ ទាំងឡាយ ១០៩ព្រះអង្គផង ៤ម៉ឺន ៨ពាន់ ព្រះអង្គផង ២លាន ព្រះអង្គផង ដោយត្បូងរបស់ខ្ញុំព្រះករុណា។

**តេសំ ធម្មញ្ច សង្ឃញ្ច អាទរេន នមាមិហំ។** ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវ ព្រះធម៌ផង នូវព្រះសង្ឃផង របស់ព្រះសម្មាសម្ពុទ្ធទាំងឡាយនោះដោយគោរព។

**នមក្ការានុភាវេន ហន្ត្វា សព្វេ ឧបទ្ទវេ អនេកា អន្តរាយាបិ វិនស្សន្តុ អសេសតោ។** ដោយអានុភាព នៃកិរិយានមស្ការថ្វាយបង្គំ សូមឱ្យកំចាត់បង់នូវឧបទ្រព ទាំងឡាយទាំងពួងទាំងសេចក្តីអន្តរាយទាំងឡាយជាអនេកក៏ចូលឱ្យវិនាសកុំបីមានសេសសល់ឡើយ។

(ក្រាបថ្វាយបង្គំម្តង)

# ពុទ្ធរតនប្បណាម

**យោ សន្និសិន្នោ វរពោធិមូលេ មារំ សសេនំ**

**មហតឹ វិជេយ្យោ សម្ពោធិមាគច្ឆិ អនន្តញាណោ**

**លោកុត្តមោ តំ បនមាមិ ពុទ្ធំ។**

សេចក្តីប្រែ៖ ព្រះសម្មាសម្ពុទ្ធអង្គឯណា ទ្រង់គង់ចម្រើននូវព្រះអានាបាណស្សតិកម្មដ្ឋាន លើរតនបល្ល័ង្កក្រោមម្លប់ពោធិព្រឹក្សដ៏ប្រសើរ បានផ្ចាញ់នូវមារាធិរាជព្រមទាំងសេនាដ៏ច្រើនហើយ ទ្រង់ត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ មានប្រាជ្ញារកទីបំផុតគ្មាន ព្រះអង្គប្រសើរជាងសត្វលោកខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធអង្គនោះដោយគោរព។

(ក្រាបថ្វាយបង្គំម្តង)

**យេ ច ពុទ្ធា អតីតា ច យេ ច ពុទ្ធា អនាគតា**

**បច្ចុប្បន្នា ច យេ ពុទ្ធា អហំ វន្ទាមិ សព្វទា។**

សេចក្តីប្រែ៖ ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធនិព្វានកន្លងទៅហើយក្តី ព្រះសម្មាសម្ពុទ្ធ ទាំងឡាយអង្គឯណា ដែលនឹងត្រាស់ដឹងជាព្រះពុទ្ធក្នុងកាលខាងមុខក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយ អង្គឯណាដែលបានត្រាស់ជាព្រះពុទ្ធក្នុងភទ្រកប្បនេះក្តី។ ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ គ្រប់កាលទាំងពួង៕

# ពុទ្ធគុណា

**ឥតិបិសោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជា**
**ចរណ សម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិស**
**ទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ។**

សេចក្តីប្រែ៖ **ឥតិបិសោ ភគវា អរហំ** ព្រះដ៏មានព្រះភាគអង្គនោះទ្រង់ព្រះនាមថា **អរហំ** ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវពោល គឺកិលេសព្រមទាំងវាសនាគឺកាយបយោគ និងវចីបយោគ។ **សម្មាសម្ពុទ្ធោ** ទ្រង់ព្រះនាមថា **សម្មាសម្ពុទ្ធោ** ព្រោះព្រះអង្គត្រាស់ដឹង នូវញេយ្យធម៌ទាំងពួងដោយប្រពៃ ចំពោះព្រះអង្គឥតមានគ្រូអាចារ្យណា ប្រដៅព្រះអង្គឡើយ។ **វិជ្ជាចរណសម្បន្នោ** ទ្រង់ព្រះនាមថា **វិជ្ជាចរណសម្បន្នោ** ព្រោះព្រះអង្គបរិបូណ៌ដោយវិជ្ជា៣ និងវិជ្ជា៨ និងចរណៈ១៥។ **សុគតោ** ទ្រង់ព្រះនាមថា **សុគតោ** ព្រោះព្រះអង្គមានដំណើរល្អ យាងទៅកាន់សុន្ទរស្ថាន គឺអមតៈមហានិព្វាន។ **លោកវិទូ** ទ្រង់ព្រះនាមថា **លោកវិទូ** ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក។ **អនុត្តរោ** ទ្រង់ព្រះនាមថា **អនុត្តរោ** ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន។ **បុរិសទម្មសារថិ** ទ្រង់ព្រះនាមថា បុរិសទម្មសារថិ ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរសដែលមានឧបនិស្ស័យគួរនឹងទូន្មានបាន។ **សត្ថា ទេវមនុស្សានំ** ទ្រង់ព្រះនាមថា **សត្ថាទេវមនុស្សានំ** ព្រោះព្រះអង្គជាសាស្តាចារ្យនៃទេវតា និងមនុស្សទាំងឡាយ។ **ពុទ្ធោ** ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ច ហើយញុំាងអ្នកដទៃឱ្យត្រាស់ដឹងផង។ **ភគវា** ទ្រង់ព្រះ

នាមថា **ភគវា** ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រៃភពខ្ជាក់ចោលហើយ គឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ។

(ក្រាបថ្វាយបង្គំម្តង)

រួចហើយត្រូវប្រកាសប្តេជ្ញាខ្លួនចំពោះពុទ្ធគុណថា៖

**នត្ថិ មេ សរណំ អញ្ញំ ពុទ្ធោ មេ សរណំ វរំ ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ។**

សេចក្តីប្រែ៖ នត្ថិ មេ សរណំ អញ្ញំ វត្ថុដទៃជាទីពឹងទីរឭកនៃខ្ញុំព្រះករុណាមិនមានឡើយ។ ពុទ្ធោ មេ សរណំ វរំ មានតែព្រះពុទ្ធជាម្ចាស់ ជាទីពឹងទីរឭកដ៏ប្រសើររបស់ខ្ញុំព្រះករុណា។ ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ សូមសិរីសួស្តីជយមង្គល ចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចនេះ។

រួចហើយត្រូវខមាទោសចំពោះពុទ្ធគុណដូច្នេះថា៖

**ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ ពុទ្ធេ យោ ខលិតោ ទោសោ ពុទ្ធោ ខមតុ តំ មមំ។**

សេចក្តីប្រែ៖ ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវល្អងធូលីព្រះបាទនៃព្រះសម្មាសម្ពុទ្ធដ៏ប្រសើរខ្ពង់ខ្ពស់ដោយអវយវៈដ៏ឧត្តមគឺត្បូង។ ពុទ្ធេ យោ ខលិតោ ទោសោ ទោសឯណាដែលខ្ញុំព្រះករុណាធ្វើឱ្យភ្លាំងភ្លាត់ហើយក្នុងព្រះពុទ្ធជាម្ចាស់។ ពុទ្ធោ ខមតុ តំ មមំ សូមព្រះពុទ្ធជាម្ចាស់អត់នូវទោសនោះដល់ខ្ញុំព្រះករុណា។

(ក្រាបថ្វាយបង្គំម្តង)

# ធម្មរតនប្បណាម

អដ្ឋង្គិការិយបថោ ជនានំ មោក្ខប្បវេសាយ ឧជូ ច មគ្គោ ធម្មោ អយំ សន្តិករោ បណីតោ និយ្យានិកោ តំ បណមាមិ ធម្មំ។

សេចក្តីប្រែ៖ ព្រះសទ្ធម្មឯណា ជាធម៌ប្រកបដោយអង្គ ៨ប្រការ ជាគន្លងដំណើរនៃព្រះអរិយបុគ្គលជាម្ចាស់ ជាផ្លូវដ៏ត្រង់ ក្នុងកិរិយាញ៉ាំងជន ដែលប្រាថ្នានូវព្រះនិព្វាន ឱ្យចូលទៅកាន់ព្រះនិព្វានបាន ព្រះធម៌នេះជាធម៌ធ្វើឱ្យត្រជាក់រម្ងាប់បង់ នូវភ្លើងទុក្ខ ភ្លើងកិលេស ជាធម៌ដ៏ឧត្តម ជាគុណញ៉ាំងសត្វ ឱ្យចេញចាកសង្សារទុក្ខ ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះសទ្ធម្មនោះ ដោយគោរព ។

យេ ច ធម្មា អតីតា ច យេ ច ធម្មា អនាគតា បច្ចុប្បន្នា ច យេ ធម្មា អហំ វន្ទាមិ សព្វទា។

សេចក្តីប្រែ៖ ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធដែលនិព្វានកន្លងទៅហើយក្តី។ ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ នឹងមានមកក្នុងកាលខាងមុខក្តី។ ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រតិស្ឋាន

ទុកក្នុងកាលសព្វថ្ងៃនេះក្តី។ ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះធម៌ទាំងឡាយនោះគ្រប់កាលទាំងពួង ។

(ក្រាបថ្វាយបង្គំម្តង)

## ធម្មគុណា

ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯ
ហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ។

សេចក្តីប្រែ៖ **ស្វាក្ខាតោ ភគវតា ធម្មោ** ព្រះបរិយត្តិធម៌គឺ ព្រះត្រៃបិដកជាធម៌គឺ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងហើយដោយល្អ។ **ធម្មោ** ព្រះនព្វលោកុត្តរធម៌មាន ៩ប្រការគឺ មគ្គ៤ ផល៤ និព្វាន១។ **សន្ទិដ្ឋិកោ** ជាធម៌គឺព្រះអរិយបុគ្គលទាំងពួង ដឹងពិត ឃើញពិត ដោយបច្ចវេក្ខណញ្ញាណគឺថា នឹងបានដឹង ដោយស្តាប់ ដោយជឿបុគ្គលដទៃនោះៗក៏ទេគឺឃើញច្បាស់ដោយខ្លួនឯង។ **អកាលិកោ** ជាធម៌ឱ្យនូវផលមិនរង់ចាំកាលគឺថា កាលបើព្រះអរិយមគ្គកើតឡើងហើយ ព្រះអរិយផលក៏កើតក្នុងលំដាប់គ្នា មិនបានយឺនយូរឡើយ។ **ឯហិបស្សិកោ** ជាធម៌គួរដល់ឯហិបស្សវិធី គឺថាបើព្រះអរិយបុគ្គលដែលបានសម្រេចមគ្គផលហើយ ក៏គួរនឹងហៅ បុគ្គលដទៃឱ្យចូលមកមើលបាន។ **ឱបនយិកោ** ជាធម៌គឺព្រះអរិយបុគ្គល គប្បីបង្អោនចូលមកទុកក្នុងខ្លួន ដោយអំណាចនៃភាវនា។ **បច្ចត្តំ វេទិតព្វោ វិញ្ញូហិ** ជាធម៌គឺអ្នកប្រាជ្ញទាំងឡាយ មាន**ឧគ្ឃដិតញ្ញូ**បុគ្គលជាដើមគប្បីដឹង គប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន។

(ក្រាបថ្វាយម្តង)

រួចហើយត្រូវប្រកាសប្តេជ្ញាខ្លួនចំពោះធម្មគុណថា៖

**នត្ថិ មេ សរណំ អញ្ញំ ធម្មោ មេ សរណំ វរំ ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ។**

សេចក្តីប្រែ៖ **នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹងទីរឭកនៃខ្ញុំព្រះករុណាមិនមានឡើយ។ **ធម្មោ មេ សរណំ វរំ** មានតែព្រះធម៌ជាម្ចាស់ជាទីពឹងទីឭកដ៏ប្រសើររបស់ខ្ញុំព្រះករុណា។ **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** សូមសិរីសួស្តីជយមង្គលចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចនេះ។

រួចហើយត្រូវខមាទោសចំពោះធម្មគុណដូច្នេះថា៖

**ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ ធម្មេ យោ ខលិតោ ទោសោ ធម្មោ ខមតុ តំ មមំ។**

សេចក្តីប្រែ៖ **ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ** ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះធម៌ដ៏ប្រសើរមានពីរប្រការ គឺព្រះបរិយត្តិធម៌ និងព្រះនព្វលោកុត្តរធម៌ ដោយអវយវៈដ៏ឧត្តមគឺត្បូង។ **ធម្មេ យោ ខលិតោ ទោសោ** ទោសឯណាដែល ខ្ញុំព្រះករុណាធ្វើឱ្យភ្លាំងភ្លាត់ ហើយក្នុងព្រះធម៌ជាម្ចាស់។ **ធម្មោ ខមតុ តំ មមំ** សូមព្រះធម៌ជាម្ចាស់អត់នូវទោសនោះដល់ខ្ញុំព្រះករុណា។

# សង្ឃរតនប្បណាម

**សង្ឃោ វិសុទ្ធោ វរទក្ខិណេយ្យោ សន្តិន្ទ្រិយោ សព្វមលប្បហីនោ គុណេហិនេកេហិ សមិទ្ធិបត្តោ អនាសវោ តំ បណមាមិ សង្ឃំ។**

សេចក្តីប្រែ៖ ព្រះអរិយសង្ឃឯណា ដ៏បរិសុទ្ធវិសេសជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ មានឥន្ទ្រិយ៍រម្ងាប់ហើយ មានមន្ទិល គឺ រាគាទិក្កិលេសទាំងពួង បន្សាត់បង់ហើយ ជាព្រះសង្ឃដល់ហើយនូវ កិរិយាសម្រេចដោយគុណទាំងឡាយដ៏ច្រើន ជាព្រះសង្ឃមានអាសវធម៌មិនមាន គឺថាជាព្រះខីណាស្រព ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះអរិយសង្ឃនោះ ដោយគោរព។

(ក្រាបថ្វាយបង្គំម្តង)

**យេ ច សង្ឃា អតីតា ច យេ ច សង្ឃា អនាគតា បច្ចុប្បន្នា ច យេ សង្ឃា អហំ វន្ទាមិ សព្វទា។**

សេចក្តីប្រែ៖ ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសម្រេចមគ្គ និងផលកន្លងទៅហើយក្តី។ ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃនឹងបានសម្រេចមគ្គ និងផល ក្នុងកាលខាងមុខក្តី។ ព្រះសង្ឃទាំងឡាយឯណា ដែលបានសម្រេចមគ្គ និងផលក្នុងកាលជា

បច្ចុប្បន្ននេះក្តី។ ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវ ព្រះសង្ឃទាំងឡាយនោះ គ្រប់កាលទាំងពួង។

(ក្រាបថ្វាយបង្គំម្តង)

# សង្ឃគុណា

**សុបដិបន្នោ ភគវតោ សាវកសង្ឃោ**

**ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ**

**ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ**

**សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ**

**យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋបុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ។**

សេចក្តីប្រែ៖ **សុបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័ក នៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃគឺប្រតិបត្តិតាមគន្លង ព្រះនព្វលោកុត្តរធម៌ ។ **ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយត្រង់ គឺប្រតិបត្តិជាមជ្ឈិមប្បដិបទា។ **ញាយបដិបន្នោ ភគវតោ សាវក សង្ឃោ** ព្រះសង្ឃជាសាវ័កនៃ ព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វានជាស្ពានក្សេមផុតចាកទុក្ខទាំងពួង។ **សាមីចិបដិ បន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័ក នៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម គឺប្រតិបត្តិ

គួរដល់ **សីល សមាធិ បញ្ញា។ យទិទំ ចត្តារិ បុរិសយុគានិ** ព្រះសង្ឃឯណាបើរាប់ជាគូរនៃបុរសទាំងឡាយមាន៤គូគឺ ព្រះសង្ឃដែលបានសម្រេចនូវ **សោតាបត្តិមគ្គ និងសោតាបត្តិផលជាគូ១ សកទាគាមិមគ្គ និងសកទាគាមិផលជាគូ១ អានាគាមិមគ្គ និងអានាមិផលជាគូ១អរហត្តមគ្គ និងអរហត្តផលជាគូ១។អដ្ឋបុរិសបុគ្គលា** បើរាប់រៀងជាបុរសបុគ្គលមាន ៨ គឺព្រះសង្ឃដែលបានសម្រេចនូវ សោតាបត្តិមគ្គ១ សោតាបត្តិផល១ សកទាគាមិមគ្គ១ សកទាគាមិផល១ អានាគាមិមគ្គ១ អានាគាមិផល១ អរហត្តមគ្គ១ អរហត្តផល១។ **ឯស ភគវតោ សាវកសង្ឃោ** ព្រះសង្ឃទាំងនោះ ជាសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ។ **អាហុនេយ្យោ** លោកគួរទទួលនូវចតុប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីល ហើយនាំមកអំពីចម្ងាយបង្អោនចូលមកបូជា។ **បាហុនេយ្យោ** លោកគួរទទួលនូវអាគន្តុកទានគឺទានដែលបុគ្គលតាក់តែងដើម្បីញាតិ និងមិត្ត ដែលមកអំពីទិសផ្សេងៗហើយបង្អោនចូលមកបូជា។ **ទក្ខិណេយ្យោ** លោកគួរទទួលនូវទាន ដែលបុគ្គលជឿនូវកម្ម និងផលនៃកម្មហើយបូជា។ **អញ្ជលិករណីយោ** លោកគួរដល់អញ្ជលិកម្មដែលសត្វលោកគប្បីធ្វើ។ **អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** លោកជាបុញ្ញក្ខេត្ត គឺជាទីដុះឡើងនៃពូជ គឺបុណ្យនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន។

(ក្រាបថ្វាយបង្គំម្តង)

រួចហើយត្រូវប្រកាសប្តេជ្ញាខ្លួនចំពោះសង្ឃគុណថា៖

**នត្ថិ មេ សរណំ អញ្ញំ សង្ឃោ មេ សរណំ វរំ ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ។**

សេចក្តីប្រែះ នត្ថិ មេ សរណំ អញ្ញំ វត្ថុដទៃជាទីពឹងទីរឭកនៃខ្ញុំព្រះករុណាមិនមានឡើយ។សង្ឃោ មេ សរណំ វរំ មានតែព្រះសង្ឃជាម្ចាស់ ជាទីពឹងទីរឭកដ៏ប្រសើររបស់ខ្ញុំព្រះករុណា។ ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ សូមសិរីសួស្តីជយមង្គលចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចនេះ។

រួចហើយត្រូវខមាទោសចំពោះសង្ឃគុណដូច្នេះថា៖

ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ សង្ឃេ យោ ខលិតោ ទោសោ សង្ឃោ ខមតុ តំ មមំ។

សេចក្តីប្រែ៖ ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះសង្ឃដ៏ប្រសើរមានពីរប្រការ គឺសម្មតិសង្ឃ និងអរិយសង្ឃ ដោយអវយវៈដ៏ឧត្តមគឺត្បូង។ សង្ឃេ យោ ខលិតោ ទោសោ ទោសឯណាដែលខ្ញុំព្រះករុណាធ្វើឱ្យភ្លាំងភ្លាត់ហើយក្នុងព្រះសង្ឃជាម្ចាស់។ សង្ឃោ ខមតុ តំ មមំ សូមព្រះសង្ឃជាម្ចាស់អត់នូវទោសនោះដល់ខ្ញុំព្រះករុណា។

(ក្រាបថ្វាយបង្គំម្តង)

# "បញ្ហាជាកែវនៃជនទាំងឡាយ"

(បិដកលេខ២៩ ទំព័រ៩៤)

# ថ្វាយបង្គំព្រះរតនត្រ័យ បែបសង្ខេប

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**

សេចក្តីប្រែ៖ វីកិរិយានមស្ការថ្វាយបង្គំ នៃខ្ញុំព្រះករុណា ចូលមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្ត ដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ។

(ក្រាបថ្វាយបង្គំម្តង)

## ពុទ្ធគុណ

**ឥតិបិសោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណ សម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថាទេវមនុស្សានំ ពុទ្ធោ ភគវាតិ។**

**តំ អរហាទិគុណសំយុត្តំ ពុទ្ធំ សិរសា នមាមិ តញ្ច ពុទ្ធំ ឥមេហិ សក្ការេហិ អភិបូជយាមិ។**

សេចក្តីប្រែ៖ **តំ អរហាទិគុណសំយុត្តំ ពុទ្ធំ សិរសា នមាមិ** ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គប្រកបព្រមដោយគុណមានគុណថាអរហំ ជាដើមនោះ ដោយសិរសាគឺត្បូង។ **តញ្ច ពុទ្ធំ ឥមេហិ សក្ការេហិ អភិបូជយាមិ** ខ្ញុំព្រះករុណា សូមបូជាចំពោះនូវព្រះសម្មាសម្ពុទ្ធជាម្ចាស់នោះ ដោយគ្រឿងសក្ការៈទាំងឡាយ មានប្រមាណប៉ុណ្ណេះ។

# ធម្មគុណា

ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ។

តំ ស្វាក្ខាតាទិគុណសំយុត្តំ ធម្មំ សិរសា នមាមិ តញ្ច ធម្មំ ឥមេហិ សក្ការេហិ អភិបូជយាមិ។

សេចក្តីប្រែ៖ តំ ស្វាក្ខាតា ទិគុណសំយុត្តំ ធម្មំ សិរសា នមាមិ ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះធម៌ជាម្ចាស់ ប្រកបព្រមដោយគុណ មានគុណថា ស្វាក្ខាតា ជាដើមនោះ ដោយសិរសាគឺត្បូង។តញ្ច ធម្មំ ឥមេហិ សក្ការេហិ អភិបូជយាមិ ខ្ញុំព្រះករុណាសូមបូជាចំពោះនូវព្រះធម៌ជាម្ចាស់នោះដោយគ្រឿងសក្ការៈទាំងឡាយ មានប្រមាណប៉ុណ្ណេះ។

(ក្រាបថ្វាយបង្គំម្តង)

# សង្ឃគុណា

សុបដិបន្នោ ភគវតោ សាវកសង្ឃោ
ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ
ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ
សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ
យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋបុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ

**ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ។**

**តំ សុបដិបន្នា ទិគុណាសំយុត្តំ សង្ឃំ សិរសា នមាមិ តញ្ច សង្ឃំ ឥមេហិ សក្ការេហិ អភិបូជយាមិ។**

*សេចក្ដីប្រែ៖* **តំ សុបដិបន្នា ទិគុណាសំយុត្តំ សង្ឃំ សិរសា នមាមិ** *ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះសង្ឃជាម្ចាស់ ព្រះអង្គប្រកបព្រមដោយគុណមានគុណថា* **សុបដិបន្នោ** *ជាដើមនោះដោយសិរសាគឺត្បូង។* **តញ្ច សង្ឃំ ឥមេហិ សក្ការេហិ អភិបូជយាមិ** *ខ្ញុំព្រះករុណាសូមបូជាចំពោះនូវព្រះសង្ឃជាម្ចាស់នោះដោយគ្រឿងសក្ការៈទាំងឡាយ មានប្រមាណប៉ុណ្ណោះ។*

*-ចប់វិធីនមស្សការព្រះរតនត្រ័យបែបសង្ខេប-*

# គាថាសរសើរគុណព្រះរតនត្រ័យ (ប្រែជាកាព្យ)

## នមស្ការព្រះគុណព្រះពុទ្ធ

**អហោ ពុទ្ធោ នមោ តស្ស    អហោ ពុទ្ធោ នមាមិហំ**

**អហោ ពុទ្ធោ នមេហិតំ    អហោ ពុទ្ធោ អហំ នមេ។**

ឱហ្ន៎ព្រះពុទ្ធ អស្ចារ្យក្រៃលែង    ចិត្តខ្ញុំចាត់ចែង ក្រាបថ្វាយបង្គំ

ឱនកាយសំពះ ថ្វាយចិត្តសន្សំ    សែនជ្រះថ្លាជុំ ដល់ព្រះសម្ពុទ្ធ។

## នមស្ការព្រះគុណព្រះធម៌

**អហោ ធម្មោ នមោ តស្ស    អហោ ធម្មោ នមាមិហំ**

**អហោ ធម្មោ នមេហិតំ    អហោ ធម្មោ អហំ នមេ។**

ឱហ្ន៎ព្រះធម៌ អស្ចារ្យវិសុទ្ធ    ចិត្តខ្ញុំបរិសុទ្ធ ក្រាបថ្វាយបង្គំ

ឱនកាយសំពះ ថ្វាយចិត្តសន្សំ    សែនជ្រះថ្លាជុំ ដល់ព្រះធម៌ថ្លៃ។

## នមស្ការព្រះគុណព្រះសង្ឃ

**អហោ សង្ឃោ នមោ តស្ស    អហោ សង្ឃោ នមាមិហំ**

**អហោ សង្ឃោ នមេហិតំ    អហោ សង្ឃោ អហំ នមេ។**

ឱហ្ន៎ព្រះសង្ឃ អស្ចារ្យប្រពៃ    ចិត្តខ្ញុំអាល័យ ក្រាបថ្វាយបង្គំ

ឱនកាយសំពះ ថ្វាយចិត្តសន្សំ    សែនជ្រះថ្លាជុំ ដល់ព្រះសង្ឃថ្លៃ។

# សរសើរបីតិកើតអំពីព្រះរតនត្រ័យ

## បីតិក្នុងព្រះពុទ្ធ

ពុទ្ធោតិ កិត្តិ យន្តស្ស   កាយេ ភវតិ យា បីតិ
វរមេវ ហិ សា បីតិ   កសិណេនបិ ជម្ពុទីបស្ស។

បីតិកើតមាន ក្នុងកាយបុគ្គល   អ្នកលាន់មាត់ដល់ ថាពាក្យ «ពុទ្ធោ»
បីតិនោះថ្លៃ ប្រសើរអនគ្ឃា   លើសលប់ពន្លោ ក្នុងជម្ពូទីប។

## បីតិក្នុងព្រះធម៌

ធម្មោតិ កិត្តិ យន្តស្ស   កាយេ ភវតិ យា បីតិ
វរមេវ ហិ សា បីតិ   កសិណេនបិ ជម្ពុទីបស្ស។

បីតិកើតមាន ក្នុងកាយបុគ្គល   អ្នកលាន់មាត់ដល់ ថាពាក្យ «ធម្មោ»
បីតិនោះថ្លៃ ប្រសើរអនគ្ឃា   លើសលប់ពន្លោ ក្នុងជម្ពូទីប។

## បីតិក្នុងព្រះសង្ឃ

សង្ឃោតិ កិត្តិ យន្តស្ស   កាយេ ភវតិ យា បីតិ
វរមេវ ហិ សា បីតិ   កសិណេនបិ ជម្ពុទីបស្ស។

បីតិកើតមាន ក្នុងកាយបុគ្គល   អ្នកលាន់មាត់ដល់ ថាពាក្យ«សង្ឃោ»
បីតិនោះថ្លៃ ប្រសើរអនគ្ឃា   លើសលប់ពន្លោ ក្នុងជម្ពូទីប។

# គាថាសរសើរពាក្យ និងបទនៃព្រះរតនត្រ័យ

## បទ ពុទ្ធោ

ពុទ្ធោតិ វចនំ សេដ្ឋំ ពុទ្ធោតិ បទមុត្តមំ
នត្ថិ តេន សមំ លោកេ អញ្ញំ សោតរសាយនំ។

ពាក្យថា«ពុទ្ធោ» ថ្លៃប្រសើរផុត បទដ៏បរិសុទ្ធ ខ្ពស់ខ្ពង់ក្រៃលែង
គ្មានពាក្យឯណាពីរោះប្រដែង ស្មើពាក្យថ្លាថ្លៃងពុទ្ធោ ឡើយណា។

## បទ ធម្មោ

ធម្មោតិ វចនំ សេដ្ឋំ ធម្មោតិ បទមុត្តមំ
នត្ថិ តេន សមំ លោកេ អញ្ញំ សោតរសាយនំ។

ពាក្យថា«ធម្មោ» ថ្លៃ ប្រសើរផុត បទដ៏បរិសុទ្ធ ខ្ពស់ខ្ពង់ក្រៃលែង
គ្មានពាក្យឯណាពីរោះប្រដែង ស្មើពាក្យថ្លាថ្លៃងធម្មោ ឡើយណា។

## បទ សង្ឃោ

សង្ឃោតិ វចនំ សេដ្ឋំ សង្ឃោតិ បទមុត្តមំ
នត្ថិ តេន សមំ លោកេ អញ្ញំ សោតរសាយនំ។

ពាក្យថា សង្ឃោ ថ្លៃ ប្រសើរផុត បទដ៏បរិសុទ្ធ ខ្ពស់ខ្ពង់ក្រៃលែង
គ្មានពាក្យឯណាពីរោះប្រដែង ស្មើពាក្យថ្លាថ្លៃងសង្ឃោឡើយណា។

“ចិត្តដែលបុគ្គលមិនបានទូន្មានហើយ
តែងញុំាងប្រយោជន៍ធំឲ្យវិនាស”

# គាថាសរសើរគុណព្រះរតនត្រ័យ

(គម្ពីរតេលកដាហគាថា)

“ពុទ្ធរតនគាថា”

**យោ សព្វលោកមហិតោ ករុណាធិវាសោ មោក្ខាករោ រវិកុលម្ពរបុណ្ណចន្ទោ ញេយ្យោទធី សុវិបុលំ សកលំ វិពុទ្ធោ លោកុត្តមំ នមថ តំ សិរសា មុនិន្ទំ។**

សេចក្តីប្រែ៖ ព្រះមុនិន្ទអង្គឯណា ដែលសត្វលោកទាំងពួងបូជាហើយ ទ្រង់បរិបូណ៌ដោយមហាករុណា ជាអ្នកញ៉ាំងសត្វឱ្យបានរួចផុតចាកទុក្ខ ទ្រង់ប្រៀបដូចព្រះចន្ទពេញបូណ៌មីនៅកណ្តាលនភា ដែលជាវង្សដ៏ប្រសើរ ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងអស់ដ៏ទូលាយ ប្រៀបដូចមហាសមុទ្រ សូមអ្នកទាំងឡាយនមស្ការនូវព្រះមុនិន្ទដ៏ប្រសើរក្នុងលោកអង្គនោះ។

“ធម្មរតនគាថា”

**សោបានមាលមមលំ តិទសាលយស្ស សំសារសាគរសមុត្តរណាយ សេតុំ សព្វាគតីភយវិវជ្ជិតខេមមគ្គំ ធម្មំ នមស្សថ សទា មុនិនា បណីតំ។**

សេចក្តីប្រែ៖ សូមអ្នកទាំងឡាយនមស្ការនូវព្រះធម៌ ដែលព្រះមុនីទ្រង់បានសម្តែង ជាជណ្តើរដ៏បរិសុទ្ធនៃសួគ៌ ជាស្ពានឆ្លងមហាសមុទ្រ គឺសង្សារវដ្ត និងជាផ្លូវដ៏ក្សេម ដែលរួចផុតចាកទុគ្គតិភ័យទាំងពួង។

"សង្ឃរតនគាថា"

**ទេយ្យំ តនុម្បមបិ យត្ថ បសន្នចិត្តា ទត្វា នរា ផល**

**មុឡារតរំ លភន្តេ តំ សព្វទា ទសពលេនបិ សុប្បស**

**ត្ថំ សង្ឃំ នមស្សាម សមាមិតបុញ្ញខេត្តំ។**

សេចក្តីប្រែ៖ សូមអ្នកទាំងឡាយនមស្ការនូវព្រះសង្ឃ ដែលជាស្រែបុណ្យរកស្រែបុណ្យដទៃក្រៃលែងជាងគ្មាន សូម្បីព្រះទសពលក៏ទ្រង់សរសើរនូវព្រះសង្ឃជានិច្ច ដែលមហាជនមានចិត្តជ្រះថ្លាហើយប្រគេនទេយ្យធម៌សូម្បីតិច ក៏មានផលដ៏ច្រើន។

## ឧបមាព្រះរតនត្រ័យ ២២ យ៉ាង

(អដ្ឋកថា ខុទ្ទកនិកាយ ខុទ្ទកបាឋ)

១-ព្រះពុទ្ធប្រៀបដូចជាព្រះចន្ទពេញបូណ៌មី ព្រះធម៌ប្រៀបដូចជារស្មីនៃព្រះចន្ទ ព្រះសង្ឃប្រៀបដូចជា លោកដែលស្រស់បស់ដោយរស្មីនៃព្រះចន្ទពេញបូណ៌មីនោះ។

២-ព្រះពុទ្ធប្រៀបដូចជាព្រះអាទិត្យ ព្រះធម៌ប្រៀបដូចជារស្មីនៃព្រះអាទិត្យ ព្រះសង្ឃប្រៀបដូចជាលោក ដែលដួងអាទិត្យកម្ចាត់ភាពងងឹតហើយ។

៣-ព្រះពុទ្ធប្រៀបដូចជាអ្នកដុតព្រៃ ព្រះធម៌ដុតព្រៃ គឺកិលេសប្រៀបដូចជាភ្លើងដុតព្រៃ ព្រះសង្ឃដែលជាបុញ្ញក្ខេត្ត

ព្រោះដុតកិលេសបានហើយប្រៀបដូចជាភូមិភាគដែលជាស្រែ ព្រោះដុតព្រៃអស់ហើយ។

៤-ព្រះពុទ្ធប្រៀបដូចជាមហាមេឃដែលឲ្យនូវភ្លៀង ព្រះធម៌ប្រៀបដូចជាទឹកភ្លៀង ព្រះសង្ឃអ្នករម្ងាប់នូវលំអងកិលេស ប្រៀបដូចជាជនបទដែលរម្ងាប់នូវលំអងធូលីព្រោះភ្លៀងធ្លាក់។

៥-ព្រះពុទ្ធប្រៀបដូចជាសារថីដ៏ប្រសើរ ព្រះធម៌ប្រៀបដូចជាឧបាយសម្រាប់បង្ហឹកសេះអាជានេយ្យ ព្រះសង្ឃប្រៀបដូចជាហ្វូងសេះអាជានេយ្យដែលហ្វឹកហាត់ល្អហើយ។

៦-ព្រះពុទ្ធប្រៀបដូចជាអ្នកដកព្រួញ ព្រោះទ្រង់ដកសរគឺទិដ្ឋិបានអស់ ព្រះធម៌ប្រៀបដូចជាឧបាយដកសរចេញបាន ព្រះសង្ឃជាអ្នកដែលត្រូវដកសរគឺទិដ្ឋិចេញបានហើយ ប្រៀបដូចជាជនដែលត្រូវដកសរចេញបាន។

៧-ព្រះពុទ្ធប្រៀបដូចជាពេទ្យភ្នែក ព្រោះទ្រង់បកស្រទាប់មោហៈចេញបានហើយ ព្រះធម៌ប្រៀបដូចឧបាយជាគ្រឿងបកភ្នែក ព្រះសង្ឃមានស្រទាប់ភ្នែកបង់ហើយមានភ្នែកគឺញាណដ៏ភ្លឺថ្លា ប្រៀបដូចជាជនដែលបកភ្នែកមានភ្នែកភ្លឺ។

៨-ព្រះពុទ្ធប្រៀបដូចជាពេទ្យដ៏ពូកែ ព្រោះទ្រង់អាចកម្ចាត់នូវព្យាធិ គឺកិលេស ព្រមទាំងអនុស័យចេញបាន ព្រះធម៌ប្រៀបដូចជាថ្នាំដែលផ្សំត្រឹមត្រូវហើយ ព្រះសង្ឃដែលមានព្យាធិគឺកិលេស និងអនុស័យរម្ងាប់ហើយ ប្រៀបដូចជាពពួកជនដែលមានព្យាធិរម្ងាប់ហើយព្រោះកបនឹងថ្នាំ។

៩- ព្រះពុទ្ធប្រៀបដូចជាអ្នកចង្អុលផ្លូវ ព្រះធម៌ប្រៀបដូចជាផ្លូវល្អ គឺផ្លូវដែលសម្រាប់រួចផុតពីភ័យ ព្រះសង្ឃប្រៀបដូចជាអ្នកដើរផ្លូវដល់ទីដែលផុតភ័យ។

១០- ព្រះពុទ្ធប្រៀបដូចជាអ្នកអុំទូកដ៏ចំណាន ព្រះធម៌ប្រៀបដូចជាទូកព្រះសង្ឃប្រៀបដូចជាអ្នកដើរផ្លូវបានដល់ត្រើយ។

១១- ព្រះពុទ្ធប្រៀបដូចជាព្រៃហិមពាន្ត (ព្រៃដែលមានទឹកសន្សើម) ព្រះធម៌ប្រៀបដូចជាឱសថដែលកើតនៅព្រៃហិមពាន្តនោះ ព្រះសង្ឃប្រៀបដូចជាជនអ្នកមិនមានរោគព្រោះប្រើថ្នាំ។

១២- ព្រះពុទ្ធប្រៀបដូចជាអ្នកប្រទានទ្រព្យ ព្រះធម៌ប្រៀបដូចជាទ្រព្យ ព្រះសង្ឃអ្នកអរិយទ្រព្យមកដោយប្រពៃ ប្រៀបដូចជាជនអ្នកបានទ្រព្យតាមបំណង។

១៣- ព្រះពុទ្ធប្រៀបដូចជាអ្នកចង្អុលកំណប់ទ្រព្យ ព្រះធម៌ប្រៀបដូចជាកំណប់ទ្រព្យ ព្រះសង្ឃប្រៀបដូចជាជនអ្នកបានកំណប់ទ្រព្យ។

១៤- ព្រះសម្មាសម្ពុទ្ធជាវិរបុរស ប្រៀបដូចជាអ្នកប្រទាននូវការមិនមានភ័យ ព្រះធម៌ប្រៀបដូចជាការមិនមានភ័យ ព្រះសង្ឃដែលរួចពីភ័យគ្រប់យ៉ាង ប្រៀបដូចជាជនដល់នូវការមិនមានភ័យ។

១៥- ព្រះពុទ្ធប្រៀបដូចជាអ្នកលួងលោម ព្រះធម៌ប្រៀបដូចជាការលួងលោមព្រះសង្ឃប្រៀបដូចជាជនអ្នកត្រូវលួងលោម។

១៦- ព្រះពុទ្ធប្រៀបដូចជាមិត្តល្អ ព្រះធម៌ប្រៀបដូចជាពាក្យដាស់តឿនដែលជាពាក្យមានប្រយោជន៍ ព្រះសង្ឃប្រៀបដូចជាជនអ្នកជួបប្រសព្វនូវប្រយោជន៍ព្រោះធ្វើតាមពាក្យរបស់មិត្តល្អ។

១៧- ព្រះពុទ្ធប្រៀបដូចជាអណ្តូងនាំឲ្យកើតទ្រព្យ ព្រះធម៌ប្រៀបដូចជាទ្រព្យដែលមានសារៈ ព្រះសង្ឃប្រៀបដូចជាជនអ្នកប្រើទ្រព្យដែលជាសារៈ។

១៨- ព្រះពុទ្ធប្រៀបដូចជាអ្នកស្រោចទឹកផ្កូតឲ្យព្រះរាជកុមារ ព្រះធម៌ប្រៀបដូចជាទឹកស្រោចស្រពលើព្រះរាជកុមារតាំងពីព្រះសីសៈចុះមក ព្រះសង្ឃអ្នកបានទទួលនូវការស្រោចស្រពទឹកល្អហើយ ដោយទឹកគឺព្រះសទ្ធម្ម ប្រៀបដូចជាក្រុមព្រះរាជកុមារដែលបានស្រង់ទឹកល្អហើយ។

១៩- ព្រះពុទ្ធប្រៀបដូចជាជាងធ្វើគ្រឿងប្រដាប់ ព្រះធម៌ប្រៀបដូចជាគ្រឿងប្រដាប់ (អលង្ការ) ព្រះសង្ឃជាអ្នកប្រដាប់ដោយព្រះសទ្ធម្ម ប្រៀបដូចជាព្រះរាជឱរសទាំងឡាយដែលទ្រង់ប្រដាប់ហើយ។

២០- ព្រះពុទ្ធប្រៀបដូចជាដើមចន្ទន៍ ព្រះធម៌ប្រៀបដូចជាក្លិនដែលកើតអំពីខ្លឹមចន្ទន៍នោះ ព្រះសង្ឃបានរម្ងាប់នូវសេចក្តីក្តៅក្រហាយចិត្តដោយព្រះសទ្ធម្ម ប្រៀបដូចជាជនអ្នករម្ងាប់នូវភាពក្តៅផ្លូវកាយ ព្រោះបើលម្អិតខ្លឹមចន្ទន៍នោះឯង។

២១- ព្រះពុទ្ធប្រៀបដូចជាបិតា អ្នកចែកទ្រព្យមរតកប្រកបដោយធម៌ ព្រះធម៌ប្រៀបដូចជាទ្រព្យមរតក ព្រះសង្ឃអ្នក

ទទួលនូវទ្រព្យមរតកគឺព្រះសទ្ធម្មប្រៀបដូចជាបុត្រទាំងឡាយ ដែលជាអ្នកទទួលនូវទ្រព្យមរតក។

២២- ព្រះពុទ្ធប្រៀបដូចជាផ្កាឈូកដែលរីក ព្រះធម៌ប្រៀបដូចជាលំអងកេសរដែលកើតក្នុងផ្កាឈូកនោះ ព្រះសង្ឃប្រៀបដូចជាភមរជាតិ (មានសត្វឃ្មុំជាដើម) ដែលក្រេបយកលំអងកេសរក្នុងផ្កាឈូក។

គប្បីប្រកាសព្រះសរណត្រ័យនោះ ដោយសេចក្តីឧបមារទាំងឡាយ ដូចពោលមកនេះឯង។

សព្វញ្ញូ សព្វទស្សាវី ជិនោ អាចរិយោ មម
មហាការុណិកោ សត្ថា សព្វលោកតិកិច្ឆកោ។

ព្រះជិនស្រីព្រះអង្គជាសព្វញ្ញូ ទ្រង់ឃើញនូវធម៌ទាំងពួង ជាសាស្តាប្រកបដោយករុណាដ៏ធំ ទ្រង់រក្សានូវសត្វលោកទាំងអស់ ជាអាចារ្យនៃខ្ញុំ។

## បណាមគាថា

យោ កប្បកោដីហិបិ អប្បមេយ្យំ កាលំ ករោន្តោ អតិទុក្ករានិ ខេទំ គតោ លោកហិតាយ នាថោ នមោ មហាការុណិកស្ស តស្ស អសម្ពុធំ ពុទ្ធនិសេវិតំ យំ ភវាភវំ គច្ឆតិ ជីវលោ

កោ នមោ អវិជ្ជានិកិលេសជាលំ វិទ្ធំសិតោ ធម្មវរស្ស តស្ស គុណេហិ យោ សីល សមាធិ បញ្ញា វិមុត្តិញ្ញាណប្បវត្តីហិ យុត្តោ ខេត្តញ្ជ នានំ កុសលត្ថិកានំ តមរិយសង្ឃំ សិរសា នមាមិ។

(ក្រាបថ្វាយបង្គំម្តង)

## បណាមគាថា (ប្រែជាកាព្យ)

យោ កប្បកោដី ហិបិ អប្បមេយ្យំ កាលំ

ករោន្តោ អតិទុក្ករានិ ខេទំ គតោ លោកហិតា

យ នាថោ នមោ មហាការុណិកស្ស តស្ស។

ព្រះពុទ្ធជាទីពឹង ជាពុំនឹងសព្វសត្តា

ព្រះអង្គកាលប្រាថ្នា ធ្វើកសាងអស់កាលយូរ។

រាប់ដោយកោដិកប្បា ច្រើនគណនាហួសគិតគូរ

បានត្រាស់ជាសព្វញ្ញូ ត្រាស់ជាគ្រូលើភពឋាន។

ធ្វើកម្មជាកម្រ សត្វនិករគ្រាប់ពុំបាន

តោកយ៉ាកលំបាកប្រាណ ព្រោះប្រយោជន៍ដល់សព្វសត្វ។

ខ្ញុំសូមឱនសិរសា ចិត្តប្រាថ្នាបង្គំថ្វាត់

ព្រះពុទ្ធករុណាសត្វ នោះជាទីពឹងសព្វកាល។

អសម្ពុធំ ពុទ្ធ និសេវិតំ យំ ភវាភវំ គច្ឆតិ ជីវ លោកោ នមោ អវិជ្ជា និក្កិលេសជាលំ វិទ្ធំសិតោ ធម្មវរស្ស តស្ស។

សត្វតែងកើតស្លាប់បង់ ព្រោះចំណងកម្មជាគោល
ឱ្យវិលវល់អន្ទោល ក្នុងភពតូចនិងភពធំ។
ហេតុតែមិនដឹងធម៌ ជាម្ចាស់ល្អស្អាតសុខុម
ព្រះពុទ្ធទ្រង់សេពសម ចិត្តខ្ញុំសូមនមស្ការ។
នូវធម៌ប្រពៃពិត វិសេសសុទ្ធនោះឯងណា
កាត់បង់នូវអវិជ្ជា គឺបណ្តោញកិលេសហើយ។

**គុណេហិ យោ សីល សមាធិ បញ្ញា វិមុត្តិញ្ញាណប្ប ភូតីហិ យុត្តោ ខេត្តញ្ញ នានំ កុសលត្ថិកានំ តមរិយស ង្ឃំ សិរសា នមាមិ។**

ព្រះសង្ឃអង្គសាវ័ក មានសំវរៈសទ្ធាទ្រង់
កបដោយគុណសីលត្រង់ និងសមាធិបញ្ញា។
និងវិមុត្តិញ្ញាណ កិលេសគ្មានក្នុងអាត្មា
ជាបុញ្ញក្ខេត្តា ជនត្រូវការជាកុសល។
ខ្ញុំសូមឱនសិរសី ដល់ព្រះអរិយបុគ្គល
ជាបុត្រព្រះទសពល ជាមង្គលដល់សព្វសត្វ។

(ក្រាបថ្វាយបង្គំម្តង)

“ចិត្តដែលបុគ្គលបានទូន្មានល្អហើយ

តែងប្រព្រឹត្តទៅដើម្បីប្រយោជន៍យ៉ាងធំ”

# ត្រៃបណាម

ឥច្ចេវមច្ចន្ត នមស្សនេយ្យំ នមស្សមានោ រតនត្តយំ យំ បុញ្ញាភិសន្ទំ វិបុលំ អលត្ថំ តស្សានុភាវេន ហតន្តរាយោ។

ប្រែ៖ ខ្ញុំសូមនមស្ការ លើកហត្ថាឱនសិរសី
បង្គំគុណទាំងបី ខ្ពស់លើសលប់ត្រៃលោកា។
សូមបុណ្យកងកុសល ឱ្យបានដល់យើងខ្ញុំណា
ពេញពោរស្មើធារា ដូចជលសាធំទូលាយ។
សូមឱ្យកំចាត់បង់ អពមង្គលទាំងឡាយ
ឱ្យចៀសចេញចាកឆ្ងាយ ក្តីអន្តរាយកុំបីមាន។
ដោយកម្លាំងអានុភាព បុញ្ញលាភជាប្រធាន
កងបុញ្ញរាសីមាន សូមបានក្សាន្តកុំមានមោះ។
ដោយគុណនមស្ការ ត្រៃរតនាប្រសើរខ្ពស់
សូមអានិសង្សនោះ ដាក់ដល់ព្រះនិព្វានហោង ។

(ក្រាបថ្វាយបង្គំម្តង)

## ថ្វាយបង្គំបញ្ចពុទ្ធបាទា

វន្ទាមិ ពុទ្ធំ ភវបារតិណ្ណំ តិលោកកេតុំ តិភវេកនាថំ យោ លោកសេដ្ឋោ សកលំ កិលេសំ ឆេត្វា ច ពោធេសិ ជនំ អនន្តំ យំ នម្មទាយ នទិយា បុលិនេ ច តីរេ យំ សច្ចពន្ធគិរិកេ

**សុមនាចលគ្គេ យំ តត្ថ យោនកបុរេ មុនិនោ ច ធាតុំ តំ ធាតុលញ្ឆនមហំ សិរសា នមាមិ សុវណ្ណមាលិកេ សុវណ្ណបព្វតេ សុមនកូដេ យោ នកបុរេ នម្មទាយ នទិយា បញ្ច ធាតុវរំ ឋានំ អហំ វន្ទាមិ ទូរតោ។**

ប្រែ៖ **វន្ទាមិ ពុទ្ធំ ភវបារតិណ្ណំ តិលោកកេតុំ តិភវេកនាថំ យោ លោកសេដ្ឋោ សកលំ កិលេសំ ឆេត្វាន ពោធេសិ ជនំ អនន្តំ** ព្រះសម្មាសម្ពុទ្ធឯណា ព្រះអង្គប្រសើរក្នុងលោក ទ្រង់កាត់បង់នូវកិលេសទាំងអស់ បានហើយ ញ៉ាំងជនជាអនន្តឱ្យត្រាស់ដឹងហើយ ខ្ញុំសូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធនោះ ព្រះអង្គឆ្លងផុតអំពីប្រាំងនៃភពហើយ ព្រះអង្គជាទង់ជ័យនៃត្រៃលោក មានតែព្រះអង្គមួយ ជាទីពឹងនៃសព្វសត្វក្នុងត្រៃភព ។ **យំ នម្មទាយ នទិយា បុលិនេ ច តីរេ យំ សច្ចពន្ធគិរិកេ សុមនាចលគ្គេ យំ តត្ថ យោនកបុរេ មុនិនោ ច ធាតុំ តំ ធាតុ លញ្ឆនមហំ សិរសា នមាមិ** ស្នាមព្រះបាទឯណា (ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក) លើផ្ទៃខ្សាច់ទៀបឆ្នេរនៃស្ទឹងឈ្មោះនម្មទា ស្នាមព្រះបាទឯណា (ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក) លើភ្នំសច្ចពន្ធ និងលើភ្នំសុមនកូដ ស្នាមព្រះបាទឯណា (ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក) ក្នុងយោនកបុរី ខ្ញុំសូមក្រាបថ្វាយបង្គំដោយត្បូង ចំពោះទៅព្រះបាទនិងស្នាមព្រះបាទទាំងនោះនៃព្រះសក្យមុនី។ **សុវណ្ណមាលិកេ សុវណ្ណបព្វតេ សុមនកូដេ យោនកបុរេ  នម្មទាយ នទិយា បញ្ច ធាតុវរំ ឋានំ អហំ វន្ទាមិ ទូរតោ** ខ្ញុំសូមនមស្សការអំពីចម្ងាយ នៅស្ថានដែលមានព្រះបាទដ៏ប្រសើរ៥កន្លែង គឺស្ថាន

លើភ្នំសុវណ្ណមាលិក១ លើភ្នំសុវណ្ណបពិត១ លើភ្នំសុមនកូដ១ ក្នុងយោនកបុរី១ ក្បែរស្ទឹងនម្មទា១។

(ក្រាបថ្វាយបង្គំម្តង)

# ថ្វាយបង្គំព្រះសារីរិកធាតុ

**វន្ទាមិ ចេតិយំ សព្វំ សព្វដ្ឋានេ សុបតិដ្ឋិតំ**

**សារីរិកធាតុមហាពោធិំ ពុទ្ធរូបំ សកលំ សទា។**

ប្រែ៖ ខ្ញុំសូមថ្វាយបង្គំ ធ្លោះព្រះបរមចេតិយ
ព្រមទាំងព្រះសារី រិកធាតុនៃព្រះពុទ្ធ។
និងមហាពោធិព្រឹក្ស ដែលគួរនឹកដោយលំអុត
លំអោនចិត្តបរិសុទ្ធ លើកកំបង់អញ្ជលី។
និងព្រះពុទ្ធរូប តំណាងអង្គព្រះមុនី
ដែលស្ថិតនៅគ្រប់ទី ស្ថាននានានោះទាំងអស់។
ដោយតេជះនៃគុណ ព្រះមានបុណ្យប្រសើរខ្ពស់
ដែលតែងតែរំលោះ រំដោះទុក្ខភ័យអន្តរាយ។
សូមឲ្យខ្ញុំបានសុខ ឃ្លាតចាកទុក្ខជងទាំងឡាយ
សត្រូវទោះជិតឆ្ងាយ សូមឲ្យក្លាយមកជាមិត្ត។
សូមទាន់ព្រះអរិយ មេត្រិយ៍ថ្លៃវិសិដ្ឋ
សូមបានឃើញធម៌ពិត សមដូចចិត្តប្រាថ្នាហោង។

# សត្តមហាឋាន

(បនបដ្ឋារត្ត)

បឋមំ ពោធិបល្លង្កំ ទុតិយំ អនិមិស្សកំ
តតិយំ ចង្កមំ សេដ្ឋំ ចតុត្ថំ រតនាឃរំ។
បញ្ចមំ អជ្ជបាលញ្ច មុចលិន្ទេន ឆដ្ឋមំ
សត្តមំ រាជាយតនំ សត្តាហំ មុនិ សេវិតំ។
ឯតេ សត្ត មហាឋានា ជម្ពូទីបេ បតិដ្ឋិតា
បូជិតា នរទេវេហិ អហំ វន្ទាមិ ទូរតោ។

"ប្រែជាកាព្យពាក្យ ៨"

ទី១ បល្ល័ង្កដែលព្រះសាស្ដា ចម្រើនអានាបានស្សតិ
ទី២ ឮសានពីដើមពោធិ ហៅថាអនិមិស្សកចេតិយ។
ទី៣ គឺទីដែលព្រះជិនស្រី ព្រះអង្គឃ្លាតឱ្យទ្រង់យាងចង្ក្រម
ទី៤ គឺទីដែលព្រះបរម ចម្រើនអភិធម្មជាធម៌បរមត្ថ ។
ទី៥ គឺទីដែលព្រះភគវ័ត ទ្រង់គង់ស្ងប់ស្ងាត់ក្រោមអជ្ជបាល
ទី៦ ទីវិសេសវិសាល សម្រិតសម្រាលក្បែរស្រះមុចលិន្ទ។
ទី៧ គឺទីព្រះមុនិន្ទ សង្រួមកាយិន្ទ្រិយ៍រាជាយតនា
ទីទាំងប្រាំពីរដែលពោលនេះណា ជាទីថ្លៃថ្លាមានពិតប្រាកដ។
ក្នុងជម្ពូទ្វីបនេះជាកំណត់ ប្រាជ្ញលោកសន្មតហៅថាឋានធំ
ព្រោះជាកន្លែងដ៏ល្អឧត្ដម ជាទីមនោរម្យដល់មនុស្សទេវតា។
ជាទីសម្រាប់អ្នកមានសទ្ធា នាំគ្នាវន្ទាយកបុណ្យកុសល

ខ្ញុំសូមក្រាបថ្វាយបង្គំនោះដល់ ឋានធំនិមលនោះពីចម្ងាយ៕

(ក្រាបថ្វាយបង្គំម្តង)

# អដ្ឋមហាឋាន

(បទបថ្យាវត្ត)

បឋមំ លុម្ពិនីជាតំ ទុតិយំ ពោធិមុត្តមំ
តតិយំ ធម្មចក្កញ្ច ចតុត្ថំ ចាលិលេយ្យកំ។
បញ្ចមំ ច នាឡាគិរី ឆដ្ឋមំ ចាជីហារិយំ
សត្តមំ សិរិនេរិញ្ច អដ្ឋមំ បរិនិព្វុតំ។
ឯតេ អដ្ឋ មហាឋានា ជម្ពូទីបេ បតិដ្ឋិតា
បូជិតា នរទេវេហិ អហំ វន្ទាមិ ទូរតោ។

“ប្រែបទពាក្យ ៨”

ឋានធំទាំងឡាយប្រាំបីកន្លែង ជាទីស្ងប់ស្ងែងដល់ពពួកសត្វ
ទី១ ឧទ្យានជាឋានព្រៃស្ងាត់ គឺព្រៃសាលវ័តន៍ដែលទ្រង់ប្រសូត
ទី២ ប្រសើរដែលព្រះទ្រង់ស្រូត ត្រាស់ក្រោមដើមពោធិព្រឹក្សឧត្តម
ទី៣ កន្លែងដែលព្រះបរម សំដែងព្រះធម្មឈ្មោះធម្មចក្រ។
ប្រោសភិក្ខុប្រាំអង្គគឺពួកបញ្ចវគ្គ- គីយ៍ដែលជាអ្នកបម្រើព្រះអង្គ
ដោយព្រះទ័យថ្លៃមិនអាចលះបង់ ហើយយាងតម្រង់ពីដើមជ្រៃទៅ
ទី៤ គឺទីដែលទ្រង់គង់នៅ ក្នុងឋានព្រៃជ្រៅឈ្មោះបាលិលេយ្យ

ទីនោះគ្មានមនុស្សមានតែសត្វព្រៃ គឺដំរីថ្វៃបម្រើព្រះអង្គ។
ទី៥ គឺទីដែលព្រះពុទ្ធអង្គ ផ្ចាញ់សត្វទ្រនង់នាឡាគិរី
ទីនោះមានមនុស្សបែកពួកជាទ្វី ទៅមើលពិធីនៃព្រះសម្ពុទ្ធ។
ទី៦ កាលព្រះសព្វញ្ញុត- ញ្ញាណជាមកុដត្រៃលោកាចារ្យ
ផ្ចាញ់ពួកនិគ្រន្ថដោយបាដិហារ្យ ឈ្មោះល្បីអស្ចារ្យគ្មាននរណាដល់។
ទី៧ កាលព្រះទសពល គង់លើមណ្ឌលថ្មព្រះឥន្ទ្រា។
ទ្រង់បានសំដែងនូវព្រះធម្មា ប្រាកដនាមជាធម៌អភិធម្ម។
សង់គុណមាតាដែលមានគុណធំ លើព្រះបរមសម្ពុទ្ធថ្លៃថ្លា។
ទី៨ កាលអង្គព្រះសាស្តា ផ្ទំក្រោមដើមសាលព្រឹក្សទាំងគូ។
ពេលនោះឯងហើយព្រះសព្វញ្ញូ ព្រះអង្គជាគ្រូយាងចូលនិព្វាន។
ឋានធំប្រាំបីកន្លែងនោះមាន ប្រតិស្ឋានជម្ពូទ្វីបា។
ជាទីដែលពួកមនុស្សនិងទេវតា មានចិត្តជ្រះថ្លាគួរទៅយង់យល់
ខ្ញុំសូមឱនកាយបង្គំត្តោះដល់ ឋានធំនិមលប្រាំបីនោះឯង។
សូមសុខចម្រើនកើនយូរអង្វែង ទុក្ខទោសចំបែងកុំកើតមានឡើយ ៕

# នមស្សការពុទ្ធប្បវត្តិ

(ស្មូត្រជាការញ)

ខ្ញុំសូមថ្វាយវន្ទា ព្រះសាស្តាដ៏មានបុណ្យ
និងសូមគោរពគុណ គ្រាព្រះអង្គចុះចាកឋាន។
មកចាប់ផ្ទៃមាតា ស្រីស្រីង៉ាស្រស់កល្យាណ
កាលនោះមហាជនបាន សុខក្សេមក្សាន្តព្រោះបារមី។

ក្នុងថ្ងៃព្រហស្បតិ៍អា- សាឍមាសាពេញបូណ៌មី
រកាជាឆ្នាំថ្មី សុខសិរីដល់ជនា។
កាលបានដប់ខែហើយ ព្រះគុណអើយកើតអស្ចារ្យ
នៅនាដងព្រឹក្សា ឈ្មោះហៅថាព្រៃសាលវ័ន។
កក្រើកផែនពសុធា មានទេវតាវាប់រយពាន់
ឋិតនៅក្នុងតំបន់ នៃឧទ្យានលុម្ពិនី។
ឆ្នាំចពិសាខនា ថ្ងៃសុក្រជាពេញបូណ៌មី
ថ្ងៃនោះព្រះជិនស្រី ទ្រង់ប្រសូតឥតមានព្រួយ។
កាលសិទ្ធត្ថក្សត្រា មានវស្សាដប់ប្រាំមួយ
បិតាបានលើកស្ងួយ អភិសេកនឹងស្រីផ្កា។
នារីស្រស់កល្យាណ អ្នកជងបានស្គាល់គ្រប់គ្នា
ថាឈ្មោះនាងពិម្ពា ស្រស់សោភាលើសលែងក្រៃ។
កាលនោះក្នុងឆ្នាំឆ្លូវ ត្រូវថ្ងៃសៅរ៍មានសិរី
អាសាឍពេញបូណ៌មី ក្សត្រាថ្លៃបានសុខា។
ស្ដេចមានព្រះរាជបុត្រ បរិសុទ្ធភ័ក្ត្រស្រស់ថ្លា
គួរឱ្យព្រះរាជា ស្ដេចជំពាក់ចិត្តពេកក្រៃ។
តែទ្រង់បានកាត់ផ្ដាច់ ទ្រង់សម្រេចព្រះហឫទ័យ
ថាត្រូវកាត់អាល័យ ពីបុត្រថ្លៃមួយគ្រាណា។
បើបិតាបានត្រាស់ វិលរហ័សរកបុត្រា
មកប្រោសស្ងួនពុំងារ ចាកសង្សារណាបុត្រថ្លៃ។

កាលនោះថ្ងៃព្រហស្បតិ៍ ក្នុងឆ្នាំថោះមានសិរី
អាសាឍពេញបូណ៌មី ក្សត្រាថ្លៃចេញបព្វជ្ជា។
កាលបានបព្វជ្ជាហើយ មិនព្រងើយខំឧស្សាហ៍
ធ្វើទុក្ករកិរិយា គ្មាននរណាធ្វើដូចអី។
បានត្រាស់ឆ្នាំរកា ពិសាខាពុធបុណ្ណមី
ជាថ្ងៃព្រះជិនស្រី មានសិរីឈ្នះក្រុងមារ។
ត្រាស់ដឹងបានពីរខែ ទ្រង់គ្មាន់គ្នេរប្រោសទេសនា
ប្រោសបញ្ចវគ្គិយា នាកណ្ដាលដងព្រឹក្សព្រៃ។
គឺក្នុងឆ្នាំរកា អាសាឍមាសាបុណ្ណមី
ថ្ងៃសៅរ៍ព្រះជិនស្រី ផ្ដើមពោលស្ដីធម៌ទេសនា។
ក៏ជាថ្ងៃកំណើត សង្ឃបានកើតក្នុងលោកា
សាវ័កព្រះសាស្ដា មានរហូតដល់សព្វថ្ងៃ។
នាថ្ងៃមួយនោះណា គួរសោកាណាស់ម្ចាស់ថ្លៃ
គឺថ្ងៃព្រះជិនស្រី កាត់ព្រះទ័យដាក់សង្ខារ។
គឺក្នុងថ្ងៃអាទិត្យ ឆ្នាំម្សាញ់ពិតមាឃមាសា
នៅចំពោះមុខមារ នាបាវាលចេតិយ។
បីខែកន្លងទៅ មិនឈប់នៅយឺតយូរអី
ដល់ថ្ងៃព្រះជិនស្រី ទ្រង់និព្វានចាកលោកា។
គឺក្នុងឆ្នាំនោះឯង មានការជ្រេងតែមាសា
គឺខែពិសាខនា ថ្ងៃអង្គារពេញបូណ៌មី ។

ដោយអំណាចអានុភាព ដែលខ្ញុំក្រាបថ្វាយវន្ទីយ៍
នឹកគុណព្រះមុនី សូត្រប្រវត្តិព្រះសាស្តា។
សូមឱ្យសម្រេចបុណ្យ ដែលជាគុណល្អថ្លៃថ្លា
អន្ទោលក្នុងសង្សារ សូមប្រាថ្នាជួបបណ្ឌិត។
សូមជួបព្រះសិអារ្យ ជាសាស្តាដ៏ពិសិដ្ឋ
សូមចាក់ធ្លុះធម៌ពិត សមដូចចិត្តប្រាថ្នាហោង៕

## ថ្វាយបង្គំព្រះអរហន្ត៩ទិសា

អរហំតាំងស្មារតី ឱនសិរសីថ្វាយបង្គំ
ព្រះពុទ្ធោជាធំ គង់និយមនៅកណ្តាល។
មានព្រះអរហន្តា គ្រប់ទិសាសព្វៗកាល
ព្រះទ័យត្រេកត្រអាល ប្រោសប្រទានធម៌ទេសនា។
ព្រះសារីបុត្តចាំ គង់ខាងស្តាំព្រះសាស្តា
អានន្ទបច្ឆិមា គង់ខាងក្រោយព្រះអង្គស្មោះ
ព្រះមោគ្គល្លានា ឧត្តរាឆ្វេងចំពោះ
កោណ្ឌញ្ញោត្តរនោះ គង់ទិសបូពិចំព្រះភ័ក្ត្រ។
គវម្បតីថេរ គង់នៅឯពាយ័ព្យជាក់
ឧបាលិយត្ថេរ គង់និរតីខាងព្រះអង្គ។
ព្រះកស្សបត្ថេរ គង់នៅឯអាគ្នេយ៍ត្រង់
រាហុលបុត្តព្រះអង្គ គង់នៅត្រង់ទិសឦសាន។
បើអ្នកណាដឹងយល់ ពុទ្ធមង្គលគួរឱ្យបាន

ទន្ទេញទុកក្នុងប្រាណ ខំសិក្សាថ្វាយបង្គំ។
បាលីលោកចែងថា បើអ្នកណាមួយផ្ចិតផ្ចង់
លំអុតលំឱនអង្គ កុំបោះបង់ធម៌ប្រពៃ។
ទុក្ខសោករោគាពាធិ ឧត្បាតវាទវាងវៃ
ភាន់ភាំងភាគភិតភ័យ ឥតមោះមែមកបៀតបាន។
សួស្តីជ័យជំនះ មានតេជះរក្សាប្រាណ
ឥតអ្វីមកបៀនបាន រៀងរួចដល់និព្វានហោង៕

# សង្វេគគាថា

សិរិឱនលំទោនកាយ ហត្ថាថ្វាយបង្គំផ្ចង់
ចិត្តស្មោះចំពោះត្រង់ អង្គព្រះមុនិន្ទពិនលោកា ។
កាលទ្រង់គង់នៅឡើយ ព្រះគុណអើយតែងមេត្តា
ប្រោសសត្វមនុស្សទេវតា រាល់វេលាពុំដែលខាន ។
ឥឡូវព្រះពុទ្ធអង្គ នឹងទ្រាំគង់យូរពុំបាន
យាងចូលកាន់និព្វាន ខានទូន្មានយើងរាល់គ្នា ។
សាវ័កព្រះជាម្ចាស់ គង់ច្រើនណាស់នៅត្រៀបត្រា
បាត់តែអង្គសាស្តា ពីគ្រានោះលុះឥឡូវ ។
រឿងនេះសែនវិវេក គួរសង្វេគពេកណាស់កូវ
ព្រះរូបគង់ច្រងូវ សត្វត្រូវពឹងយកនិស្ស័យ ។
ពេញបូណ៌វិសាខា ថ្ងៃនេះណាព្រះម្ចាស់ថ្លៃ
ប្រសូតចេញចាកផ្ទៃ និងក្សត្រថ្លៃចេញបព្វជ្ជា ។

បានត្រាស់ពោធិញាណ    ចូលនិព្វានឋានសោភា
ពេញបូណ៌ិវិសាខា    មានចរិតបួននោះឯង ។
កាលស្តេចនិព្វានទៅ    សាវ័កនៅគិតកោតក្រែង
រៀបធ្វើគ្រឿងតាំងតែង    រាល់វេលាតែរៀងរាប ។
មកដល់ឥឡូវនេះ    យើងខ្ញុំនេះវន្ទាក្រាប
នឹកដល់ព្រះទ្រង់ភាព    ជាបុញ្ញលាភទាន់សាសនា ។
ខ្ញុំបានគោរពហើយ    ព្រះគុណអើយខ្ញុំប្រាថ្នា
ទាន់ព្រះមេត្តេយ្យា    ត្រាស់ឯក្រោយដោយប្រពៃ
ពាក្យប៉ងបំណងណាត់    កុំបីភ្លាត់ឡើយម្ចាស់ថ្លៃ
សូមទាន់ព្រះមេត្តេយ្យ    គ្រាន់អាស្រ័យទៅនិព្វាន ៕

# ថ្វាយបង្គំព្រះពុទ្ធ៥អង្គ

ភទ្ទកល្បនេះមាន    ព្រះអង្គទ្រង់ញាណ    ប្រាំអង្គយាត្រា
ព្រះនាមថ្លាថ្លៃ    ប្រពៃសោភា    រីព្រះសាស្តា
ទីទៃពល់អង្គ។

ព្រះកុក្កុសន្ធោ    ដើមជ្រៃជាពោ-    ធិព្រឹក្សខ្ពស់ខ្ពង់
ធព្វណ្ណរង្សី    រស្មីព្រះអង្គ    ព្រះជន្មស្តេចគង់
៤មុឺនព្រះវស្សា។

ព្រះកោនាគមនោ    ដើមល្វាជាពោ-    ធិព្រឹក្សសាខា
ធព្វណ្ណរង្សី    រស្មីថ្លៃថ្លា    ព្រះជន្មសាស្តា
៣មុឺនឆ្នាំគត់។

ព្រះកស្សបោ ដើមជ្រៃជាពោ- ធិព្រឹក្សបរិសុទ្ធ
ឆព្វណ្ណរង្សី រស្មីព្រះពុទ្ធ ព្រះជន្មកំណត់
២ម៉ឺនព្រះវស្សា។

ព្រះសមណគោតម ត្រាស់ជាបឋម បរមសាស្ដា
ផុសរតនបល្ល័ង្ក ទីនាំងពេជ្រថ្លា ស្ដេចគង់ផ្ចាញ់មារ
ព្រះអង្គឥតភ្លឹក។

ដោយទសបារមី ឆព្វណ្ណរង្សី ក្រោមពោធិព្រឹក្ស
នាងគង្ហីងធរណី ទេវីសាចទឹក ពលមារអធិក
ចាញ់ព្រះសាស្ដា។

ព្រះជន្មប៉ែតសិប ឆ្នាំហើយទើបរាប់ ៥០០០ព្រះវស្សា
ស្ដេចចូលនិព្វាន ទុកព្រះសាសនា ប្រោសអស់ទេព្ដា
មនុស្សសត្វទាំងឡាយ។

ព្រះសិអារ្យមេត្រី ពោធិសត្វថ្លៃ រស្មីឆើតឆាយ
នឹងត្រាស់ជាក្រោយ ដោយពុទ្ធព្យាករណ៍ ព្រះជន្មបវរ
៨ម៉ឺនព្រះវស្សា។

ដើមខ្ទឹងជាពោ- ធិព្រឹក្សសេដ្ឋា មែកមានផលផ្កា
ប៉ុនកង់រាជរថ បរិសុទ្ធថ្លៃថ្លា លំអង់កេសរ
រុះរោយដោយដី។

ក្រអូបភាសភាយ ក្លិនក្លែបខ្ចរខ្ចាយ សាយសព្វទៅដល់
ទិសទីទាំង១០ អប់អស់មណ្ឌល ទិសទាំងបួនសល់

ដល់ឋានសួគ៌ិនាយ។

ភទ្ទកប្បយូរក្តាត់ បើកសំពៅរតន៍ ទាំង៥ព្រោងព្រាយ
ភេត្រាទាំង ៥ បើកបរផ្លោះឆ្ងាយ ឆ្លងជលសាសាយ
ឥតភ្លឹកវាយោ។

ទន្ទេរទន្ទាំ លលេលលាំ លឿនលើអាប៉ោ
សមុទ្ទធំធេង បែកជ្រែងសាគរ ត្រីនាគឆ្លាមម្ករ
ពោរពេញត្រៀប
ត្រា។

ព្រះអង្គផ្ទុកសត្វ ដោយពុទ្ធក្រឹត្យ សល់សែនសង្ខ័យ
ភេត្រារតន៍ដល់ ថ្នល់កែវរដ្ឋា សុខារិកា
ព្រោងព្រាយរស្មី។

ព្រះអង្គតែងប្រោស សត្វនោះឱ្យរស់ មិនឱ្យមានសល់
នាំឡើងទៅដាក់ ដល់ឋានសុកល ឋាននោះមណ្ឌល
គឺនិព្វានហោង៕

## ទេវធម៌

សុខោ ពុទ្ធានមុប្បាទោ សុខា សទ្ធម្មទេសនា សុខា សង្ឃស្សសាមគ្គី សមគ្គានំ តបោ សុខោ ទិវា តបតិ អាទិច្ចោ រត្តិមាភាតិ ចន្ទិមា សន្នទ្ធោ ខត្តិយោ តបតិ ឈាយី តបតិ ព្រាហ្មណោ អថ សព្វមហោរត្តិ ពុទ្ធោ តបតិ តេជសា (ឯតេន សច្ចវជ្ជេន សុវត្ថិ ហោតុ សព្វទា)។

**ហិរិ ឱត្តប្ប សម្បន្នា សុក្កធម្ម សមាហិតា សន្តោ សប្បុរិសា លោកេ ទេវ ធម្មាតិ វុច្ចរេ។**

សេចក្តីប្រែ៖ កិរិយាបានត្រាស់នៃព្រះពុទ្ធទាំងឡាយ នាំមកនូវសេចក្តីសុខ កិរិយាសំដែងនូវធម៌របស់សប្បុរសនាំមកនូវសេចក្តីសុខ សេចក្តីព្រមព្រៀងគ្នារបស់សង្ឃ ឬពួកក្រុមនាំមកនូវសេចក្តីសុខ សេចក្តីព្យាយាមរបស់អ្នកដែលព្រមព្រៀងគ្នាទាំងឡាយនាំមកនូវសេចក្តីសុខ។ ព្រះអាទិត្យរុងរឿងតែពេលថ្ងៃ ព្រះចន្ទរុងរឿងតែពេលយប់ ក្សត្រទ្រង់គ្រឿងក្រោសទើបរុងរឿង ព្រាហ្មណ៍មានឈានទើបរុងរឿង ឯព្រះពុទ្ធទ្រង់រុងរឿងដោយតេជះទាំងថ្ងៃទាំងយប់។ ដោយសច្ចៈវាចានេះសូមសិរីសួស្តីកើតមានដល់ខ្ញុំគ្រប់កាលទាំងពួង។ ពួកសប្បុរសមានសណ្តានចិត្តស្ងប់បរិបូណ៌ដោយហិរិនិងឱត្តប្ប មានស្មារតីតម្កល់មាំក្នុងធម៌ (ស) បណ្ឌិតទាំងឡាយហៅថា ទេវធម៌ក្នុងលោក។

## ធម៌សុខោ (ប្រែ)

**សុខោ ពុទ្ធានមុប្បាទោ** កិរិយាកើតឡើងនៃព្រះពុទ្ធទាំងឡាយជាទីនាំមកនូវសេចក្តីសុខ។ **សុខា សទ្ធម្មទេសនា** កិរិយាសំដែងនូវព្រះសទ្ធម្ម គឺព្រះបរិយត្តិធម៌ និងព្រះនព្វលោកុត្តរធម៌ ជាទីនាំមកនូវសេចក្តីសុខ។ **សុខា សង្ឃស្ស សាមគ្គី** សេចក្តីព្រមព្រៀងគ្នានៃព្រះសង្ឃ ជាទីនាំមកនូវសេចក្តីសុខ **សមគ្គានំ តបោ សុខោ** តបៈគុណនៃព្រះសង្ឃទាំងឡាយ អ្នក

ព្រមព្រៀងគ្នា ជាទីនាំមក នូវសេចក្ដីសុខ។ **ទិវា តបតិ អាទិច្ចោ** ព្រះអាទិត្យរុងរឿងបានតែក្នុងវេលាថ្ងៃ **រត្តិមាភាតិ ចន្ទិមា** ព្រះចន្ទរុងរឿងបានតែក្នុងវេលាយប់ **សន្នទ្ធោ ខត្តិយោ តបតិ** ព្រះមហាក្សត្រលុះទ្រង់គ្រឿងប្រដាប់សម្រាប់រាជ្យ ទើបរុងរឿងបាន។ **ឈាយី តបតិ ព្រាហ្មណោ** ព្រាហ្មណ៍លុះតែចំរើននូវឈានទើបរុងរឿងបាន។ **អថ សព្វមហោរត្តិ ពុទ្ធោ តបតិ តេជសា** ឯព្រះពុទ្ធជាម្ចាស់ ទ្រង់រុងរឿងដោយតេជៈទាំងថ្ងៃទាំងយប់។ **ឯតេន សច្ចវជ្ជេន សុវត្ថិ ហោតុ សព្វទា** សេចក្ដីសុខសួស្ដីសូមកើតមានក្នុងកាលទាំងពួង ដោយកិរិយាពោលនូវ ពាក្យសច្ចៈនេះ។ **ហិរិ ឱត្តប្បសម្បន្នា សុក្កធម្មសមាហិតា សន្តោ សប្បុរិសាលោកេ ទេវ ធម្មាតិ វុច្ចរេ** សប្បុរសទាំងឡាយ មានចិត្តរម្ងាប់ប្រកបព្រមហើយដោយ **ហិរិ និងឱត្តប្បៈ** ថែមទាំងមានចិត្តចុះស៊ប់ ចំពោះធម៌មានពណ៌ស គឺសុចរិតធម៌ អ្នកប្រាជ្ញទាំងឡាយលោកឲ្យនាមថាអ្នកមានទេវធម៌ក្នុងលោក។

# គាថាពោលសរសើរគុណព្រះពុទ្ធអង្គ

(បិដកលេខ៧៤ និង១៩)

**នមោ តេ បុរិសាជញ្ញ នមោ តេ បុរិសុត្តម**

**សព្វញ្ញុសិ មហាវីរ លោកជេដ្ឋ នរាសភ។**

បពិត្រព្រះអង្គ ជាបុរសអាជានេយ្យ ខ្ញុំសូមនមស្ការព្រះអង្គ បពិត្រព្រះអង្គ ជាបុរសឧត្តម ខ្ញុំសូមនមស្ការព្រះអង្គ បពិត្រព្រះអង្គទ្រង់មាន

ព្យាយាមធំជាបុគ្គលខ្ពង់ខ្ពស់ជាងសត្វលោក ប្រសើរជាងនរជន ព្រះអង្គជាព្រះសព្វញ្ញុពុទ្ធ។

**នមោ តេ បុរិសាជញ្ញ នមោ តេ បុរិសុត្តម**

**ពហុជ្ជនំ តារយសិ ទេសេន្តោ អមតំ បទំ។**

បពិត្រព្រះអង្គ ជាបុរសអាជានេយ្យ ខ្ញុំសូមនននមស្ការព្រះអង្គ បពិត្រព្រះអង្គ ជាបុរសឧត្តម ខ្ញុំសូមនមស្ការព្រះអង្គ ព្រះអង្គកាលសម្តែងនូវ អមតបទ គឺ ព្រះនិព្វាន ញ៉ាំងជនដ៏ច្រើនឱ្យឆ្លងវដ្តទុក្ខបាន។

**រូបេ សីលេ សមាធិម្ហិ បញ្ញាយ ច អសាទិសោ**

**វិមុត្តិយា អសមសមោ ធម្មចក្កប្បវត្តនេ ។**

ព្រះអង្គមិនមានបុគ្គលស្មើ ក្នុងព្រះរូបផង សីលផង សមាធិផង បញ្ញាផង ព្រះអង្គស្មើដោយព្រះពុទ្ធទាំងឡាយ ដែលមិនមានបុគ្គលស្មើ ចំពោះវិមុត្តិធម៌ និង ការញ៉ាំងធម្មចក្កឱ្យប្រព្រឹត្តទៅ។

**លាភាលាភេ ន សជ្ជន្តិ សម្មានេ វិមានេ**

**បថវី សទិសា ពុទ្ធា តស្មា តេ ន វិរោធិយា។**

ព្រះពុទ្ធទាំងឡាយ មានចិត្តស្មើដោយផែនដី មិនជាប់ជំពាក់ក្នុងលាភ និង អលាភ ក្នុងការព្យាយាមរាប់អាន ក្នុងការព្យាយាមមើលងាយ ហេតុនោះ បុគ្គលមិនគប្បីឱ្យគ្នាំគ្នងនឹងព្រះពុទ្ធទាំងនោះឡើយ ។

# គាថាពោលសរសើរគុណព្រះពុទ្ធអង្គ

**នមោ តេ បុរិសាជញ្ញ នមោ តេ បុរិសុត្តម**

**តុវំ អគ្គោ សម្មុប្បន្នោ ជេដ្ឋោ សេដ្ឋោ អនុត្តរោ។**

បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ បពិត្រព្រះអង្គជាបុរសដ៏ឧត្តម ខ្ញុំសូមនមស្ការចំពោះព្រះអង្គ ព្រះអង្គទ្រង់កើតឡើងក្នុងលោកហើយជាបុគ្គលដ៏កំពូលបំផុត ជាបុគ្គលដ៏ចម្បងបំផុត ជាបុគ្គលដ៏ប្រសើរបំផុតជាងសត្វលោក មិនមានបុគ្គលណាមួយកំពូលចម្បងប្រសើរជាងព្រះអង្គឡើយ ។

**នមោ តេ វាទិសូទន នមោ តេ ឥសិសត្តម**

**នមោ តេ សព្វលោកគ្គ នមោ តេ អភយន្ទរ។**

បពិត្រព្រះអង្គទ្រង់បង្វែរនូវពាក្យប្រៀនប្រដៅ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ បពិត្រព្រះអង្គទ្រង់ជាឥសីទី ៧ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ បពិត្រព្រះអង្គទ្រង់ប្រសើរជាងសត្វលោកទាំងអស់ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ បពិត្រព្រះអង្គទ្រង់ធ្វើនូវអភ័យខ្ញុំសូមនមស្ការចំពោះព្រះអង្គ ។

**នមោ តេ មារមថន នមោ តេ ទិដ្ឋិសូទន**

**នមោ តេ សន្តិសុខទ នមោ តេ សរណន្ទរ។**

បពិត្រព្រះអង្គទ្រង់ញាំញីនូវមារទាំងប្រាំ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ បពិត្រព្រះអង្គទ្រង់បង្វែរនូវទិដ្ឋិ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ បពិត្រព្រះអង្គទ្រង់ប្រទាននូវសន្តិសុខ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ បពិត្រព្រះអង្គទ្រង់ធ្វើនូវទីពឹង ខ្ញុំសូមនមស្ការចំពោះព្រះអង្គ ។

**នមោ តេ សព្វទស្សាវិ  នមោ តេ ករុណាករ**

**នមោ តេ តិណ្ណសំសារ  នមោ តេ អមតំ ទទ។**

បពិត្រព្រះអង្គទ្រង់ឃើញនូវហេតុផលទាំងពួង ខ្ញុំសូមនមស្ការចំពោះព្រះអង្គ បពិត្រព្រះអង្គទ្រង់ធ្វើនូវករុណា ខ្ញុំសូមនមស្ការចំពោះព្រះអង្គ បពិត្រព្រះអង្គទ្រង់មានសំសារឆ្លងផុតហើយខ្ញុំសូមនមស្ការចំពោះព្រះអង្គ បពិត្រព្រះអង្គទ្រង់ប្រទាននូវអមតៈធម៌ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ ។

**នមោ តេ បុរិសាជញ្ញ  នមោ តេ បុរិសុត្តម**

**សទេវ កស្មិំ លោកស្មិំ  នត្ថិ តេ បដិបុគ្គលោ។**

បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ បពិត្រព្រះអង្គជាបុរសដ៏ឧត្តម ខ្ញុំសូមនមស្ការចំពោះព្រះអង្គ ព្រះអង្គមិនមានបុគ្គលប្រៀបផ្ទឹមក្នុងលោកព្រមទាំងទេវលោក ។

**នមោ តេ បុរិសាជញ្ញ  នមោ តេ បុរិសុត្តម**

**សព្វញ្ញូសិ មហាវីរ  លោកជេដ្ឋ នរាសភ។**

បពិត្រព្រះអង្គ ជាបុរសអាជានេយ្យ ខ្ញុំសូមនមស្ការព្រះអង្គ បពិត្រព្រះអង្គ ជាបុរសឧត្តម ខ្ញុំសូមនមស្ការព្រះអង្គ បពិត្រព្រះអង្គទ្រង់មានព្យាយាមធំជាបុគ្គលខ្ពង់ខ្ពស់ជាងសត្វលោក ប្រសើរជាងនរជន ព្រះអង្គជាព្រះសព្វញ្ញុពុទ្ធ។

**នមោ តេ បុរិសាជញ្ញ  នមោ តេ បុរិសុត្តម**

**ពហុជ្ជនំ តារយសិ  ទេសេន្តោ អមតំ បទំ។**

បពិត្រព្រះអង្គ ជាបុរសអាជានេយ្យ ខ្ញុំសូមនមស្ការព្រះអង្គ បពិត្រព្រះអង្គ ជាបុរសឧត្តម ខ្ញុំសូមនមស្ការព្រះអង្គ ព្រះអង្គកាលសម្តែងនូវ អមតបទ គឺ ព្រះនិព្វាន ញ៉ាំងជនដ៏ច្រើនឱ្យឆ្លងវដ្តទុក្ខបាន។

**រូបេ សីលេ សមាធិម្ហិ បញ្ញាយ ច អសាទិសោ**

**វិមុត្តិយា អសមសមោ ធម្មចក្កប្បវត្តនេ។**

ព្រះអង្គមិនមានបុគ្គលស្មើ ក្នុងព្រះរូបផង សីលផង សមាធិផង បញ្ញាផង ព្រះអង្គស្មើដោយព្រះពុទ្ធទាំងឡាយ ដែលមិនមានបុគ្គលស្មើ ចំពោះវិមុត្តិធម៌ និង ការញ៉ាំងធម្មចក្កឱ្យប្រព្រឹត្តទៅ។

**លាភាលាភេ ន សជ្ជន្តិ សម្មានេ វិមានេ**

**បឋវី សទិសា ពុទ្ធា តស្មា តេ ន វិរោធិយា។**

ព្រះពុទ្ធទាំងឡាយ មានចិត្តស្មើដោយផែនដី មិនជាប់ជំពាក់ក្នុងលាភ និង អលាភ ក្នុងការព្យាយាមរាប់អាន ក្នុងការព្យាយាមមើលងាយ ហេតុនោះ បុគ្គលមិនគប្បីឱ្យគ្តាំគ្គងនឹងព្រះពុទ្ធទាំងនោះឡើយ ។

# មោរបរិត្ត

(សូត្រពេលព្រឹក) **ឧទេតយញ្ចក្ខុមា ឯករាជា ហរិស្សវណ្ណោ បឋវិប្បភាសោ** ព្រះអាទិត្យនេះ ជាដួងភ្នែក (នៃលោក) ជាឯករាជ មានពណ៌ដូចជាពណ៌នៃមាស ញ៉ាំងប្រឹថពីឲ្យភ្លឺស្វាង ហើយរះឡើង។ **តំ តំ នមស្សាមិ ហរិស្សវណ្ណំ បឋវិប្បភាសំ** ព្រោះហេតុនោះខ្ញុំសូមនមស្ការនូវព្រះ

អាទិត្យនោះ ដែលមានពណ៌ ដូចជាពណ៌នៃមាស ញុំាំងប្រឹថពី ឲ្យភ្លឺស្វាង។ **តយជ្ជ គុត្តា  វិហរេមុ ទិវសំ** យើងទាំងឡាយ ដែលលោកគ្រប់គ្រងរក្សា ហើយក្នុងថ្ងៃនេះ គប្បីនៅជាសុខអស់មួយថ្ងៃ។ **យេ ព្រាហ្មណា វេទគុ សព្វធម្មេ** ព្រាហ្មណ៍ទាំងឡាយឯណា ដល់នូវវេទក្នុងធម៌ទាំងពួង។ **តេ មេ នមោ តេ ច មំ បាលយន្តុ** ព្រាហ្មណ៍ទាំងឡាយនោះ (ចូរទទួល) នូវកិរិយានមស្ការរបស់ខ្ញុំ ម្យ៉ាងទៀត ព្រាហ្មណ៍ទាំងឡាយនោះ ចូររក្សានូវខ្ញុំ។ **នមត្ថុ ពុទ្ធានំ មនត្ថុ ពោធិយា** សូមនមស្ការថ្វាយបង្គំចំពោះព្រះពុទ្ធជាម្ចាស់ទាំងឡាយ សូមនមស្ការថ្វាយបង្គំចំពោះពោធិញ្ញាណ (នៃព្រះពុទ្ធទាំងឡាយនោះ)។ **នមោ វិមុត្តានំ នមោ វិមុត្តិយា** សូមនមស្ការថ្វាយបង្គំចំពោះ (ព្រះអរិយបុគ្គល ទាំងឡាយ) ដែលលោកផុតហើយចាករាគាទិក្កិលេសសូមនមស្ការថ្វាយបង្គំចំពោះវិមុត្តិធម៌(នៃព្រះអរិយបុគ្គលទាំងឡាយនោះ)។ **ឥមំ សោ បរិត្តំ កត្វា មោរោ ចរតិ ឯសនា** ក្រោកនោះ លុះតែបានធ្វើនូវព្រះបរិត្តនេះហើយ ទើបចរទៅដើម្បីស្វែងរកអាហារ។

(សូត្រពេលល្ងាច) **អបេតយញ្ចក្ខុមា ឯករាជា ហរិស្សវណ្ណោ បឋវិប្បភាសោ** ព្រះអាទិត្យនេះ ជាដួងភ្នែក (នៃលោក) ជាឯករាជ មានពណ៌ដូចជាពណ៌នៃមាស ញុំាំងប្រឹថពីឲ្យភ្លឺស្វាង ហើយអស្តង្គតទៅ។ **តំ តំ នមស្សាមិ  ហរិស្សវណ្ណំ** បឋវិប្បភាសំ ព្រោះហេតុនោះ ខ្ញុំសូមនមស្ការនូវព្រះអាទិត្យនោះ ដែលមានពណ៌ ដូចជាពណ៌នៃមាស ញុំាំងប្រឹថពីឲ្យភ្លឺស្វាង។ **តយជ្ជ គុត្តា វិហរេមុរត្តឹ** យើងទាំងឡាយ ដែលលោកគ្រប់គ្រងរក្សាហើយក្នុងថ្ងៃនេះ គប្បីនៅជាសុខអស់ ១រាត្រី។ **យេ ព្រាហ្ម**

ណា ទេវតា សព្វធម្មេ ព្រាហ្មណ៍ទាំងឡាយឯណា ដល់នូវវេទក្នុងធម៌ ទាំងពួង។ តេ មេ នមោ តេ ច មំ បាលយន្តុ ព្រាហ្មណ៍ទាំងឡាយនោះ (ចូរទទួល) នូវកិរិយានមស្ការរបស់ខ្ញុំ ម្យ៉ាងទៀតព្រាហ្មណ៍ទាំងឡាយនោះ ចូររក្សានូវខ្ញុំ។ **នមត្ថុ ពុទ្ធានំ នមត្ថុ ពោធិយា** សូមនមស្ការថ្វាយបង្គំចំពោះព្រះពុទ្ធជាម្ចាស់ទាំងឡាយ សូមនមស្ការថ្វាយបង្គំចំពោះពោធិញ្ញាណ (នៃព្រះពុទ្ធទាំងឡាយនោះ)។ **នមោ វិមុត្តានំ នមោ វិមុត្តិយា** សូមនមស្ការថ្វាយបង្គំចំពោះ (ព្រះអរិយបុគ្គល ទាំងឡាយ) ដែលលោកផុតហើយចាករាគាទិក្កិលេស សូមនមស្ការថ្វាយបង្គំ ចំពោះវិមុត្តិធម៌ (នៃព្រះអរិយបុគ្គល ទាំងឡាយនោះ)។ **ឥមំ សោ បរិត្តំ កត្វា មោរោ វាសមកប្បយីតិ** ក្រោកនោះ លុះតែបានធ្វើនូវព្រះបរិត្តនេះហើយ ទើបបានសម្រេចនូវកិរិយានៅ។

# ផ្សាយមេត្តាចំពោះទិសទាំង១០

សព្វេ បុរត្ថិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ បុរត្ថិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ ទក្ខិណាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ ទក្ខិណាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ បច្ឆិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ បច្ឆិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ ឧត្តរាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

**សព្វេ ឧត្តរាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ**

**សព្វេ ហេដ្ឋិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ**

**សព្វេ ឧបរិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ**

**សព្វេ សត្តា អវេរា ហោន្តុ សុខិតា ហោន្តុនិទ្ទុក្ខា ហោន្តុ អព្យា បជ្ឈា ហោន្តុ អនីឃា ហោន្តុ ទីឃាយុកា ហោន្តុ អរោគា ហោន្តុ សម្បត្តីហិ សមិជ្ឈន្តុ សុខី អត្តានំ បរិហរន្តុ ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ ចាណិនោ។**

*សេចក្តីប្រែ៖* សព្វេ បុរត្ថិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ *សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសបូព៌ សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ។*

សព្វេ បុរត្ថិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ *សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសអាគ្នេយ៍ សូមកុំឱ្យមានពៀរនឹង គ្នា មានតែសេចក្តីសុខ។*

សព្វេ ទក្ខិណាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ *សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសទក្សិណ សូមកុំឱ្យមានពៀរនឹង គ្នា មានតែសេចក្តីសុខ។*

សព្វេ ទក្ខិណាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ *សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសនិរតី សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ។*

**សព្វេ បច្ឆិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសបស្ចិម សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ។

**សព្វេ បច្ឆិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសពាយ័ព្យ សូមកុំឱ្យមានពៀរនឹង គ្នា មានតែសេចក្តីសុខ។

**សព្វេ ឧត្តរាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសឧត្តរ សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។

**សព្វេ ឧត្តរាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសឦសាន សូមកុំឱ្យមានពៀរនឹង គ្នា មានតែសេចក្តីសុខ។

**សព្វេ ហេដ្ឋិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសខាងក្រោម សូមកុំឱ្យមានពៀរ នឹងគ្នា មានតែសេចក្តីសុខ។

**សព្វេ ឧបរិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសខាងលើ សូមកុំឱ្យមានពៀរ នឹងគ្នា មានតែសេចក្តីសុខ។

**សព្វេ សត្តា អវេរា ហោន្តុ** សូមឱ្យសត្វទាំងឡាយ ទាំងពួងកុំមានពៀរនឹងគ្នា។ **សុខិតា ហោន្តុ** សូមឱ្យបាននូវសេចក្តីសុខ **និទ្ទុក្ខា ហោន្តុ** សូមកុំឱ្យមានទុក្ខ **អព្យាបជ្ឈា ហោន្តុ** សូមកុំឱ្យបៀតបៀន ដល់គ្នានឹង

ជ្ឈា អនីឃា ហោន្តុ សូមកុំឱ្យមានសេចក្តីព្រួយលំបាក ទីឃាយុកា ហោន្តុ សូមឱ្យមានអាយុវែង។ អរោគា ហោន្តុ សូមកុំឱ្យមានរោគ។ សម្បត្តីហិ សមិជ្ឈន្តុ សូមឱ្យសម្រេចដោយសម្បត្តិ គ្រប់យ៉ាង។ សុខី អត្តានំ បរិហរន្តុ សូមឱ្យរក្សានូវខ្លួនជាសុខស្រួលចុះ។ ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ បាណិនោ សត្វទាំងឡាយទាំងពួង ដែលដល់ហើយនូវសេចក្តីទុក្ខ សូមឱ្យជាសត្វបាត់សេចក្តីទុក្ខទៅដែលដល់ហើយនូវភ័យ សូមឱ្យជាសត្វបាត់ភ័យទៅដែលដល់ហើយនូវសេចក្តីសោក សូមឱ្យជាសត្វបាត់សេចក្តីសោកទៅហោង។

# បត្តិទានគាថា

ឥមិនា បុញ្ញកម្មេន ឧបជ្ឈាយា គុណុត្តរា
អាចរិយូបការា ច មាតាបិតា បិយា មមំ
សុរិយោ ចន្ទិមា រាជា គុណវន្តា នរាបិ ច
ព្រហ្មា មារា ច ឥន្ទា ច លោកបាលា ច ទេវតា
យមោ មិត្តា មនុស្សា ច មជ្ឈត្តា វេរិកាបិ ច
សព្វេ សត្តា សុខី ហោន្តុ បុញ្ញានិ បកតានិ មេ
សុខញ្ច តិវិធំ ទេន្តុ ខិប្បំ បាបេថ វោមតំ។

សេចក្តីប្រែ៖ ឥមិនា បុញ្ញកម្មេន ដោយបុញ្ញកម្មនេះ ឧបជ្ឈាយ គុណុត្តរា ឧបជ្ឈាយ៍ទាំងឡាយ មានគុណដ៏ខ្ពង់ខ្ពស់ក្តី អាចរិយូបការា ច អាចារ្យទាំងឡាយមានឧបការៈក្តី មាតាបិតា បិយា មមំ មាតានិងបិតា ជាទីស្រឡាញ់

នៃខ្ញុំក្តី សុរិយោ ចន្ទិមា រាជា ព្រះអាទិត្យ ព្រះច័ន្ទ និង ព្រះរាជាក្តី គុណវន្តា នរាបិ ច មួយវិញទៀត ជនទាំងឡាយដែលជាអ្នក មានគុណក្តី ព្រហ្មមារា ច ឥន្ទ្រា ច ពួកព្រហ្មក្តី មារក្តី ព្រះឥន្ទទាំងឡាយក្តី លោកបាលា ច ទេវតា ទេវតាទាំងឡាយ ជាអ្នករក្សានូវលោកក្តី យមោ មិត្តា មនុស្សា ច យមរាជក្តី ពួកមនុស្សជាទីរាប់អានគ្នាក្តី មជ្ឈត្តា វេរិកាបិ ច មួយវិញទៀត សត្វទាំងឡាយ ដែលមានចិត្តជា ឧបេក្ខាក្តី មានពៀរនឹងគ្នាក្តី សព្វេ សត្តា សុខី ហោន្តុ សព្វសត្វទាំងឡាយ ចូរឱ្យបាននូវសេចក្តីសុខ បុញ្ញានិ បកតានិ មេ បុណ្យទាំងឡាយ ដែលខ្ញុំ បានធ្វើហើយ សុខញ្ច តិវិធំ ទេន្តុ សូមឱ្យបាន នូវសេចក្តីសុខទាំង ៣ ប្រការ (គឺសុខក្នុងមនុស្ស ទេវតា និង ព្រះនិព្វាន) ខិប្បំ បាបេថ វោមតំ អ្នក ទាំងឡាយ ចូរដល់នូវព្រះនិព្វាន ឈ្មោះអមតៈ ដោយឆាប់រួសរាន់ទាន់ចិត្ត។

ឥមិនា បុញ្ញកម្មេន ឥមិនា ឧទ្ទិសេន ច
ខិប្បាហំ សុលភេ ចេវ តណ្ហុប្បាទានឆេទនំ
យេ សន្តានេ ហិនា ធម្មា យាវ និព្វានតោ មមំ
នស្សន្តុ សព្វទា យេវ យត្ថ ជាតោ ភវាភវេ
ឧជុចិត្តំ សតិប្បញ្ញា សល្លេខោ វីរិយម្ហិនា
មារា លភន្តុ នោកាសំ កាតុញ្ច វីរិយេសុ មេ
ពុទ្ធោ ទីបវរោ នាថោ ធម្មោ នាថោ វរុត្តមោ។
នាថោ បច្ចេកពុទ្ធោ ច សង្ឃោ នាថោត្តរោ មមំ
តេសោត្តមានុភាវេន មារោកាសំ លភន្តុ មា ។

សេចក្តីប្រែ៖ ឥមិនា បុញ្ញកម្មេន ដោយបុញ្ញកម្មនេះផង **ឥមិនា ឧទ្ទិសេន ច** ដោយពាក្យឧទ្ទិសនេះផង **ខិប្បាហំ សុលភេ ចេវ តណ្ហុប្បាទានឆេទនំ** ខ្ញុំគប្បីបានដោយងាយនូវការកាត់ផ្តាច់តណ្ហា និងឧបាទាន ដោយឆាប់រួសរាន់ **យេ សន្តានេ ហិនា ធម្មា** ធម៌ទាំងឡាយណាដែល ថោកទាបមានក្នុងសន្តាន(នៃខ្ញុំ) **យាវ និព្វានតោ មមំ នស្សន្តុ សព្វទាយេវ** ធម៌ថោកទាបទាំងនោះចូរវិនាសទៅ (ចាកសន្តាន) នៃខ្ញុំសព្វៗកាល ដរាបដល់ព្រះនិព្វាន **យត្ថ ជាតោ ភវេ ភវេ** ខ្ញុំកើតហើយក្នុងភពតូច និងភពធំណាៗ **ឧជុចិត្តោ សតិប្បញ្ញា សល្លេខោ វិរិយោម្ហិនា** សូមឱ្យជាអ្នកមានចិត្តត្រង់ មានស្មារតីនិងប្រាជ្ញា ទាំងសូមឱ្យមានចិត្តជួរជង់ និងសេចក្តីព្យាយាមផង (ក្នុងភពនោះៗ) **មារា លភន្តុ នោកាសំ កាតុញ្ច វិរិយេសុ មេ** មារទាំងឡាយ ចូរកុំបាននូវឱកាសដើម្បីធ្វើ (នូវសេចក្តីអន្តរាយ) ក្នុងព្យាយាមទាំងឡាយនៃខ្ញុំ **ពុទ្ធោ ទីបវរោ នាថោ** ព្រះពុទ្ធដូចជាប្រទីបដ៏ប្រសើរ ព្រះអង្គជាទីពឹង (របស់ខ្ញុំ) **ធម្មោ នាថោ** វរុត្តមោ ព្រះធម៌ដ៏ឧត្តមបវរជាទីពឹង (របស់ខ្ញុំ) **នាថោ បច្ចេកពុទ្ធោ ច** ព្រះបច្ចេកពុទ្ធក៏ជាទីពឹង (របស់ខ្ញុំ) **សង្ឃោ នាថោត្តរោ មមំ** ព្រះសង្ឃ ជាទីពឹងដ៏ប្រសើររបស់ខ្ញុំ **តេសោតមានុភាវេន** ដោយឧត្តមានុភាពនៃ ព្រះពុទ្ធ ព្រះធម៌ ព្រះបច្ចេកពុទ្ធ និងព្រះសង្ឃទាំងឡាយនោះ **មារោកាសំ លភន្តុ មា** មារចូរកុំបានឱកាសឡើយ៕

## អនុមោទនារក្ខាយាចនគាថា

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ សាសនំ។**

សេចក្តីប្រែ៖ ទេវតាទាំងឡាយ ដែលស្ថិតឰដ៏អាកាសក្តី ដែលស្ថិតនៅលើផែនដីក្តី នាគទាំងឡាយដែលមានឥទ្ធានុភាពច្រើនក្តី សូមអនុមោទនានូវបុណ្យរបស់យើងទាំងឡាយ សូមរក្សានូវព្រះពុទ្ធសាសនា (ឱ្យស្ថិតស្ថេរ និងឱ្យរុងរឿង) អស់កាលជាយូរអង្វែងទៅ។

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា បុញ្ញំ តោ អនុមោទន្តុ រក្ខន្តុ រាជានោ។**

សេចក្តីប្រែ៖ ទេវតាទាំងឡាយ ដែលស្ថិតឰដ៏អាកាសក្តី ដែលស្ថិតនៅលើផែនដីក្តី នាគទាំងឡាយ ដែលមានឥទ្ធានុភាពច្រើនក្តី សូមអនុមោទនានូវបុណ្យរបស់យើងទាំងឡាយ សូមរក្សានូវព្រះរាជាឱ្យបានសុខចម្រើន អស់កាលជាយូរអង្វែងទៅ ។

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា បុញ្ញំ តោ អនុមោទន្តុ ចិរំ រក្ខន្តុ ញាតយោ។**

សេចក្តីប្រែ៖ ទេវតាទាំងឡាយ ដែលស្ថិតឰដ៏អាកាសក្តី ដែលស្ថិតនៅលើផែនដីក្តី នាគទាំងឡាយ ដែលមានឥទ្ធានុភាពច្រើនក្តី សូមអនុមោទនានូវបុណ្យរបស់យើងទាំងឡាយ សូមរក្សានូវញាតិទាំងឡាយ (ឱ្យចំរុងចំរើន និងសុខសាន្ត) អស់កាលជាយូរអង្វែងទៅ ។

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា បុញ្ញំ តោ អនុមោទន្តុ ចិរំ រក្ខន្តុ បាណិនោ។**

សេចក្តីប្រែ៖ ទេវតាទាំងឡាយ ដែលស្ថិតឰដ៏អាកាសក្តី ដែលស្ថិតនៅលើផែនដីក្តី នាគទាំងឡាយ ដែលមានឥទ្ធានុភាពច្រើនក្តី សូម

អនុមោទនានូវបុណ្យរបស់យើងទាំងឡាយ សូមរក្សានូវសត្វទាំងឡាយ (ឱ្យបានចំរុងចំរើន និងសុខសាន្ត) អស់កាលជាយូរអង្វែងទៅ ។

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា បុញ្ញំ តោ អនុមោទន្តុ ចិរំ រក្ខន្តុ នោ សទា។**

សេចក្តីប្រែ៖ ទេវតាទាំងឡាយ ដែលស្ថិតឮដ៏អាកាសក្តី ដែលស្ថិតនៅលើផែនដីក្តី នាគទាំងឡាយ ដែលមានឥទ្ធានុភាពច្រើនក្តី សូមអនុមោទនានូវបុណ្យរបស់យើងទាំងឡាយ សូមរក្សាយើងទាំងឡាយ (ឱ្យស្ថិតស្ថេរនិងរុងរឿង) អស់កាលជាយូរអង្វែងទៅ៕

# សុមង្គលគាថា

**ហោតុ សព្វំ សុមង្គលំ** សុមង្គលគឺសេចក្តីចម្រើនដ៏ល្អ គ្រប់យ៉ាងចូរមានដល់ខ្ញុំ **រក្ខន្តុ សព្វទេវតា** ទេវតាទាំងពួងទាំងឡាយ ចូររក្សានូវខ្ញុំ **សព្វពុទ្ធានុភាវេន** ដោយអានុភាពនៃព្រះពុទ្ធគ្រប់ព្រះអង្គ **សោត្ថិ ហោតុ និរន្តរំ** សូមសិរីសួស្តីចូរមានដល់ខ្ញុំ ឱ្យបានគ្រប់ពេលកុំបីមានចន្លោះឡើយ។

**ហោតុ សព្វំ សុមង្គលំ** សុមង្គលគឺសេចក្តីចម្រើន ដ៏ល្អ គ្រប់យ៉ាងចូរមានដល់ខ្ញុំ **រក្ខន្តុ សព្វទេវតា** ទេវតាទាំងពួងទាំងឡាយ ចូររក្សានូវខ្ញុំ **សព្វធម្មានុភាវេន** ដោយអានុភាពនៃព្រះធម៌ទាំងពួង **សោត្ថិ ហោតុ និរន្តរំ** សូមសិរីសួស្តី ចូរមានដល់ខ្ញុំ ឱ្យបានគ្រប់ពេលកុំបីមានចន្លោះ ឡើយ។

**ហោតុ សព្វំ សុមង្គលំ** សុមង្គលគឺសេចក្តីចម្រើន ដ៏ល្អ គ្រប់យ៉ាងចូរមានដល់ខ្ញុំ **រក្ខន្តុ សព្វទេវតា** ទេវតាទាំងពួងទាំងឡាយ ចូររក្សានូវខ្ញុំ **សព្វ**

សង្ឃានុភាវេន ដោយអានុភាពនៃព្រះសង្ឃទាំងពួង សោត្ថិ ហោតុ និរន្តរំ សូមសិរីសួស្តីចូរមានដល់ខ្ញុំ ឱ្យបានគ្រប់ពេលកុំបីមានចន្លោះឡើយ។

# បត្តិទានគាថា

យំ កិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម
កាយេន វាចាមនសា តិទសេ សុគតំ កតំ
យេ សត្តា សញ្ញិនោ អត្ថិ យេ ច សត្តា អសញ្ញិនោ
កតំ បុញ្ញផលំ មយ្ហំ សព្វេ ភាគី ភវន្តុ តេ
យេ តំ កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ មយា
យេ ច តត្ថ ន ជានន្តិ ទេវា គន្ត្វា និវេទយុំ
សព្វេ លោកម្ហិ យេ សត្តា ជីវន្តាហារហេតុកា
មនុញ្ញំ ភោជនំ សព្វេ លភន្តុ មម ចេតសា ។

សេចក្តីប្រែ៖ យំ កិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម អំពើជាកុសលឯណាមួយ ដែលខ្ញុំគប្បីធ្វើ កាយេន វាចាមនសា ដោយទ្វារទាំងបីគឺ កាយ វាចា ចិត្ត តិទសេ សុគតំ កតំ អំពើជាកុសលទាំងអស់នោះ ដែលខ្ញុំបានធ្វើហើយ ជាកុសលអាចនឹងនាំឱ្យ ទៅកើត ក្នុងឋានត្រៃត្រិង្សសួគ៌បាន យេ សត្តា សញ្ញិនោ អត្ថិ សត្វទាំងឡាយឯណា គឺមនុស្ស ឬទេវតា ឬព្រហ្ម ដែលជាសត្វមានសញ្ញាក្តី យេ ច សត្តា អសញ្ញិនោ សត្វទាំងឡាយឯណា ជាអសញ្ញីសត្វ គឺសត្វ ដែលឥតសញ្ញាក្តី កតំ បុញ្ញផលំ មយ្ហំ សព្វេ ភាគី ភវន្តុ តេ សត្វទាំងឡាយទាំងអស់នោះ ចូរឱ្យបាននូវចំណែកផលនៃបុណ្យហើយ ចូរសោយផលនៃបុណ្យ ដែលខ្ញុំបានធ្វើ

ហើយ បានឧទ្ទិសផ្សាយឱ្យទៅនេះចុះ **យេ តំ កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ មយា** បុណ្យដែលខ្ញុំ បានធ្វើហើយនោះ បើសត្វទាំងឡាយឯណា បាន ដឹងច្បាស់ហើយ សត្វទាំងឡាយ នោះ ចូរសោយនូវផលនៃបុណ្យ ដែល ខ្ញុំបានឧទ្ទិសឱ្យទៅនេះចុះ **យេ ច តត្ថ ន ជានន្តិ** ម្យ៉ាងទៀត បណ្តាអស់ សត្វទាំងនោះ បើសត្វទាំងឡាយឯណា មិនបានដឹងនូវបុណ្យ ដែលខ្ញុំបាន ធ្វើហើយនោះ **ទេវា គន្ត្វា និវេទយុំ** សូមទេវតាទាំងឡាយ អញ្ជើញទៅ ឱ្យដំណឹងដល់សត្វទាំងឡាយនោះ ឱ្យបាន ដឹងផង ថាជនឯនុ៎ះគេបានធ្វើ បុណ្យហើយ គេបានឧទ្ទិសផ្សាយផលបុណ្យនោះ មកដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរអនុមោទនាត្រេកអរនឹងបុណ្យគេនោះចុះ **សព្វេ លោកម្ហិ យេ សត្តា ជីវន្តាហារហេតុកា** សត្វទាំងឡាយ ឯណា ក្នុងលោកទាំងអស់ ដែលអាស្រ័យនូវអាហារហើយរស់នៅ **មនុញ្ញំ ភោជនំ សព្វេ លភន្តុ មម ចេតសាតិ** សត្វទាំងឡាយ ទាំងអស់នោះ ចូរឱ្យបាននូវភោជនជាទីគាប់ចិត្ត ដែលសម្រេចដោយបុញ្ញឫទ្ធិតាមចិត្តដែលខ្ញុំ ឧទ្ទិសផ្សាយទៅឱ្យនេះចុះ។

# បត្តិទានគាថា

(ប្រែជាពាក្យកាព្យ)

កម្មកុសលឯណា ដែលជាការឥតសៅហ្មង
យើងខ្ញុំបានកសាង ដោយទ្វារកាយវាចាចិត្ត។
កុសលទាំងអស់នោះ ឱ្យជួយដោះជួយបង្ខិត
នាំសត្វឱ្យជាប់ចិត្ត បិតនៅនាឋានឧត្តម។
សត្វណាមានសញ្ញា គឺទេវតាមនុស្សឬឥន្ទព្រហ្ម
ដែលមានស័ក្តិតូចធំ ព្រមទាំងសត្វឥតសញ្ញា។

ឱ្យបានចំណែកបុណ្យ ដែលជាគុណល្អថ្លៃថ្លា
យើងខ្ញុំបានរចនា ចាត់ចែងការកុសលហ្នឹង។
ម្យ៉ាងទៀតសត្វឯណា ឆ្ងាយណាស់ណាពុំបានដឹង
សូមទេវតាទៅប្តឹង ជាដំណឹងយ៉ាងនេះថា។
នរជនឈ្មោះឯណោះ ស្រីឬប្រុសបានជ្រះថ្លា
កសាងបុញ្ញកិរិយា វត្តជាផ្លូវធើតធាយ។
ហើយគេឧទ្ទិសផល ឱ្យបានដល់អ្នកទាំងឡាយ
ចូរមានចិត្តរីករាយ បន្ទន់កាយទទួលយក។
សត្វលោកទាំងអស់នោះ ដែលបានរស់តរៀងមក
លុះតែបានបរិភោគ នូវអាហារទើបរស់បាន។
សត្វទាំងអស់នោះណា បានសុខាសព្វគ្រប់ប្រាណ
អាហារយ៉ាងចំណាន សូមឱ្យបានកុំខានឡើយ។
ឥរិយាទាំងសព្វសត្វ ដែលវិបត្តិទ៍លទុក្ខា
ទ៍លភ័យទ៍លសោកា សោយផលកម្មជាប់សន្តាន។
សូមឱ្យសត្វទាំងនោះ រួចរំដោះរាល់រូបប្រាណ
ចាកទុក្ខភ័យសោកសាន្ត ឆ្លងដល់ត្រើយនិព្វាននាយ។

# តេជៈខ្ញុំសាង

តេជៈខ្ញុំសាង សំអិតសំអាង ឱនកាយវាចា
សូមសុខសុភាព រួចពីទុក្ខា ឆ្លងដល់ត្រើយមហា
ពោលគឺនិព្វាន។

គ្រប់ជាន់គ្រប់ជាតិ កុំឱ្យខ្ញុំឃ្លាត ពីសីល និងទាន
គំនិតខ្ញុំកើត កំណើតខ្ញុំមាន មគ្គផលជាស្ពាន
ដល់ស្ថានថ្លៃថ្លា។

សូមជូនកុសល ចំពោះទៅដល់ មាតាបិតា
គុណគ្រូឧប- ជ្ឈាយាចារ្យ គុណញាតកា
សព្វៗសន្តាន។

ជីដូនជីតា រស់នៅក្តីណា លោកម្ចាស់ចែកស្ថាន
សូមជូនកុសល ផលបុណ្យថ្កើងថ្កា សូមសុខក្សេមក្សាន្ត
ដល់ស្ថានផុតទុក្ខ។

ខ្ញុំសូមប្រាថ្នា សច្ចៈវាចា តទៅខាងមុខ
សូមមានបញ្ញា ភ្លឺថ្លាមោះមុត កន្លងផុតទុក្ខ
ដល់និព្វានហោង។

# ឧទ្ទិសកុសល

ទានដែលខ្ញុំធ្វើហើយ ព្រះគុណណើយសូមសច្ចា
ឧទ្ទិសផលនេះណា ជូនមាតាបិតាខ្ញុំ។
ជីដូននិងជីតា គ្រូអាចារ្យទាំងតូចធំ
ញាតិមិត្រគ្រប់និគម មកជួបជុំទទួលផល។
ដែលកូនចៅបានធ្វើ នូវអំពើជាកុសល
សូមទានឱ្យបានដល់ ទោះមណ្ឌលឆ្ងាយយ៉ាងណា។
កុសលទាំងអស់ហ្នឹង សូមទីពឹងលើទេវតា

សូមមានចិត្តមេត្តា នាំផលាទាំងអស់នេះ។
ទៅជូនឱ្យខ្ញុំផង ដូចបំណងកុំបីធ្វេស
កូនចៅនៅឯណោះ មិនប្រហែសបញ្ជូនមក។
សូមមានចិត្តរីករាយ បន្ទន់កាយទទួលយក
កូនចៅបានលៃលក បញ្ជូនមកលោកគ្រប់គ្នា។
ដើម្បីសោយកម្សាន្ត សូមឱ្យបាននូវសុខជា
កូនចៅទាំងអស់គ្នា សូមបូជាជូនទៅហោង។

# អាដានាដិយបរិត្ត

នមោ មេ សព្វពុទ្ធានំ ឧប្បន្នានំ មហេសិនំ
តណ្ហង្ករោ មហាវីរោ មេធង្ករោ មហាយសោ
សរណង្ករោ លោកហិតោ ទីបង្ករោ ជុតិន្ធរោ
កោណ្ឌញ្ញោ ជនបាមោក្ខោ មង្គលោ បុរិសាសភោ
សុមនោ សុមនោ ធីរោ រេវតោ រតិវឌ្ឍនោ
សោភិតោ គុណសម្បន្នោ អនោមទស្សី ជនុត្តមោ
បទុមោ លោកបជ្ជោតោ នារទោ វរសារថី
បទុមុត្តរោ សត្តសារោ សុមេធោ អប្បដិបុគ្គលោ
សុជាតោ សព្វលោកគ្គោ បិយទស្សី នរាសភោ
អត្ថទស្សី ការុណិកោ ធម្មទស្សី តមោនុទោ
សិទ្ធត្ថោ អសមោ លោកេ តិស្សោ ច វទតំ វរោ

ផុស្សោ ច វរទោ ពុទ្ធោ វិបស្សី ច អនូបមោ
សិខី សព្វហិតោ សត្ថា វេស្សភូ សុខទាយកោ
កកុសន្ធោ សត្ថវាហោ កោនាគមនោ រណញ្ជហោ
កស្សបោ សិរិសម្បន្នោ គោតមោ សក្យបុង្គវោ ។
ឯតេ ចញ្ញេ ច សម្ពុទ្ធា អនេកសតកោដិយោ
សព្វេ ពុទ្ធា អសមសមា សព្វេ ពុទ្ធា មហិទ្ធិកា
សព្វេ ទសពលូបេតា វេសារជ្ជេហុបាគតា
សព្វេ តេ បដិជានន្តិ អាសភណ្ឋានមុត្តមំ
សីហនាទំ នទន្តេ តេ បរិសាសុ វិសារទា
ព្រហ្មចក្កំ បវត្តេន្តិ លោកេ អប្បដិវត្តិយំ
ឧបេតា ពុទ្ធធម្មេហិ អដ្ឋារសហិ នាយកា
ទ្វត្តឹសលក្ខណូបេតា សីតានុព្យញ្ជនាធរា
ព្យាមប្បភាយ សុប្បភា សព្វេ តេ មុនិកុញ្ជរា
ពុទ្ធា សព្វញ្ញុនោ ឯតេ សព្វេ ខីណាសវា ជិនា
មហប្បភា មហាតេជា មហាបញ្ញា មហព្វលា
មហាការុណិកា ធីរា សព្វេសានំ សុខាវហា
ទីបា នាថា បតិដ្ឋា ច តាណា លេណា ច បាណិនំ
គតី ពន្ធូ មហស្សាសា សរណា ច ហិតេសិនោ
សទេវកស្ស លោកស្ស សព្វេ ឯតេ បរាយនា

តេសាហំ សិរសា បាទេ វន្ទាមិ បុរិសុត្តមេ
វចសា មនសា ចេវ វន្ទាមេតេ តថាគតេ
សយនេ អាសនេ ឋានេ គមនេ ចាបិ សព្វទា
សទា សុខេន រក្ខន្តុ ពុទ្ធា សន្តិករា តុវំ
តេហិ ត្វំ រក្ខិតោ សន្តោ មុត្តោ សព្វភយេន ច
សព្វរោគវិនិមុត្តោ សព្វសន្តាបវជ្ជិតោ
សព្វវេរមតិក្កន្តោ និព្វុតោ ច តុវំ ភវ ។
តេសំ សច្ចេន សីលេន ខន្តិមេត្តាពលេន ច
តេបិ តុម្ហេ អនុរក្ខន្តុ អារោគ្យេន សុខេន ច
បុរត្ថិមស្មឹ ទិសាភាគេ សន្តិ ភូតា មហិទ្ធិកា
តេបិ តុម្ហេ អនុរក្ខន្តុ អារោគ្យេន សុខេន ច
ទក្ខិណស្មឹ ទិសាភាគេ សន្តិ ទេវា មហិទ្ធិកា
តេបិ តុម្ហេ អនុរក្ខន្តុ អារោគ្យេន សុខេន ច
បច្ឆិមស្មឹ ទិសាភាគេ សន្តិ នាគា មហិទ្ធិកា
តេបិ តុម្ហេ អនុរក្ខន្តុ អារោគ្យេន សុខេន ច
ឧត្តរស្មឹ ទិសាភាគេ សន្តិ យក្ខា មហិទ្ធិកា
តេបិ តុម្ហេ អនុរក្ខន្តុ អារោគ្យេន សុខេន ច
បុរិមទិសំ ធតរដ្ឋោ ទក្ខិណេន វិរុឡ្ហកោ
បច្ឆិមេន វិរូបក្ខោ កុវេរោ ឧត្តរំ ទិសំ

ចត្តារោ តេ មហារាជា　　លោកបាលា យសស្សិនោ
តេបិ តុម្ហេ អនុរក្ខន្តុ　　អារោគ្យេន សុខេន ច
អាកាសដ្ឋា ច ភុម្មដ្ឋា　　ទេវា នាគា មហិទ្ធិកា
តេបិ តុម្ហេ អនុរក្ខន្តុ　　អារោគ្យេន សុខេន ច។

សេចក្តីប្រែ៖ នមោ មេ សព្វពុទ្ធានំ ឧប្បន្នានំ មហេសិនំ ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ ចំពោះព្រះពុទ្ធជាម្ចាស់គ្រប់ព្រះអង្គ ដែលបាន ត្រាស់រួចមកហើយ ព្រះអង្គស្វែងរកនូវគុណដ៏ធំ (ព្រះសម្ពុទ្ធទាំងនោះគឺ) តណ្ហង្ករោ មហាវីរោ ព្រះតណ្ហង្ករ ព្រះអង្គមានព្យាយាមធំ។ មេធង្ករោ មហាយសោ ព្រះមេធង្ករ ព្រះអង្គមានយសធំ។ សរណង្ករោ លោកហិតោ ព្រះសរណង្ករ ព្រះអង្គធ្វើឱ្យជា ប្រយោជន៍ដល់សត្វលោក។ ទីបង្ករោ ជុតិន្ធរោ ព្រះទីបង្ករ ព្រះអង្គទ្រទ្រង់នូវបញ្ញាដ៏រុងរឿង។ កោណ្ឌញ្ញោ ជនបាមោក្ខោ ព្រះកោណ្ឌញ្ញៈ ព្រះអង្គជាប្រធាន នៃពពួកជន។ មង្គលោ បុរិសាសភោ ព្រះមង្គល ព្រះអង្គជាបុរសដ៏ប្រសើរ។ សុមនោ សុមនោ ធីរោ ព្រះសុមនៈ ព្រះអង្គជាអ្នកប្រាជ្ញ មានព្រះហឫទ័យដ៏ល្អ។ រេវតោ រតិវឌ្ឍនោ ព្រះរេវតៈ ព្រះអង្គញុំាងសេចក្តីត្រេកអរឱ្យចំរើន។ សោភិតោ គុណសម្បន្នោ ព្រះសោភិតៈ ព្រះអង្គបរិបូណ៌ដោយ ព្រះគុណ។អនោមទស្សី ជនុត្តមោ ព្រះអនោមទស្សី ព្រះអង្គឧត្តមជាងពពួកជន។បទុមោ លោកបជ្ជោតោ ព្រះបទុមៈ ព្រះអង្គញុំាងលោកឱ្យភ្លឺស្វាង។ នារទោ វរសារថី ព្រះនារទៈ ព្រះអង្គដូចជាសារថីដ៏ប្រសើរ។ បទុមុត្តរោ សត្តសារោ ព្រះបទុមុត្តរៈ ព្រះអង្គជាខ្លឹមសារនៃពួកសត្វ ។ សុមេធោ

**អប្បដិបុគ្គលោ** ព្រះសុមេធៈ ព្រះអង្គរកបុគ្គលប្រៀប ដូចគ្មាន។ **សុជាតោ សព្វលោកគ្គោ** ព្រះសុជាត ព្រះអង្គប្រសើរលើសជាង សត្វលោកទាំងពួង។ **បិយទស្សី នរាសភោ** ព្រះបិយទស្សី ព្រះអង្គប្រសើរជាងនរជន។ **អត្ថទស្សី ការុណិកោ** ព្រះអត្ថទស្សី ព្រះអង្គប្រកបដោយករុណា។ ធម្មទស្សី តមោនុទោ ព្រះធម្មទស្សី ព្រះអង្គបន្ទោបង់នូវងងឹត។ **សិទ្ធត្ថោ អសមោ លោកេ** ព្រះសិទ្ធត្ថៈ ព្រះអង្គឥតមានអ្នកណា ស្មើក្នុងលោក។ **តិស្សោ ច វទតំ វរោ** ព្រះតិស្សៈ ព្រះអង្គប្រសើរជាងអ្នកប្រាជ្ញ ខាងសំដីទាំងឡាយ។**ផុស្សោ ច វរទោ ពុទ្ធោ** ព្រះពុទ្ធទ្រង់ព្រះនាមផុស្ស ព្រះអង្គប្រទាននូវធមិដ៏ប្រសើរ។ **វិបស្សី ច អនូបមោ** ព្រះវិបស្សី ព្រះអង្គឥតមានអ្នកណាប្រៀបផ្ទឹម បានឡើយ។ **សិខី សព្វហិតោ សត្ថា** ព្រះសិខី ព្រះអង្គជាគ្រូប្រៀនប្រដៅ ធ្វើឱ្យ ជាប្រយោជន៍ ដល់សត្វទាំងពួង។ **វេស្សភូ សុខទាយកោ** ព្រះវេស្សភូ ព្រះអង្គប្រទាននូវសេចក្តីសុខ។ **កកុសន្ធោ សត្ថវាហោ** ព្រះកកុសន្ធៈ ព្រះអង្គនាំសត្វចេញចាកផ្លូវ ឆ្ងាយដាច់ស្រយាល គឺកិលេស។ **កោនាគមនោ រណញ្ជហោ** ព្រះកោនាគមនៈ ព្រះអង្គបំបាក់នូវ សត្រូវគឺកិលេស។ **កស្សបោ សិរិសម្បន្នោ** ព្រះកស្សបៈ ព្រះអង្គបរិបូណ៌ដោយសិរី។ **គោតមោ សក្យបុង្គវោ** ព្រះគោតម ព្រះអង្គប្រសើរចម្បងជាងពួក សក្យរាជ។

**“ធម៌រមែងរក្សាបុគ្គលអ្នកប្រព្រឹត្តធម៌ដោយពិត”**

(បិដកលេខ៥៦ ទំព័រ២១០)

# “ធម្មនិយាម៣០
# របស់ព្រះពុទ្ធគ្រប់ព្រះអង្គ”

សូមក្រាបបង្គំប្រណម្យវន្ទា
ព្រោះព្រះភគវាពុទ្ធាបានត្រាស់
ធម្មនិយាមទំនៀមល្អល្អះ
សាមសិបមុខច្បាស់ខ្ញុំសូមពណ៌នា។
**មួយ** វេស្សាយភពជាតិគ្រប់ចុងក្រោយ
បារមីនាំឱ្យដឹងពេលវេលា
ទ្រង់យាងកាន់ផ្ទៃស្មារតីល្អជា
ដឹងខ្លួនគ្រប់គ្រាក្នុងគភ៌មាតា ។
**ពីរ** គឺព្រះភគ្គ្រវរលក្ខណ៍ក្នុងគភ៌
ស្អឹងស្មាធិ៍ក្នុងធម៌បវរកាយា
ព្រះភគ្គ្របែរផ្ទុយពីខ្នងមាតា
ព្រោះផ្ទៃភ្លឺថ្លាមាតារំពៃ ។
**បី** តវិយាបថនៃព្រះមាតាពេលគ្រប់
មាសាសាស្ដាចាកផ្ទៃមាតា
ទ្រង់ឈរខុសស្រីដទៃ
ប្រសូតបុត្រថ្លៃហប្ញទ័យជ្រះថ្លា។
**បួន** សួនឧស្យានទីបានប្រសូត
ក្នុងព្រៃរហូតឈើស្រូតចេញផ្កា

ទេវតានិងមនុស្សថ្វាយសាធុការ
ចក្រវាឡបព្វតាខ្ទរខ្ទារអ៊ូអរ។
**ប្រាំ** ព្រះប្រសូតចុះយាងឈាន
ប្រាំពីរជំហានឆ្ពោះទិសឧត្តរ
ត្រួតគ្រប់ទិសឋានក្លាហាន
បវរទើបបានបន្លឺសីហនាទ។
**ប្រាំមួយ** ប្រមើលទតមើលនិមិត្ត
ទេវទូតបួនពិតចិត្តគិតលះញាតិ
បុត្រកើតថ្ងៃណាថ្ងៃនោះទ្រង់ឃ្លាត
ចិត្តឥតរវាតយាត្រាសាងផ្នួស។
**ប្រាំពីរ** ធីរោផ្តាច់ប្តូរព្យាយាម
ឥតមានទាក់ទាមក្នុងនាមអ្នកបួស
កំណត់វេលាមិនអាចតិចហួស
ប្រាំពីរថ្ងៃនោះនឹងបានត្រាស់ដឹង។
**ប្រាំបី** មហេសីគង់សោយបាយាស
ក្នុងថ្ងៃបានត្រាស់ទ្រង់ច្បាស់ទីពឹង
បាយាសថាសមាសថ្វាយព្រះថ្ងៃហ្នឹង
ហៅបាយត្រាស់ដឹងបានបុណ្យមហិមា។
**ប្រាំបួន** ជួនភ័ព្វទ្រង់ទ្រាប់ស្មៅភ្លាំង
ក្លាយជាបល្ល័ង្កគង់តាំងភាវនា
នៅគល់ពោធិព្រឹក្សនាទិសបូពា

ទេពធីតាមារមកគ្រាសាយ័ណ។

**ដប់** គាប់ហឫទ័យអានាបាណៈ

បរិកម្មប្រចក្សស្មតិដឹងទាន់

ខ្យល់ចេញខ្យល់ចូលចិត្តមូលមិនភាន់

ដំណើរជវ័នជាន់ធ្លងកាមា ។

**ដប់មួយ** ជំនួយពីព្រះបារមី

ផ្ចាញ់មារអប្រីយ៍ព្រមទាំងសេនា

ពុទ្ធប្បវត្តិត្រង់នេះអស្ចារ្យ

បរិស័ទជ្រះថ្លាបាចផ្កាអភិសេក។

**ដប់ពីរ** មុនីអង្គទ្រង់សម្រេចញាណ

ត្រៃវិជ្ជាមានទ្រង់ញាណអនេក

ពិសាខបុណ្ណមីកើតញាណប្លែកៗ

ពោធិញ្ញាណខ្ពស់ឯកកក្រើកធរណី ។

**ដប់បី** ក្សត្រថ្លៃគង់ក្នុងមហាឋាន

វិមុត្តិក្សេមក្សាន្តអស់ឋានប្រាំពីរ

សប្តាហ៍ឋានមួយលើកស្ទួយស្ថានទី

ចេតិយព្រះមុនីប្រាំពីរកន្លែង ។

**ដប់បួន** ជូនព្រហ្មជុំអារាធនា

សូមព្រះភគវាយាងត្រាស់សម្ដែង

ព្រះធម៌ប្រពៃវិស័យសូរ្យសែង

ទ្រង់ព្រមសម្ដែងដោយព្រហ្មវិហារ ។

**ដប់ប្រាំ** ចាំច្បាស់ទ្រង់ត្រាស់ធម្មចក្ក

ឥសិបតនៈព្រៃមិគទាយា

បានត្រៃរតនៈអាសាឡ្ហបូជា

ថ្ងៃព្រះភគវាស្ថាបនាព្រះសង្ឃ ។

**ដប់ប្រាំមួយ** ទ្រង់គង់ត្រាស់ឱវាទ

បាដិមោក្ខស្អាងស្អាតឱវាទផ្លូវផង់

បេះដូងព្រះធម៌ពន្លឺចតុរង្គ

ថ្ងៃនោះត្រូវត្រង់មាឃបុណ្ណមី ។

**ដប់ប្រាំពីរ** ទ្រង់គង់វត្តជេតពន

ប្រោសដល់មហាជននិរន្តប្រក្រតី

ទ្រង់យកអរុណជេតពនសួស្តី

ជេតពនជិនស្រីអាស្រ័យជានិច្ច ។

**ដប់ប្រាំបី** ទ្រង់សម្ដែងបាដិហារ្យ

យមកៈអស្ចារ្យរត់គេចនៅក្រុង

សាវត្ថីប្រុសស្រីមិនតិចនេះគឺ

ពុទ្ធកិច្ចសង្គ្រោះលោកា ។

**ដប់ប្រាំបួន** ទ្រង់គង់ឋានត្រ័យត្រិង្ស

ត្រិះរិះរំពឹងថ្លឹងគុណមាតា

សម្ដែងអភិធម្មស័ក្តិសមអស្ចារ្យ

ថ្វាយព្រះមាតាសុខាអមតៈ ។

**ម្ភៃ** គឺព្រះអង្គទ្រង់ចាកទេវលោក

ស្ដេចយាងចុះមកដែនសង្កស្សៈ

មហាជនច្រើនពិតយកចិត្តទុកដាក់

បូជាគារវៈអចលចេតិយ ។

**ម្ដេមួយ** គឺទ្រង់គង់ក្នុងសមាបត្តិ

ព្រះញាណស្ងប់ស្ងាត់លះកាត់

លោកីយ៍

អរហត្តផលតម្កល់ប្រក្រតី

ធាប់ក្ដីយូរក្ដីវិស័យពុទ្ធញ្ញាណ ។

**ម្ដេពីរ** ប្រមើលគ្រប់វេនេយ្យ

ឧបនិស្ស័យសព្វសត្វដែលមាន

ដោយដោយព្រះករុណាសមាបត្តិញ្ញាណ

ត្រួតសត្វកោដិលានមានពីរវារៈ ។

**ម្ដេបី** ទ្រង់លៃវិន័យអាជ្ញា

បញ្ញត្តសិក្ខាតាមការជ្រាបជាក់

មានរឿងកើតមុនខូចគុណសាវ័ក

មានហេតុជាក់លាក់ទើបដាក់វិន័យ ។

**ម្ដេបួន** អង្រួនហឫទ័យករុណា

ជាតក ទេសនា សាស្ដា លកលៃ

ដើមរឿង ជាហេតុ បង្កើត អត្ថន័យ

ជាតកប្រពៃលៃតាម ហេតុការណ៍។

**ម្ដេប្រាំ** ទ្រង់ប្រោសដល់ពួកព្រះញាតិ

អង្គព្រះលោកនាថ សម្តែង បាដិហារ្យ

កម្ចាត់មានះ ព្រះញាតិវង្សា

ទើប ត្រាស់ ទេសនា គម្ពីរ ពុទ្ធវង្ស។

**ម្តៃប្រាំមួយ** ទ្រង់គង់ ធូន់ក្នុងធម៌

បរិស័ទ ណាល្អ មានធម៌ ទ្រទ្រង់

ស្តេចយាងទទួលស្រុះស្រួលដោយអង្គ

គារវៈ ជូរជង់ ត្រោះត្រង់ ព្រះធម៌ ។

**ម្តៃប្រាំពីរ** ទ្រង់ គង់ ចាំ វស្សា

បើ មាន នរណា និមន្ត ដោយល្អ

ពេលចេញ វស្សា មុនយាង ចេញចរ

ទ្រង់ចម្រើនពរ ត្រាស់លាអ្នកនោះ។

**ម្តៃប្រាំបី** ទ្រង់គង់ យ៉ាង ហ្មត់ចត់

មុនភត្ត ក្រោយភត្តគ្មានភ្លាត់ភ្លេចសោះ

បំពេញ ពុទ្ធកិច្ច គ្រប់យាម ទាំងអស់

ពុទ្ធកិច្ចសង្គ្រោះ មនុស្សនិងទេវតា។

**ម្តៃប្រាំបួន** ទ្រង់ គង់ សោយ មំសៈ

ក្នុងថ្ងៃ ទ្រង់ដាក់អនុដ្ឋាន កាយា

បិណ្ឌបាត ចុងក្រោយជាទាន ថ្លៃថ្លា

សោយរសមំសា ហឫទ័យ បរិសុទ្ធ ។

**សាមសិប** អវសានទ្រង់បានចូលឈាន

មុននឹង និព្វាន ឈានច្រើន បំផុត

ម្ភៃបួនសែនកោដិ សមាបត្តិ បរិសុទ្ធ
រួចហើយ ទ្រង់ផុត រលត់ សង្ខារ ។
អហំ វី ខ្ញុំ បង្គំ វន្ទា
ចំពោះ ព្រះ ភគវា ព្រះធម៌ ថ្លៃថ្លា
ព្រមទាំង ព្រះសង្ឃ ផូរផង់ សីលា
ចិន្តា លំអុតព្រះពុទ្ធនិយាម ។
សូមឱ្យ សព្វសត្វ បដិបត្តិ តាមធម៌
សាសនា បវរ ល្អដូច ព្រះនាម
អរហំ សម្មា គ្មានការទាក់ទាម
កិលេស រវាម រវាត សូន្យបង់។
សូមឱ្យ សាសនា សម្មា សម្ពុទ្ធ
បរិសុទ្ធ មោះមុត រួមចិត្ត ទ្រទ្រង់
បិតថេរចិរកាអភិបាលដោយសង្ឃ
ព្រមព្រៀងស្មោះត្រង់ផ្ចិត ផ្គង់សិក្ខា។
សូមមនុស្ស ទេវតា មានការ គោរព
ទាំងថ្ងៃ ទាំងយប់ ក្នុងព្រះសាសនា
សូមបាន សម្រេច ដូចក្តី ប្រាថ្នា
អស់នូវតណ្ហាទុក្ខាចប់ហោង។

(ក្រាបថ្វាយបង្គំម្តង)

# បទសូត្រជាក់ទង់ព្រះពុទ្ធសាសនា

- ជាតិយើងអ្នកកាន់សាសនា　　ត្រូវដឹងច្បាស់ថាព្រះពុទ្ធជិនស្រី
ទ្រង់មានធពណ្ណរង្សី　　គឺព្រះរស្មីទាំងប្រាំមួយពណ៌។
-ផ្សាយចេញពីព្រះកាយទ្រង់　　រុងរឿងឫទ្ធិរុងប្រសើរបវរ
ធៀលធ្វាត់កាយឆើតឆាយល្អ　　ទាំងប្រាំមួយពណ៌ស្រស់ល្អសោភា។
-កំណើតនៃព្រះរស្មី　　កើតដោយបារមីនៃព្រះភគវា
ធ្វើទានឥតមានរួញរា　　កាលដែលនៅជាព្រះពោធិសត្វ។
-រស្មីពណ៌ខៀវនោះណា　　កាលធៀលនេត្រាទ្រង់ដោយចិត្តកាត់
ឲ្យទានដល់ឥន្ទព្រាហ្មណ៍ពិត　　កាលនៅជាក្សត្រនាមស្រីពិរាស្រ្ត។
-រស្មីពណ៌លឿងភ្លឺថ្លា　　កាលដែលទ្រង់អារសាច់ដៃធ្វើមាស
បិតពុទ្ធរូបភ្លឺល្អឱភាស　　ព្រះឥន្ទជាងមាសទ្រង់វៃបណ្ឌិត។
-រស្មីក្រហមនោះណា　　កាលដែលមាតាពស់ខាំស្លាប់ពិត
បទុមស្វិប្តូរជីវិត　　កាត់បេះដូងបិតធ្វើថ្នាំមាតា។
-រស្មីពណ៌សសុទ្ធសាធ　　កាលដែលព្រះបាទវេស្សន្តរក្សត្រា
ឲ្យទានដំរីសសោភា　　កាលព្រះប្រាថ្នារកពោធិញ្ញាណ។

-រស្មីពណ៌ដូចដើងហង្ស កាលមាតាទ្រង់យក្សចាប់យកបាន
វិជ្ជាធរអោរសាច់ខ្លួនប្រាណ ឲ្យយក្សសាមាន្យស៊ីប្តូរជីវិត។
-រស្មីពណ៌ផ្លេកពណ្ណរាយ កាលជាទន្សាយឈ្មោះសោមបណ្ឌិត
ឲ្យទានសាច់ឈាមជីវិត ដល់ឥន្ទព្រាហ្មណ៍ពិតជាអត់អាហារ។
-រស្មីពណ៌លឿងក្រហម សហង្សបាទព្រមភ្លឺផ្លេកអស្ចារ្យ
ត្រូវជាប្រាំមួយប្រការ ក្មេងចាស់កុមារចូរចាំទុកអើយ។

# បទស្ទូត្រលើកទង់ព្រះពុទ្ធសាសនា

១.សូមមើលទង់ជ័យ ឆព្វណ្ណរង្សី ដែលមានរស្មីភ្លឺស្រស់ល្អ
ខៀវលឿងក្រហម ព្រមទាំងពណ៌ស ហង្សបាទនិងពណ៌ដ៏ភ្លឺផ្លេ
ក។២.ប្រទេសតូចធំ បានសុំគ្រស្មាគម ជំនុំគ្នាច្រើនអនេក
ព្រមយករស្មី ព្រះពុទ្ធគួរត្រេក ប្រសើរពន់ពេកក្រែកន្លង។
៣.ធ្វើជាសញ្ញា ទង់ជ័យសាសនា នៃព្រះសម្ពុទ្ធធំចម្បង
ចូរយើងរាល់គ្នា យកចិត្តចាំចង នឹកដល់ព្រះអង្គជាអម្ចាស់ ។
៤.ទោះជាតិផ្សេងគ្នា ក៏ត្រូវដឹងថា សុទ្ធសឹងតែជាពុទ្ធសាសន៍
ចូរយើងសាមគ្គី ទាំងក្មេងទាំងចាស់ ប្រឹងប្រែងឲ្យណាស់គ្រប់ៗគ្នា។
៥.សូមសាសនាពុទ្ធ កុំថ្កើងបំផុត រុងរឿងវិសុទ្ធថ្លៃថ្លា
ហើយមានជ័យជោគ ផ្សាយពេញលោកា ដោយជនជ្រះថ្លាច្រើនសែនលាន។
៦.មានចិត្តស្នេហា គោរពបូជា ចំពោះព្រះធម៌ដ៏កល្យាណ

ទាំងមនុស្សទេវតា ស្នេហាគ្រប់ប្រាណ ប្រាថ្នាចង់បានសេចក្តីសុខ ។ ៧.យើងខេមរៈជាតិ នាំគ្នាខ្មីឃ្មាត កាន់ធម៌នឹងបានផុតទុក្ខ រួបរួមសាមគ្គី ពីនេះទៅមុខ យើងនឹងបានសុខក្សេមក្សាន្តគ្រាណា។៨.ព្រមព្រៀងប្រព្រឹត្ត កាន់ធម៌សុចរិត ឆ្ពោះទៅកាន់ឋាននិព្វាន ជាទីផុតទុក្ខ បានសុខក្សេមក្សាន្ត ជាតិយើងនឹងបានសោយសុខា ។

## នមស្ការធាតុចេតិយ

មហាគោតមសម្ពុទ្ធោ កុសិនារាយ និព្វុតោ ធាតុវិត្ថារកំ កត្វា តេសុ តេសុ វិសេសតោ។

ឧណ្ហីសំ ច តស្សោ ទាឋា អក្ខកា ទ្វេ ច សត្តមា អសម្ភិន្នា វ តា សត្តសេសា ភិន្នា វ ធាតុយោ។

មហន្តា បញ្ច ធាត្វី ច មជ្ឈិមា ច ឆ ធាត្វិយោ ខុទ្ទកា បញ្ច ធាត្វី ច សម្ភិន្នា តិវិធា មតា។

មហន្តា ភិន្នមុគ្គា ច មជ្ឈិមា ភិន្នតណ្ឌុលា ខុទ្ទកា សាសបមត្តា ឯវំ ធាតុប្បមាណិកា។

មហន្តា សុវណ្ណវណ្ណា មជ្ឈិមា ផលិកប្បភា ខុទ្ទកា ពកុលវណ្ណា តាបិ វន្ទាមិ ធាតុយោ។

ឯកោ ថូកោ រាជគហ ឯកោ វេសាលិយា អហុ ឯកោ កបិលវត្ថុស្មឹ ឯកោ ច អលកប្បកេ ឯកោ ច រាមគាមស្មឹ ឯកោ ច វេដ្ឋទីបកេ ឯកោ បាវេយ្យកេ មល្លេ ឯកោ ច កុសិនារកេ។

ឯកេ សារីរិកា ជូឍា ជម្ពុទីបេ បតិដ្ឋិតា បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ ។

ឯកា ទាឋា តិទសបុរេ ឯកា នាគបុរេ អហុ ឯកា គន្ធារវិសយេ ឯកា សីហឡទីបកេ ។

ឥមា ចតូសុ ឋានេសុ សត្ត ទាឋា បតិដ្ឋិតា បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ។

ឧទ្ធំ ទក្ខិណទាឋា ច តាវត្តិង្សេ បតិដ្ឋិតា អធោ ទក្ខិណទាឋា ច សីហឡទីបេ បតិដ្ឋិតា វាមទាឋា ច ឧទ្ធម្ហិ គន្ធាររដ្ឋេ បតិដ្ឋិតា វាមទាឋា ច អធោបិ នាគលោកេ បតិដ្ឋិតា បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ។

ព្រហ្មលោកេ ទុស្សធាតុ វាមអក្ខកធាតុយោ សព្វេ ព្រហ្មាភិបូជេន្តិ ជូបំ ទ្វាទសយោជនំ ។

តាវត្តិង្សម្ហិ ទេវានំ ចូឡាមណិម្ហិ កេសំ សព្វេ ទេវាភិបូជេន្តិ បសន្នា ពុទ្ធសាសនេ បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ។

បត្តាឡីស សមានន្តា កេសា លោមា នខាបិ ច ទេវា ហរន្តិ ឯកេកំ ចក្កវាឡបរម្បរា បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ។

អដ្ឋារស ទ្វេ វស្សសតេ ធម្មាសោកោ តទា អហុ ចតុរាសីតិ សហស្សា ចេតិយា ច ការាបិតា បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ។

# កំណើតទង់ពុទ្ធសាសនា

| | |
|---|---|
| ១-ពណ៌ខៀវកាលត្មៀលព្រះនេត្រ | ឱ្យឥន្ទព្រាហ្មណាកាលជាស្តេច |
| នាមស្រីកិរាស្រ្តចង់សម្រេច | ឱ្យបានសារពេជ្ជសាស្តាចារ្យ។ |
| ២-ពណ៌លឿងកាលអារសាច់ធ្វើមាស | បិតលន់អង្គព្រះពុទ្ធបដិមា |
| ព្រះឥន្ទជាជាងឆ្នៃរចនា | ថ្វាយពរសាធុការពេញផែនដី។ |
| ៣-ក្រហមជាពណ៌ឈាមបេះដូង | ត្មៀលពីដើមទ្រូងដោយឃ្មាតខ្មី |
| បិតពិសពស់ខាំព្រះជនី | គង់រស់ជីវីជាស្បើយទៅ។ |
| ៤-ពណ៌សឱ្យទានដំរីស | មង្គលបវរមាសត្បូងនខ្មៅ |
| ត្រូវរាស្ត្របណ្តេញមិនឱ្យនៅ | ព្រមទាំងកូនចៅកិរិយាណា។ |
| ៥-ហង្សបាទលូហិតសាច់មំសំ | អារសាច់ខ្លួនតាំងជូរមាតា |
| កាលយក្សវាចាប់បរិភោគ្គា | ជីវិតមាតារស់វិញខ្មី។ |
| ៦-ផ្លេកពណ្ណរាយកាលជាទន្សាយ | ឱ្យទានពុំស្តាយជីវិតអី |
| លោតចូលភ្នក់ភ្លើងពុំថាអ្វីឱ្យ | ជាចំណីឥន្ទព្រាហ្មណា។ |
| ៧-កាលដែលបានត្រាស់ជាព្រះពុទ្ធ | ជាមកុដត្រៃភពក្នុងលោកា |
| ពណ៌ទាំងប្រាំមួយនេះសោតណា | ក្លាយមកកើតជាឆព្វណ្ណរង្សី។ |
| ៨-ពេលនេះក្នុងលោកគេសន្មតិ | យកពណ៌នេះកត់ជាសេចក្តី |
| ហៅទង់សាសនាព្រះជិនស្រី | ពាសពេញផែនដីផ្តែពសុធា។ |
| ៩-យើងខ្ញុំរាល់គ្នាសូមគោរព | វន្ទាចមកភពទង់សាសនា |
| សូមមានមង្គលឈ្នះមារា | សត្រូវនានាក្នុងភពបី។ |
| ១-សូមឱ្យយើងខ្ញុំប្រញាប់ដល់ | ដើរកាត់តាមផ្លូវទៅបុរី |
| ជាស្ថានបរមសុខសួស្តី | ដោយព្រះបារមីនិព្វានហោង។ |

# វិធីសមាទាននិច្ចសីល

➢ *សីល (តើអ្វីជាតួសីល?)*

*ធម៌ ៤យ៉ាង គឺចេតនា១ ចេតសិក១ សំវរៈ១ អវីតិក្កមៈ១ របស់បុគ្គលវៀរចាកអំពើ មានបាណាតិបាត (ការសម្លាប់សត្វ) ជាដើមឬថារបស់បុគ្គលកាលបំពេញនូវវត្តប្រតិបត្តិ ហៅថា សីល។*

*ក្នុងបដិសម្ភិទា មានពោលថា៖* **ចេតនាហំ ភិក្ខវេ សីលំ វទាមិ** *ម្នាលភិក្ខុទាំងឡាយ តថាគតហៅចេតនាជាតួសីល។*

*ចេតនា គឺធម្មជាតអ្នកគិត ចាត់ចែង សន្សំ។ បានសេចក្ដីថា ធម្មជាតដែលញុំាងសម្បយុត្តធម៌ គឺចិត្ត និងចេតសិក ដែលប្រកបជាមួយ ឲ្យហូរចុះទៅក្នុងសីល។*

*ការគិត គំនិត ការចាត់ចែងរបស់បុគ្គល វៀរចាកបញ្ចវេរា (ការសម្លាប់សត្វ ១ ការលួចទ្រព្យគេ ១ ការប្រព្រឹត្តខុសក្នុងកាម ១ ការពោលពាក្យកុហក ១ ការផឹកនូវទឹកស្រវឹង ១) តាមផ្លូវកាយ ឬផ្លូវវាចា ហៅថា សីល។ម្យ៉ាងទៀត ចេតនាក្នុងការលះអកុសលកម្មបថ៧ (កាយកម្ម៣ វចីកម្ម ៤) របស់បុគ្គល ក៏ហៅថាសីល។ ការគិត គំនិត ការចាត់ចែងរបស់បុគ្គលអ្នករក្សាឧបោសថសីលក្ដី សីល ១០ក្ដី ការលះបង់នូវអំពើ មានបាណាតិបាត (សម្លាប់សត្វ) ជាដើម ហៅថា សីល។ ការគិត គំនិត ការចាត់ចែងរបស់*

បុគ្គល កាលបំពេញនូវវត្តប្រតិបត្ត មានឧបជ្ឈាយវត្ត ដោយកាយ វាចា អាចរិយវត្តជាដើម ក្នុងព្រះពុទ្ធសាសនានេះ ក៏ហៅថា សីល។

**ចេតសិកំ សីលំ** ចេតសិកជាតួសីល។ ចេតសិក គឺធម្មជាតិ មានការកើត និងការរលត់ព្រមគ្នានឹងចិត្ត ហៅថា ចេតសិក។ ចេតសិកក្នុងទីនេះ បានដល់ធម៌ ៣យ៉ាង គឺ៖

- **អនភិជ្ឈា** ការមិនសំឡឹងរំពៃចង់បានទ្រព្យរបស់អ្នកដទៃ ជាអលោភចេតសិក។
- **អព្យាបាទោ** ការមិនចងគំនុំចង់ឲ្យអ្នកដទៃវិនាស ជាអទោសចេតសិក។
- **សម្មាទិដ្ឋិ** កាលយល់ឃើញត្រូវ ជាអមោហចេតសិក។

សំវរោសីលំ សេចក្ដីសង្រួមជាតួសីល។

ការសង្រួមមាន ៥យ៉ាងគឺ៖

- **បាតិមោក្ខសំវរ** (សេចក្ដីសង្រួមក្នុងបាតិមោក្ខ)
- **សតិសំវរ** (សេចក្ដីសង្រួមក្នុងការរឭក)
- **ញាណសំវរ** (សេចក្ដីសង្រួមក្នុងការកំណត់ដឹង)
- **ខន្តិសំវរ** (សេចក្ដីសង្រួមក្នុងភាពអំណត់)
- **វីរិយសំវរ** (សេចក្ដីសង្រួមក្នុងភាពព្យាយាម)។

**អវីតិក្កមោសីលំ** ការមិនប្រព្រឹត្តកន្លង ជាតួសីល។ បានដល់ការមិនប្រព្រឹត្តកន្លងដែលប្រកបដោយកាយ វាចារបស់

បុគ្គលដែលបានសមាទានសីល មានសីល៥ សីល៨ សីល១០ ហ្នឹងឯង។ ឧបាសក ឧបាសិកាដែលបានសមាទានសីលហើយ ក៏ប្រឹងសង្រួមកាយ វាចាដោយប្រពៃតាមសិក្ខាបទទាំងឡាយដែលខ្លួនបានសមាទានហើយ គឺមិនប្រព្រឹត្តកន្លងនូវសិក្ខាបទណាមួយឡើយ។ សីលរបស់ឧបាសក ឧបាសិកា ដែលកើតឡើងនេះឯង ហៅថា **អវិតិក្កមសីល**។

❖ សីលមាន ៤ប្រភេទ៖

សីលមាន ៤ប្រភេទគឺ សីល៥សីល៨សីល១០និងសីល៤។ សីល៥ និងសីល១០ ហៅថានិច្ចសីល គឺសីលដែលបុគ្គលអ្នកមានបំណងសមាទាន អាចរក្សាពល់ថ្ងៃបាន។ សីល៨ ហៅថាឧបោសថសីល ជាសីលដែលបុគ្គលអ្នកសមាទាន ត្រូវរក្សាតាមពេលវេលានៃថ្ងៃឧបោសថ។ សីល៤ ហៅថា អធិសីល ជាសីលដ៏ក្រៃលែងរបស់ភិក្ខុ និងភិក្ខុនី ដែលជាញត្តិសីល។

ឧបាសក ឧបាសិកា ត្រូវសូត្រថា៖

ឱកាស អហំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ចសីលានិ យាចាមិ។

ទុតិយម្បិ អហំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហបញ្ចសីលានិ យាចាមិ។

**កតិយម្បិ អហំ ភន្តេ ទិសុំ ទិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ចសីលានិ យាចាមិ។**

*សេចក្តីបញ្ជាក់: បើម្នាក់ឯងត្រូវសូត្រថា* **អហំ** *និង* **មិ** *បើមានគ្នាចាប់ពី២នាក់ឡើងត្រូវសូត្រថា* **មយំ** *និង* **ម**។

## នមស្ការគាថា

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**

*វិកិរិយានមស្ការថ្វាយបង្គំ នៃខ្ញុំព្រះករុណា ចូលមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ។*

## ត្រៃសរណគមន៍

**ពុទ្ធំ សរណំ គច្ឆាមិ**

*ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹងទីរឭក។*

**ធម្មំ សរណំ គច្ឆាមិ**

*ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីពឹងទីរឭក។*

**សង្ឃំ សរណំ គច្ឆាមិ**

*ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីពឹងទីរឭក។*

**ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹងទីរឭក ជាគម្រប់ពីរដងផង។

**ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីពឹងទីរឭក ជាគម្រប់ពីរដងផង។

**ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីពឹងទីរឭក ជាគម្រប់ពីរដងផង។

**តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹងទីរឭក ជាគម្រប់បីដងផង។

**តតិយម្បិ ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីពឹងទីរឭក ជាគម្រប់បីដងផង។

**តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីពឹងទីរឭក ជាគម្រប់បីដងផង។

ព្រះសង្ឃពោលបន្តទៀតថា៖ **តិសរណគ្គហណំ បរិបុណ្ណំ**

ឧបាសក ឧបាសិកាត្រូវទទួលថា៖ **អាម ភន្តេ**

ព្រះសង្ឃឱ្យនិច្ចសីល ជាបច្ចេកសមាទានថា៖

**១–បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ។**

ប្រែ៖ខ្ញុំព្រះករុណាសូមសមាទាន នូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា ធ្វើនូវសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ ។

**២–អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ។**

ប្រែ៖ ខ្ញុំព្រះករុណាសូមសមាទាន នូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា កាន់យកនូវវត្ថុដែលគេមិនបានឲ្យ ដោយកាយឬដោយវាចា។

**៣–កាមេសុ មិច្ឆាចារា វេរមណី សិក្ខាបទំ សមាទិយាមិ។**

ប្រែ៖ ខ្ញុំព្រះករុណាសូមសមាទាន នូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ។

**៤–មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ។**

ប្រែ៖ ខ្ញុំព្រះករុណាសូមសមាទាន នូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា ពោលនូវពាក្យកុហក។

**៥–សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ។**

ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យ។

ព្រះសង្ឃរំលឹកថា៖ **ឥមានិ បញ្ចសិក្ខាបទានិ សាធុកំ កត្វា អប្បមាទេន និច្ចកាលំ សម្បាទេតព្វំ។**

សេចក្តីប្រែ៖ អ្នក (ទាំងឡាយ) គប្បីធ្វើនូវសិក្ខាបទទាំងឡាយប្រាំនេះឲ្យប្រពៃ ត្រូវរក្សាឲ្យល្អអស់កាលជានិច្ច ដោយសេចក្តីមិនប្រមាទ គឺថាកុំធ្វេសប្រហែសឡើយ។

អ្នកសមាទានត្រូវទទួលថា៖ **អាម ភន្តេ** (ករុណាលោកម្ចាស់)។

ព្រះសង្ឃលោកសម្តែងអានិសង្សនៃសីលថា៖

**សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ។** សត្វទាំងឡាយ បានទៅកាន់ស្ថានសួគ៌ក៏ព្រោះសីល សត្វទាំងឡាយបានបរិបូណ៌ដោយភោគក៏ព្រោះសីល សត្វទាំងឡាយ បានទៅកាន់ទីរំលត់ទុក្ខ គឺព្រះនិព្វាន ក៏ព្រោះសីល ព្រោះហេតុនោះ បុគ្គលជាសប្បុរស គប្បីជំរះនូវសីលឲ្យបរិសុទ្ធ កុំឲ្យសៅហ្មង ។

អ្នកសមាទានត្រូវទទួលថា៖ **សាធុ សាធុ សាធុ។**

# វិធីសមាទានឧបោសថ

ឧបាសក ឧបាសិកា ជាអ្នករក្សានូវឧបោសថសីល កាលបើដល់ថ្ងៃជិតនឹងរក្សានូវឧបោសថសីល គឺថ្ងៃមុន១ថ្ងៃដែលកំណត់ថា ព្រឹកឡើងនឹងរក្សានូវឧបោសថសីលនោះគប្បីចាត់ចែងការងារដែលគួរនឹងចាត់ចែង មានការចាត់ចែងនូវអាហារជាដើម ដែលជាការងារគឺខ្លួននឹងត្រូវធ្វើ ឬនឹងត្រូវប្រើឲ្យគេធ្វើក្នុងថ្ងៃស្អែក គឺក្នុងថ្ងៃឧបោសថកាល ឲ្យហើយក្នុងថ្ងៃនោះមុន តែកុំចាត់ចែងការងារដែលមិនប្រកបដោយធម៌ ដែលជាការងារគឺខ្លួនជាឧបាសក ឧបាសិកា មិនគួរនឹងចាត់ចែងនោះឡើយ។ លុះដល់ថ្ងៃព្រឹកឡើងជាថ្ងៃឧបោសថកាល ត្រូវរក្សាឧបោសថសីល គប្បីភ្ញាក់ឡើងពីព្រលឹមហើយខ្ពុរមាត់ ជំរះធ្មេញឲ្យស្អាតរួចហើយ ទើបបានសមាទាននូវឧបោសថសីលក្នុងថ្ងៃនោះក៏ជាការប្រពៃ បើឃើញ

ថានឹងសមាទានពីព្រលឹមនោះមិនទាន់ទេ ក៏គប្បីកំណត់នូវឧបោសថកាល គឺកាលជាទីរក្សានូវឧបោសថសីល ក្នុង១ថ្ងៃ១យប់នោះដោយបញ្ចេញវាចាអធិដ្ឋានថា៖ **អជ្ជ ឧបោសថោ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ ឧបោសថិកោ ភវិស្សាមិ។** (បើជាឧបាសិកាត្រូវថាប្តូរត្រង់ **ឧបោសថិកោ** មកជា **ឧបោសថិកា**)។

សេចក្តីប្រែ ៖ថ្ងៃនេះជាថ្ងៃត្រូវរក្សានូវឧបោសថសីល ខ្ញុំនឹងជាអ្នករក្សានូវឧបោសថសីល អស់ថ្ងៃនេះនិងយប់នេះ។

កាលបើបានអធិដ្ឋានដូច្នេះរួចហើយ តអំពីពេលនោះមក ក៏គប្បីសមាទាននូវឧបោសថសីល អំពីបុគ្គលដទៃមានភិក្ខុជាដើមតាមកាលគួរ បើទុកជាដល់ពេលព្រះអាទិត្យរះខ្ពស់ឡើង ប្រមាណពេញពន្លឺធំទើបបានសមាទានក្តី ក៏ឈ្មោះថាបានសមាទានដោយប្រពៃ ឈ្មោះថាបានរក្សានូវឧបោសថសីល ពេញកាលកំណត់១ថ្ងៃ ១យប់ដោយបរិបូណ៌។

កាលបើឧបាសក ឧបាសិកា នឹងសមាទាននូវឧបោសថសីល ប្រកបដោយអង្គ៨ ជាបច្ចេកសមាទាន អំពីព្រះសង្ឃនោះត្រូវសូត្រនមស្ការ ហើយសូមនូវឧបោសថសីលព្រមទាំងព្រះត្រៃសរណគមន៍ ចំពោះព្រះសង្ឃថា៖

**ឱកាស អហំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋសីលានិ យាចាមិ។**

**ទុតិយម្បិ អហំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋសីលានិ យាចាមិ។**

**តតិយម្បិ អហំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋសីលានិ យាចាមិ។**

សូមគោរព បពិត្រព្រះករុណាដ៏ចំរើន ខ្ញុំព្រះករុណា សូមនូវឧបោសថសីល ប្រកបព្រមដោយអង្គ៨មួយអន្លើ ដោយព្រះត្រៃសរណគមន៍ដើម្បី ប្រយោជន៍នឹងរក្សាផ្សេងៗគ្នា បពិត្រព្រះករុណាដ៏ចំរើន សូមព្រះករុណាមេត្តាធ្វើ នូវសេចក្តីអនុគ្រោះអោយនូវសីល ដល់ខ្ញុំព្រះករុណា។ បពិត្រព្រះករុណាដ៏ចំរើន ខ្ញុំព្រះករុណាសូមនូវឧបោសថ សីលប្រកប ព្រមដោយអង្គ៨មួយអន្លើដោយព្រះត្រៃសរណគមន៍ដើម្បីប្រយោជន៍ រក្សាផ្សេងៗគ្នា បពិតព្រះករុណា ដ៏ចំរើន សូមព្រះករុណាមេត្តាធ្វើនូវសេចក្តីអនុគ្រោះអោយនូវសីល ដល់ខ្ញុំព្រះករុណាជាគំរប់បីដងផង។ បពិត្រព្រះករុណាដ៏ចំរើន សូមព្រះករុណាមេត្តាធ្វើនូវសេចក្តីអនុគ្រោះអោយនូវសីល ដល់ខ្ញុំព្រះករុណា។

# សិក្ខាបទរបស់ឧបោសថសីល

**១–បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ។**

ប្រែ៖ខ្ញុំព្រះករុណាសូមសមា ទាននូវ សិក្ខាបទគឺចេតនាជា ហេតុវៀរចាកកិរិយាធ្វើសត្វ មានជីវិតអោយធ្លាក់ចុះក្នុងគន្លងគឺ សំលាប់សត្វ។

**២–អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ ។**

ប្រែ៖ខ្ញុំព្រះករុណា សូមសមាទាននូវ សិក្ខាបទគឺចេតនាជាហេតុវៀរចាកកិរិយា កាន់យកនូវវត្ថុ ដែលគេមិនបាន អោយដោយ កាយឬដោយវាចា។

**៣–អព្រហ្មចរិយា វេរមណី សិក្ខាបទំ សមាទិយាមិ។**

ប្រែ៖ ខ្ញុំព្រះករុណា សូមសមទាននូវ សិក្ខាបទគឺចេតនាជាហេតុវៀរចាកកិរិយា ប្រព្រិត្តធម៌មិនប្រសើរគឺសេពនូវមេថុនធម្ម។

**៤–មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ។**

ប្រែ៖ ខ្ញុំព្រះករុណា សូមសមាទាន នូវសិក្ខា បទគឺចេតនាជាហេតុវៀរ ចាកកិរិយាពោលនូវពាក្យកុហក។

**៥–សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ។**

ប្រែ៖ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទគឺ ចេតនា ជាហេតុវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទគឺ ផឹកនូវទឹកស្រវឹងគឺសុរា និងមេរ័យ។

**៦–វិកាលភោជនា វេរមណី សិក្ខាបទំ សមាទិយាមិ។**

ប្រែ៖ ខ្ញុំព្រះករុណាសូមសមាទានូវសិក្ខា បទគឺចេតនាជាហេតុវៀរចាកកិរិយា បរិភោគនូវ ភោជនាហារក្នុងកាលខុស។

**៧–នច្ចគីតវាទិត វិសូកទស្សន មាលាគន្ធ វិលេបន ធារណ មណ្ឌនវិភូសនដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ។**

ប្រែ៖ ខ្ញុំព្រះករុណា សូមសមាទាន នូវសិក្ខាបទ គឺចេតនាជាហេតុ វៀរចាកកិរិយារាំ និងច្រៀង និងមើល នូវល្បែងដែលជាសត្រូវ

ដល់កុសលធម៌និង កិរិយាទ្រទ្រង់និងប្រដាប់និងតាក់តែងស្អិតស្អាងរាង កាយដោយផ្កាកំរង និង គ្រឿងក្រអូប និងគ្រឿងលាបផ្សេងៗ។

**៨–ឧច្ចាសយនមហាសយនា វេរមណី សិក្ខាបទំ សមាទិយាមិ។**

ប្រែ៖ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុ វៀរចាកទីសេនាសនៈដ៏ខ្ពស់ហួសប្រមាណ និងទី សេនាសនៈដ៏ប្រសើរ។

**បន្តមកអ្នកសមាទានសូត្រកំណត់ឧបោសថកាលថា៖**

**ឥមំ អដ្ឋង្គសមន្នាគតំ ពុទ្ធប្បញ្ញត្តំ ឧបោសថំ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សម្មទេវ អភិរក្ខិតុំ សមាទិយាមិ។**

សេចក្តីប្រែ៖ ខ្ញុំព្រះករុណា សូមសមាទាននូវឧបោសថ សីល ដ៏ប្រកបព្រម ដោយអង្គ៨ ដែលព្រះ សម្មាសម្ពុទ្ធ ជាម្ចាស់ ទ្រង់ត្រាស់បញ្ញត្តិទុកហើយនេះ ដើម្បីនឹងរក្សាអោយ បរិបូរណ៍ ប្រពៃ អស់កាលកំណត់ថ្ងៃនេះ និងយប់នេះ សូមកុសលចូរជា ឧបនិស្ស័យធ្វើ អោយ ច្បាស់នូវព្រះនិព្វានព្ធដ៏អានាគត ទៅមុខ នោះហោង។

ព្រះសង្ឃពោលរំលឹកថា៖ **ឥមានិ អដ្ឋ សិក្ខាបទានិ សាធុកំ ឧបោសថសីលវសេន ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សាធុកំ កត្វា អប្បមាទេន សម្មារក្ខិតព្វំ។**

សេចក្តីប្រែ៖ អ្នកទាំងឡាយ គប្បីធ្វើនូវសិក្ខាបទទាំឡាយ៨ នេះឱ្យ ប្រពៃត្រូវរក្សា អោយល្អ អស់កាលត្រឹម១យប់ ១ថ្ងៃនេះ ដោយសេចក្តីមិនប្រមាទគឺថាកុំធ្វើប្រហែសឡើយ។

អ្នកសមាទានត្រូវទទួលថា៖ **អាម ភន្តេ**

ព្រះសង្ឃសម្តែងអំពីអនិសង្សសីលបន្តថា៖

**សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា។**

**សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ៕**

សេចក្តីប្រែ៖ សត្វទាំងឡាយ ទៅកាន់ស្ថានសួគ៌ បានក៏ ព្រោះសីល សត្វទាំងឡាយ បានបរិបូណ៌ដោយភោគៈ ក៏ព្រោះ សីល សត្វទាំងឡាយ បានទៅកាន់ទីរំលត់ទុក្ខគឺព្រះ និព្វានក៏ព្រោះ សីល ព្រោះហេតុនោះ បុគ្គលជា សប្បុរស គប្បីជំរះនូវសីលអោ យបរិសុទ្ធ កុំអោយសៅហ្មង ។

អ្នកសមាទានត្រូវទទួលថា៖ **សាធុ សាធុ សាធុ។**

# អំពីកម្មបថ១០

កម្មបថចែកចេញជាកម្មមាន៣យ៉ាង គឺកាយកម្ម១ វចីកម្ម ១ និងមនោកម្ម១។ ចែកប្រភេទមានពីរយ៉ាងគឺ អកុសលកម្មបទ១ កុសលកម្មបទ១ ។

# កុសលកម្មបថ១០

**ក.កាយសុចរិត ៣**

**១-បាណាតិបាតា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ។

**២-អទិន្នាទានា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឲ្យដោយកាយឬដោយវាចា។

**៣-កាមេសុមិច្ឆាចារា** វេរមណី ចេតនាជាហេតុវៀរចាកកិរិយា ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ។

**ខ.វចីសុចរិត ៤**

**១-មុសាវាទា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក។

**២-បិសុណាវាចា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យញុះញង់ស៊កសៀត បំបែកបំបាក់អ្នកដទៃ។

**៣-ផរុសវាចា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យអាក្រក់ មានពាក្យទ្រគោះបោះបោក ជេរប្រទេចអ្នកដទៃជាដើម។

**៤-សម្ផប្បលាបា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យរោយរាយឥតប្រយោជន៍។

**គ.មនោសុចរិត ៣**

**១-អនភិជ្ឈា** មិនមានចិត្តគិតសម្លឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃ ដោយគិតបំរុងនឹងឲ្យបានមកជាទ្រព្យរបស់ខ្លួនឡើយ។

**២–អព្យាបាទោ** មិនមានចិត្តចងគំនុំគុំគួន គិតប៉ងនឹងឲ្យអ្នកដទៃដល់នូវសេចក្តីវិនាសឡើយ។

**៣–សម្មាទិដ្ឋិ** គំនិតយល់ឃើញត្រូវពិត ហើយប្រកាន់ឡើងថាត្រូវមែន។

(ចំពោះអកុសលកម្មបថវិញ គឺការប្រព្រឹត្តផ្ទុយពីកុសលកម្មបថ)

# អង្គរបស់កម្មបថ១០

**ក.បាណាតិបាតមានអង្គ៥៖**

**១.បាណោ** សត្វមានជីវិត។

**២.បាណសញ្ញិតោ** សេចក្តីដឹងថា សត្វមានជីវិត។

**៣.វធកចិត្តំ** គិតនឹងសម្លាប់។

**៤.ឧបក្កមោ** ព្យាយាមនឹងសម្លាប់។

**៥.តេនមរណំ** សត្វស្លាប់ដោយព្យាយាមនោះ។

**ខ.អទិន្នាទានមានអង្គ៥៖**

**១.បរបរិគ្គហិតំ** ទ្រព្យដែលម្ចាស់គេហួងហែងរក្សា។

**២.បរបរិគ្គហិតសញ្ញិតា** សេចក្តីដឹងថា ទ្រព្យមានម្ចាស់គេហួងហែងរក្សា។

**៣.ថេយ្យចិត្តំ** គិតនឹងលួច។

**៤.ឧបក្កមោ** ព្យាយាមនឹងលួច។

**៥.តេន ហរណំ** លួចបានមកដោយព្យាយាមនោះ។

ក.កាមេសុមិច្ឆាចារ មានអង្គ ៤៖

១.អគមនីយដ្ឋានំ ស្ត្រីដែលមិនគួរនឹងគប់រក គឺស្ត្រីដែលមានគេហួងហែងរក្សា។

២.តស្មិំសេវនចិត្តំ គិតនឹងសេពនូវមេថុនធម្ម។

៣.ឧបក្កមោ ព្យាយាមនឹងសេពនូវមេថុនធម្ម។

៤.មគ្គេនមគ្គប្បដិបាទនំ ញ៉ាំងមគ្គនឹងមគ្គឲ្យដល់គ្នា។

ឃ.មុសាវាទ មានអង្គ៤៖

១.អតថំវត្ថុ វត្ថុមិនពិត។

២.វិសំវាទនចិត្តំ គិតនឹងពោលឲ្យខុស។

៣.តជ្ជោវាយាមោ ព្យាយាមនឹងពោលឲ្យខុស។

៤.បរស្សតទត្ថវិជាននំ ញ៉ាំងអ្នកដទៃ ឲ្យដឹងច្បាស់នូវសេចក្ដីនោះ។

ង.បិសុណាវាចា មានអង្គ៤៖

១.ភិន្ទិតព្វោបរោ អ្នកដទៃដែលមានរូប គឺខ្លួនគប្បីញុះញង់បំបែក។

២.ភេទនបុរេក្ខារតា គិតនឹងញុះញង់បំបែកបំបាក់អ្នកដទៃនោះ។

៣.តជ្ជោវាយាមោ ព្យាយាមបំបែកបំបាក់អ្នកដទៃនោះ។

៤.តស្សតទត្ថវិជាននំ ញ៉ាំងអ្នកដទៃឲ្យដឹងច្បាស់នូវដំណើរដែលញុះញង់នោះ។

**ច.ផរុសវាចា មានអង្គ៣៖**

**១.អក្កោសិតព្វោបរោ** អ្នកដទៃដែលមានរូបគឺខ្លួនគប្បីជេរប្រទេច។

**២.កុបិតចិត្តំ** ចិត្តខឹងរន្ធត់។

**៣.អក្កោសនា** បានជេរប្រទេច។

**ឆ.សម្ផប្បលាប មានអង្គ២៖**

**១. និរត្ថកកថាបុរេក្ខារតា** ការប្រកបដោយវាចាឥតប្រយោជន៍។

**២.តថារូបី កថា កថនញ្ច** បានពោលនូវពាក្យឥតប្រយោជន៍ មានសភាពដូច្នេះ។

**ជ.អភិជ្ឈា មានអង្គ២៖**

**១.បរភណ្ឌំ** ទ្រព្យជារបស់អ្នកដទៃ។

**២.អត្តនោ បរិណាមនំ** គិតចង់បង្អោនទ្រព្យរបស់អ្នកដទៃនោះ ឲ្យមកជាទ្រព្យរបស់ខ្លួន ដោយកលឧបាយផ្សេងៗ។

**ឈ.ព្យាបាទ មានអង្គ២៖**

**១.បរសត្តោ** អ្នកដទៃក្រៅពីខ្លួន។

**២.តស្សតំតំវិនាសចិន្តា** គិតចង់គំនុំគុំគួននឹងអ្នកនោះ ឲ្យដល់នូវសេច-ក្តីវិនាសដោយហេតុនោះ។

**ញ.មិច្ឆាទិដ្ឋិ មានអង្គ២៖**

**១.វត្ថុនោ ច គហិតាការវិបរិតតា** ចិត្តប្រែប្រួលដោយអាការខុស អំពីព្រះរតនត្រ័យជាដើម ។

២.យថា ច តំ គណ្ហាតិ តថាភាវេន គណ្ហបរដ្ឋានំ គំនិតដែលយល់ខុសនោះ ឃើញខុសយ៉ាងណា ក៏ប្រកាន់សេចក្តីខុសនោះថាជាត្រូវវិញ។

## អានិសង្សនៃការរក្សាឧបោសថសីល

ម្នាលភិក្ខុទាំងឡាយ ឧបោសថប្រកបដោយអង្គ ៨ប្រការ ដែលបុគ្គលចាំរក្សាហើយ រមែងមានផលច្រើន មានអានិសង្សច្រើន មានសេចក្តីរុងរឿងច្រើន មានសេចក្តីផ្សាយទៅច្រើន។ ម្នាលភិក្ខុទាំងឡាយ ឧបោសថប្រកបដោយអង្គ ៨ ប្រការ ដែលបុគ្គលចាំរក្សាហើយ រមែងមានផលច្រើន មាន អនិសង្សច្រើន មានសេចក្តីរុងរឿងច្រើន មានសេចក្តីផ្សាយទៅច្រើនតើដោយប្រការដូចម្តេច?

ម្នាលភិក្ខុទាំងឡាយ អរិយសាវក ក្នុងសាសនានេះ ពិចារណាថា ព្រះអរហន្តទាំងឡាយ លះបង់បាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានគ្រឿងសស្ត្រា ដាក់ចុះហើយ មានសេចក្តីខ្មាសបាប មានសេចក្តីអាណិត មានសេចក្តីអនុគ្រោះ ដោយប្រយោជន៍ដល់សព្វសត្វ ដរាបអស់ជីវិត ក្នុងថ្ងៃនេះ ចំណែកខ្លួនអញលះបង់ បាណាតិបាត វៀរចាកបាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានគ្រឿងសស្ត្រាដាក់ចុះហើយ មានសេចក្តីខ្មាសបាប មានសេចក្តីអាណិត មានសេចក្តីអនុគ្រោះ ដោយប្រយោជន៍ដល់សព្វសត្វ

អស់យប់នេះ និងថ្ងៃនេះយកតម្រាប់ព្រះអរហន្ត ទាំងឡាយផង ខ្លួនអញនឹងចាំរក្សាឧបោសថផង ដោយអង្គនេះឯង ។ ឧបោសថប្រកបដោយអង្គទី១នេះឯង ។

(សេចក្ដីពិស្ដារដូចអង្គទី ១) ព្រះអរហន្តទាំងឡាយលះបង់សេនាសនៈដ៏ខ្ពស់ហួសប្រមាណ និងសេនាសនៈដ៏ប្រសើរ សម្រេចនូវទីដេកដ៏ទាប លើគ្រែក្ដី លើកម្រាល ដែលគេធ្វើដោយស្មៅ ក្ដី ក្នុងថ្ងៃនេះ ចំណែកខ្លួនអញ លះបង់សេនាសនៈ ដ៏ខ្ពស់ហួសប្រមាណ និងសេនាសនៈដ៏ប្រសើរ វៀរចាកសេនាសនៈ ដ៏ខ្ពស់ហួសប្រមាណ នឹង សេនាសនៈដ៏ប្រសើរ សម្រេចនូវទីដេកដ៏ទាបលើគ្រែក្ដី លើកម្រាលដែលធ្វើដោយស្មៅក្ដីអស់យប់នេះនឹងថ្ងៃនេះដែរយកតម្រាប់ព្រះអរហន្តទាំងឡាយផងអញនឹងចាំរក្សាឧបោសថផងដោយអង្គនេះឯង។ ឧបោសថប្រកបដោយអង្គទី៨នេះឯង។

ម្នាលភិក្ខុទាំងឡាយ ឧបោសថប្រកបដោយអង្គ ៨ ប្រការដែលបុគ្គលចាំរក្សាយ៉ាងនេះឯង រមែងមានផលច្រើន មានអានិសង្សច្រើន មានសេចក្ដីរុងរឿងច្រើន មានសេចក្ដីផ្សាយទៅច្រើន។ ឧបោសថ មានផលច្រើនដូចម្ដេច មានអានិសង្សច្រើនដូចម្ដេច មានសេចក្ដីរុងរឿងច្រើនដូចម្ដេច មានសេចក្ដីផ្សាយទៅច្រើនដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចបុគ្គលសោយរាជ្យជាឥស្សរាធិបតីនៃមហាជនបទទាំង១៦នេះ ដែលជាជនបទ សម្បូ

រដោយកែវ៧ប្រការ គឺមហាជន ឈ្មោះ អង្គៈ១ មគធៈ១ កាសី ១ កោសលៈ១ វជ្ជី១ មល្លៈ១ ចេត ១ វង្សៈ១ កុរុ១ បញ្ចាលៈ១ មច្ឆៈ១ សូរសេនៈ១អស្សកៈ១អវន្តី១គន្ធារ១កម្ពោជៈ១រាជសម្បត្តិនៃមហាជនបទទាំងនុ៎ះ មិនដល់នូវចំណិត១ក្នុងចំណិតទី១៦ៗលើកនៃឧបោសថប្រកបដោយអង្គ៨ប្រការឡើយ។ ដំណើរនោះព្រោះហេតុអ្វី?

ម្នាលភិក្ខុទាំងឡាយ រាជសម្បត្តិរបស់មនុស្ស ជារបស់ស្តួចស្តើង ហើយយកទៅប្រៀបធៀបនឹងសេចក្តីសុខជារបស់ទិព្វ។ ម្នាលភិក្ខុទាំងឡាយ ៥០ឆ្នាំ របស់មនុស្សត្រូវជា ១យប់ ១ថ្ងៃ របស់ចាតុម្មហារាជិកាទេវតា របស់រាត្រីនោះបាន ៣០រាត្រី ត្រូវជា ១ខែ រាប់ខែនោះ បាន ១២ខែ ត្រូវជា ១ឆ្នាំ រាប់ឆ្នាំនោះបាន ៥០០ឆ្នាំទិព្វ ត្រូវជាប្រមាណនៃអាយុរបស់ចាតុម្មហារាជិកទេវតា។

ម្នាលភិក្ខុទាំងឡាយ ហេតុនេះ រមែងមាន ត្រង់ដែលស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះចាំរក្សានូវឧបោសថដែលប្រកបដោយអង្គ ៨ប្រការ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកចាតុម្មហារាជិកទេវតា។ ម្នាលភិក្ខុទាំងឡាយ រាជសម្បត្តិរបស់មនុស្ស ជារបស់ស្តួចស្តើង ហើយយកទៅប្រៀបធៀបនឹងសេចក្តីសុខ ជារបស់ទិព្វ ដែលតថាគត សម្តែងហើយ ព្រោះអាស្រ័យហេតុនេះឯង។

ម្នាលភិក្ខុទាំងឡាយ ១០០ឆ្នាំ របស់មនុស្សត្រូវជា ១យប់ ១ ថ្ងៃ របស់តាវត្តឹង្សទេវតា រាប់រាត្រីនោះបាន ៣០ ត្រូវជា ១ ខែ រាប់ខែនោះ បាន ១២ ខែត្រូវជា ១ឆ្នាំ រាប់ឆ្នាំនោះបាន ១០០០ឆ្នាំទិព្យ ត្រូវជាប្រមាណ នៃអាយុរបស់តាវត្តឹង្សទេវតា ។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះ រមែងមាន ត្រង់ដែលស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ ចាំរក្សានូវឧបោសថ ប្រកបដោយអង្គ ៨ ប្រការ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកតាវត្តឹង្សទេវតា។ ម្នាលភិក្ខុទាំងឡាយ រាជសម្បត្តិរបស់មនុស្សនេះឯង ជារបស់ស្តួចស្តើង ហើយយកទៅប្រៀបធៀបនឹងសេចក្តីសុខ ជារបស់ទិព្វ ដែលតថាគតសម្តែងហើយ ព្រោះអាស្រ័យហេតុនេះឯង ។

ម្នាលភិក្ខុទាំងឡាយ ២០០ឆ្នាំរបស់មនុស្សត្រូវជា ១យប់ ១ ថ្ងៃ របស់ពួកយាមាទេវតា រាប់រាត្រីនោះ បាន ៣០រាត្រីត្រូវជា ១ ខែ រាប់ខែនោះបាន ១២ខែត្រូវជា ១ឆ្នាំ រាប់ឆ្នាំនោះបាន ២០០០ឆ្នាំទិព្វ ត្រូវជាប្រមាណនៃអាយុរបស់យាមទេវតា។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះ រមែងមាន ត្រង់ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ ចាំរក្សានូវឧបោសថប្រកបដោយអង្គ ៨ប្រការ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកយាមទេវតា ។ម្នាលភិក្ខុទាំងឡាយរាជសម្បត្តិរបស់មនុស្សនេះឯងជារបស់ស្តួចស្តើងហើយ

យកទៅប្រៀបធៀបនឹងសេចក្ដីសុខ ជារបស់ទិព្វ ដែលគថាគត សម្ដែងហើយ ព្រោះអាស្រ័យហេតុនេះឯង។

ម្នាលភិក្ខុទាំងឡាយ ៤០០ឆ្នាំមនុស្ស ត្រូវជា ១យប់ ១ថ្ងៃ របស់ពួកតុសិតទេវតា រាប់រាត្រីនេះ បាន ៣០រាត្រីត្រូវជា ១ខែ រាប់ខែនោះបាន ១២ ខែ ត្រូវជា ១ឆ្នាំ រាប់ឆ្នាំ នោះបាន ៤០០០ឆ្នាំ ទិព្យ ត្រូវជាប្រមាណនៃអាយុរបស់ពួកតុសិតទេវតា ។ ម្នាលភិក្ខុ ទាំងឡាយ ហេតុនេះរមែងមានត្រង់ដែលស្ត្រី ឬបុរស ពួកខ្លះក្នុង លោកនេះ ចាំរក្សាឧបោសថ ប្រកបដោយអង្គ ៨ ប្រការ លុះបែក ធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកតុសិតទេវ តា។ ម្នាលភិក្ខុទាំងឡាយ រាជសម្បត្តិរបស់មនុស្សនេះឯង ជារបស់ ស្ដួចស្ដើង ហើយយកទៅប្រៀបធៀបនឹងសេចក្ដីសុខ ជារបស់ ទិព្វ ដែលតថាគតសម្ដែងហើយ ព្រោះអាស្រ័យហេតុនេះឯង ។

ម្នាលភិក្ខុទាំងឡាយ ៨០០ឆ្នាំ របស់មនុស្ស ត្រូវជា ១ យប់ ១ ថ្ងៃ របស់ពួកនិម្មានរតីទេវតា រាប់រាត្រីនោះបាន ៣០ ត្រូវជា១ខែ រាប់ខែនោះ បាន ១២ខែ ត្រូវជា ១ឆ្នាំ រាប់ឆ្នាំនោះ បាន ៨០០០ឆ្នាំ ទិព្វ ត្រូវជាប្រមាណនៃអាយុរបស់ពួកនិម្មានរតីទេវតា។ ម្នាលភិក្ខុ ទាំងឡាយ ហេតុនេះរមែងមានត្រង់របស់ស្ត្រី ឬបុរសពួកខ្លះ ក្នុង លោកនេះ ចាំរក្សា នូវឧបោសថប្រកបដោយអង្គ ៨ប្រការ លុះបែ កធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកនិម្មានរតី

ទេវតា។ម្នាលភិក្ខុទាំងឡាយរាជសម្បត្តិរបស់មនុស្សនេះឯងជារបស់ស្តួចស្តើងហើយយកទៅប្រៀបធៀបនឹងសេចក្តីសុខជារបស់ទិព្វដែលតថាគតសម្តែងហើយ ព្រោះអាស្រ័យហេតុនេះឯង។

ម្នាលភិក្ខុទាំងឡាយ ១៦០០ឆ្នាំ របស់មនុស្ស ត្រូវជា ១ យប់ ១ ថ្ងៃ របស់ពួកបរនិម្មិតវសវត្តីទេវតា រាប់រាត្រីនោះ បាន ៣០ ត្រូវជា ១ខែ រាប់ខែនោះបាន ១២ ខែ ត្រូវជា ១ឆ្នាំ រាប់ឆ្នាំនោះបាន ១៦០០០ឆ្នាំទិព្វ ត្រូវជាប្រមាណនៃអាយុរបស់ពួកបរនិម្មិតវសវត្តីទេវតា។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះ រមែងមានត្រង់ដែលស្ត្រី ឬបុរសពួកខ្លះ ក្នុងលោកនេះ ចាំរក្សានូវឧបោសថប្រកបដោយអង្គ ៨ប្រការ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកបរនិម្មិតវសវត្តីទេវតា។ ម្នាលភិក្ខុទាំងឡាយ រាជសម្បត្តិរបស់មនុស្សនេះឯង ជារបស់ស្តួចស្តើង ហើយយកទៅប្រៀបធៀបនឹងសេចក្តីសុខ ជារបស់ទិព្វ ដែលតថាគតសម្តែងហើយ ព្រោះអាស្រ័យហេតុនេះឯង។

បុគ្គលមិនគប្បីសម្លាប់សត្វ១ មិនគប្បីកាន់យកវត្ថុដែលគេមិនបានឲ្យ ១ មិនគប្បីពោលពាក្យកុហក១ មិនគប្បីផឹកទឹកស្រវឹង១ គប្បីវៀរចាកការប្រព្រឹត្តមិនប្រសើរ គឺមេថុន១ មិនគប្បីបរិភោគភោជន ក្នុងវេលារាត្រី និងក្នុងវេលាវិកាល១ មិនគប្បីទ្រទ្រង់ផ្កាកម្រង មិនគប្បីប្រស់ព្រំដោយគ្រឿងក្រអូប១ គប្បីដេកលើគ្រែ

លើផែនដី ឬលើកម្រាល១ ព្រះពុទ្ធព្រះអង្គ ដល់នូវទីបំផុតនៃទុក្ខ ទ្រង់ប្រកាសហើយ នូវឧបោសថដែលប្រកបដោយអង្គ ៨ ប្រការ នេះឯង សភាវៈទាំងឡាយ ពីរគឺ ព្រះចន្ទ១ ព្រះអាទិត្យ១ ជាសភាវៈ ល្អមើល កាលបំភ្លឺលោក រមែងចរទៅអស់ទីត្រឹមណា ព្រះចន្ទនិង ព្រះអាទិត្យ ទាំងនោះ ដែលកម្ចាត់បង់នូវងងឹត ចរក្នុងអាកាស ញុំាងទិសឲ្យរុងរឿងភ្លឺច្បាស់ ក្នុងអាកាសអស់ទីត្រឹមនោះ ទ្រព្យ ណា មានក្នុងចន្លោះនេះ គឺកែវមុក្តាក្តី កែវមណីក្តី កែវពិទូរ្យដ៏ល្អក្តី មាសឈ្មោះសិង្គីក្តី ឈ្មោះសុវណ្ណក្តី ឬមាសឈ្មោះកាញ្ចនៈក្តី ឈ្មោះជាតរូបក្តី ឈ្មោះហដកៈក្តី ទ្រព្យទាំងអម្បាលនោះ មិនដល់ នូវចំណិត១ ក្នុងចំណែក ១៦ៗ លើកនេះឧបោសថដែលប្រកប ដោយអង្គ៨ ប្រការឡើយ ដូចជាពួកផ្កាយទាំងអស់មិនដល់នូវពន្លឺ នៃព្រះចន្ទ ហេតុដូច្នោះ ស្ត្រីក្តី បុរសក្តី ជាអ្នកមានសីល គួរចាំរក្សា នូវឧបោសថប្រកបដោយ អង្គ៨ ប្រការពួកជន ដែលមិនមានគេ និន្ទា បំពេញនូវបុណ្យទាំងឡាយ ដែលមានសេចក្តីសុខជាកម្រៃ រមែងចូលទៅកាន់ឋានសួគ៌បាន ។

(បិដកលេខភាគ៤៨ ទំព័រ ១៨៨-១៩៥)

## ធម៌ដែលនាំឱ្យមានសេចក្តីចម្រើន ៨ប្រការ

១-សេពគប់ជាមួយសប្បុរស សប្បុរសជាមនុស្សស្ងប់ ប្រព្រឹត្តសុចរិតដោយកាយ វាចា ចិត្ត ជាអ្នកគោរពច្បាប់ មានភូមិ

ធម៌ មានភូមិបញ្ញា គួរដល់ការគោរពរាប់អាន។ មនុស្សដែលមិនរឹងត្អឹង មិនចចេសមុខរឹង បានជ្រើសរើសយកសប្បុរសជាកល្យាណមិត្ត សេពគប់ជិតដិត។ មនុស្សមិនរឹងត្អឹងមានបំណងកសាងខ្លួនឲ្យបានជាមនុស្សល្អ រមែងស្វែងរកនូវសប្បុរសសម្រាប់រំលឹកដាស់តឿនខ្លួនរកទីប្រឹក្សាល្អមិត្តល្អ សៀវភៅល្អរហូតដល់បរិយាកាសសង្គមជុំវិញខ្លួនក៏ល្អទៀតផង ដើម្បីជាឧបការៈឲ្យមានបញ្ញាស្មារតី។

២-ស្តាប់ធម៌របស់សប្បុរស ការសេពគប់ជាមួយសប្បុរសដើម្បីឲ្យបាននូវប្រយោជន៍ គឺត្រូវស្តាប់នូវព្រះធម៌ដោយការយកចិត្តទុកដាក់ ស្តាប់ក្រេបយកនូវអត្ថរសអំពីន័យសំខាន់ៗ ជាគ្រឿងដាស់ស្មារតីខ្លួនឲ្យភ្ញាក់រលឹក ទាំងស្តាប់អំពីបុគ្គលផ្ទាល់ ទាំងអានសៀវភៅ តាំងចិត្តរៀន ស្រាវជ្រាវសន្ទនាសាកសួរ ធ្វើឲ្យមានការចេះដឹងពិតប្រាកដ។

៣-ធ្វើទុក្ខក្នុងចិត្តដោយឧបាយត្រូវទំនង បានឃើញបានឮបានអាន បានស្តាប់ រួចហើយក៏ចេះគិតពិចារណាដោយខ្លួនឯងវែកញែករកហេតុផលថា នុ៎ះគឺអ្វី កើតឡើងបានយ៉ាងណា ដូច

ម្ដេចបានជាយ៉ាងហ្នឹង តើហេតុផលនេះវាសមគ្នាដែរឬទេ ដូចនេះជាដើម។

៤-បដិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ គឺបដិបត្តិត្រឹមត្រូវតាមគោលរបស់ព្រះធម៌ នាំយកធម៌ដែលបានស្ដាប់បានរៀន និងបានត្រិះរិះឃើញច្បាស់ហើយ មកបដិបត្តិកម្ចាត់ភាពសៅហ្មងក្នុងសន្ដាន។ ការបដិបត្តិជាការងារនាំមកនូវផល ដែលផលរមែងសមស្របទៅតាមការងារជាហេតុដោយពិត។

(អង្គុត្តរនិកាយ ចតុក្កនិបាត)

# ទិដ្ឋធម្មិកត្ថ៤យ៉ាង

(ប្រយោជន៍បច្ចុប្បន្ន)

សម្បទា ៤ យ៉ាង សម្រាប់គ្រហស្ថអ្នកគ្រប់គ្រងផ្ទះ ឲ្យមានការប្រតិបត្តិដើម្បីសុខចម្រើនកើតសុភមង្គលក្នុងគ្រួសារគឺ៖

**១-ឧដ្ឋានសម្បទា** មានន័យថា ខ្លួនយើងត្រូវព្យាយាមរកស៊ីទាំងយប់ ទាំងថ្ងៃមិនខ្ជិលច្រអូស ប្រកបដោយឧបាយជាគ្រឿងពិចារណាក្នុងការងារទាំងនោះ ហើយគួរធ្វើ គួរចាត់ចែង ។ កាលបើយើងខ្ជិលរកស៊ី គិតតែពីដើរលេងគ្មានស្គាល់ថ្ងៃយប់នេះ ជាប្រធាននៃសេចក្ដីវិនាស សុភមង្គលក្នុងគ្រួសាររបស់យើង មិនអាច

ចម្រើនរុងរឿងទៅបានឡើយ ព្រោះហេតុនោះ យើងត្រូវមានសតិដាស់តឿនខ្លួនឯងថា អាត្មាអញមិនមែននៅកម្លោះក្រមុំ ដូចពីមុនទេ គឺអញមានប្តីប្រពន្ធហើយ ដូច្នេះអញត្រូវធ្វើខ្លួនឲ្យសមជាអ្នកមានគ្រួសារមួយដ៏ល្អ មិនគួរធ្វើជាអ្នកអារ៉ាំសែ ដូចបុគ្គលពាលឡើយ ត្រូវតែព្យាយាមរកស៊ីដើម្បីឲ្យមានទ្រព្យធន ដើម្បីចិញ្ចឹមប្រពន្ធ ប្តីឲ្យបានសេចក្តីសុខ ។

២-**អារក្ខសម្បទា** បានន័យថា កាលរកលុយកាក់បានមកហើយ ត្រូវសន្សំទុកឲ្យបាលល្អ ត្រូវចេះបែងចែកឲ្យបានសមគួរ មានចំណាយលើម្ហូបប្រចាំថ្ងៃ របស់របរសម្រាប់ប្រើប្រាស់ក្នុងផ្ទះ ចិញ្ចឹមឪពុកម្តាយ ធ្វើបុណ្យជាដើម ។ កាលបើយើងបែងចែកបានល្អនោះ លុយកាក់របស់យើងនឹងគង់វង្សសម្រាប់តម្កល់ទុកទៅខាងមុខ ។ ដូច្នេះលុយកាក់ដែលយើងខំព្យាយាមរកមកទាំងយប់ទាំងថ្ងៃនោះ យើងត្រូវដឹងថាជាការលំបាកណាស់ទម្រាំបានមក បើយើងធ្វើការរាជការត្រូវដឹងថា វាហត់នឿយលំបាកខួរក្បាលដោយសារសការគិត ។ បើលក់ដូរក៏លំបាកក្នុងការចំណេញបានមួយពាន់ពីរពាន់ ដូច្នេះយើងមិនគួរចំណាយទៅលើអ្វី ៗ ដែលឥតប្រយោជន៍ដូចជា ខ្ជះខ្ជាយមិនដឹងប្រមាណឬយកទៅលេងល្បែងភ្នាល់ជាដើម ។ ចំណែកយើងជាស្ត្រីកុំឲ្យដូចជាពាក្យខ្មែរបុរាណពោលថា "ស្រីកញ្ជើធ្លុះ" ឡើយ ។ ក្នុងរឿង មារយើង

មានពេលពីនាងកញ្ជើធ្លុះថា នាងមិនបានថែរក្សានូវគ្រឿ កំពីស ដែលប្តីបានមកនោះទេ គិតតែពីយកឈើចាក់ក្រញ្ជែងឲ្យធ្លុះ ធ្លាក់គ្រឿកំពីសអស់ ដែលបានន័យថា ស្ត្រីខ្លះក្នុងលោកនេះពេលដែលប្តីរកទ្រព្យបានមកខ្លួនមិនខំថែរក្សាឲ្យបានល្អ គិតតែចាយវាយឥតដឹងមុខ ធ្វើឲ្យទ្រព្យនោះអស់រលីង ដល់ពេលមានកិច្ចចាំបាច់រកប្រាក់គ្មាន ព្រោះហេតុនោះចាស់ ៗ តែងថា "មេស្រីកញ្ជើធ្លុះ"។ ហេតុនោះឯង មិនថា ស្ត្រីឬបុរសទេ យើងមានភារកិច្ចជួយគ្នា ថែរក្សាទ្រព្យសម្បត្តិដែលរកបានមក ហើយឲ្យនៅគង់វង្សមិនឲ្យវិនាសបាត់បង់ដោយប្រការណាមួយឡើយ ។

**៣-កល្យាណមិត្តតា** បានន័យថា ត្រូវចេះសេពគប់មិត្តណាមានប្រយោជន៍ ជាមិត្តនាំមកនូវសេចក្តីសុខចម្រើន ដល់គ្រួសារយើង មិនមែនជាមិត្តប្លម មិត្តពាលដើរកាន់អាវ៉ាសែនោះឡើយ ។ បើក្នុងភូមិណា មានអ្នកមានសីល បរិបូណ៌ដោយសទ្ធា បរិបូណ៌ដោយចាគៈ បរិបូណ៌ដោយបញ្ញា យើងត្រូវចូលទៅសាកសួរសាកច្ឆាជាមួយជនទាំងនោះទោះជាក្មេងក៏ដោយចាស់ក៏ដោយយើងត្រូវដឹងថាអ្នកទាំងនោះជាកល្យាណមិត្តដ៏ប្រសើររបស់យើង។

**៤-សមជីវិតា** បានន័យថា ចិញ្ចឹមជីវិតស្មើ គឺថា យើងចេះដឹងការវិនាសទៅនៃភោគៈដោយហេតុនេះ ការចម្រើនភោគៈដោយហេតុនេះ ហើយចេះបរិភោគមិនត្បិតត្បៀតពេក មិនខ្ជះ

ខ្វាយពេក គួរបរិភោគឲ្យសមល្មមនឹងភោគៈដែលខ្លួនមាន មិនមែនខ្លួនជាអ្នកមាន តែទៅហូបរបស់សៅហ្មងមិនឆ្ងាញ់ ដូចជាមនុស្សថាំពេកមើលតែមិនមានលុយទិញហូប។ បើខ្លួនជាអ្នកទាល់ក្រ ហើយស្រាប់តែចំណាយហួសប្រមាណដូចភាសិតថា "ស៊ីដូចមុស ជុះដូចដំរី" នេះក៏មិនត្រូវដែរ។ កាលបើលុយកាក់មានដោយខំប្រឹងរកស៊ី អស់កម្លាំងល្ងិតល្ងៃទាំងថ្ងៃទាំងយប់ ហើយមានលុយកាក់ល្មមគ្រាន់បើហើយយើង មិនហ៊ានហូបចុកទៀត ហាក់ដូចជាអ្នកក្រមិនមានទ្រព្យសោះ អ្នកប្រាជ្ញលោកឲ្យឈ្មោះថា "អ្នកកំណាញ់ក្រៅតម្រា" ។

# មង្គលសូត្រ៣៨ប្រការ

ឯវមេ សុត្តំ (សូត្រនេះឈ្មោះមង្គលសូត្រ) គឺខ្ញុំ (ឈ្មោះអានន្ទ បានស្តាប់មកហើយយ៉ាងនេះថា) **ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ** សម័យមួយព្រះដ៏មានព្រះភាគទ្រង់គង់នៅ ក្នុងវត្តជេតពន ជាអារាមរបស់អានាថបណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ **អថខោ អញ្ញតរា ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ ជេតវនំ ឱភាសេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ** លំដាប់នោះឯង ទេវតាអង្គ១ កាល

ដែលវេលារាត្រីបឋមយាម កន្លងទៅហើយ មានរស្មីដ៏ល្អមញាំង វត្តជេតពន ជុំវិញទាំងអស់ឲ្យភ្លឺស្វាង ហើយព្រះដ៏មានព្រះភាគ ទ្រង់គង់ក្នុងទីណា ក៏ចូលទៅក្នុងទីនោះ លុះចូលទៅដល់ហើយ ទើបថ្វាយបង្គំចំពោះព្រះអង្គដ៏មានព្រះភាគ ហើយឈរនៅក្នុងទីដ៏ សមគួរ **ឯកមន្តំ ឋិតា ខោសា ទេវតា ភគវន្តំ គាថាយ អជ្ឈ ភាសិ** កាលទេវតានោះឈរក្នុងទីដ៏សមគួរហើយ ទើបក្រាបទូល ព្រះដ៏មានព្រះភាគដោយពាក្យជាគាថា (យ៉ាងនេះ) ថា៖

**ពហូ ទេវា មនុស្សា ច មង្គលានិ អចិន្តយុំ**

**អាកង្ខមានា សោត្ថានំ ព្រូហិ មង្គលមុត្តមំ។**

ទេវតានិងមនុស្សទាំងឡាយជាច្រើន ប្រាថ្នានូវសេចក្តីសួស្តី បានគិតរកនូវមង្គលទាំងឡាយ សូមព្រះអង្គទ្រង់ព្រះមេត្តាសំដែងប្រាប់នូវមង្គលដ៏ឧត្តម។ (**ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដែងតបពាក្យទេវតានោះដោយពុទ្ធភាសិតជាគាថាយ៉ាងនេះថា៖**)

**អសេវនា ច ពាលានំ បណ្ឌិតានញ្ច សេវនា**

**បូជា ច បូជនីយានំ ឯតម្មង្គលមុត្តមំ។**

កិរិយាមិនសេពគប់ នូវបុគ្គលពាលទាំងឡាយ១ កិរិយាសេពគប់នូវបុគ្គលជាបណ្ឌិតទាំងឡាយ១ កិរិយាបូជាដល់បុគ្គល ដែលគួរបូជាទាំងឡាយ១ ទាំង៣នេះ ជាមង្គលដ៏ឧត្តម។

**បដិរូបទេសវាសោ ច បុព្វេ ច កតបុញ្ញ**

**តា អត្តសម្មាបណីធិ ច ឯតម្មង្គលមុត្តមំ។**

កិរិយានៅក្នុងប្រទេសដ៏សមគួរ១ ភាវៈនៃបុគ្គលបានធ្វើបុណ្យទុកហើយក្នុងកាលមុន១ កិរិយាដំកល់ខ្លួនដោយប្រពៃ១ ទាំង៣នេះ ជាមង្គលដ៏ឧត្តម។

**ពាហុសច្ចញ្ច សិប្បញ្ច វិនយោ ច សុសិក្ខិតោ**

**សុភាសិតា ច យា វាចា ឯតម្មង្គលមុត្តមំ។**

ភាវៈនៃបុគ្គលបានស្តាប់ បានរៀនហើយដោយច្រើន១ សិល្បសាស្ត្រគឺសេចក្តីឆ្លៀវឆ្លាស់ក្នុងហត្ថកម្ម របស់អ្នកបួសនិងគ្រហស្ថ១ វិន័យដែលបុគ្គលសិក្សាដោយប្រពៃ១ វាចាដែលបុគ្គលពោលត្រឹមត្រូវ១ ទាំង៤នេះ ជាមង្គលដ៏ឧត្តម។

**មាតាបិតុឧបដ្ឋានំ បុត្តទារស្ស សង្គហោ**

**អនាកុលា ច កម្មន្តា ឯតម្មង្គលមុត្តមំ។**

កិរិយាបំរើនូវមាតា១ កិរិយាបំរើនូវបិតា១ សេចក្តីសង្គ្រោះដល់បុត្រនិងភរិយា១ ការងារទាំងឡាយដែលមិនច្របូកច្របល់១ ទាំង៤នេះ ជាមង្គលដ៏ឧត្តម។

**ទានញ្ច ធម្មចរិយា ច ញាតិកានញ្ច**

**សង្គហោ អនវជ្ជានិ កម្មានិ ឯតម្មង្គលមុត្តមំ។**

កិរិយាបរិច្ចាគទាន១ កិរិយាប្រព្រឹត្តនូវធម៌១ សេចក្តីសង្គ្រោះដល់ញាតិទាំងឡាយ១ ការងារទាំងឡាយដែលមិនមានទោស១ ទាំង៤នេះ ជាមង្គលដ៏ឧត្តម។

**អារតី វិរតី បាបា មជ្ជបានា ច សញ្ញមោ**

**អប្បមាទោ ច ធម្មេសុ ឯតម្មង្គលមុត្តមំ។**

កិរិយាមិនត្រេកអរក្នុងបាប និងកិរិយាវៀរចាកបាប១ សេចក្តីសង្រួមចាកកិរិយាផឹកនូវទឹកស្រវឹង១ សេចក្តីមិនប្រមាទក្នុងធម៌ទាំងឡាយ១ ទាំង៣នេះ ជាមង្គលដ៏ឧត្តម។

**គារវោ ច និវាតោ ច សន្តុដ្ឋី ច កតញ្ញុតា**

**កាលេន ធម្មស្សវនំ ឯតម្មង្គលមុត្តមំ។**

សេចក្តីគោរពចំពោះបុគ្គល ដែលគួរគោរព១ កិរិយាប្រព្រឹត្តបន្ទាបនូវខ្លួន១ សេចក្តីត្រេកអរចំពោះរបស់ដែលមាន១ ភាវៈនៃបុគ្គលអ្នកដឹងនូវឧបការៈ ដែលអ្នកដទៃធ្វើហើយដល់ខ្លួន១ កិរិយាស្តាប់នូវធម៌តាមកាល១ ទាំង៥នេះ ជាមង្គលដ៏ឧត្តម។

**ខន្តី ច សោវចស្សតា សមណានញ្ច ទស្សនំ**

**កាលេន ធម្មសាកច្ឆា ឯតម្មង្គលមុត្តមំ។**

សេចក្តីអត់ធន់១ ភាវៈនៃបុគ្គលដែល គេប្រដៅបានដោយងាយ១ កិរិយាបានឃើញបានជួបនូវសមណៈទាំងឡាយ១ ធម្ម

សាកច្ឆាគឺកិរិយាសន្ទនាទៅវិញទៅមក នូវធម៌តាមកាល១ ទាំង៤នេះ ជាមង្គលដ៏ឧត្តម។

**តបោ ច ព្រហ្មចរិយញ្ច អរិយសច្ចាន**

**ទស្សនំ និព្វានសច្ឆិកិរិយា ច ឯតម្មង្គលមុត្តមំ។**

សេចក្តីព្យាយាមដុតនូវបាបធម៌១ កិរិយាប្រព្រឹត្តនូវធម៌ដ៏ប្រសើរ១ កិរិយាឃើញនូវអរិយសច្ចៈទាំងឡាយ១ កិរិយាធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន១ ទាំង៤នេះ ជាមង្គលដ៏ឧត្តម។

**ផុដ្ឋស្ស លោកធម្មេហិ ចិត្តំ យស្ស ន**

**កម្បតិ អសោកំ វិរជំ ខេមំ ឯតម្មង្គលមុត្តមំ។**

ចិត្តនៃបុគ្គលឯណា ដែលលោកធម៌ទាំងឡាយពាល់ត្រូវហើយមិនរំភើបញាប់ញ័រ១ មិនមានសេចក្តីសោក១ មានធុលីគឺរាគៈទៅប្រាសហើយ១ ជាចិត្តក្សេមក្សាន្ត១ ទាំង៤នេះ ជាមង្គលដ៏ឧត្តម។

**ឯតាទិសានិ កត្វាន សព្វត្ថមបរាជិតា សព្វត្ថ សោត្ថឹ**

**គច្ឆន្តិ តន្តេសំ មង្គលមុត្តមន្តិ។**

ទេវតានិងមនុស្សទាំងឡាយ ធ្វើនូវមង្គលទាំងឡាយ ប្រាកដដូច្នេះ ហើយជាអ្នកមិនចាលចាញ់ក្នុងទីទាំងពួងតែងដល់នូវសេរីសួស្តីក្នុងទីទាំងពួង(ម្នាលទេវតា ចូរអ្នកប្រកាន់ជឿថា) មង្គលទាំង៣៨ប្រការ មានកិរិយាមិនសេពគប់ នូវបុគ្គលពាលជាដើមនោះ របស់ទេវតានិងមនុស្សទាំងអម្បាលណោះ ជាមង្គលដ៏ឧត្តម។ (ចប់)

# បរាភវសូត្រ (សង្ខេប)

ខ្ញុំ(ឈ្មោះអានន្ទ)បានស្តាប់មកយ៉ាងនេះថា សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិក សេដ្ឋី ជិតក្រុងសាវត្ថី។ គ្រានោះឯង ទេវតា១អង្គ កាលដែលរាត្រី បឋមយាមកន្លងទៅហើយ មានរស្មីដ៏រុងរឿង ញុំាងវត្តជេតពនជុំ វិញទាំងអស់ឲ្យភ្លឺស្វាងហើយ ក៏ចូលទៅគាល់ព្រះមានព្រះភាគ។ លុះចូលទៅដល់ ទេវតានោះបានក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយស្ថិតក្នុងទីសមគួរ ទើបក្រាបបង្គំទូលដោយគាថាដូច្នេះថា យើងទាំងឡាយមកដើម្បីសួរព្រះគោតមដ៏ចម្រើន ដោយគិតថា យើងទាំងឡាយសូមសួរអំពីបុរសបុគ្គលដែលមានសេចក្តីវិនាស ចុះអ្វីជាប្រធាននៃសេចក្តីវិនាស?

ព្រះមានព្រះភាគទ្រង់ត្រាស់សម្តែងថា៖

១-ព្រះមានព្រះភាគត្រាស់ថា បុរសដែលចម្រើន ជាបុគ្គលគឺ បណ្ឌិតដឹងបានដោយងាយ បុរសដែលវិនាស ជាបុគ្គលគឺបណ្ឌិតដឹង បានដោយងាយដែរ បុគ្គលអ្នកប្រាថ្នាធម៌ រមែងចម្រើន អ្នកស្អប់ធម៌ រមែងវិនាស។ ទេវតាក៏បានទូលតបថា យើងទាំងឡាយដឹងច្បាស់នូវ

ហេតុនុ៎ះថា នោះជាសេចក្តីវិនាសទី១បពិត្រព្រះមានព្រះភាគសូមព្រះអង្គសម្តែងនូវហេតុទី២អ្វីជាប្រធាននៃសេចក្តីវិនាស។

២-ព្រះអង្គត្រាស់បន្តថា បុគ្គលមានពួកអសប្បុរសជាទីស្រឡាញ់ មិនធ្វើសេចក្តីស្រឡាញ់ចំពោះពួកសប្បុរស ពេញចិត្តចំពោះធម៌របស់ពួកអសប្បុរស នោះជាប្រធាននៃសេចក្តីវិនាស។ ទេវតាទូលថា យើងទាំងឡាយដឹងច្បាស់នូវហេតុនុ៎ះថា នោះជាសេចក្តីវិនាសទី២បពិត្រព្រះមានព្រះភាគសូមព្រះអង្គសម្តែងនូវហេតុទី៣អ្វីជាប្រធាននៃសេចក្តីវិនាស។

៣-ព្រះអង្គត្រាស់ថា ជនអ្នកដេកលក់ច្រើនក្តី និយាយច្រើនក្តី មិនខ្មីឃ្មាតក្តី ខ្ជិលច្រអូសក្តី ប្រាកដតែខាងក្រោធក្តី នោះជាប្រធាននៃសេចក្តីវិនាស។ ទេវតាទូលថា យើងទាំងឡាយដឹងច្បាស់នូវហេតុនុ៎ះថា នោះជាសេចក្តីវិនាសទី៣បពិត្រព្រះមានព្រះភាគសូមព្រះអង្គសម្តែងនូវហេតុទី៤អ្វីជាប្រធាននៃសេចក្តីវិនាស។

៤-ព្រះអង្គត្រាស់ថា បុគ្គលជាអ្នកស្តុកស្តម្ភ តែមិនចិញ្ចឹមមាតាក្តី បិតាក្តី ដែលចាស់ មានវ័យកន្លងហើយ នោះជាប្រធាននៃសេចក្តីវិនាស។ ទេវតាទូលថា យើងទាំងឡាយដឹងច្បាស់នូវហេតុនុ៎ះ

ថា នោះជាសេចក្តីវិនាសទី៤បពិត្រព្រះមានព្រះភាគ សូមព្រះអង្គសម្តែងនូវហេតុទី៥ អ្វីជាប្រធាននៃសេចក្តីវិនាស។

៥-ព្រះអង្គត្រាស់ថា បុគ្គលបញ្ឆោតព្រាហ្មណ៍ក្តី សមណៈក្តី ឬអ្នកសូមដទៃក្តី ដោយពាក្យកុហក នោះជាប្រធាននៃសេចក្តីវិនាស។ ទេវតាទូលថា យើងទាំងឡាយដឹងច្បាស់នូវហេតុនុ៎ះថា នោះជាសេចក្តីវិនាសទី៥ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គសម្តែងនូវហេតុទី៦ អ្វីជាប្រធាននៃសេចក្តីវិនាស។

៦-ព្រះអង្គត្រាស់ថា បុរសបុគ្គល មានទ្រព្យជាគ្រឿងគ្រេកអរច្រើន មានប្រាក់ សម្បូណ៌ភោជន បរិភោគនូវភោជនមានរសឆ្ងាញ់តែម្នាក់ឯង នោះជាប្រធាននៃសេចក្តីវិនាស។ ទេវតាទូលថា យើងទាំងឡាយដឹងច្បាស់នូវហេតុនុ៎ះថា នោះជាសេចក្តីវិនាសទី៦ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គសម្តែងនូវហេតុទី៧ អ្វីជាប្រធាននៃសេចក្តីវិនាស។

៧-ព្រះអង្គត្រាស់ថា ជនដែលរឹងត្អឹងដោយអាងជាតិក្តី រឹងត្អឹងដោយអាងទ្រព្យក្តី រឹងត្អឹងដោយអាងគោត្រកូលក្តី ហើយមើលងាយញាតិរបស់ខ្លួន នោះជាប្រធាននៃសេចក្តីវិនាស។ ទេវតាទូលថា យើងទាំងឡាយដឹងច្បាស់នូវហេតុនុ៎ះថា នោះជាសេច

ក្តីវិនាសទី៧ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គសម្តែងនូវហេតុទី៨ អ្វីជាប្រធាននៃសេចក្តីវិនាស។

៨-ព្រះអង្គត្រាស់ថា ជនជាអ្នកលេងស្រីក្តី លេងសុរាក្តី លេងល្បែងភ្នាល់ក្តី រមែងញ៉ាំងទ្រព្យ ដែលខ្លួនបានហើយៗ ឲ្យវិនាសទៅ នោះជាប្រធាននៃសេចក្តីវិនាស។ ទេវតាទូលថា យើងទាំងឡាយដឹងច្បាស់នូវហេតុនុ៎ះថា នោះជាសេចក្តីវិនាសទី៨ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គសម្តែងនូវហេតុទី៩ អ្វីជាប្រធាននៃសេចក្តីវិនាស។

៩-ព្រះអង្គត្រាស់ថា “ជនមិនត្រេកអរនឹងប្រពន្ធរបស់ខ្លួនទៅខូចចំពោះពួកស្រីពេស្យា ឬខូចចំពោះប្រពន្ធនៃបុគ្គលដទៃ នោះជាប្រធាននៃសេចក្តីវិនាស”។ ទេវតាទូលថា យើងទាំងឡាយដឹងច្បាស់នូវហេតុនុ៎ះថា នោះជាសេចក្តីវិនាសទី៩ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គសម្តែងនូវហេតុទី១០ អ្វីជាប្រធាននៃសេចក្តីវិនាស។

១០-ព្រះអង្គត្រាស់ថា “បុរសមានវ័យកន្លងហើយ នាំយកស្ត្រីក្មេងដែលមានដោះក្បំ ដូចជាផ្លែទន្លាប់ រមែងដេកមិនលក់ព្រោះសេចក្តីប្រចណ្ឌចំពោះស្ត្រីនោះ នោះជាប្រធាននៃសេចក្តី

វិនាស"។ ទេវតាទូលថា យើងទាំងឡាយដឹងច្បាស់នូវហេតុនុ៎ះថា នោះជាសេចក្តីវិនាសទី១០បពិត្រព្រះមានព្រះភាគសូមព្រះអង្គសម្តែងនូវហេតុទី១១អ្វីជាប្រធាននៃសេចក្តីវិនាស។

១១-ព្រះអង្គត្រាស់ថា "បុរសបុគ្គល តាំងស្ត្រីអ្នកលេងខ្ជះខ្ជាយ ឬបុរសបែបនោះដែរ ក្នុងឋានៈជាធំ នោះជាប្រធាននៃសេចក្តីវិនាស"។ ទេវតាទូលថា យើងទាំងឡាយដឹងច្បាស់នូវហេតុនុ៎ះថា នោះជាសេចក្តីវិនាសទី១១ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គសម្តែងនូវហេតុទី១២ អ្វីជាប្រធាននៃសេចក្តីវិនាស។

១២-ព្រះអង្គត្រាស់ថា"បុគ្គលដែលកើតក្នុងខត្តិយត្រកូលមានភោគៈតិចតែមានសេចក្តីប្រាថ្នាធំ ទៅប្រាថ្នារជ្ជសម្បត្តិ នោះជាប្រធាននៃសេចក្តីវិនាស"។

បុគ្គលជាបណ្ឌិត បរិបូណ៌ដោយការឃើញដ៏ប្រសើរ ពិចារណាឃើញច្បាស់នូវសេចក្តីវិនាសទាំងនុ៎ះក្នុងលោក បណ្ឌិតនោះរមែងគប់រកនូវលោក ដែលមានសេចក្តីសុខដ៏ក្សេមក្សាន្ត។

"ចប់ បរាភវសូត្រ"

(បិដកលេខ៥៤ ទំព័រ៣៦)

# “ ធម្មបទ ”



# គាថាធម្មបទ

ប្រារព្ធចំពោះសញ្ជ័យជាគ្រូដើមរបស់ព្រះអគ្គសាវ័កទាំងពីរ

(បិដកលេខ៥២ទំព័រ២៣)

**អសារេ សារមតិនោ សារេ ចាសារទស្សិនោ**

**តេ សារំ នាធិគច្ឆន្តិ មិច្ឆាសង្កប្បគោចរា ។**

ជនទាំងឡាយ ដែលយល់ឃើញក្នុងធម៌មានខ្លឹម ថាជាធម៌មិនមានខ្លឹមផងជាអ្នកមានតម្រិះខុសជាអារម្មណ៍រមែងមិនបាននូវធម៌ដែលមានខ្លឹមឡើយ។



# គាថាធម្មបទ

(បិដកលេខ៥២ ទំព័រ៤៩)

**សព្វេ តសន្តិ ទណ្ឌស្ស សព្វេ ភាយន្តិមច្ចុនោ**
**អត្តានំ ឧបមំ កត្វា ន ហនេយ្យ ន ឃាតយេ។**

សត្វទាំងឡាយគ្រប់ប្រាណ តែងតក់ស្លុតនឹងអាជ្ញា សត្វទាំងឡាយតែងខ្លាចចំពោះសេចក្តីស្លាប់គ្រប់ៗរូបបុគ្គល គួរធ្វើខ្លួនឲ្យជាឧបមា ហើយមិនគួរប្រហារដោយខ្លួនឯងមិនគួរប្រើគេឲ្យប្រហារឡើយ។



# គាថាធម្មបទ

(បិដកលេខ៥២ ទំព័រ៤៩-៥០)

**សុខកាមានិ ភូតានិ យោទណ្ឌេនវិហឹសតិ អត្តនោសុខមេសានោបេច្ច សោនលភតេសុខំ ។សុខកាមានិ ភូតានិ យោទណ្ឌេន នហឹសតិ អត្តនោសុខមេសានោបេច្ច សោលភតេសុខំ។**

ជនណា ស្វែងរកសេចក្ដីសុខ ដើម្បីខ្លួន តែបៀតបៀនសត្វទាំងឡាយ ដែលប្រាថ្នាសេចក្ដីសុខ ដោយអាជ្ញា ជននោះលះលោកនេះទៅហើយនឹងមិនបានសេចក្ដីសុខឡើយ ។ ជនណា ស្វែងរកសេចក្ដីសុខ ដើម្បីខ្លួន តែមិនបៀតបៀនសត្វទាំងឡាយ ដែលប្រាថ្នាសេចក្ដីសុខ ដើម្បីខ្លួន ដោយអាជ្ញា ជននោះលះលោកនេះទៅហើយ រមែងបានសេចក្ដីសុខ។



# គាថាធម្មបទ

**មាវោ ច ផរុសំ កញ្ចិ វុត្តា បដិវទេយ្យុ តំ ទុក្ខា ហិ សារម្ភកថា បដិទណ្ឌា ផុសេយ្យុ តំ។ សចេ នេរេសិ អត្តានំ កំសោ ឧបហតោ យថា ឯស បត្តោសិ និព្វានំ សារម្ភោ តេ ន វិជ្ជតិ។**

អ្នកកុំនិយាយពាក្យអាក្រក់នឹងអ្នកណាមួយឡើយ ជនទាំងឡាយដែលអ្នកស្តីថាឲ្យហើយ គេគប្បីស្តីថាតបមកអ្នកវិញ ព្រោះថាការពោលពាក្យប្រណាំងប្រជែង ជាហេតុនាំឲ្យកើតទុក្ខអាជ្ញាតប ត្រូវបានធ្លាក់ចុះមកប៉ះពាល់ដល់អ្នកវិញ ។ បើអ្នកធ្វើខ្លួនមិនឲ្យញាប់ញ័រ ដូចរគាំងដែលចៀរមាត់ចេញហើយ (រមែងមិនលាន់ឮសូរ ) ដូច្នោះ អ្នកនុះជាបុគ្គលដល់នូវព្រះនិព្វាន ការប្រណាំងប្រជែង មិនមានដល់អ្នកឡើយ ។

(បិដកលេខ៥២ ទំព័រ៥០)



# គាថាធម្មបទ

**យថា ទណ្ឌេន គោបាលោ គាវោ បាជេតិ គោចរំ ឯវំ ជរា ច មច្ចុ ច អាយុំ បាជេន្តិ បាណិនំ។**

គង្វាលគោរមែងកៀងគោទៅកាន់ទីគោចរដោយអាជ្ញាដូម្តេច មិញ ជរានិងមច្ចុ តែងកៀងអាយុរបស់សត្វទាំងឡាយដូច្នោះឯង។

**អថ បាបានិ កម្មានិ ករំ ពាលោ ន ពុជ្ឈតិ សេហិ កម្មេហិ ទុម្មេធោ អគ្គិទឌ្ឍោវ តប្បតិ។**

បុគ្គលពាល កាលធ្វើអំពើអាក្រក់ទាំងឡាយ រមែងមិនភ្ញាក់ខ្លួនឡើយ (លុះកាលជាខាងក្រោយ) បុគ្គលអប្បប្រាជ្ញានោះទើបក្តៅក្រហាយ ដោយសារកម្មរបស់ខ្លួនឯងដូចជាត្រូវភ្លើងឆេះ។

(បិដកលេខ៥២ទំព័រ៥០)



# គាថាធម្មបទ

(បិដកលេខ៥២ ទំព័រ៥១)

យោ ទណ្ឌេន អទណ្ឌេសុ អប្បទុដ្ឋេសុ ទុស្សតិ
ទសន្នមញ្ញតរំ ឋានំ ខិប្បមេវ និគច្ឆតិ
វេទនំ ផរុសំ ជានឹ សរីរស្ស ច ភេទនំ
គរុកំ វាបិ អាពាធំ ចិត្តក្ខេបំ វ បាបុណេ
រាជតោ វា ឧបសគ្គំ អព្ភក្ខានំ វ ទារុណំ
បរិក្ខយំ វ ញាតីនំ ភោគានំ វ បភង្គុណំ
អថវស្ស អគារានិ អគ្គិ ឌហតិ បាវកោ
កាយស្ស ភេទា ទុប្បញ្ញោ និរយំ សោ ឧបបជ្ជតិ។

បុគ្គលណា ប្រទូស្តដោយអាជ្ញា ចំពោះបុគ្គលទាំងឡាយ ដែលមិនមានអាជ្ញាប្រទូស្ត បុគ្គលនោះ រមែងដល់នូវហេតុនៃសេ

ចក្ខុទុក្ខណាមួយ ក្នុងហេតុ ១០ យ៉ាង ដោយទាន់ហន់ គឺគប្បីដល់នូវវេទនាដ៏អាក្រក់ សេចក្ដីវិនាសទ្រព្យ បែកធ្លាយសរីរៈ អាពាធជាទម្ងន់ ក្រឡកចិត្ត (ឆ្កួត) រឹបជាន់អំពីស្ដេច ពោលពាក្យបង្កាច់ដ៏អាក្រក់ អស់ពួកញាតិរលីង ពុកផុយភោគសម្បត្តិទាំងឡាយ ទាំងភ្លើងនឹងឆេះបំផ្លាញនូវផ្ទះរបស់បុគ្គលនោះ បុគ្គលមិនមានប្រាជ្ញានោះ លុះបែកធ្លាយរាងកាយរមែងទៅកើតក្នុងនរក។



ននគ្គចរិយានជដានបង្កានានាសកា ថណ្ឌិលសាយិកា
វា រជោជល្លំ ឧក្កុដិកប្បធានំ សោធេន្តិ មច្ចំ អវិតិណ្ណកង្ខំ។

ការប្រព្រឹត្តអាក្រាតកាយ ទុកសក់ ដេកលើភក់ មិនបរិភោគបាយ ដេកលើផែនដី ប្រឡាក់ខ្លួនដោយធូលី ព្យាយាម

អង្គុយប្រហោង មិនអាចជម្រះសត្វដែលមិនទាន់ឆ្លងផុតសេចក្តីសង្ស័យបានទេ។ (បិដកលេខ៥២ ទំព័រ៥១)



**អលង្កតោ ចេបិ សមំ ចរេយ្យ សន្តោ ទន្តោ និយតោ ព្រហ្មចារី សព្វេសុ ភូតេសុ និធាយ ទណ្ឌំ សោ ព្រាហ្មណោ សោ សមណោ ស ភិក្ខុ។**

បើបុគ្គលណា ស្អិតស្អាងរាងកាយហើយ(ដោយគ្រឿងអម្ពរ) តែមានការប្រព្រឹត្តស្មើ ជាអ្នកស្ងប់រម្ងាប់ ទូន្មាននូវឥន្ទ្រិយជាបុគ្គលទៀង (ចំពោះមគ្គផល) មានប្រក្រតីប្រព្រឹត្តធម៌ដ៏ប្រសើរ ទម្លាក់ចោលនូវអាជ្ញាក្នុងសត្វទាំងពួងចេញហើយ បុគ្គលនោះហៅថាព្រាហ្មណ៍ក៏បានថាសមណៈក៏បាន ថាភិក្ខុក៏បាន ។

(បិដកលេខ៥២ ទំព័រ៥១)



ហិរិនិសេធោ បុរិសោ កោចិ លោកស្មិ វិជ្ជតិ យោ និន្ទំ អបពោធេតិ អស្សោ ភទ្រោ កសាមិវ។ អស្សោ យថា ភទ្រោ កសានិវិដ្ឋោ អាតាបិនោ សំវេគិនោ ភវាថ សទ្ធាយ សីលេន ច វីរិយេន ច សមាធិនា ធម្មវិនិច្ឆយេនចសម្បន្នវិជ្ជាចរណាប តិស្សតាបហស្សថទុក្ខមិទំ អនប្បកំ។

បុរសអ្នកកម្ចាត់បង់នូវអកុសលវិតក្កៈ ដោយសេចក្ដីខ្មាសបាប មានតិចក្នុងលោក បុគ្គលណាបន្ទោរបង់នូវការដេកលក់ដូចសេះល្អមិនឲ្យរំពាត់ត្រូវខ្លួន បុគ្គលនោះ រកបានដោយក្រ ។ សេះល្អដែលនាយសារថីទូន្មាន ដោយរំពាត់ តក់ស្លុតយ៉ាងណា អ្នកទាំងឡាយ ចូរជាបុគ្គលមានព្យាយាម មានសេចក្ដីតក់ស្លុតយ៉ាងនោះឯង បើអ្នកទាំងឡាយ ប្រកបព្រមដោយសទ្ធាផង សីលផង ព្យាយាមផង សមាធិផង និងធម្មវិនិច្ឆ័យផង ជាអ្នកមានវិជ្ជា និងចរណៈដ៏បរិបូណ៌ មានស្មារតីតម្កល់មាំ រមែងលះបង់ទុក្ខមានប្រមាណច្រើននេះបានមិនខាន ។

(បិដកលេខ៥២ ទំព័រ៩២)



# គាថាធម្មបទ

(ប្រារព្ធព្រះចក្ខុបាលត្ថេរ បិដកលេខ៥២ទំព័រ២១)

**មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា**
**មនសា ចេ បទុដ្ឋេន ភាសតិ វា ករោតិ វា**
**តតោ នំ ទុក្ខមន្វេតិ ចក្កំវ វហតោ បទំ។**

ធម៌ទាំងឡាយមានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត(មានចិត្តធំ) សម្រេចអំពីចិត្ត បើបុគ្គលមានចិត្តត្រូវទោសប្រទូស្តហើយ ពោលក្តី ធ្វើក្តី (នូវទុច្ចរិត) ព្រោះទុច្ចរិតទាំងនោះ ទុក្ខរមែងជាប់តាមបុគ្គលនោះទៅដូចកង់រទេះវិលតាមដានជើងគោដែលកំពុងអូសទៅ។



# គាថាធម្មបទ

(ប្រាវត្តមដ្ឋកុណ្ឌលី បិដកលេខ៥២ទំព័រ២១)

**មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា**

**មនសា ចេ បសន្នេន ភាសតិ វា ករោតិ វា**

**តតោ នំ សុខមន្វេតិ ឆាយាវ អនុបាយិនី ។**

ធម៌ទាំងឡាយមានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត សម្រេចអំពីចិត្តបើបុគ្គលមានចិត្តជ្រះថ្លាហើយ ពោលក្ដី ធ្វើក្ដី (នូវសុចរិត) ព្រោះសុចរិតទាំងនោះសុខរមែងជាប់តាមបុគ្គលនោះទៅ ដូចស្រមោលអន្ទោលតាមប្រាណ។



# គាថាធម្មបទ

(ប្រារព្ធព្រះតិស្សត្ថេរ បិដកលេខ៥២ ទំព័រ២១)

**អក្កោច្ឆិ មំ អវធិ មំ អជិនិ មំ អហាសិ មេ**
**យេ ច តំ ឧបនយ្ហន្តិ វេរំ តេសំ ន សម្មតិ ។**
**អក្កោច្ឆិ មំ អវធិ មំ អជិនិ មំ អហាសិ មេ**
**យេ ច តំ នុបនយ្ហន្តិ វេរំ តេសូបសម្មតិ។**

*ជនទាំងឡាយណា ចងសេចក្តីក្រោធនោះទុកថា អ្នកឯណោះ បានជេរអញ អ្នកឯណោះបានវាយអញ អ្នកឯណោះ បានផ្ចាញ់អញ អ្នកឯណោះបានលួចយកទ្រព្យរបស់អញ ទៅហើយ ( ដូច្នេះ ) ពៀររបស់ជនទាំងឡាយនោះ មិនរម្ងាប់ឡើយ ។ ជនទាំងឡាយណា មិនចងសេចក្តីក្រោធនោះទុកថា អ្នកឯណោះ បានជេរអញ អ្នកឯណោះបានវាយអញ អ្នកឯណោះ បានផ្ចាញ់អញ អ្នកឯណោះបានលួចយកទ្រព្យរបស់អញ ទៅហើយ ( ដូច្នេះ ) ពៀររបស់ជនទាំងឡាយនោះ ទើបរម្ងាប់បាន។*



# គាថាធម្មបទ

(ប្រារព្ធពួកភិក្ខុនៅក្នុងក្រុងកោសម្ពី បិដកលេខ៥២ទំព័រ២២)

**បរេ ច ន វិជានន្តិ មយមេត្ថ យមាមសេ**

**យេ ច តត្ថ វិជានន្តិ តតោ សម្មន្តិ មេធគា។**

ជនទាំងឡាយដទៃ ( ក្រៅអំពីបណ្ឌិត ) តែងមិនដឹងខ្លួនថា យើងទាំងឡាយនឹងវិនាសក្នុងកណ្តាលនៃពួកនេះ ដូច្នេះហើយ ចំណែកជនទាំងឡាយណា ក្នុងពួកនេះ ដឹងខ្លួនថាយើងទាំងឡាយនឹងវិនាសក្នុងកណ្តាលនៃពួកនេះ ដូច្នេះ ការឈ្លោះប្រកែកទាំងឡាយ រមែងរម្ងាប់អំពីជនទាំងឡាយនោះ។



ប្រារព្ធចុល្លកាល និងមហាកាល បិដកលេខ៥២ទំព័រ២២)

សុភានុបស្សិំ វិហរន្តំ ឥន្ទ្រិយេសុ អសំវុតំ

ភោជនម្ហិ អមត្តញ្ញុំ កុសីតំ ហីនវីរិយំ

តំ វេ បសហតិ មារោ វាតោ រុក្ខំវ ទុព្ពលំ។

អសុភានុបស្សិំ វិហរន្តំ ឥន្ទ្រិយេសុ សុសំវុតំ

ភោជនម្ហិ ច មត្តញ្ញុំ សទ្ធំ អារទ្ធវីរិយំ

តំ វេ នប្បសហតិ មារោ វាតោ សេលំវ បព្វតំ។

បុគ្គលដែលយល់ឃើញនូវអារម្មណ៍ថាល្អ មិនសង្រួមក្នុងឥន្ទ្រិយទាំងឡាយ មិនដឹងប្រមាណក្នុងភោជន ខ្ជិលច្រអូស មានព្យាយាមថយ កិលេសមាររមែងគ្របសង្កត់ បុគ្គលនោះឯង ដូចខ្យល់ដែលគ្របសង្កត់ដើមឈើទុព្វល ដូច្នោះ ។ ឯបុគ្គល ដែលយល់ឃើញនូវអារម្មណ៍ថាមិនល្អ សង្រួមប្រពៃក្នុងឥន្ទ្រិយទាំងឡាយ ដឹងប្រមាណក្នុងភោជន មានសទ្ធា ប្រារព្ធព្យាយាម កិលេសមារតែងគ្រប់សង្កត់ បុគ្គលនោះមិនបាន ដូចខ្យល់គ្របសង្កត់ថ្មភ្នំតាន់មិនបានដូច្នោះ ។



ប្រារព្ធទេវទត្តបានសំពត់កាសាវៈ បិដកលេខ៥២ទំព័រ២៣

**អនិក្កសាវោ កាសាវំ យោ វត្ថំ បរិទហេស្សតិ**
**អបេតោ ទមសច្ចេន ន សោ កាសាវមរហតិ។**
**យោ ច វន្តកសាវស្ស សីលេសុ សុសមាហិតោ**
**ឧបេតោ ទមសច្ចេន ស វេ កាសាវមរហតិ។**

អ្នកណា នៅមានទឹកចត់គឺរាគាទិក្កិលេស ( ក្នុងសន្តាន ) ជាអ្នកបោះបង់ការទូន្មាននូវឥន្ទ្រិយនិងសច្ចៈ ហើយស្លៀកដណ្ដប់សំពត់កាសាវៈ អ្នកនោះ មិនគួរនឹងស្លៀកដណ្ដប់សំពត់កាសាវៈឡើយ ។

លុះតែអ្នកណា មានទឹកចត់គឺរាគាទិក្កិលេស ខ្ជាក់ចោលអស់ហើយ ជាអ្នកមានចិត្តតម្កល់មាំ ក្នុងចតុប្បារិសុទ្ធិ-សីល ប្រកបដោយការទូន្មាននូវឥន្ទ្រិយនិងសច្ចៈ អ្នកនោះឯង ទើបគួរនឹងស្លៀកដណ្ដប់សំពត់កាសាវៈបាន ។



# គាថាធម្មបទ

(ប្រារព្ធព្រះនន្ទត្ថេរ បិដកលេខ៥២ទំព័រ២៣)

**យថា អគារំ ទុច្ឆន្នំ វុដ្ឋី សមតិវិជ្ឈតិ**

**ឯវំ អភាវិតំ ចិត្តំ រាគោ សមតិវិជ្ឈតិ ។**

**យថា អគារំ សុឆន្នំ វុដ្ឋី ន សមតិវិជ្ឈតិ**

**ឯវំ សុភាវិតំ ចិត្តំ រាគោ ន សមតិវិជ្ឈតិ។**

ផ្ទះដែលប្រក់ខ្ជីខ្ជាហើយ តំណក់ទឹកភ្លៀងរមែងលេចរហូត យ៉ាងណាមិញ ចិត្តដែលបុគ្គលមិនបានអប់រំទុកហើយ រាគៈរមែងចាក់ដោតយ៉ាងនោះឯង ។

ផ្ទះដែលប្រក់ល្អហើយ តំណក់ទឹកភ្លៀងរមែងមិនលេចរហូត យ៉ាងណាមិញ ចិត្តដែលបុគ្គលបានអប់រំទុកល្អហើយ រាគៈរមែងមិនចាក់ដោតបាន យ៉ាងនោះឯង ។



# គាថាធម្មបទ

(ប្រារព្ធបុរសចុន្ទសូករិកៈ បិដកលេខ៥២ទំព័រ២៤)

**ឥធ សោចតិ បេច្ច សោចតិ បាបការី ឧភយត្ថ សោចតិ សោ សោចតិ សោ វិហញ្ញតិ ទិស្វា កម្មកិលិដ្ឋមត្តនោ។**

*បុគ្គលអ្នកធ្វើបាបតែងសោកស្តាយក្នុងលោកទាំងពីរ គឺសោកស្តាយក្នុងលោកនេះ១ ក្នុងលោកខាងមុខ១ បុគ្គលនោះរមែងសោកស្តាយក្តៅក្រហាយព្រោះឃើញអំពើសៅហ្មងរបស់ខ្លួន។*

# គាថាធម្មបទ

(ប្រាវត្តធម្មិកឧបាសក បិដកលេខ៥២ទំព័រ២៤)

**ឥធ មោទតិ បេច្ច មោទតិ កតបុញ្ញោ ឧភយត្ថ មោទតិ សោ មោទតិ សោ បមោទតិ ទិស្វា កម្មវិសុទ្ធិ មត្តនោ។**

បុគ្គលអ្នកធ្វើបុណ្យទុក រមែងរីករាយក្នុងលោកទាំងពីរ គឺ រីករាយក្នុងលោកនេះ ១ រីករាយក្នុងលោកខាងមុខ ១ បុគ្គលនោះ រមែងរីករាយស្រស់ស្រាយ ព្រោះឃើញអំពើបរិសុទ្ធរបស់ខ្លួន ។

(ប្រាវត្តទេវទត្តបំបែកសង្ឃ បិដកលេខ៥២ទំព័រ២១)

**ឥធ តប្បតិ បេច្ច តប្បតិ បាបការី ឧភយត្ថ តប្បតិ បាបំ មេ កតន្តិ តប្បតិ ភិយ្យោ តប្បតិ ទុគ្គតឹ គតោ។**

បុគ្គលអ្នកធ្វើអំពើបាប តែងក្តៅក្រហាយក្នុងលោកទាំងពីរ គឺក្តៅក្រហាយក្នុងលោកនេះ ១ ក្តៅក្រហាយក្នុងលោកខាងមុខ១ បុគ្គលនោះ រមែងក្តៅក្រហាយដោយគិតឃើញថា បាបអញបានធ្វើហើយ លុះធ្វើមរណកាលទៅកាន់ទុគ្គតិ ក៏រឹងរឹតតែក្តៅក្រហាយដ៏ក្រៃលែង ។

# ធម្មបទគាថា

(ប្រារព្ធភិក្ខុពីរអង្គ បិដកលេខ៥២ទំព័រ២៥)

ពហុម្បិ ចេ សហិតំ ភាសមានោ ន តក្ករោ ហោតិ នរោ បមត្តោ គោបោវ គាវោ គណយំ បរេសំ ន ភាគវា សាមញ្ញស្ស ហោតិ។ អប្បម្បិ ចេ សហិតំ ភាសមានោ ធម្មស្ស ហោតិ អនុធម្មចារី រាគញ្ច ទោសញ្ច បហាយ មោហំ សម្មប្បជានោ សុវិមុត្តចិត្តោ អនុបាទិយានោ ឥធ វា ហុរំ វា ស ភាគវា សាមញ្ញស្ស ហោតិ។

បើនរជនពោលពាក្យប្រកបដោយប្រយោជន៍សូម្បីច្រើន តែជាអ្នកប្រមាទមិនធ្វើតាមពាក្យនោះ រមែងជាអ្នកមិនមានចំណែកសាមញ្ញផលឡើយ ដូចអ្នករក្សាគោ កាលរាប់គោប្រគល់ឲ្យអ្នកដទៃហើយ(ជាអ្នកមិនបានបរិភោគនូវបញ្ចគោរស)ដូច្នោះឯង។

បើនរជនពោលពាក្យប្រកបដោយប្រយោជន៍សូម្បីបន្តិចបន្តួច តែជាអ្នកប្រព្រឹត្តនូវធម៌សមគួរដល់ធម៌ បានលះបង់រាគៈ ទោសៈនិងមោហៈ ជាអ្នកដឹងនូវធម៌ ដែលគួរកំណត់តាមហេតុ មានចិត្តដកផុតអំពីសេចក្ដីសៅហ្មង មិនមានសេចក្ដីប្រកាន់មាំ ក្នុងលោកនេះនិងលោកខាងមុខ នរជននោះ រមែងជាអ្នកបានចំណែកសាមញ្ញផល។



(ប្រារព្ធកុម្ភឃោសកសេដ្ឋី បិដកលេខ៥២ទំព័រ២៦)

**ឧដ្ឋានវតោ សតីមតោ សុចិកម្មស្ស និសម្មការិនោ**
**សញ្ញតស្ស ច ធម្មជីវិនោ អប្បមត្តស្ស យសោភិវឌ្ឍតិ។**

យស តែងចម្រើនយ៉ាងក្រៃលែង ដល់បុគ្គលមានសេចក្តីប្រឹងប្រែង មានស្មារតី មានការងារស្អាត ( ឥតទោស ) ជាអ្នកពិចារណារួចហើយទើបធ្វើ ជាអ្នកសង្រួម រស់នៅដោយធម៌ មិនមានសេចក្តីប្រមាទ។

(ប្រារព្ធព្រះចូឡបន្ថកត្ថេរ បិដកលេខ៥២ទំព័រ២៦)

**ឧដ្ឋានេនប្បមាទេន សញ្ញមេន ទមេនចធីបំ កយិរា**
**ថ មេធាវី យំ ឱឃោ នាភិកីរតិ ។**

អ្នកប្រាជ្ញ គប្បីសាងនូវកោះ គឺអរហត្តផល ជាកោះដែលជំនន់ គឺកិលេសជន់ពន្លិចមិនបាន ដោយសេចក្តិប្រឹងប្រែងផង ដោយសេចក្តិមិនប្រមាទផង ដោយការសង្រួមក្នុងចតុប្បារិសុទ្ធិសីលផង ដោយទមៈ គឺការទូន្មាននូវឥន្ទ្រិយផង។



# គាថាធម្មបទ

(ប្រារព្ធល្បែងនៃជនពាល បិដកលេខ៥២ទំព័រ២៦)

**បមាទមនុយុញ្ជន្តិ ពាលា ទុម្មេធិនោ ជនា អប្បមាទញ្ច មេធាវី ធនំ សេដ្ឋំវ រក្ខតិ។ មា បមាទមនុយុញ្ជេថ មា កាមរតិសន្ថវំ អប្បមត្តោ ហិ ឈាយន្តោ បប្បោតិ វិបុលំ សុខំ។**

*ពួកជនពាលអប្បឥតប្រាជ្ញា តែងប្រកបរឿយៗ នូវសេចក្តីប្រមាទ ចំណែកអ្នកប្រាជ្ញ រមែងរក្សាទុកនូវសេចក្តីមិន ប្រមាទ ដូចទ្រព្យយ៉ាងប្រសើរ ។ អ្នកទាំងឡាយ ចូរកុំប្រកបរឿយៗ នូវសេចក្តីប្រមាទ ចូរកុំប្រកបរឿយៗ នូវសេចក្តីរីករាយ ត្រេកអរក្នុងកាមឡើយ ដ្បិតបុគ្គលអ្នកមិនប្រមាទ ខំសង្កេតពិនិត្យ រមែងបាន សេចក្តីសុខដ៏ទូលាយ។*



# គាថាធម្មបទ

(ប្រារព្ធចំពោះព្រះមហាកស្សបត្ថេរ បិដកលេខ៥២ទំព័រ២៧)

**បមាទំ អប្បមាទេន　　យទា នុទតិ បណ្ឌិតោ**

**បញ្ញាបាសាទមារុយ្ហ　　អសោកោ សោកិនឹ បជំ**

**បព្វតដ្ឋោវ ភុម្មដ្ឋេ　　ធីរោ ពាលេ អវេក្ខតិ។**

កាលណាបណ្ឌិត បន្ទោបង់នូវសេចក្តីប្រមាទ ដោយសេចក្តីមិនប្រមាទ កាលណោះ លោកនឹងឡើងកាន់ប្រាសាទគឺបញ្ញា ជាបុគ្គលមិនសោក រមែងឃើញពួកសត្វដែលមានសោក ។

ធីរជនតែងពិចារណាឃើញពួកជនពាល ដូចបុគ្គលដែលឈរលើកំពូលភ្នំហើយក្រឡេកមើលពួកជន ដែលឋិតនៅលើផែនដី ដូច្នោះឯង ។

# ធម្មបទគាថា

(ប្រារព្ធភិក្ខុពីរអង្គដែលមានបដិបទាផ្សេងគ្នា បិដកលេខ៥២ទំព័រ២៧)

**អប្បមត្តោ បមត្តេសុ សុត្តេសុ ពហុជាគរោ**

**អពលស្សំវ សីឃស្សោ ហិត្វា យាតិ សុមេធសោ។**

បណ្ឌិតមានប្រាជ្ញាមោះមុត កាលពួកបុគ្គលកំពុងប្រមាទ លោកមិនប្រមាទ កាលពួកបុគ្គលកំពុងដេកលក់ លោកភ្ញាក់រឭកច្រើន លោករមែងលះបង់ចោលនូវបុគ្គលបែបនោះ ដូចសេះដែលរត់លឿន បានទៅចោលសេះដែលមានកម្លាំងទន់ទាបដូច្នោះឯង ។

(ប្រារព្ធសក្កទេវរាជដែលពីជាតិមុនជាមឃមាណព បិដកលេខ៥២)

**អប្បមាទេន មឃវា ទេវានំ សេដ្ឋតំ គតោ**

**អប្បមាទំ បសំសន្តិ បមាទោ គរហិតោ សទា ។**

មឃមានព គឺព្រះឥន្ទ្រ បានដល់នូវភាពជាបុគ្គលប្រសើរបំផុតជាងទេវតាទាំងឡាយ ព្រោះតែសេចក្តីមិនប្រមាទ អ្នកប្រាជ្ញទាំងឡាយ តែងសរសើរនូវសេចក្តីមិនប្រមាទ ហើយត្មះតិះដៀលនូវសេចក្តីប្រមាទសព្វៗ កាល ។



(ប្រារព្ធភិក្ខុមួយអង្គដែលមិនប្រមាទ បិដកលេខ៥២ទំព័រ២៧)

**អប្បមាទរតោ ភិក្ខុ បមាទេ ភយទស្សិ វា សញ្ញោជនំ អណុំ ថូលំ ឌហំ អគ្គីវ គច្ឆតិ។**

ភិក្ខុអ្នកត្រេកអរ ក្នុងសេចក្តីមិនប្រមាទ ឬឃើញភ័យ ក្នុងសេច ក្តីប្រមាទ តែងដុតចោលនូវសំយោជនៈទាំងតូច ទាំងធំ ដូចភ្លើងឆេះ (កម្ទេចនូវព្រៃ ទាំងព្រៃតូច ទាំងព្រៃធំ ) ដូច្នោះឯង។

(ប្រារព្ធព្រះតិស្សត្ថេរ បិដកលេខ៥២ទំព័រ២៨)

**អប្បមាទរតោ ភិក្ខុ បមាទេ ភយទស្សិ វា អព្វោ បរិហានាយ និព្វានស្សេវ សន្តិកេ។**

ភិក្ខុអ្នកត្រេកអរ ក្នុងសេចក្តីមិនប្រមាទ ឬឃើញភ័យ ក្នុងសេច ក្តីមិនប្រមាទ ជាអ្នកមិនគួរនឹងសាបសូន្យចាកនូវគុណធម៌ឡើយ ឈ្មោះថា ឋិតនៅក្នុងទីជិតនៃព្រះនិព្វាន។



# គាថាធម្មបទ

(ប្រារព្ធចំពោះព្រះមេឃិយត្ថេរ បិដកលេខ៥២ទំព័រ២៨)

**ផន្ទនំ ចបលំ ចិត្តំ រក្ខំ ទុន្និវារយំ ឧជុំ ករោ**
**តិ មេធាវី ឧសុការោវ តេជនំ។**
**វារិជោវ ថលេ ខិត្តោ ឱកមោកតឧព្ភតោ**
**បរិផន្ទតិទំ ចិត្តំ មារធេយ្យំ បហាតវេ។**

អ្នកប្រាជ្ញតែងធ្វើចិត្តដែលញាប់ញ័រ ឃ្លេងឃ្លោង រក្សាបានដោយកម្រ ហាមឃាត់បានដោយលំបាក ឲ្យជាចិត្តត្រង់បាន ដូចអ្នកធ្វើព្រួញ ពត់ព្រួញឲ្យត្រង់ ។ ចិត្តនេះដែលបុគ្គលលើកឡើងចាកអាល័យ គឺកាមគុណ ប្រាំ បោះទៅក្នុងវិបស្សនាកម្មដ្ឋាន ដើម្បីលះបង់នូវវដ្តៈជាទីនៅនៃមារ រមែងញាប់ញ័រ ដូចត្រីដែលគេលើកឡើងចាកទីនៅគឺទឹក បោះទៅលើគោក ដូច្នោះឯង។



# ធម្មបទគាថា

(ប្រារព្ធភិក្ខុមួយអង្គនៅមាតិកគ្រាម បិដកលេខ៥២ទំព័រ២៨)

**ទុន្និគ្គហស្ស លហុនោ យត្ថ កាមនិបាតិនោ**
**ចិត្តស្ស ទមថោ សាធុ ចិត្តំ ទន្តំ សុខាវហំ។**

ការទូន្មានចិត្តដែលសង្កត់សង្កិន បានដោយលំបាក ជាធម្មជាតរហ័ស មានប្រក្រតីធ្លាក់ចុះទៅតាមសេចក្ដីប្រាថ្នា ក្នុងអារម្មណ៍ណាមួយ (ការទូន្មានចិត្តដូច្នេះ) រមែងជាគុណញុំាំងប្រយោជន៍ឲ្យសម្រេច(ព្រោះថា) ចិត្តដែលហ្វឹកហ្វឺនបានហើយ រមែងនាំមកនូវសេចក្ដីសុខ។



# គាថាធម្មបទ

(ប្រារព្ធភិក្ខុមួយអង្គដែលចង់សឹកបិដកលេខ៥២ទំព័រ២៩)

**សុទុទ្ទសំ សុនិបុណំ យត្ថ កាមនិបាតិនំ**

**ចិត្តំ រក្ខេថ មេធាវី ចិត្តំ គុត្តំ សុខាវហំ។**

អ្នកមានប្រាជ្ញា គួររក្សាចិត្តដែលឃើញដោយកម្រក្រៃពេក ដែលល្អិតពេកណាស់ មានប្រក្រតីធ្លាក់ចុះទៅតាមសេចក្តីប្រាថ្នាក្នុងអារម្មណ៍ណាមួយ (ព្រោះថា) ចិត្តដែលគេរក្សាបានហើយរមែងនាំមកនូវសេចក្តីសុខ។



# គាថាធម្មបទ

(ប្រារព្វព្រះចិត្តហត្ថត្ថេរ បួសសឹកៗ បិដកលេខ៥២ទំព័រ៣០)

**អនវដ្ឋិតចិត្តស្ស សទ្ធម្មំ អវិជានតោ**
**បរិប្លវប្បសាទស្ស បញ្ញា ន បរិបូរតិ។**
**អនវស្សុតចិត្តស្ស អនន្វាហតចេតសោ**
**បុញ្ញបាបប្បហីនស្ស នត្ថិ ជាគរតោ ភយំ។**

*ប្រាជ្ញា រមែងមិនបរិបូណ៌ដល់បុគ្គលដែលមានចិត្តមិនខ្ជាប់ខ្ជួន មិនដឹងច្បាស់នូវព្រះសទ្ធម្ម មានសេចក្តីជ្រះថ្លាអណ្តែតទៅ ។ភ័យរមែងមិនមានដល់បុគ្គលអ្នកមានចិត្តមិនទទឹកដោយរាគៈ មានចិត្តដែលទោសខ្ទាំងខ្ទប់មិនបាន មានបុណ្យនិងបាបបានលះចោលហើយភ្ញាក់រឭកជានិច្ច។*



(ប្រារព្ធព្រះសង្ឃរក្ខិតត្ថេរ បិដកលេខ៥២ទំព័រ២៩)

**ទូរង្គមំ ឯកចរំ អសរីរំ គុហាសយំ**

**យេ ចិត្តំ សញ្ញមេស្សន្តិ មោក្ខន្តិ មារពន្ធនា។**

អ្នកទាំងឡាយណា នឹងសង្រួមចិត្តដែលទៅឆ្ងាយ ជាចិត្តត្រាច់ទៅតែឯង មិនមានសរីរៈ មានគុហាគឺមហាភូតរូប ៤ ជាទីអាស្រ័យនៅ អ្នកទាំងនោះឯង រមែងរួចចាកចំណងនៃមារ ។

(ប្រារព្ធពួកភិក្ខុអ្នកចម្រើនវិបស្សនា បិដកលេខ៥២ទំព័រ៣០)

**កុម្ភូបមំ កាយមិមំ វិទិត្វា នគរូបមំ ចិត្តមិទំ ថបេត្វា**

**យោធេថ មារំ បញ្ញាវុធេន ជិតញ្ច រក្ខេ អនិវេសនោ សិយា។**

បុគ្គលគប្បីដឹងច្បាស់នូវកាយនេះថា ដូចជាឆ្នាំង គប្បីបិទនូវចិត្តនេះឲ្យដូចជាបិទទ្វារនគរ គប្បីច្បាំងនូវមារដោយអាវុធគឺបញ្ញា គប្បីរក្សាទុកនូវធម៌ ដែលខ្លួនឈ្នះហើយ មិនគប្បីជាអ្នកជំអក់នៅ(ក្នុងធម៌នោះ)ឡើយ ។



(ប្រារព្ធព្រះបូតិគត្តតិស្សត្ថេរ បិដកលេខ៥២ទំព័រ៣០)

**អចិរំ វតយំ កាយោ បឋវឹ អធិសេស្សតិ**

**ឆុទ្ធោ អបេតវិញ្ញាណោ និរត្ថំវ កលិង្គរំ។**

ឱហ្ន៎! មិនយូរប៉ុន្មានទេតើ កាយនេះ មានតែវិញ្ញាណទៅប្រាសហើយ គេនឹងយកទៅបោះបង់ចោល មុខជានឹងដេកស្តូកស្តឹងនៅលើផែនដី ដូចជាអង្កត់ឧស រកប្រយោជន៍គ្មានឡើយ។

(ប្រារព្ធនាយគោបាល ឈ្មោះនន្ទៈ បិដកលេខ៥២ទំព័រ៣០)

**ទិសោ ទិសំ យន្តំ កយិរា វេរី វា បន វេរិនំ**

**មិច្ឆាបណិហិតំ ចិត្តំ បាបិយោ នំ តតោ ករេ។**

ចោរក្រឡេកឃើញចោរផងគ្នា ឬក៏បុគ្គលមានពៀរក្រឡេកឃើញបុគ្គលមានពៀរផងគ្នា គប្បីធ្វើនូវសេចក្តីវិនាសណាមួយដល់

គ្នា ឯចិត្តដែលបុគ្គលតាំងទុកខុសហើយរមែងធ្វើបុគ្គលនោះ ឲ្យអាក្រក់ក្រៃលែងជាងសេចក្ដីវិនាសនោះទៅទៀត។

(ប្រារព្ធភិក្ខុ ៥០០ អង្គ ខ្វល់ខ្វាយពីរឿងផែនដី បិដកលេខ៥២ទំព័រ៣០)

**កោ ឥមំ បឋវឹ វិចេស្សតិ យមលោកញ្ច ឥមំ សទេវកំ កោ ធម្មបទំ សុទេសិតំ កុសលោ បុប្ផមិវ បចេស្សតិ។**

**សេក្ខោ បឋវឹ វិចេស្សតិ យមលោកញ្ច ឥមំ សទេវកំ សេក្ខោ ធម្មបទំ សុទេសិតំ កុសលោ បុប្ផមិវ បចេស្សតិ។**

អ្នកណានឹងដឹងច្បាស់នូវផែនដី គឺអត្តភាពនេះ និងយមលោក គឺអបាយភូមិ ៤ និងមនុស្សលោកនេះ ព្រមទាំងទេវលោកបាន អ្នកណានឹងជ្រើសរើសនូវចំណែកនៃធម៌ ដែលព្រះតថាគតសម្ដែងប្រពៃហើយ ដូចមាលាការដែលឈ្លាសវៃ ជ្រើសរើសនូវផ្កាដូច្នោះ ។

ព្រះសេក្ខបុគ្គល នឹងដឹងច្បាស់នូវផែនដីគឺអត្តភាពនេះ និងយមលោក គឺអបាយភូមិ ៤ និងមនុស្សលោកនេះ ព្រមទាំងទេវលោកបាន ព្រះសេក្ខបុគ្គលនឹងជ្រើសរើសនូវចំណែកនៃធម៌ដែលព្រះតថាគតសម្ដែងប្រពៃហើយដូចមាលាការដែលឈ្លាសវៃជ្រើសរើសនូវផ្កាដូច្នោះឯង។

# គាថាធម្មបទ

(ប្រារព្ធសោរេយ្យត្ថេរ បានជាព្រះអរហន្ត បិដកលេខ៥២ទំព័រ៣០)

**ន តំ មាតា បិតា កយិរា អញ្ញេ វាបិ ច ញាតកា សម្មាបណិហិតំ ចិត្តំ សេយ្យសោ នំ តតោ ករេ។**

មាតាបិតា មិនគប្បីធ្វើហេតុនោះបាន ឬជនទាំងឡាយដទៃជាញាតិមិនគប្បីធ្វើនូវហេតុនោះបាន ចំណែកខាងចិត្ត ដែលបុគ្គលតាំងទុកត្រូវហើយ រមែងធ្វើបុគ្គលនោះ ឲ្យប្រសើរជាងហេតុនោះបាន។

(ប្រារព្ធភិក្ខុមួយអង្គពិចារណាថ្ងៃបណ្តើរកូន បិដកលេខ៥២ទំព័រ៣១)

**ផេណូបមំ កាយមិមំ វិទិត្វា មរីចិធម្មំ អភិសម្ពុធានោ ឆេត្វាន មារស្ស បបុប្ផកានិ អទស្សនំ មច្ចុរាជស្ស គច្ឆេ។**

ភិក្ខុកាលដឹងច្បាស់នូវកាយនេះថា ដូចជាដុំពពុះទឹក ដឹងច្បាស់នូវកាយនេះថា មានសភាពដូចជាថ្ងៃបណ្តើរកូន គប្បីកាត់នូវកម្រងផ្កាជារបស់មារ គឺវដ្ដៈ ៣ ទៅកាន់ស្ថានទីដែលមច្ចុរាជមើលមិនឃើញ។

# ធម្មបទគាថា

(ប្រារព្ធភិក្ខុ ៥០០ អង្គ ខ្វល់ខ្វាយពីរឿងផែនដី បិដកលេខ៥២ទំព័រ៧០)

**កោ ឥមំ បឋវឹ វិជេស្សតិ យមលោកញ្ច ឥមំ សទេវកំ កោ ធម្មបទំ សុទេសិតំ កុសលោ បុប្ផមិវ បចេស្សតិ។**

**សេក្ខោ បឋវឹ វិជេស្សតិ យមលោកញ្ច ឥមំ សទេវកំ សេក្ខោ ធម្មបទំ សុទេសិតំ កុសលោ បុប្ផមិវ បចេស្សតិ។**

*អ្នកណានឹងដឹងច្បាស់នូវផែនដី គឺអត្តភាពនេះ និងយមលោក គឺអបាយភូមិ ៤ និងមនុស្សលោកនេះ ព្រមទាំងទេវលោកបាន អ្នកណានឹងជ្រើសរើសនូវចំណែកនៃធម៌ ដែលព្រះតថាគតសម្ដែងប្រពៃហើយ ដូចមាលាការដែលឈ្លាសវៃ ជ្រើសរើសនូវផ្កាដូច្នោះ ។*

*ព្រះសេក្ខបុគ្គល នឹងដឹងច្បាស់នូវផែនដីគឺអត្តភាពនេះ និងយមលោក គឺអបាយភូមិ ៤ និងមនុស្សលោកនេះ ព្រមទាំងទេវលោកបាន ព្រះសេក្ខបុគ្គលនឹងជ្រើសរើសនូវចំណែកនៃធម៌ដែលព្រះតថាគតសម្ដែងប្រពៃហើយដូចមាលាការដែលឈ្លាសវៃជ្រើសរើសនូវផ្កាដូច្នោះឯង។*



# គាថាធម្មបទ

(ប្រារព្ធវិឌូឌភៈ បិដកលេខ៥២ទំព័រ៣១)

**បុប្ផានិ ហេវ បចិនន្តំ    ព្យាសត្តមនសំ នរំ**
**សុត្តំ គាមំ មហោឃោវ    មច្ចុ អាទាយ គច្ឆតិ។**

មច្ចុគឺសេចក្ដីស្លាប់ តែងកៀរយកទៅនូវនរជន អ្នកមានចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេងៗ កំពុងជ្រើសរើសនូវផ្កាគឺកាមគុណ៥ នោះឯង ដូចទឹកជំនន់ធំ ដែលក្ដួចយកអ្នកស្រុកកំពុងដេកលក់ទៅ ដូច្នោះឯង ។

(ប្រារព្ធនាងបតិបូជិកា បិដកលេខ៥២ទំព័រ៣១)

**បុប្ផានិ ហេវ បចិនន្តំ    ព្យាសត្តមនសំ នរំ**
**អតិត្តំយេវ កាមេសុ    អន្តកោ កុរុតេ វសំ។**

អ្នកធ្វើនូវទីបំផុត ( នៃជីវិត ) គឺមច្ចុរាជ តែងក្រុងសត្វដែលមានចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេងៗ កំពុងជ្រើសរើសនូវផ្កាគឺកាមគុណ៥ មិនឆ្អែតឆ្អន់ក្នុងកាមទាំងឡាយនោះឯង ឲ្យនៅក្នុងអំណាចរបស់ខ្លួន ។



(ប្រារព្ធកោសិយសេដ្ឋីដែលកំណាញ់ បិ៤២ ទំ៣១)

**យថាបិ ភមរោ បុប្ផំ    វណ្ណគន្ធំ អហេឋយំ**

**បលេតិ រសមាទាយ    ឯវំ គាមេ មុនី ចរេ។**

ភមរជាតិ មិនធ្វើផ្កាឈើដែលមានពណ៌និងក្លិនឲ្យវិនាសទេ ក្រេបយកតែរសហើយ ហើរទៅ យ៉ាងណាមិញ អ្នកប្រាជ្ញ គប្បីត្រាច់ទៅក្នុងស្រុក ក៏យ៉ាងនោះឯង ។

(ប្រារព្ធបាដិកាជីវក បិ៤២ ទំ៣២)

**ន បរេសំ វិលោមានិ    ន បរេសំ កតាកតំ**

**អត្តនោ វ អវេក្ខេយ្យ    កតានិ អកតានិ ច។**

ពាក្យចាក់ដោតទាំងឡាយរបស់ជនដទៃ បុគ្គលមិនគួរធ្វើទុកក្នុងចិត្តទេ កិច្ចដែលធ្វើហើយ និងមិនទាន់ធ្វើហើយរបស់ជនដទៃ (ដែលមិនមែនជាមុខការរបស់ខ្លួន) បុគ្គលមិនគួរ ពិនិត្យមើលទេបុគ្គលគួរពិនិត្យ ពិចារណា តែកិច្ចការទាំងឡាយ ដែលធ្វើហើយ និងមិនទាន់ធ្វើហើយរបស់ខ្លួនតែម្យ៉ាង។



(ប្រារព្ធឆត្តបាណិឧបាសក ជាព្រះអនាគាមី បិ៥២ ទំ៣២)

**ឯវំ សុភាសិតា វាចា អផលា ហោតិ អកុព្វតោ។ យថាបិ រុចិរំ បុប្ផំ វណ្ណវន្តំ អគន្ធកំ ថាបិ រុចិរំ បុប្ផំ វណ្ណវន្តំ សគន្ធកំ ឯវំ សុភាសិតា វាចា សផលា ហោតិ សុកុព្វតោ។**

ផ្កាឈើមានទ្រង់ទ្រាយល្អ មានពណ៌(ល្អ) តែគ្មានក្លិ(ក្រអូប)(រមែងមិនក្លិនក្រអូបដល់អ្នកដែលទ្រទ្រង់ )ដូចម្តេចមិញ វាចាជាសុភាសិតរមែងគ្មានផលដល់អ្នកដែលមិនធ្វើតាមដូច្នោះ។ ផ្កាឈើដែលមានទ្រង់ទ្រាយល្អ មានពណ៌ មានក្លិន(រមែងក្រអូបដល់អ្នកដែលទ្រទ្រង់) ដូចម្តេចមិញ វាចាជាសុភាសិតរមែងមានផលដល់អ្នកដែលធ្វើតាមដោយគោរព ដូច្នោះឯង។



(ប្រារព្ធឧបាសិកាវិសាខា បិដកលេខ៥២ទំព័រ៣២)

**យថាបិ បុប្ផរាសិម្ហា កយិរា មាលាគុឡេ ពហូ**

**ឯវំ ជាតេន មច្ចេន កត្តព្វំ កុសលំ ពហុំ។**

មាលាការបេះធ្វើសំណុំនៃកម្រងផ្កាអំពីគំនរនៃផ្កា ( ផ្សេងៗគ្នា ) ឲ្យបានច្រើន យ៉ាងណាមិញ សត្វដែលកើតមកហើយតែងស្លាប់ទៅវិញជាធម្មតា គួរធ្វើកុសលឲ្យច្រើន យ៉ាងនោះឯង។

(ប្រារព្ធដល់ព្រះមហាកស្សបត្ថេរ បិដកលេខ៥២ទំព័រ៣៣)

**អប្បមត្តោ អយំ គន្ធោ យាយំ តគរចន្ទនី**

**យោ ច សីលវតំ គន្ធោ វាតិ ទេវេសុ ឧត្តមោ។**

ក្លិនក្រស្នា និងក្លិនចន្ទន៍ណា ក្លិននេះ ក្រអូបមានប្រមាណតិចទេ ចំណែកក្លិននៃបុគ្គលមានសីលទាំងឡាយណា ក្លិននោះ ទើបក្រអូបលើសលប់ ផ្សាយទៅក្នុងទេវលោក និងមនុស្សលោកបាន។



# គាថាធម្មបទ

(ប្រារព្ធចំពោះបញ្ហានៃព្រះអានន្ទត្ថេរ បិដកលេខ៥២ទំ៣២)

**ន បុប្ផគន្ធោ បដិវាតមេតិ ន ចន្ទនំ តគរមល្លិកា វា សតញ្ច គន្ធោ បដិវាតមេតិ សព្វា ទិសា សប្បុរិសោ បវាយតិ។**

**ចន្ទនំ តគរំ វាបិ ឧប្បលំ អថ វស្សិកី ឯតេសំ គន្ធជាតានំ សីលគន្ធោ អនុត្តរោ។**

ក្លិនផ្កាឈើ ផ្សាយទៅប្រាសខ្យល់ មិនបាន ក្លិនខ្លឹមចន្ទន៍ក្ដី ក្លិនខ្លឹមក្រស្នាក្ដី ក្លិនផ្កាម្លិះរួតក្ដី ក៏ផ្សាយទៅប្រាសខ្យល់ មិនបាន ចំណែកក្លិនរបស់សប្បុរសទាំងឡាយ រមែងផ្សាយទៅប្រាសខ្យល់បាន ព្រោះសប្បុរស រមែងផ្សាយទៅបានគ្រប់ទិស។

ក្លិននៃសីល ជាគុណជាតិប្រសើរបំផុតជាងគន្ធជាតិទាំងនេះគឺ ខ្លឹមចន្ទន៍ ខ្លឹមក្រស្នា ផ្កាឧប្បល ផ្កាម្លិះលា។



# គាថាធម្មបទ

(ប្រារព្ធគរហទិន្នៈសាវ័ករបស់និគ្រន្ថ បិដកលេខ៥២ទំព័រ៣៣)

**យថា សង្ការធានស្មឹ ឧជ្ឈិតស្មឹ មហាបថេ**
**បទុមំ តត្ថ ជាយេថ សុចិគន្ធំ មនោរមំ**
**ឯវំ សង្ការភូតេសុ អន្ធភូតេ បុថុជ្ជនេ**
**អតិរោចតិ បញ្ញាយ សម្មាសម្ពុទ្ធសាវកោ។**

ផ្កាឈូក ទុកជាកើតក្នុងគំនរសំរាម ដែលគេចាក់ចោលក្បែរផ្លូវធំនោះ ក៏គង់មានក្លិនក្រអូប ជាទីរីករាយនៃចិត្តបាន ដូចម្តេចមិញ សាវ័ករបស់ព្រះសម្មាសម្ពុទ្ធ ទោះបីកើតនៅក្នុងសមាគមនៃពួកជនដែលដូចជាគំនរសំរាមក៏ដោយ ក៏នៅតែរុងរឿងលើសបុថុជ្ជនទាំងឡាយដែលងងឹតសូន្យឈឹង ដោយបញ្ញា (របស់ខ្លួន) ដូច្នោះឯង។



# ធម្មទស្សន៍

**(មឃទេវជាតក) ព្រះរាជាពោធិសត្វពោលថា៖**

*សក់ទាំងឡាយនេះ នាំទៅនូវវ័យ (ស្កូវ) កើតដល់អញហើយ ទេវទូត កើតប្រាកដហើយ (នេះ) ជាសម័យនៃផ្នួសរបស់អញ។*

*(សុត្តន្តបិដកលេខ៥៨ ទំព័រ៤)*

**(សុខវិហារិជាតក) ឥសីពោធិសត្វពោលថា៖**

*ពួកជនដទៃ មិនរក្សាជនណា ម្យ៉ាងទៀត ជនណាមិនរក្សាពួកជនដទៃ បពិត្រព្រះរាជា ជននោះឯង មិនមានសេចក្តីអាឡោះអាល័យក្នុងការទាំងឡាយទេ រមែងដេកជាសុខ។*

*(សុត្តន្តបិដកលេខ៥៨ ទំព័រ៤)*



## គាថាធម្មបទ

សុភានុបស្សឹ វិហរន្តំ ឥន្ទ្រិយេសុ អសំវុតំ
ភោជនម្ហិ អមត្តញ្ញុំ កុសីតំ ហីនវិរិយំ
តំ វេ បសហតី មារោ វាតោ រុក្ខំវ ទុព្វលំ។
អសុភានុបស្សឹ វិហរន្តំ ឥន្ទ្រិយេសុ សុសំវុតំ
ភោជនម្ហិ ច មត្តញ្ញុំ សទ្ធំ អារទ្ធវិរិយំ
តំ វេ នប្បសហតី មារោ វាតោ សេលំវ បព្វតំ។

បុគ្គលដែលយល់ឃើញនូវអារម្មណ៍ថាល្អ មិនសង្រួមក្នុងឥន្ទ្រិយទាំងឡាយ មិនដឹងប្រមាណក្នុងភោជន ខ្ជិលច្រអូស មានព្យាយាមធូរថយ កិលេសមារ រមែងគ្របសង្កត់បុគ្គលនោះឯង ដូចខ្យល់ដែលគ្របសង្កត់ដើមឈើទុព្វលដូច្នោះ។ ឯបុគ្គល ដែលយល់ឃើញនូវអារម្មណ៍ថាមិនល្អ សង្រួមប្រពៃក្នុងឥន្ទ្រិយទាំងឡាយ ដឹងប្រមាណក្នុងភោជន មានសទ្ធាប្រារព្ធព្យាយាម កិលេសមារ រមែងគ្របសង្កត់បុគ្គលនោះមិនបានដូចខ្យល់គ្របសង្កត់ភ្នំ ថ្មតាន់ មិនបានដូច្នោះឯង។



# គាថាធម្មបទ

(ប្រារព្ធទេវទត្តបានសំពត់កាសាវៈ បិដក ភាគ ៥២ ទំព័រទី ២៣)

**អនិក្កសាវោ កាសាវំ　　យោ វត្ថំ បរិទហិស្សតិ**

**អបេតោ ទមសច្ចេន　　ន សោ កាសាវមរហតិ។**

អ្នកណា នៅមានទឹកចត់គឺរាគាទិក្កិលេស(ក្នុងសន្តាន) ជាអ្នកបោះបង់ការទូន្មានឥន្ទ្រិយនិងសច្ចៈ ហើយស្លៀក ដណ្ដប់សំពត់កាសាវៈអ្នកនោះមិនគួរនឹងស្លៀកដណ្ដប់ សំពត់កាសាវៈឡើយ។

**“បើគេឱ្យផែនដីទាំងមូលដល់បុរសអកតញ្ញូជាអ្នកឃើញគុណទោសជានិច្ច ក៏មិនគប្បីញុំាងបុរសអកតញ្ញូនោះឱ្យត្រេកអរបានឡើយ”** (បិដកលេខ៥៨ ទំព័រ៣១)



(ប្រារព្ធព្រះបាទបសេនទិកោសល បិដក ភាគ៥២ ទំព័រទី៣៤)

**ទីឃា ជាគរតោ រត្តិ ទីឃំ សន្តស្ស យោជនំ**

**ទីឃោ ពាលាន សំសារោ សទ្ធម្មំ អវិជានតំ។**

រាត្រីវែង ចំពោះតែអ្នកភ្ញាក់រឮក (អ្នកដេកមិនលក់) យោជន៍វែង ចំពោះតែអ្នកនឿយហត់ សង្សារវដ្តវែង ចំពោះតែបុគ្គលពាលមិនដឹងច្បាស់នូវព្រះសទ្ធម្ម។

(ប្រារព្ធសទ្ធិវិហារិករបស់ព្រះមហាកស្សបត្ថេរ បិដកភាគ៥២ ទំព័រទី៣៤)

**ចរញ្ចេ នាធិគច្ឆេយ្យ សេយ្យំ សទិសមត្តនោ**

**ឯកចរិយំ ទឡ្ហំ កយិរា នត្ថិ ពាលេ សហាយតា។**

បុគ្គលកាលស្វះស្វែងរកកល្យាណមិត្ត បើមិនបានមិត្តដ៏ប្រសើរជាងខ្លួន ឬមិត្តដែលស្មើនឹងខ្លួនទេ គប្បីប្រព្រឹត្តនៅតែម្នាក់ឯង ឲ្យខ្ជាប់ខ្ជួនវិញ ព្រោះថា សហាយតាគុណ(១) មិនមានក្នុងបុគ្គលពាលឡើយ។



(ប្រារព្ធនាងសាមាវតី មានប្រក្រតីមិនប្រមាទ)

អប្បមាទោ អមតំ បទំ បមាទោ មច្ចុនោ បទំ
អប្បមត្តា ន មីយន្តិ យេ បមត្តា យថា មតា
ឯតំ វិសេសតោ ញត្វា អប្បមាទម្ហិ បណ្ឌិតា
អប្បមាទេ បមោទន្តិ អរិយានំ គោចរេ រតា
តេ ឈាយិនោ សាតតិកា និច្ចំ ទឡ្ហបរក្កមា
ផុសន្តិ ធីរា និព្វានំ យោគក្ខេមំ អនុត្តរំ។

សេចក្តីមិនប្រមាទ ជាផ្លូវនៃសេចក្តីមិនស្លាប់ សេចក្តីប្រមាទ ជាផ្លូវនៃសេចក្តីស្លាប់ ជនទាំងឡាយ ដែលមិនប្រមាទហើយ ឈ្មោះថាមិនស្លាប់ ជនទាំងឡាយដែលប្រមាទហើយទុកដូចជាមនុស្សស្លាប់ទៅហើយ។ ពួកបណ្ឌិតបានជ្រាបនូវដំណើរនេះដោយប្លែកគ្នា (ទើបឋិតនៅ) ក្នុងសេចក្តីមិនប្រមាទ រីករាយក្នុងសេចក្តីមិនប្រមាទ បណ្ឌិតទាំងនោះ ជាអ្នកត្រេកអរក្នុងធម៌ជាទីគោចរ នៃព្រះអរិយបុគ្គលទាំងឡាយ។ បណ្ឌិតអ្នកមិនប្រមាទទាំងនោះ មានការពិនិត្យជាប្រក្រតី មានព្យាយាមជាប់តគ្នា មានសេចក្តីប្រឹងប្រែងមាំមួនជានិច្ច ជាអ្នកមានប្រាជ្ញា តែងពាល់ត្រូវនូវព្រះនិព្វានជាទីក្សេមក្សាន្តចាកយោគៈ ជាធម្មគុណដ៏ប្រសើរបំផុត។



# គាថាធម្មបទ

(ប្រារព្ធព្រះឧទាយីដែលមិនដឹងព្រះសទ្ធម្ម បិដក ភាគ៥២ ទំព័រទី៣៥)

**យាវជីវម្បិ ចេ ពាលោ បណ្ឌិតំ បយិរុបាសតិ**
**ន សោ ធម្មំ វិជានាតិ ទព្វី សូបរសំ យថា។**

មនុស្សពាល បើចូលទៅអង្គុយជិតអ្នកប្រាជ្ញ សូម្បីអស់មួយជីវិត ក៏ឥតមានដឹងរសធម៌អ្វីឲ្យច្បាស់លាស់ឡើយដូចវែកដែលមិនដឹងរសសម្ល ។

(ប្រារព្ធភិក្ខុ ៣០ អង្គ និមន្តមកពីដែនបាវ៉ា បិដក ភាគ៥២ ទំព័រទី៣៥)

**មុហុត្តមបិ ចេ វិញ្ញូ បណ្ឌិតំ បយិរុបាសតិ**
**ខិប្បំ ធម្មំ វិជានាតិ ជិវ្ហា សូបរសំ យថា។**

វិញ្ញូជន បើចូលទៅអង្គុយជិតអ្នកប្រាជ្ញ សូម្បីតែមួយរំពេចរមែងយល់រសធម៌ ដោយឆាប់រហ័ស ដូចអណ្តាតដឹងនូវរសសម្ល។



# គាថាធម្មបទ

(ប្រារព្ធបុរសកើតឃ្លង់ បិដកភាគ៥២ ទំព័រទី៣៥)

**ចរន្តិ ពាលា ទុម្មេធា   អមិត្តេនេវ អត្តនា**
**ករោន្តា បាបកំ កម្មំ   យំ ហោតិ កដុកប្ផលំ។**

ពួកជនពាលមិនមានប្រាជ្ញា មានខ្លួនដូចជាសត្រូវ តែងធ្វើកម្មលាមក ដែលជាអំពើមានផលក្ដៅក្រហាយ។

(ប្រារព្ធអ្នកស្រែម្នាក់  បិដកភាគ៥២ ទំព័រទី៣៥)

**ន តំ កម្មំ កតំ សាធុ   យំ កត្វា អនុតប្បតិ**
**យស្ស អស្សុមុខោ រោទំ   វិបាកំ បដិសេវតិ។**

បុគ្គលធ្វើកម្មណាហើយ រមែងក្ដៅក្រហាយ ឬមានមុខប្រឡាក់ដោយទឹកភ្នែក ស្រែកយំ ទទួលផលនៃកម្មណា កម្មដែលគេធ្វើហើយនោះ ឈ្មោះថា ជាកម្មមិនល្អឡើយ។



# គាថាធម្មបទ

(ប្រារព្ធសុមនមាលាការ ថ្វាយផ្កាម្លិះដល់ព្រះអង្គ)

**តញ្ច កម្មំ កតំ សាធុ    យំ កត្វា នានុតប្បតិ**

**យស្ស បតីតោ សុមនោ    វិបាកំ បដិសេវតិ។**

បុគ្គលធ្វើកម្មណាហើយ រមែងមិនក្ដៅក្រហាយតាមក្រោយ ដល់នូវសេចក្ដីពេញចិត្ត មានចិត្តល្អ ទទួលផលនៃកម្មណា កម្មដែលគេធ្វើហើយនោះឯង ឈ្មោះថាជាកម្មល្អ។

(ប្រារព្ធឧប្បលវណ្ណាថេរី ត្រូវនន្ទមាណពប្រទូស្ត)

**មធុវា មញ្ញតី ពាលោ    យាវ បាបំ ន បច្ចតិ**

**យទា ច បច្ចតី បាបំ អថ (ពាលោ) ទុក្ខំ និគច្ឆតិ។**

បាបមិនទាន់ឲ្យផលត្រឹមណា ជនពាល តែងសំគាល់នូវបាបនោះថា ដូចទឹកឃ្មុំ លុះដល់កាលណា បាបឲ្យផល ជនពាល ទើបប្រទះនូវសេចក្ដីទុក្ខក្នុងកាលណោះ។



(ប្រាវត្តសដ្ឋិកូដប្រេត បិដកលេខ៥២ ទំ.៣៦)

**យាវទេវ អនត្ថាយ ញត្តំ ពាលស្ស ជាយតិ**

**ហន្តិ ពាលស្ស សុក្កំសំ មុទ្ធំ អស្ស វិបាតយំ។**

ការចេះដឹង កើតឡើងដល់បុគ្គលពាល គ្រាន់តែដើម្បីសេចក្ដីវិនាសប៉ុណ្ណោះ រមែងញ៉ាំងក្បាលគឺបញ្ញាឲ្យធ្លាក់ចុះ បំផ្លិចបំផ្លាញ ចំណែកនៃធម៌ស គឺកុសលរបស់បុគ្គលពាលនោះឯង ។

(ប្រាវត្តអហិប្រេតមានបុព្វកម្មដុតកុដិព្រះបច្ចេកពុទ្ធ បិដកលេខ៥២ទំ.៣៦)

**ន ហិ បាបំ កតំ កម្មំ សជ្ជុខីរំវ មុច្ចតិ**

**ឌហន្តំ ពាលមន្វេតិ ភស្មាច្ឆន្នោវ បាវកោ។**

កម្មលាមក ដែលជនពាលធ្វើហើយ មិនទាន់ឲ្យផលនោះក៏មាន ដូចទឹកដោះស្រស់ ដែលមិនទាន់ប្រែក្លាយ(ក្នុង១រំពេច)ដូច្នោះ បាបកម្មនោះ តាមដុតបុគ្គលពាល ដូចរងើកភ្លើង ដែលបិទបាំងទុកដោយផេះដូច្នោះ។



# គាថាធម្មបទ

(ប្រារព្ធព្រះរាធត្ថេរ ជាបុគ្គលងាយប្រដៅបិដកភាគ៥២ទំព័រទី ៣៧)

**និធីនំវ បវត្តារំ យំ បស្សេ វជ្ជទស្សិនំ និគ្គយ្ហ**
**វាទឹ មេធាវឹ តាទិសំ បណ្ឌិតំ ភជេ តាទិសំ ភ**
**ជមានស្ស សេយ្យោ ហោតិ ន បាបិយោ។**

បុគ្គលគួរឃើញនូវអ្នកប្រាជ្ញណា ដែលជាអ្នកពោលសង្កត់សង្កិន ចង្អុលប្រាប់ទោស ថាដូចជាបុគ្គលអ្នកប្រាប់កំណប់ទ្រព្យឲ្យដូច្នោះ គួរគប់អ្នកប្រាជ្ញបែបនោះ (ព្រោះថា) កាលបុគ្គលគប់អ្នកប្រាជ្ញបែបនោះហើយ រមែងមានសេចក្តីគាប់ប្រសើរ ឥតមានទោសដ៏លាមកឡើយ។



# គាថាធម្មបទ

(ប្រារព្ធភិក្ខុពីរអង្គ ជាបុគ្គលមិនងាយប្រដៅ បិដកភាគ៥២ ទំព័រទី៣៨)

**ឱវទេយ្យានុសាសេយ្យ អសព្ភា ច និវារយេ**
**សតញ្ហិ សោ បិយោ ហោតិ អសតំ ហោតិ អប្បិយោ។**

បណ្ឌិតគួរទូន្មានប្រៀនប្រដៅ គួរហាមឃាត់នូវជនទាំងឡាយចាកអំពើអសប្បុរស បណ្ឌិតនោះ រមែងជាទីស្រឡាញ់របស់សប្បុរសតែម្យ៉ាង មិនជាទីស្រឡាញ់នៃអសប្បុរសឡើយ។

(ប្រារព្ធព្រះឆន្នត្ថេរ ដេរព្រះអគ្គសាវ័កទាំងពីរ បិដកភាគ៥២ ទំព័រទី៣៨)

**ន ភជេ បាបកេ មិត្តេ ន ភជេ បុរិសាធមេ**
**ភជេថ មិត្តេ កល្យាណេ ភជេថ បុរិសុត្តមេ។**

បុគ្គលមិនគួរគប់មិត្តអាក្រក់ មិនគួរគប់បុរសថោកទាប គួរគប់តែមិត្តដែលល្អ គួរគប់តែបុរសជាន់ខ្ពស់ ។



# គាថាធម្មបទ

(ប្រារព្ធបណ្ឌិតសាមណេរទូន្មានខ្លួនបានសម្រេចបិដកភាគ៥២ទំព័រទី ៣៨)

**ឧទកញ្ហិ នយន្តិ នេត្តិកា ឧសុការា នមយន្តិ តេជនំ**

**ទារុំ នមយន្តិ តច្ឆកា អត្តានំ ទមយន្តិ បណ្ឌិតា។**

ធម្មតាអ្នកបង្ហូរទឹក តែងបង្ហូរទឹកទៅ អ្នកធ្វើព្រួញ តែងពត់ព្រួញ(ឲ្យត្រង់)អ្នកចាំងឈើ តែងចាំងឈើ ឯបណ្ឌិតទាំងឡាយ តែងទូន្មានខ្លួន (ដូច្នោះដែរ)។

(ប្រារព្ធព្រះលកុណ្តកភទ្ទិយត្ថេរមិនក្រោធខឹងបិដកភាគ ៥២ ទំព័រទី ៣៨)

**សេលោ យថា ឯកឃនោ វាតេន ន សមីរតិ**

**ឯវំ និន្ទាបសំសាសុ ន សមិញ្ជន្តិ បណ្ឌិតា។**

ភ្នំថ្មតាន់ មិនរំភើបព្រោះខ្យល់ ដូចម្តេចមិញ បណ្ឌិតទាំងឡាយក៏មិនរំភើប ព្រោះពាក្យតិះដៀល និងពាក្យសរសើរ (ជាដើម) ដូច្នោះឯង។



# គាថាធម្មបទ

(ប្រារព្ធភិក្ខុ ៥០០អង្គ នៅចាំវស្សានៅវេរញ្ជា បិដកភាគ ៥២ ទំព័រទី ៣៩)

**សព្វត្ថ វេ សប្បុរិសា វជន្តិ ន កាមកាមា លបយន្តិ សន្តោ**

**សុខេន ផុដ្ឋា អថវា ទុខេន ន ឧច្ចាវចំ បណ្ឌិតា ទស្សយន្តិ។**

ពួកសប្បុរសតែងលះ (ឆន្ទរាគ) ក្នុងធម៌ទាំងពួង ពួកលោកអ្នកស្ងប់រមែងមិនរអែរអ៊ូវ ព្រោះសេចក្តីប្រាថ្នាក្នុងកាម ពួកបណ្ឌិតបើសេចក្តីសុខ ឬទុក្ខពាល់ត្រូវហើយ រមែងមិនសំដែងអាការឡើងចុះឡើយ។

(ប្រារព្ធមាតារបស់នាងកាណា បិដកភាគ ៥២ ទំព័រទី ៣៨)

**យថាបិ រហទោ គម្ភីរោ វិប្បសន្នោ អនាវិលោ**

**ឯវំ ធម្មានិ សុត្វាន វិប្បសីទន្តិ បណ្ឌិតា។**

អន្លង់ទឹកជ្រៅរមែងថ្លាមិនល្អក់យ៉ាងណា បណ្ឌិតទាំងឡាយបានស្តាប់ធម៌ទេសនាហើយ រមែងជ្រះថ្លាស៊ប់ស្ងួនយ៉ាងនោះ។



# គាថាធម្មបទ

(ប្រារព្ធការស្ដាប់ធម៌របស់អ្នកក្រុងសាវត្ថី បិដកភាគ ៥២-ទំព័រទី ៣៩)

អប្បកាតេមនុស្សេសុ យេជនាបារគាមិនោ
អថាយំ ឥតរាបជា តីរមេវានុធាវតិ។
យេចខោសម្មទក្ខាតេ ធម្មេ ធម្មានុវត្តិនោ
តេជនាបារមេស្សន្តិ មច្ចុធេយ្យំ សុទុត្តរំ។

បណ្ដាមនុស្សទាំងឡាយ ពួកជនណា ដែលឆ្លងដល់ត្រើយ គឺព្រះនិព្វាន ពួកជននោះ មានប្រមាណតិច ចំណែកពួកសត្វក្រៅនេះ រមែងស្ទុះទៅកាន់ត្រើយ (គឺសក្កាយទិដ្ឋិ)។

ជនទាំងឡាយណា ប្រព្រឹត្តតាមធម៌ក្នុងធម៌ ដែលព្រះតថាគតទ្រង់សំដែងទុកហើយ ដោយប្រពៃ ជនទាំងនោះ នឹងឆ្លងនូវលំនៅនៃមច្ចុ ដែលមិនងាយឆ្លងបាន ហើយដល់នូវព្រះនិព្វាន។



# គាថាធម្មបទ

ប្រារព្ធបញ្ហារបស់ពេទ្យជីវកទូលសួរព្រះអង្គអំពីអាពាធ

**គតទ្ធិនោ វិសោកស្ស វិប្បមុត្តស្ស សព្វធិ**

**សព្វគន្ថប្បហីនស្ស បរិឡាហោ ន វិជ្ជតិ។**

សេចក្តីក្តៅក្រហាយ រមែងមិនមានដល់អ្នកដែលមានផ្លូវឆ្ងាយ បានទៅដល់ហើយ មិនមានសេចក្តីសោក រួចស្រឡះចាកធម៌ទាំងពួង ( មានខន្ធជាដើម ) មានកិលេសជាគ្រឿងចាក់ស្រែះទាំងពួងលះបង់ហើយ ។

ប្រារព្ធព្រះមហាកស្សបត្ថេរដូចរាជហង្ស

**ឧយ្យុញ្ជន្តិ សតីមន្តោ ន និកេតេ រមន្តិ តេ**

**ហំសាវ បល្លលំ ហិត្វា ឱកមោកំ ជហន្តិ តេ។**

ព្រះខីណាស្រពទាំងឡាយ មានស្មារតី រមែងខ្វល់ខ្វាយ [ ក្នុងគុណដែលខ្លួនបានហើយ ឬក្នុងឈាននិងវិបស្សនា ដោយកិច្ច គឺ រំពឹង ចូល ចេញ អធិដ្ឋាន ឬពិចារណាមិនសម្រាក ] លោកមិនត្រេកអរក្នុងទីនៅអាស្រ័យ លះបង់ចោលស្រឡះនូវអាល័យទាំងអស់ ដូចហង្សលះបង់ភក់ហើរទៅ ដូច្នោះឯង។



ប្រារព្ធព្រះពេឡដ្ឋសីសត្ថេរ មិនសន្សំកិលេស

**យេសំ សន្និចយោ នត្ថិ　យេ បរិញ្ញាតភោជនា**
**សុញ្ញតោ អនិមិត្តោ ច　វិមោក្ខោ យេស គោចរោ**
**អាកាសេវ សកុន្តានំ　គតិ តេសំ ទុរន្នយា។**

ពួកជនណាមិនមានសេចក្តីសន្សំ ពួកជនណាកំណត់ដឹងភោជន ហើយ ជនណា មានសុញ្ញតវិមោក្ខ អនិមិត្ត-វិមោក្ខ និង(អប្បណិហិត វិមោក្ខ)ជាគោចរ គតិគឺដំណើររបស់ពួកជននោះៗ គេកម្រដឹងបាន ដូច ដំណើរនៃពួកសត្វស្លាបឰដ៏អាកាស ដូច្នោះ។

ប្រារព្ធព្រះអនុរុទ្ធត្ថេរ មិនពោលពាក្យសូមអាហារអ្នកស្រុក

**យស្សាសវា បរិក្ខីណា　អាហារេ ច អនិស្សិតោ**
**សុញ្ញតោ អនិមិត្តោ ច　វិមោក្ខោ យស្ស គោចរោ**
**អាកាសេវ សកុន្តានំ　បទន្តស្ស ទុរន្នយំ។**

ជនណា អស់អាសវៈហើយ ទាំងមិនអាស្រ័យ ( តណ្ហា និង ទិដ្ឋិ ) ក្នុងអាហារ ជនណា មានសុញ្ញតវិមោក្ខ អនិមិត្ត-វិមោក្ខ និង ( អប្បណិហិតវិមោក្ខ ) ជាគោចរ ដានជើងរបស់ជននោះ គេកម្រ ដឹងបាន ដូចដានជើងនៃពួកសត្វស្លាបឰដ៏អាកាស ដូច្នោះ។



# គាថាធម្មបទ

ប្រារព្ធព្រះមហាកច្ចាយនត្ថេរ ដែលព្រះឥន្ទ្រជ្រះថ្លា

**យស្សិន្ទ្រិយានិ សមថង្គតានិ អស្សា យថា សារថិនា សុទន្តា បហីនមានស្ស អនាសវស្ស ទេវាបិ តស្ស បិហយន្តិ តាទិនោ ។**

ឥន្ទ្រិយទាំងឡាយរបស់អ្នកណាដល់នូវការស្ងប់រម្ងាប់ ដូចសេះ ដែលនាយសារថី ហ្វឹកហ្វឺនល្អហើយ សូម្បីទេវតាទាំងឡាយ ក៏ស្រឡាញ់អ្នកនោះឯង ដែលជាអ្នកមានមានះលះបង់ហើយ មិនមានអាសវៈ ជាបុគ្គលមានចិត្តនឹងធឹងមិនញាប់ញ័រ ។

ប្រារព្ធព្រះសារីបុត្តមានចិត្តដូចផែនដី

**បឋវីសមោ នោ វិរុជ្ឈតិ ឥន្ទខីលូបមោ តាទិ សុព្វតោ រហទោវ អបេតកទ្ទមោ សំសារា ន ភវន្តិ តាទិនោ ។**

ភិក្ខុមានចិត្តដូចផែនដី មិនក្រោធ មានវត្តល្អ មានចិត្តនឹងធឹងដូចសសរគោល មានចិត្តថ្លា ដូចអន្លង់ប្រាសចាកភក់ សង្សារទាំងឡាយរបស់ភិក្ខុបែបនោះ រមែងមិនមាន ។



# គាថាធម្មបទ

ប្រារព្ធសាមណេរបែកព្រះនេត្រហើយមានចិត្តស្ងប់រម្ងាប់

សន្តំ តស្ស មនំ ហោតិ សន្តា វាចា ច កម្ម ច

សម្មទញ្ញា វិមុត្តស្ស ឧបសន្តស្ស តាទិនោ។

ចិត្តស្ងប់ វាចាស្ងប់ និងកាយកម្មស្ងប់ រមែងមានដល់លោកអ្នកដែលមានចិត្តផុតស្រឡះហើយ ព្រោះដឹងដោយប្រពៃ ជាអ្នកស្ងប់រម្ងាប់មានគោលជំហររឹងប៉ឹង។

ប្រារព្ធព្រះសារីបុត្ត ក្នុងរឿងមិនជឿអ្នកដទៃ

អស្សទ្ធោ អកតញ្ញូ ច សន្ធិច្ឆេទោ ច យោ នរោ

ហតាវកាសោ វន្តាសោ ស វេ ឧត្តមបោរិសោ។

នរជនណា មិនជឿអ្នកដទៃផង ដឹងព្រះនិព្វានដែលបច្ច័យធ្វើមិនបានផង កាត់នូវគ្រឿងតគឺវដ្តៈផង មានឱកាស ( គឺការកើតក្នុងភពថ្មី ) បានកម្ចាត់បង់ហើយផង មានសេចក្តីប្រាថ្នាខ្ជាក់ចោលហើយផង នរជននោះ ជាឧត្តមបុរស ។

“

# ធម្មទស្សន៍

“



## ១.(មខទេវជាតក) ព្រះរាជាពោធិសត្វពោលថា

សក់ទាំងឡាយនេះ នាំទៅនូវវ័យ (ស្កូវ) កើតដល់អញ ហើយទេវទូតកើតប្រាកដហើយ(នេះ)ជាសម័យនៃផ្នួសរបស់អញ។

(សុត្តន្តបិដកលេខ៥៨ ទំព័រ៤)

## ២. (សុខវិហារិជាតក) ឥសីពោធិសត្វពោលថា

ពួកជនដទៃ មិនរក្សាជនណា ម្យ៉ាងទៀត ជនណាមិនរក្សាពួកជនដទៃ បពិត្រព្រះរាជា ជននោះឯង មិនមានសេចក្តីអាឡោះអាល័យក្នុងកាទាំងឡាយទេ រមែងដេកជាសុខ។

(សុត្តន្តបិដកលេខ៥៨ ទំព័រ៤)

## ៣. កណ្ឌិនជាតក (សុត្តន្តបិដកលេខ៥៨ ទំព័រ៧)

(រុក្ខទេវតាពោធិសត្វ ពោលថា) ចូរតិះដៀលនូវបុរសអ្នកមានសរមុតចូលទៅ ដែលមានរបួសយ៉ាងខ្លាំង ស្រីជាបរិណាយិកា (អ្នកត្រួតត្រា) នៅក្នុងជនបទណា ចូរតិះដៀលនូវជនបទនោះ

ម្យ៉ាងទៀត សត្វទាំងឡាយណា លុះអំណាចពួកស្រី សត្វទាំងឡាយនោះ ក៏បណ្ឌិតតិះដៀលហើយ។

៤. មតកភត្តជាតក (សុត្តន្តបិដកលេខ៥៨ ទំព័រ៧)

(រុក្ខទេវតាពោធិសត្វ ពោលថា) បើពួកសត្វគប្បីដឹងយ៉ាងនេះថា ការកើតនៃជាតិនេះ រមែងនាំមកនូវទុក្ខ សត្វមិនត្រូវសម្លាប់សត្វ ព្រោះថា បុគ្គលអ្នកសម្លាប់សត្វ រមែងសោយសោក។

៥.អាយាចិតភត្តជាតក(សុត្តន្តបិដកលេខ៥៨ទំព័រ៩)

(រុក្ខទេវតា ពោលថា) បើអ្នកចង់រួច ត្រូវរួចក្នុងលោកខាងនាយ ព្រោះថា អ្នករួចឥឡូវនេះ គង់ជាប់ (ដោយបាបកម្ម) អ្នកប្រាជ្ញទាំងឡាយ មិនធ្លាប់រួចយ៉ាងនេះឡើយ ការរួចរបស់ជនពាលឈ្មោះថាចំណងវិញទេ។

៦.កុក្កុរជាតក (សុត្តន្តបិដកលេខ៥៨ ទំព័រ១១)

(សុនខពោធិសត្វពោលថា) ពួកឆ្កែណាកើតក្នុងរាជត្រកូល បរិបូរណ៍ដោយសម្បុរ និងកំឡាំង ចំរើនហើយក្នុងរាជត្រកូល ឆ្កែទាំងនោះ គេមិនសម្លាប់ទេ យើងទាំងឡាយត្រូវគេសម្លាប់ នេះមិនឈ្មោះថាសម្លាប់ដោយត្រឹមត្រូវឡើយ នេះឈ្មោះថាសម្លាប់តែឆ្កែដែលមានកំឡាំងខ្សោយ។

### ៧.មហិឡាមុខជាតក (សុត្តន្តបិដកលេខ៥៨ ទំព័រ១២)

(អាមាត្យពោធិសត្វ ពោលថា) ដំរីដ៏ឧត្តមឈ្មោះមហិឡាមុខៈ បានស្តាប់ពាក្យរបស់ចោរទាំងឡាយមុនហើយ ក៏ប្រព្រឹត្តតាម បានបោកសម្លាប់ (ហ្មដំរី) លុះបានស្តាប់ពាក្យពួកលោកអ្នកមានខ្លួនសង្រួមល្អហើយ ក៏បានតាំងនៅក្នុងគុណគ្រប់យ៉ាង។

### ៨.មច្ឆជាតក (សុត្តន្តបិដកលេខ៥៨ ទំព័រ១៦)

(ត្រីឈ្មោល ពោលថា) ត្រជាក់មិន (បៀតបៀន) អញទេ ក្តៅក៏មិន (បៀតបៀន) អញដែរ ការបៀតបៀនអញព្រោះលប មិនមានឡើយ។ អញ)។

ព្រួយតែត្រង់ត្រីញីសំគាល់អញថា ត្រីឈ្មោលនោះ ទៅរកត្រីញីដទៃ ដោយតម្រេក។

### ៩.តិត្តិរជាតក (សុត្តន្តបិដកលេខ៥៨ ទំព័រ១៧)

(ព្រះសាស្តា ទ្រង់ត្រាស់ថា) ពួកជនណា ជាអ្នកឈ្លាសក្នុងធម៌ ប្រព្រឹត្តកោតក្រែងចំពោះបុគ្គលដែលចំរើនហើយ ពួកជននោះ អ្នកជងគប្បីសរសើរ ក្នុងបច្ចុប្បន្នផង សម្បរលោក គឺសុគតិក៏កើត(ដល់ពួកជននោះ)ផង។

### ១០.លោសកជាតក (សុត្តន្តបិដកលេខ៥៨ ទំព័រ១៩)

(អាចារ្យទិសាបាមោក្ខពោធិសត្វ ពោលថា) បុគ្គលណា កាលលោកអ្នកប្រាថ្នាសេចក្តីចំរើន អនុគ្រោះដោយប្រយោជន៍ ទូ

ន្មាន មិនធ្វើតាមពាក្យប្រៀនប្រដៅ បុគ្គលនោះ រមែងសោកសៅ ដូចជាមិត្តវិន្ទុកៈប្រគោងជើងនៃមេពពៃសោកសៅ។

### ១១.វេឡុកជាតក (សុត្តន្តបិដកលេខ៥៨ ទំព័រ២០)

(ឥសីពោធិសត្វ ពោលថា) បុគ្គលណា កាលលោកអ្នកប្រាថ្នាសេចក្តីចំរើន អនុគ្រោះដោយប្រយោជន៍ ទូន្មាន មិនធ្វើតាមពាក្យប្រៀនប្រដៅ បុគ្គលនោះ រមែងដេកស្លាប់ ដូចឥសីជាបិតានៃពស់ឈ្មោះវេឡុកៈ។

### ១២.មកសជាតក (សុត្តន្តបិដកលេខ៥៨ ទំព័រ២០)

(ឈ្មួញពោធិសត្វ ពោលថា) បុគ្គលជាសត្រូវ តែប្រកបដោយប្រាជ្ញា ប្រសើរជាងឯបុគ្គលជាមិត្ត ដែលប្រាសចាកប្រាជ្ញា មិនប្រសើរឡើយ។

### ១៣.អារាមទូសកជាតក(សុត្តន្តបិដកលេខ៥៨ទំព័រ២១)

(បណ្ឌិតបុរសពោធិសត្វ ពោលថា) ការប្រព្រឹត្តិនូវសេចក្តីចំរើន របស់អ្នកមិនឈ្លាសក្នុងហេតុចំរើន រមែងមិននាំមកនូវសេចក្តីសុខទេ បុគ្គលឥតប្រាជ្ញា តែងធ្វើប្រយោជន៍ឲ្យសាបសូន្យ ដូចស្វារក្សាសួន (បានធ្វើប្រយោជន៍ឲ្យវិនាស)។

## ១៤.វេទព្ភជាតក (សុត្តន្តបិដកលេខ៥៨ ទំព័រ២១)

(កូនសិស្សពោធិសត្វ ពោលថា) បុគ្គលណា ប្រាថ្នាសេចក្តីចំរើនដោយខុសឧបាយ បុគ្គលនោះរមែងលំបាកដូចពួកចោរនៅក្នុងដែនចេតៈ បានសម្លាប់នូវវេទព្ភព្រាហ្មណ៍ ចោរទាំងអស់នោះក៏ដល់នូវសេចក្តីវិនាស។

## ១៥.មហាសីលវជាតក (សុត្តន្តបិដកលេខ៥៨ ទំព័រ២១)

(ព្រះរាជាសីលវៈពោធិសត្វ ពោលថា) បុរសជាបណ្ឌិតគប្បីប៉ុនប៉ងឲ្យមុតមាំ មិនគប្បីនឿយណាយឡើយ យើងឃើញខ្លួនយើងស្រាប់ហើយ យើងប្រាថ្នាយ៉ាងណា បានយ៉ាងនោះ។

## ១៦.ចូឡជនកជាតក (សុត្តន្តបិដកលេខ៥៨ ទំព័រ២១)

(ព្រះបាទជនកពោធិសត្វ ពោលថា) បុរសជាបណ្ឌិត ត្រូវតែប្រឹងប្រែង មិនត្រូវនឿយណាយឡើយ យើងឃើញខ្លួនយើងដែលឡើងអំពីទឹក កាន់គោកស្រាប់ហើយ។

## ១៧.បញ្ញាវុធជាតក (សុត្តន្តបិដកលេខ៥៨ ទំព័រ២៤)

(ព្រះសាស្តា ទ្រង់ត្រាស់ថា) បុរសណា មានចិត្តមិនរួញរា ចំរើនកុសលធម៌ ដើម្បីដល់នូវព្រះនិព្វាន ជាទីក្សេមចាកយោគៈ ដោយចិត្តមិនរួញរា បុរសនោះ គប្បីដល់នូវធម៌ជាគ្រឿងអស់ទៅនៃសំយោជនៈទាំងពួង តាមលំដាប់។

## ១៨.ទានវិទ្ធជាតក (សុត្តន្តបិដកលេខ៥៨ទំព័រ២៥)

(ក្រពើ ពោលថា) បពិត្រវានរិន្ទ បុគ្គលណា មានធម៌ ៤ ដូចអ្នក គឺសេចក្ដីទៀងទាត់ ១ ធម៌ គឺប្រាជ្ញាជាគ្រឿងពិចារណា ១ ព្យាយាមមិនដាច់ ១ ការលះ ១ បុគ្គលនោះ រមែងកន្លងបង់នូវសត្រូវបាន។

## ១៩.អសាតមន្តជាតក(សុត្តន្តបិដកលេខ៥៨ទំព័រ២៧)

(មាណព ពោលថា) ធម្មតាពួកស្ត្រីក្នុងលោក តែងមានសេចក្ដីប្រាថ្នា (ចំពោះបុរសដែលមានចិត្តជាប់ចំពាក់នឹងខ្លួន) វេលា (ឬកម្រិត) របស់ស្ត្រីទាំងនោះ មិនមានឡើយ (ស្ត្រីទាំងនោះ) ត្រេកត្រអាលផង រលោភលាំផង ដូចភ្លើងដែលឆេះវត្ថុគ្រប់យ៉ាង (មិនរើសមុខ) ខ្ញុំនឹងលះបង់ស្ត្រីទាំងនោះ ហើយបួសចំរើននូវវិវេកធម៌។

## ២០.តក្កជាតក (សុត្តន្តបិដកលេខ៥៨ទំព័រ២៨)

(ព្រះសាស្ដា ទ្រង់ត្រាស់ថា) (ធម្មតាស្ត្រី) ច្រើនខឹង មិនដឹងឧបការៈដែលគេធ្វើដល់ខ្លួន ជាអ្នកញុះញង់ បំបែកបំបាក់មិត្ត ម្នាលភិក្ខុ អ្នកចូរប្រព្រឹត្តព្រហ្មចរិយៈចុះ អ្នកនោះនឹងមិនវិនាសសេចក្ដីសុខ។

## ២១.ទុរាជានជាតក (សុត្តន្តបិដកលេខ៥៨ទំព័រ២៨)

(អាចារ្យទិសាបាមោក្ខពោធិសត្វ ពោលថា) អ្នកកុំត្រេកអរ (ថាស្ត្រីនេះ) ប្រាថ្នាអញ កុំសោកសៅ (ថាស្ត្រីនេះ) មិនប្រាថ្នាអញ

ភាពរបស់ស្រ្តីទាំងឡាយ ដឹងបានដោយក្រ ដូចជាដំណើរទៅនៃត្រីក្នុងទឹក។

## ២២.សាកេតជាតក (សុត្តន្តបិដកលេខ៥៨ទំព័រ២៩)

(ព្រះសាស្តា ទ្រង់ត្រាស់ថា) ចិត្តតាំងនៅស៊ប់ ឬក៏ចិត្តជ្រះថ្លា ក្នុងបុគ្គលណា ដែលខ្លួនមិនធ្លាប់ឃើញហើយ ជនតែងស្និទ្ធស្នាលចំពោះបុគ្គលនោះ ដោយពិត។

## ២៣.ទិសវន្តជាតក (សុត្តន្តបិដកលេខ៥៨ទំព័រ៣០)

(ពស់ ពោលថា) អញនឹងស្រូបយកពិសណាវិញ ដែលអញបានខ្ជាក់ចោលហើយ ព្រោះហេតុនៃជីវិត ចូរតិះដៀលនូវពិសដែលអញខ្ជាក់ចោលហើយនោះចុះ អញស្លាប់ប្រសើរជាងរស់នៅ។

## ២៤.កុទ្ទាលជាតក (សុត្តន្តបិដកលេខ៥៨ទំព័រ៣០)

(កុទ្ទាលកបណ្ឌិតពោធិសត្វ ពោលថា) សេចក្តីឈ្នះណាត្រឡប់ចាញ់វិញបាន សេចក្តីឈ្នះនោះ មិនឈ្មោះថា ឈ្នះប្រពៃទេ សេចក្តីឈ្នះណា មិនត្រឡប់ចាញ់វិញបាន សេចក្តីឈ្នះនោះទើបឈ្មោះថា ឈ្នះប្រពៃមែនពិត។

២៥.សីលវនាគជាតក (សុត្តន្តបិដកលេខ៥៨ទំព័រ៣១)

(រុក្ខទេវតា ពោលថា) ប្រសិនបើគេឲ្យផែនដីទាំងមូលដល់បុរសអកតញ្ញូ ជាអ្នកឃើញទោសជានិច្ច ក៏មិនគប្បីញ៉ាំងបុរសអកតញ្ញូនោះឲ្យត្រេកអរបានឡើយ។

២៦.សច្ចង្កិរជាតកទី៣ (សុត្តន្តបិដកលេខ៥៨ទំព័រ៣១)

(តាបសពោធិសត្វ ពោលថា) បានឮថា នរៈពួកខ្លះ ក្នុងលោកនេះបាននិយាយពិតយ៉ាងនេះថា ឧសដែលគេស្រង់ឡើងអំពីទឹក ប្រសើរជាង នរៈពួកខ្លះដែលគេស្រង់ឡើង (អំពីទឹក) មិនប្រសើរឡើយ។

២៧.រុក្ខធម្មជាតក ទី៤ (សុត្តន្តបិដកលេខ៥៨ទំព័រ៣២)

(រុក្ខទេវតាពោធិសត្វ ពោលថា) មានពួកញាតិច្រើននាក់ប្រពៃ សូម្បីពួកឈើ ដែលដុះក្នុងព្រៃច្រើនដើម ក៏ប្រពៃដែរ ឯខ្យល់ រមែងរំលំនូវឈើជាធំក្នុងព្រៃ បរិបូណ៌ដោយមែក និងប្រគាប ដែលតាំងនៅតែឯង។

២៨.អត្ថស្សទ្វារជាតកទី៤(បិដកលេខ៥៨ទំព័រ៣៧)

(សេដ្ឋីពោធិសត្វជាបិតា ពោលថា) បុគ្គលគប្បីប្រាថ្នាលាភដ៏ឧត្តម គឺការមិនមានរោគ១ សីល (គឺមារយាទ) ១ ការយល់ឃើញតាមបណ្ឌិតអ្នកដឹង១ ការឧស្សាហ៍ស្តាប់១ ការអនុវត្ត

ន៍នូវសុចរិតធម៌១ ការមិនរួញរានៃចិត្ត ១ ធម៌ទាំង ៦ នេះ ជាទ្វារទាំងជាប្រធាននៃសេចក្ដីចំរើន។

### ២៩.កិម្បក្កជាតក (សុត្តន្តបិដកលេខ៥៨ទំព័រ៣៧)

(ព្រះសាស្ដា ទ្រង់ត្រាស់ថា) បុគ្គលណា មិនយល់ទោសក្នុងអនាគត ហើយសេពកាមទាំងឡាយ (កាមទាំងនោះ) តែងសម្លាប់បុគ្គលនោះ ក្នុងទីបំផុតនៃផល ដូចបុគ្គលស៊ីផ្លែឈើកិម្បក្កៈ (ឈើពុល)។

### ៣០.សារម្ភជាតក (សុត្តន្តបិដកលេខ៥៨ទំព័រ៣៩)

(ព្រះសាស្ដា ទ្រង់ត្រាស់ថា) បុគ្គលគប្បីបញ្ចេញវាចាល្អតែម្យ៉ាង មិនគប្បីបញ្ចេញវាចាអាក្រក់ឡើយ ការបញ្ចេញវាចាល្អជាការប្រពៃ ព្រោះបុគ្គលបញ្ចេញវាចាអាក្រក់ រមែងក្ដៅក្រហាយ។

### ៣១.អកតញ្ញូជាតក (សុត្តន្តបិដកលេខ៥៨ទំព័រ៣៩)

(សេដ្ឋីពោធិសត្វ ពោលថា) បុគ្គលណា មិនដឹងនូវអំពើល្អ ដែលគេធ្វើហើយ នូវប្រយោជន៍ដែលគេធ្វើហើយ ក្នុងកាលមុនទេ បុគ្គលនោះកាលបើកិច្ចកើតព្រមហើយក្នុងកាលខាងក្រោយ រមែងមិនបាននូវបុគ្គលអ្នកធ្វើ(ឧបការគុណមុននោះជាគ្នា) ឡើយ។

### ៣២.មហាសារជាតក(សុត្តន្តបិដកលេខ៥៨ទំព័រ៤១)

(ព្រះរាជា ទ្រង់ត្រាស់ថា) ក្នុងកាលសង្គ្រាមកើតឡើង ពួកជនរមែងប្រាថ្នានូវបុរសអ្នកក្លៀវក្លា ក្នុងពួកអ្នកប្រឹក្សាការ គេ

ប្រាថ្នានូវបុរសអ្នកមានវាចាមិនរោយរាយ ក្នុងកាលមានបាយទឹកឆ្ងាញ់ គេប្រាថ្នានូវបុរសជាទីស្រឡាញ់ ក្នុងកាលអាថ៌ (កំបាំង) កើតឡើង គេប្រាថ្នានូវបណ្ឌិត។

### ៣៣.លោមហំសជាតក (សុត្តន្តបិដកលេខ៥៨ទំព័រ៤២)

(អាជីវកពោធិសត្វ ពោលថា) អាត្មាអញ ក្ដៅណាស់ហើយ ត្រជាក់ណាស់ហើយ នៅតែម្នាក់ឯង ក្នុងព្រៃគួរខ្លាច ជាមនុស្សអាក្រាត ទាំងមិនអាំងភ្លើង ជាអ្នកខ្វល់ខ្វាយក្នុងការស្វែងរក (នូវព្រហ្មចរិយធម៌) ប្រតិបត្តិ ដើម្បីមោនៈ។

### ៣៤.មហាសុទស្សនជាតក (សុត្តន្តបិដកលេខ៥៨ទំព័រ៤២)

(ព្រះពោធិសត្វ ពោលថា) សង្ខារទាំងឡាយមិនទៀងទេ មានការកើតឡើង និងសូន្យទៅជាធម្មតា (ព្រោះ) កើតឡើងហើយតែងរលត់ទៅវិញ ការរម្ងាប់សង្ខារទាំងនោះបាន ទើបនាំមកនូវសេចក្ដីសុខ។

### ៣៥.តេលបត្តជាតក (សុត្តន្តបិដកលេខ៥៨ទំព័រ៤៣)

(ព្រះសាស្ដា ទ្រង់ត្រាស់ថា) បុគ្គលគប្បីនាំទៅនូវភាជន៍ប្រេង ដែលពេញត្រឹមកណ្ដាប់មាត់ មិនឲ្យស្រក់ទៅបាន យ៉ាងណាមិញ (ព្រះយោគាវចរ) កាលប្រាថ្នានូវទិសដែលខ្លួនមិនធ្លាប់ទៅ គឺព្រះនិព្វាន គប្បីរក្សានូវចិត្តរបស់ខ្លួន (ដោយសតិ) យ៉ាងនោះដែរ។

### ៣៦.បរោសហស្សជាតក (សុត្តន្តបិដកលេខ៥៨ទំព័រ៤៤)

(មហាព្រហ្មពោធិសត្វ ពោលថា) ជនទាំងឡាយមកប្រជុំគ្នាហើយ សូម្បីជាងពាន់នាក់ ជនទាំងនោះឥតប្រាជ្ញា គប្បីកន្ទក់កន្ទេញអស់ ១០០ ឆ្នាំ បុរសណា ប្រកបដោយប្រាជ្ញា បានដឹងច្បាស់នូវអត្ថនៃភាសិត បុរសនោះ នៅតែម្នាក់ឯង ប្រសើរជាង។

### ៣៧.អសាតរូបជាតក (សុត្តន្តបិដកលេខ៥៨ទំព័រ៤៤)

(ព្រះសាស្តា ទ្រង់ត្រាស់ថា) របស់មិនឆ្ងាញ់ រមែងគ្របសង្កត់នូវបុគ្គលប្រមាទ ដោយសភាពនៃរបស់ឆ្ងាញ់ របស់មិនគួរស្រឡាញ់ រមែងគ្របសង្កត់នូវបុគ្គលប្រមាទ ដោយសភាពនៃរបស់គួរស្រឡាញ់ សេចក្ដីទុក្ខ រមែងគ្របសង្កត់នូវបុគ្គលប្រមាទ ដោយសភាពនៃសេចក្ដីសុខ។

### ៣៨.ទេរិជាតក (សុត្តន្តបិដកលេខ៥៨ទំព័រ៤៧)

(សេដ្ឋីពោធិសត្វ ពោលថា) បុគ្គលមានពៀរ អាស្រ័យនៅក្នុងទីណា អ្នកប្រាជ្ញមិនគប្បីនៅក្នុងទីនោះ បុគ្គលនៅក្នុងសំណាក់នៃបុគ្គលមានពៀរអស់មួយរាត្រី ឬពីររាត្រី ក៏នាំមកនូវសេចក្ដីទុក្ខ។

### ៣៩.សាលិត្តកជាតក (បិដកលេខ៥៨ទំព័រ៤៨)

(អាមាត្យពោធិសត្វ ពោលថា) ធម្មតា សិល្បសាស្ត្រយ៉ាងណាក៏ដោយ សុទ្ធតែសំរេចប្រយោជន៍ សូមព្រះអង្គទត ស្រុក

ស្លួយទាំង ៤ ទិស ដែលបុរសខ្វិនបានហើយ ដោយការផ្ដាត់ (អាចម៍ពពែ) នៃបុរសខ្វិន។

៤០.គន្ធារបញ្ហា (សុត្តន្តបិដកលេខ៥៨ទំព័រ៥០)

បពិត្រព្រះរាជាដ៏ប្រសើរ ព្រះអង្គរីករាយរមែងសំគាល់ថា បិតាប្រសើរជាងកូនយ៉ាងនេះ បើដូច្នោះ មានតែសត្វលារបស់ព្រះអង្គ នេះ ប្រសើរជាងសេះអស្សតរ ព្រោះសត្វលាជាបានៃសេះអស្សតរ។

៤១.តិត្តិរជាតក (សុត្តន្តបិដកលេខ៥៨ទំព័រ៥២)

(តាបសពោធិសត្វ ពោលថា) វាចាដែលខ្ពស់ហួស ខ្លាំងហួស ពោលហួសកាលវេលា រមែងសម្លាប់បុគ្គលពាល អ្នកឥតបញ្ញា ដូចជាវាចាដែលសម្លាប់នូវសត្វទទាដែលរងាវហួស។

៤២.វដ្ដកជាតក (សុត្តន្តបិដកលេខ៥៨ទំព័រ៥២)

(ចាបពោធិសត្វ ពោលថា) បុរសកាលមិនបានរិះគិត រមែងមិនបានសម្រេចនូវគុណវិសេសឡើយ អ្នកចូរឃើញផលនៃឧបាយដែលខ្ញុំគិតហើយ ព្រោះខ្ញុំរួចអំពីសេចក្ដីស្លាប់នឹងចំណង។

៤៣.ពន្ធនមោក្ខជាតក (សុត្តន្តបិដកលេខ៥៨ទំព័រ៥៣)

(បុរោហិតពោធិសត្វ ពោលថា) ជនពាលទាំងឡាយ ពោលក្នុងទីណា ពួកជនដែលមិនទាន់ជាប់ រមែងជាប់នៅក្នុងទី

នោះ អ្នកប្រាជ្ញទាំងឡាយ ពោលក្នុងទីណា ពួកជនសូម្បីជាប់ហើយ រមែងរួចក្នុងទីនោះ។

### ៤៤.កុសនាឡិជាតក (សុត្តន្តបិដកលេខ៥៨ទំព័រ៥៣)

(រុក្ខទេវតា ពោលថា) ជនស្មើគ្នាក្តី ទាំងជនប្រសើរជាងក្តី គប្បីធ្វើ (នូវមិត្តធម៌) សូម្បីជនម្នាក់ជាអ្នកថោកទាប ក៏គប្បីធ្វើ (នូវមិត្តធម៌ដែរ) ព្រោះមិត្តទាំងនោះ គប្បីធ្វើនូវប្រយោជន៍ដ៏ឧត្តមក្នុងកាលដែលមានសេចក្តីវិនាស។

### ៤៥.ទុម្មេធជាតក (សុត្តន្តបិដកលេខ៥៨ទំព័រ៥៤)

(ទ្រម៉កដំរី ពោលថា) បុគ្គលឥតប្រាជ្ញា បានយសបរិវារហើយ តែងប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ដល់ខ្លួន ទាំងប្រតិបត្តិដើម្បីបៀតបៀនដល់ខ្លួនឯងផង ដល់ជនទាំងឡាយដទៃផង។

### ៤៦.ឈានសោធនជាតក (បិដកលេខ៥៨ទំព័រ៥៩)

(មហាព្រហ្មពោធិសត្វ ពោលថា) ពួកសត្វណា មានសញ្ញា ពួកសត្វនោះ ក៏ទុគ៌ត (មិនបានសមាបត្តិ) ពួកសត្វណា មិនមានសញ្ញា ពួកសត្វនោះក៏ទុគ៌ត អ្នកចូរវៀរនូវសត្វទាំងពីរពួកនោះចេញ សុខដែលកើតអំពីសមាបត្តិនោះ ឈ្មោះថា មិនមានទីទួល គឺកិលេសឡើយ។

## ៤៧.ចន្ទាភជាតក (សុត្តន្តបិដកលេខ៦៥៨ទំព័រ៦០)

(មហាព្រហ្មពោធិសត្វ ពោលថា) បុគ្គលណា ក្នុងលោកនេះ បាននូវកសិណ មានពន្លឺដូចព្រះចន្ទ (ឱទាតកសិណ) មានពន្លឺដូចព្រះអាទិត្យ (បីតកសិណ) ដោយបញ្ញា បុគ្គលនោះរមែងទៅកើតក្នុងអាភស្សរព្រហ្មលោក ដោយឈានមិនមានវិតក្កៈ (ទុតិយជ្ឈាន)។

## ៤៨.សុវណ្ណហំសជាតក (បិដកលេខ៦៥៨ទំព័រ៦០)

(ព្រះសាស្តា ត្រាស់ថា) ទ្រព្យណា ដែលបុគ្គលបានមកហើយ បុគ្គលគប្បីត្រេកអរដោយទ្រព្យនោះ ព្រោះថាសេចក្តីល្មោភហួសៗជារបស់លាមក (ដូចនាងព្រាហ្មណី) ក៏សាបសូន្យចាកមាស ព្រោះចាប់ស្តេចហង្ស។

## ៤៩.គោធជាតក (សុត្តន្តបិដកលេខ៦៥៨ទំព័រ៦០)

(ទន្សងពោធិសត្វ ពោលថា) ម្នាលតាបសឥតបញ្ញា ប្រយោជន៍អ្វីដោយជដារបស់អ្នក ប្រយោជន៍អ្វីដោយស្បែកខ្លាឃ្មុំរបស់អ្នក ព្រោះគ្រឿងសាំញាំដោយ (រាគាទិក្កិលេស) មានខាងក្នុងរបស់អ្នក អ្នកខំដុះខាត់តែខាងក្រៅទេ។

៥០.គោធជាតក (សុត្តន្តបិដកលេខ៥៨ទំព័រ៦៣)

(ស្តេចទន្សងពោធិសត្វ ពោលថា) បុគ្គលអ្នកសេពគប់នូវជនបាប រមែងមិនដល់នូវសេចក្តីសុខពិតទេ ដូចជាត្រកូលទន្សង មិនបានសេចក្តីសុខ ព្រោះត្រគួត រមែងញុំាងខ្លួនឲ្យដល់នូវសេចក្តីវិនាស។

៥១.សញ្ជីវជាតក (សុត្តន្តបិដកលេខ៥៨ទំព័រ៦៦)

(អាចារ្យទិសាបាមោក្ខពោធិសត្វ ពោលថា) បុគ្គលណាលើកដំកើងនូវជន ជាអសប្បុរសផង ចូលទៅសេពគប់នូវជនជាអសប្បុរសផង ជនជាអសប្បុរសនោះ រមែងធ្វើនូវបុគ្គលនោះឯងឲ្យទៅជាអាហារ ដូចខ្លានិងសញ្ជីវមាណព។

៥២.សិគាលជាតក (សុត្តន្តបិដកលេខ៥៨ទំព័រ៦៩)

(រាជសីហ៍ពោធិសត្វ ពោលថា) ការងារទាំងឡាយនោះញុំាងបុគ្គលអ្នកមានការងារមិនបានពិចារណាដោយត្រឹមត្រូវ ឲ្យសំរេចដោយរួសរាន់ឲ្យក្តៅក្រហាយ ដូចជាវត្ថុក្តៅដែលបុគ្គលពមចូលទៅក្នុងមាត់។

៥៣.រាជោវាទជាតក ទី១ (បិដកលេខ៥៨ទំព័រ៦៨)

(សារថីរបស់ព្រះបាទរាជាពល្លិកៈ ពោលថា) ព្រះបាទពល្លិកៈ រមែងបោះនូវរបស់មាំដល់បុគ្គលអ្នកមាំ ឈ្នះនូវបុគ្គលទន់

ដោយកិរិយាទន់ ឈ្នះនូវសប្បុរស ដោយសប្បុរស ឈ្នះនូវអសប្បុរស ដោយអសប្បុរស ព្រះរាជានេះ (មានសីល និងអាចារៈ) ប្រាកដដូច្នេះ ម្នាលសារថី អ្នកចូរចៀសចេញអំពីផ្លូវទៅ។

## ៥៤.រាជោវាទជាតក ទី១ (បិដកលេខ៥៨ទំព័រ៦៨)

(សារថីរបស់ព្រះបាទពារាណសី ពោលថា) ព្រះរាជាគប្បីឈ្នះបុគ្គលអ្នកក្រោធ ដោយសេចក្តីមិនក្រោធ គប្បីឈ្នះអសប្បុរស ដោយសប្បុរស គប្បីឈ្នះបុគ្គលកំណាញ់ ដោយការឲ្យ គប្បីឈ្នះបុគ្គលអ្នកពោលពាក្យកុហក ដោយការពោលពាក្យពិត ព្រះរាជានេះ (មានសីល និងអាចារៈ) ប្រាកដដូច្នេះ ម្នាលសារថី អ្នកចូរចៀសចេញអំពីផ្លូវទៅ។ ចប់ រាជោវាទជាតក ទី១។

## ៥៥.សន្ថវជាតក (សុត្តន្តបិដកលេខ៥៨ទំព័រ៧៦)

(តាបសពោធិសត្វ ពោលថា) ការស្និទ្ធស្នាលណា ជាមួយនឹងបុរសលាមក របស់ដទៃលាមកក្រៃលែងជាងការស្និទ្ធស្នាល (នោះ) មិនមានទេ ដូចជាភ្លើងដែលយើងឲ្យឆ្អែតដោយសប្បិ និងបាយាស នៅតែឆេះខ្ទមស្លឹកដែលយើងធ្វើហើយដោយលំបាក។

## ៥៦.អសទិសជាតក ទី១ (សុត្តន្តបិដកលេខ៥៨ទំព័រ៨៨)

(ព្រះសាស្តា ត្រាស់ថា) ព្រះរាជបុត្រទ្រង់ព្រះនាមអសទិសៈ ជាខ្មាន់ធ្នូមានកំឡាំងច្រើន បាញ់ធ្នូទៅក្នុងទីឆ្ងាយ បាញ់ត្រង់ទំលាយនូវកងទ័ពធំបាន។

ព្រះរាជកុមារទ្រង់ច្បាំងនឹងសត្រូវទាំងពួងបាន តែមិនបានបៀតបៀននូវជនណាមួយឡើយ ធ្វើព្រះអនុជឲ្យសួស្ដី ហើយដល់នូវសេចក្ដីសង្រួម គឺចូលទៅកាន់ផ្នួស។

## ៥៧.សង្គាមាវចរជាតក (បិដកលេខ៥៨ទំព័រ៨៨)

(ទម្រង់ដំរីពោធិសត្វ ពោលថា) ម្នាលដំរី អ្នកល្បីថាជាសត្វចូល សង្គ្រាម មានកំឡាំងក្លៀវក្លា ហេតុអ្វី មកដល់ក្លោងទ្វារហើយ ក៏ថយក្រោយទៅវិញ។

ម្នាលដំរី អ្នកចូរញាំញីទំលាយនូវសន្ទះទ្វារ ហើយដកគើចសសរខឿនចេញឲ្យឆាប់ ចូរញាំញីនូវក្លោងទារ ហើយចូលទៅយ៉ាងឆាប់។

## ៥៨.វាលោទកជាតក (សុត្តន្តបិដកលេខ៥៨ទំព័រ៨៩)

(ព្រះរាជាពារាណសី ត្រាស់ថា) សេចក្ដីស្រវឹងកើតឡើងដល់ពួកលា ព្រោះផឹកទឹកដែលច្រស់ដោយសម្បកក្រថៅ មានរសតិច ជារបស់ថោកទាប សេចក្ដីស្រវឹងមិនកើតដល់ពួកសេះសិន្ធវៈ ព្រោះផឹកទឹកមានរសដ៏ឧត្តមនេះទេ។

(អមាត្យពោធិសត្វ ក្រាបទូលថា) បពិត្រព្រះអង្គជាធំជាងជន សត្វដែលមានជាតិថោកទាប ផឹកទឹកមានរសតិចហើយ សត្វនោះ ត្រូវទឹកមានរសតិចពាល់ត្រូវហើយ រមែងស្រវឹង ចំណែក

សត្វអ្នកនាំនូវធុរៈ និងមានមារយាទ កើតក្នុងត្រកូល (ដ៏ខ្ពស់) បាន ផឹកទឹកមានរសដ៏ប្រសើរ រមែងមិនស្រវឹងទេ។

## ៥៩.អនភិរតិជាតក(សុត្តន្តបិដកលេខ៥៨ទំព័រ៩០)

(អាចារ្យទិសាបាមោក្ខ ពោលថា) កាលបើទឹកល្អក់មិនថ្លា បុគ្គលរមែងមើលមិនឃើញនូវខ្យងខ្ចៅ និងគ្រួស ដីខ្សាច់ ហ្វូងត្រី យ៉ាងណាមិញ កាលបើចិត្តល្អក់ហើយ បុគ្គលនោះ ក៏មើលមិន ឃើញនូវប្រយោជន៍ខ្លួន និងប្រយោជន៍អ្នកដទៃ យ៉ាងនោះដែរ។

កាលបើទឹកថ្លាស្អាត បុគ្គលរមែងមើលឃើញនូវខ្យងខ្ចៅ និងក្រួស ខ្សាច់ ហ្វូងត្រីបាន យ៉ាងណាមិញ កាលបើចិត្តមិនល្អក់ ហើយ បុគ្គលនោះ ក៏មើលឃើញនូវប្រយោជន៍របស់ខ្លួន និង ប្រយោជន៍អ្នកដទៃបាន យ៉ាងនោះដែរ។

## ៦០.ទធិវាហនជាតក(សុត្តន្តបិដកលេខ៥៨ទំព័រ៩១)

(ព្រះបាទទធិវាហនៈ ត្រាស់សួរថា) ក្នុងកាលមុន ដើម ស្វាយនេះ ប្រកបដោយពណ៌ ក្លិន និងរស បាននូវគ្រឿងសក្ការៈ បូជានោះដដែល ហេតុអ្វីស្វាយ ក៏មានផ្លែល្វីងទៅវិញ។

(អាមាត្យពោធិសត្វ ពោលថា) បពិត្រព្រះរាជាទ្រង់ព្រះ នាមទធិវាហនៈ ស្វាយរបស់ព្រះអង្គ មានដើមស្ដៅដុះរួបរិតជុំវិញ ឫសប្រទាក់គ្នាដោយឫស មែកពាក់ព័ន្ធគ្នានឹងមែក ដោយការនៅជាមួយ

នឹងដើមស្ដៅមិនមានរសផ្អែម ព្រោះហេតុនោះ បានជាស្វាយត្រឡប់ជាមានផ្លែល្វីងទៅវិញ។

## ៦១.សីហកោត្ថុកជាតក (សុត្តន្តបិដកលេខ៥៨ទំព័រ៩២)

(កូនសីហៈ ពោលថា) សីហៈ១ នោះ មានម្រាមជើងជាសីហៈ មានក្រចកជាសីហៈ ឈរដោយជើងជាសីហៈ តែបន្លឺឡើងប្លែកម្នាក់ឯងក្នុងហ្វូងសីហៈ។

(សីហពោធិសត្វ ពោលថា) ម្នាលកូនស្ដេចសីហៈ អ្នកកុំបន្លឺឡើយ អ្នកចូរមានសម្លេងតិចនៅក្នុងព្រៃ ហ្វូងសត្វគប្បីស្គាល់អ្នកដោយសម្លេង ព្រោះសម្លេងអ្នកមិនមែនកាត់បានមកខាងឪពុកឡើយ។

## ៦២.សីលានិសំសជាតក (សុត្តន្តបិដកលេខ៥៨ទំព័រ៩៣)

(សមុទ្ទទេវតាពោធិសត្វ ពោលថា) អ្នកចូរឃើញផលនៃសទ្ធា សីល ចាគៈ នាគនេះ មានភេទដូចជាសំពៅ នាំឧបាសកមានសទ្ធា។

# បើគ្មានធម៌៣យ៉ាងនេះ ព្រះពុទ្ធក៏មិនមានក្នុងលោក

(តយោធម្មសូត្រ)

ម្នាលភិក្ខុទាំងឡាយ (ប្រសិនបើ) ធម៌ទាំង ៣ នេះ មិនមានក្នុងលោកទេ ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ក៏មិនគប្បីកើតឡើង ក្នុងលោកឡើយ ទាំងធម្មវិន័យ ដែលព្រះតថាគតសំដែងហើយ ក៏មិនភ្លឺច្បាស់ក្នុងលោកដែរ។ ធម៌ទាំង ៣ តើដូចម្តេច។ គឺជាតិ ១ ជរា ១ មរណៈ ១។ ម្នាលភិក្ខុទាំងឡាយ (ប្រសិនបើ) ធម៌ទាំង ៣ នេះ មិនមានក្នុងលោកទេ ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ក៏មិនគប្បីកើតឡើងក្នុងលោក ទាំងធម្មវិន័យ ដែលព្រះតថាគតសំដែងហើយ ក៏មិនភ្លឺច្បាស់ ក្នុងលោកនេះដែរ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៣ នេះ រមែងមានក្នុងលោក ព្រោះហេតុណា ព្រោះហេតុនោះ ទើបព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ កើតឡើងក្នុងលោក ព្រោះហេតុនោះ ទើបធម្មវិន័យ ដែលព្រះតថាគតសំដែងហើយ ភ្លឺច្បាស់ក្នុងលោកដែរ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនបានលះបង់ធម៌ទាំង ៣ ហើយ មិនគួរលះបង់ជាតិ លះបង់ជរា លះបង់មរណៈបានទេ។ ធម៌ទាំង ៣ តើដូចម្តេច។ គឺមិនលះបង់រាគៈ ១ មិនលះបង់ទោសៈ ១ មិនលះបង់មោហៈ ១។ ម្នាលភិក្ខុទាំងឡាយ បុគ្គល កាលមិនលះបង់ធម៌ទាំង ៣ នេះចេញហើយ មិនគួរលះបង់ជាតិ លះបង់ជរា លះបង់មរណៈបានទេ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនលះបង់ធម៌ទាំង ៣ ចេញហើយ មិនគួរលះបង់រាគៈ លះបង់ទោសៈ លះបង់មោហៈបានទេ។ ធម៌ទាំង

៣ តើដូចម្តេច។ គឺមិនលះបង់សក្កាយទិដ្ឋិ ១ មិនលះបង់វិចិកិច្ឆា ១ មិនលះបង់សីលព្វតបរាមាសៈ១។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនលះបង់ធម៌ទាំង ៣ នេះហើយ មិនគួរលះបង់រាគៈ លះបង់ទោសៈ លះបង់មោហៈបានទេ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនលះបង់ធម៌ទាំង ៣ ហើយ មិនគួរលះបង់សក្កាយទិដ្ឋិ លះបង់វិចិកិច្ឆា លះបង់សីលព្វតបរាមាសៈបានទេ។ ធម៌ទាំង ៣ តើដូចម្តេច។ គឺមិនលះបង់នូវការធ្វើទុកក្នុងចិត្តដោយមិនមែនឧបាយ ១ មិនលះបង់នូវកិរិយាសេពគប់នូវផ្លូវខុស ១ មិនលះបង់នូវភាពរួញរានៃចិត្ត ១។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនបានលះបង់ធម៌ទាំង ៣ នេះចេញហើយ មិនគួរលះបង់សក្កាយទិដ្ឋិ លះបង់វិចិកិច្ឆា លះបង់សីលព្វតបរាមាសៈបានទេ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនបានលះបង់ធម៌ទាំង ៣ ចេញហើយ មិនគួរលះបង់នូវការធ្វើទុកក្នុងចិត្ត ដោយមិនមែនឧបាយ លះបង់នូវកិរិយាសេពគប់នូវផ្លូវខុស លះបង់នូវភាពរួញរានៃចិត្តបានទេ។ ធម៌ទាំង ៣ តើដូចម្តេច។ គឺមិនលះបង់ការភ្លេចស្មារតី ១ មិនលះបង់សេចក្តីមិនដឹងខ្លួន ១ មិនលះបង់សេចក្តីរវើរវាយនៃចិត្ត ១។ ម្នាលភិក្ខុទាំងឡាយ បុគ្គល កាលមិនបានលះបង់ធម៌ទាំង ៣ នេះហើយ មិនគួរលះបង់នូវការធ្វើទុកក្នុងចិត្ត ដោយមិនមែនឧបាយ លះបង់នូវកិរិយាសេពគប់នូវផ្លូវខុស លះបង់នូវភាពរួញរានៃចិត្តបានទេ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនបានលះបង់ធម៌ទាំង ៣ ហើយ មិនគួរលះបង់នូវការភ្លេចស្មារតី លះបង់នូវសេចក្តីមិនដឹងខ្លួន លះបង់នូវសេចក្តីរវើរវាយនៃចិត្តបានទេ។ ធម៌ទាំង ៣ តើដូចម្តេច។ គឺលះបង់នូវភាពនៃសេចក្តីប្រាថ្នា ដើម្បីមិន

ឃើញនូវព្រះអរិយៈទាំងឡាយ ១ មិនលះបង់នូវភាពនៃសេចក្តីប្រាថ្នា ដើម្បីមិនស្តាប់នូវអរិយធម៌ ១ មិនលះបង់នូវភាពនៃចិត្តប្រកាន់ ១។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនបានលះបង់ធម៌ទាំង ៣ នេះហើយ មិនគួរលះបង់នូវការភ្លេចស្មារតី លះបង់នូវសេចក្តីមិនដឹងខ្លួន លះបង់នូវសេចក្តីរវើរវាយ នៃចិត្តបានទេ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនបានលះបង់ធម៌ទាំង ៣ ចេញហើយ មិនគួរលះបង់នូវភាពនៃសេចក្តីប្រាថ្នា ដើម្បីមិនឃើញនូវព្រះអរិយៈទាំងឡាយ លះបង់នូវភាពនៃសេចក្តីប្រាថ្នា ដើម្បីមិនស្តាប់នូវអរិយធម៌ លះបង់នូវភាពនៃចិត្តប្រកួតប្រកាន់បានទេ។ ធម៌ទាំង ៣ តើដូចម្តេច។ គឺមិនលះបង់នូវសេចក្តីរវើរវាយ ១ មិនលះបង់នូវសេចក្តីមិនសង្រួម ១ មិនលះបង់នូវភាពទ្រុស្តសីល ១។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនបានលះបង់ធម៌ទាំង ៣ នេះហើយ មិនគួរលះបង់នូវភាពនៃសេចក្តីប្រាថ្នា ដើម្បីមិនឃើញនូវព្រះអរិយៈទាំងឡាយ លះបង់នូវភាពនៃសេចក្តីប្រាថ្នា ដើម្បីមិនស្តាប់នូវអរិយធម៌ទាំងឡាយ លះបង់នូវភាពនៃចិត្តប្រកួតប្រកាន់បានទេ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនបានលះបង់ធម៌ទាំង ៣ ហើយ មិនគួរលះបង់នូវចិត្តរវើរវាយ លះបង់នូវសេចក្តីមិនសង្រួម លះបង់នូវភាពទ្រុស្តសីលបានទេ។ ធម៌ទាំង ៣ តើដូចម្តេច។ គឺមិនលះបង់នូវភាពមិនមានសទ្ធា ១ មិនលះបង់នូវភាពមិនដឹងនូវពាក្យពោល ១ មិនលះបង់នូវសេចក្តីខ្ជិល ១។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនបានលះបង់ធម៌ ៣ នេះហើយ មិនគួរលះបង់នូវសេចក្តីរវើរវាយ លះបង់នូវសេចក្តីមិនសង្រួម លះបង់នូវភាពទ្រុស្តសីលបានទេ។ ម្នាលភិក្ខុ

ទាំងឡាយ បុគ្គលកាលមិនបានលះបង់ធម៌ទាំង ៣ ចេញហើយ មិនគួរលះបង់នូវភាពមិនមានសទ្ធា លះបង់នូវភាពមិនដឹងពាក្យពោល លះបង់នូវសេចក្ដីខ្ជិលបានទេ។ ធម៌ទាំង ៣ តើដូចម្ដេច។ គឺមិនលះបង់នូវសេចក្ដីមិនអើពើ ១ មិនលះបង់នូវភាពជាអ្នកប្រដៅក្រ ១ មិនលះបង់នូវភាពនៃបាបមិត្រ ១។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនបានលះបង់ធម៌ទាំង ៣ នេះហើយ មិនគួរលះបង់នូវភាពមិនមានសទ្ធា លះបង់នូវភាពមិនដឹងពាក្យពោល លះបង់នូវសេចក្ដីខ្ជិលបានទេ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល កាលមិនបានលះបង់ធម៌ទាំង ៣ ហើយ មិនគួរលះបង់នូវសេចក្ដីអើពើ លះបង់ភាពនៃបាបមិត្របានទេ។ ធម៌ទាំង ៣ តើដូចម្ដេច។ គឺមិនលះបង់នូវសេចក្ដីមិនអៀនខ្មាសនឹងអំពើទុច្ចរិត ១ មិនលះបង់នូវសេចក្ដីក្ដៅក្រហាយនឹងអំពើទុច្ចរិត ១ មិនលះបង់នូវសេចក្ដីធ្វេសប្រហែស ១។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនបានលះបង់ធម៌ទាំង ៣ នេះហើយ មិនគួរលះបង់នូវសេចក្ដីមិនអើពើ លះបង់នូវភាពជាអ្នកប្រដៅក្រ លះបង់នូវភាពនៃបាបមិត្របានទេ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះ ជាអ្នកមិនមានសេចក្ដីអៀនខ្មាស មិនមានសេចក្ដីក្ដៅក្រហាយនឹងអំពើទុច្ចរិត ជាអ្នកប្រមាទ។ កាលបើបុគ្គលនោះ ជាអ្នកប្រមាទហើយ មិនគួរលះបង់នូវសេចក្ដីមិនអើពើ លះបង់នូវភាពជាអ្នកប្រដៅក្រ លះបង់នូវភាពនៃបាបមិត្របានទេ។ កាលបើបុគ្គលនោះ មានបាបមិត្រហើយ មិនគួរលះបង់នូវភាពមិនមានសទ្ធា លះបង់នូវភាពមិនដឹងពាក្យពោល លះបង់នូវសេចក្ដីខ្ជិលបានទេ។ កាលបើបុគ្គលនោះ មានសេចក្ដីខ្ជិលហើយ មិនគួរលះបង់នូវសេចក្ដីរវើរវាយ

លះបង់នូវសេចក្តីមិនសង្រួម លះបង់នូវភាពទ្រុស្តសីលបានទេ។ កាលបើបុគ្គលនោះ មានភាពជាអ្នកទ្រុស្តសីលហើយ មិនគួរលះបង់ភាពនៃសេចក្តីប្រាថ្នា ដើម្បីមិនឃើញព្រះអរិយៈទាំងឡាយ លះបង់នូវភាពនៃសេចក្តីប្រាថ្នា ដើម្បីមិនស្តាប់នូវអរិយធម៌ លះបង់នូវភាពនៃចិត្តប្រកួតប្រកាន់បានទេ។ កាលបើបុគ្គលនោះ មានភាពនៃចិត្តប្រកួតប្រកាន់ហើយ មិនគួរលះបង់នូវការភ្លេចស្មារតី លះបង់នូវសេចក្តីមិនដឹងខ្លួន លះបង់នូវចិត្តរវើរវាយបានទេ។ កាលបើបុគ្គលនោះ មានចិត្តរវើរវាយហើយ មិនគួរលះបង់នូវការធ្វើទុកក្នុងចិត្ត ដោយមិនមែនឧបាយ លះបង់នូវកិរិយាសេពគប់នូវផ្លូវខុស លះបង់នូវសេចក្តីរួញរានៃចិត្តបានទេ។ កាលបើបុគ្គលនោះ មានចិត្តរួញរា មិនគួរលះបង់នូវសក្កាយទិដ្ឋិ លះបង់នូវវិចិកិច្ឆា លះបង់នូវសីលព្វតបរាមាសៈបានទេ។កាលបើបុគ្គលនោះ មានវិចិកិច្ឆា មិនគួរលះបង់រាគៈ លះបង់ទោសៈ លះបង់មោហៈបានទេ។ កាលបើមិនបានលះបង់រាគៈ មិនបានលះបង់ទោសៈ មិនបានលះបង់មោហៈ មិនគួរលះបង់ជាតិ លះបង់ជរា លះបង់មរណៈបានឡើយ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ បានហើយ ទើបគួរលះបង់ជាតិ លះបង់ជរា លះបង់មរណៈបាន។ ធម៌ទាំង ៣ តើដូចម្តេចខ្លះ។ គឺលះបង់រាគៈ ១ លះបង់ទោសៈ ១ លះបង់មោហៈ ១។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់ធម៌ទាំង ៣ នេះចេញបានហើយ ទើបគួរលះបង់ជាតិ លះបង់ជរា លះបង់មរណៈបាន។ ម្នាលភិក្ខុទាំងឡាយ បុគ្គល កាលលះបង់ធម៌ទាំង ៣ បានហើយ ទើបគួរលះបង់រាគៈ លះបង់ទោសៈ លះបង់មោហៈបាន។ ធម៌ទាំង ៣ តើដូចម្តេច។ គឺ

លះបង់សក្កាយទិដ្ឋិ ១ លះបង់វិចិកិច្ឆា ១ លះបង់សីលព្វតបរាមាសៈ ១។ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ នេះបាន ហើយ ទើបគួរលះបង់រាគៈ លះបង់ទោសៈ លះបង់មោហៈបាន។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ បានហើយ ទើប គួរលះបង់សក្កាយទិដ្ឋិ លះបង់វិចិកិច្ឆា លះបង់សីលព្វតបរាមាសៈ បាន។ ធម៌ទាំង ៣ តើដូចម្តេច។ គឺលះបង់ការធ្វើទុកក្នុងចិត្តដោយ មិនមែនឧបាយ ១ លះបង់ការសេពគប់ផ្លូវខុស ១ លះបង់សេចក្តី រួញរានៃចិត្ត ១។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ នេះបានហើយ ទើបគួរលះបង់សក្កាយទិដ្ឋិ លះបង់វិចិកិច្ឆា លះបង់ សីលព្វតបរាមាសៈបាន។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ ធម៌ទាំង ៣ បានហើយ ទើបគួរលះបង់ការធ្វើទុកក្នុងចិត្ត ដោយមិន មែនឧបាយ លះបង់នូវការសេពគប់នូវផ្លូវខុស លះបង់នូវសេចក្តី រួញរានៃចិត្តបាន។ ធម៌ទាំង ៣ តើដូចម្តេច។ គឺលះបង់នូវការភ្លេច ស្មារតី ១ លះបង់នូវសេចក្តីមិនដឹងខ្លួន ១ លះបង់នូវសេចក្តីរវើរវាយ នៃចិត្ត ១។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ បាន ហើយ ទើបគួរលះបង់នូវការធ្វើទុកក្នុងចិត្ត ដោយមិនមែនឧបាយ លះបង់នូវការសេពគប់នូវផ្លូវខុស លះបង់នូវសេចក្តីរួញរានៃចិត្តបា ន។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ បានហើយ ទើបគួរលះបង់នូវការភ្លេចស្មារតី លះបង់នូវសេចក្តីមិនដឹងខ្លួន លះបង់នូវសេចក្តីរវើរវាយនៃចិត្តបាន។ ធម៌ ទាំង ៣ តើដូចម្តេច។ គឺ លះបង់នូវសេចក្តីប្រាថ្នា ដើម្បីមិនឃើញនូវព្រះអរិយៈទាំងឡាយ ១ លះបង់នូវសេចក្តីប្រាថ្នា ដើម្បីមិនស្តាប់នូវអរិយធម៌ ១ លះបង់នូវ

ចិត្តប្រកួតប្រកាន់ ១។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ នេះបានហើយ ទើបគួរលះបង់នូវការភ្លេចស្មារតី លះបង់នូវសេចក្ដីមិនដឹងខ្លួន លះបង់នូវសេចក្ដីរវើរវាយនៃចិត្តបាន។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ បានហើយ ទើបគួរលះបង់សេចក្ដីប្រាថ្នា ដើម្បីមិនឃើញនូវព្រះអរិយៈទាំងឡាយ លះបង់នូវសេចក្ដីប្រាថ្នា ដើម្បីមិនស្ដាប់នូវអរិយធម៌ លះបង់នូវចិត្តប្រកួតប្រកាន់បាន។ ធម៌ទាំង ៣ តើដូចម្ដេច។ គឺលះបង់នូវសេចក្ដីរវើរវាយ ១ លះបង់នូវសេចក្ដីមិនសង្រួម ១ លះបង់នូវភាពទ្រុស្ដសីល ១។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ នេះបានហើយ ទើបគួរលះបង់នូវសេចក្ដីប្រាថ្នា ដើម្បីមិនឃើញនូវព្រះអរិយៈទាំងឡាយ លះបង់នូវសេចក្ដីប្រាថ្នា ដើម្បីមិនស្ដាប់នូវអរិយធម៌ លះបង់នូវចិត្តប្រកួតប្រកាន់បាន។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ បានហើយ ទើបគួរលះបង់នូវសេចក្ដីរវើរវាយ លះបង់នូវសេចក្ដីមិនសង្រួម លះបង់នូវភាពទ្រុស្ដសីល។ ធម៌ទាំង ៣ តើដូចម្ដេច។ គឺលះបង់នូវភាពមិនមានសទ្ធា ១ លះបង់នូវសេចក្ដីមិនដឹងនូវពាក្យពោល ១ លះបង់នូវសេចក្ដីខ្ជិល ១។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ នេះបានហើយ ទើបគួរលះបង់នូវសេចក្ដីរវើរវាយ លះបង់នូវសេចក្ដីមិនសង្រួម លះបង់នូវភាពទ្រុស្ដសីលបាន។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ បានហើយ ទើបគួរលះបង់នូវភាពមិនមានសទ្ធា លះបង់នូវសេចក្ដីមិនដឹងនូវពាក្យពោល លះបង់នូវសេចក្ដីខ្ជិលបាន។ ធម៌ទាំង ៣ តើដូចម្ដេច។ គឺលះបង់នូវសេចក្ដីមិនអើពើ

១ លះបង់នូវភាពជាអ្នកប្រដៅក្រ ១ លះបង់នូវភាពនៃបាបមិត្ត ១។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ បានហើយ ទើបគួរលះបង់នូវភាពមិនមានសទ្ធា លះបង់នូវភាពមិនដឹងនូវពាក្យពោល លះបង់នូវសេចក្ដីខ្ជិលបាន។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ បានហើយ ទើបគួរលះបង់នូវសេចក្ដីមិនអើពើ លះបង់នូវភាពជាអ្នកប្រដៅក្រ លះបង់នូវភាពនៃបាបមិត្តបាន។ ធម៌ទាំង ៣ តើដូចម្ដេច។ គឺលះបង់នូវសេចក្ដីមិនអៀនខ្មាសនឹងអំពើទុច្ចរិត ១ លះបង់នូវសេចក្ដីមិនក្ដៅនឹងអំពើទុច្ចរិត ១ លះបង់នូវសេចក្ដីធ្វេសប្រហែស ១។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ បានហើយ ទើបគួរលះបង់នូវសេចក្ដីមិនអើពើ លះបង់នូវភាពជាអ្នកប្រដៅក្រ លះបង់នូវភាពនៃបាបមិត្តបាន។ ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះ ជាអ្នកមានសេចក្ដីអៀនខ្មាសនឹងអំពើទុច្ចរិត ក្ដៅនឹងអំពើទុច្ចរិត មិនប្រមាទ។ កាលបើបុគ្គលនោះ មិនប្រមាទហើយ ទើបគួរដើម្បីលះបង់នូវសេចក្ដីមិនអើពើ លះបង់នូវភាពជាអ្នកប្រដៅក្រ លះបង់នូវភាពនៃបាបមិត្តបាន។ កាលបើបុគ្គលនោះ មានកល្យាណមិត្តហើយ ទើបគួរដើម្បីលះបង់នូវភាពមិនមានសទ្ធា លះបង់នូវសេចក្ដីមិនដឹងនូវពាក្យពោល លះបង់នូវសេចក្ដីខ្ជិលបាន។ កាលបើបុគ្គលនោះ មានសេចក្ដីព្យាយាមប្រារព្ធហើយ ទើបគួរដើម្បីលះបង់នូវសេចក្ដីរវើរវាយ លះបង់នូវការមិនសង្រួម លះបង់នូវភាពទ្រុស្តសីលបាន។ កាលបើបុគ្គលនោះ មានសីល ទើបគួរដើម្បីលះបង់នូវសេចក្ដីប្រាថ្នា ដើម្បីមិនឃើញនូវព្រះអរិយៈទាំងឡាយ លះបង់នូវសេចក្ដីប្រាថ្នា ដើម្បីមិនស្ដាប់នូវអរិយធម៌

លះបង់នូវចិត្តប្រកួតប្រកាន់បាន។ កាលបើបុគ្គលនោះ មិនមានចិត្តប្រកួតប្រកាន់ហើយ ទើបគួរដើម្បីលះបង់នូវការភ្លេចស្មារតី លះបង់នូវសេចក្តីមិនដឹងខ្លួន លះបង់នូវសេចក្តីរសាប់រសល់នៃចិត្តបាន។ កាលបើបុគ្គលនោះ មិនមានចិត្តរសាប់រសល់ហើយ ទើបគួរដើម្បីលះបង់នូវកិរិយាធ្វើទុកក្នុងចិត្ត ដោយមិនមែនឧបាយ លះបង់នូវការសេពគប់នូវផ្លូវខុស លះបង់នូវសេចក្តីរួញរានៃចិត្តបាន។ កាលបើបុគ្គលនោះ មិនមានចិត្តរួញរាហើយ ទើបគួរដើម្បីលះបង់នូវសក្កាយទិដ្ឋិ លះបង់នូវវិចិកិច្ឆា លះបង់នូវសីលព្វតបរាមាសៈបាន។ កាលបើបុគ្គលនោះ មិនមានវិចិកិច្ឆាហើយ ទើបគួរដើម្បីលះបង់រាគៈ លះបង់ទោសៈ លះបង់មោហៈបាន។ កាលបើបុគ្គលនោះ លះបង់រាគៈ លះបង់ទោសៈ លះបង់មោហៈហើយ ទើបគួរដើម្បីលះបង់ជាតិ លះបង់ជរា លះបង់មរណៈបាន។ តយោធម្មសូត្រ ឬប្រសិនបើធម៌ទាំង៣ នេះ មិនមានក្នុងលោកទេ ព្រះតថាគតក៏មិនគប្បីកើតឡើងក្នុងលោកដែរ។

(បិដកលេខ៥០ ទំព័រ ៣១៣)

# គន្ថនិទ្ទេស


## ១–ក្រុមប្រឹក្សាជាតិភាសាខ្មែរ

វចនានុក្រមខ្មែរ បោះពុម្ពផ្សាយដោយក.ជ.ភ.ខ. ឆ្នាំ២០២២ភ្នំពេញ

## ២–បិដកលេខ១៦

ពុទ្ធសាសនបណ្ឌិត្យ ព.ស.២៥០០ភ្នំពេញ

## ៣–បិដកលេខ១៣២

ពុទ្ធសាសនបណ្ឌិត្យ ព.ស.២៥០០ភ្នំពេញ

## ៤–បិដកលេខ១៤២

ពុទ្ធសាសនបណ្ឌិត្យ ព.ស.២៥០០ភ្នំពេញ

## ៥–បិដកលេខ១៥០

ពុទ្ធសាសនបណ្ឌិត្យ ព.ស.២៥០០ភ្នំពេញ

## ៦–បិដកលេខ១៥២

ពុទ្ធសាសនបណ្ឌិត្យ ព.ស.២៥០០ភ្នំពេញ

## ៧–បិដកលេខ១៥៨

ពុទ្ធសាសនបណ្ឌិត្យ ព.ស.២៥០០ភ្នំពេញ

## ៨–ធម្មទស្សន៍

រុន ប៉ាណា បោះពុម្ពផ្សាយបណ្តុះចំណេះដឹង ឆ្នាំ២០២៤ ភ្នំពេញ

## ៩–ប្រជុំភាណវារ

សែម សួរ ការផ្សាយរបស់អ្នកនិពន្ធ ឆ្នាំ១៩៦៦ ភ្នំពេញ

**១០-ប្រជុំគាថាធម៌ បាលី-ប្រែ ពិសេស**

ព្រហ្ម មេត្តា ក្រុមធម្មមាមកជន ឆ្នាំ២០១៦

**១១-មេរៀនសំស្ក្រឹតថ្នាក់មូលដ្ឋាន ភាគ១**

អេង សុគង់ ក្រុមកូនខ្មែរអតិជាតបុត្រ ឆ្នាំ២០២១ ភ្នំពេញ

# សិលាចារឹកបុរាណខ្មែរ

## នមស្ការព្រះរតនត្រ័យនៅប្រាសាទព្រះរាជវិហារ

**សម្ពារវិស្តរវិភាវិតធម្មកាយ សម្ភោគនិម្មិតិវបុភិគវាន្វិភក្ត យោគោចរោជិនជិនាត្មជទេហភាជាំ ពុទ្ធាយ ភូតករុណាយនមោស្តុតស្មៃ។**

ព្រះមានព្រះភាគអង្គណា មានព្រះកាយបែកចេញជា ព្រះធម្មកាយ សម្ភោគកាយ និង និម្មិតកាយ ជាព្រះកាយដ៏បរិបូណ៌ ជាព្រះកាយដ៏ល្អិតសុខុមដែលកើតពីបុញ្ញសម្ភារ ហើយផ្សាយទៅដ៏រុងរឿងៗកិរិយានមស្ការនៃខ្ញុំ ចូរមានចំពោះព្រះវរកាយទាំងនោះដែលជាទីពឹងនៃពពួកនៃសត្វ ជាព្រះសម្ពុទ្ធអង្គ ដែលមានព្រះអង្គកាយកើតពីខ្លួននៃព្រះជិនស្រី គ្រប់ជាព្រះជិនបុត្រ។

# “សរសើរគុណព្រះរតនត្រ័យ”

## នមស្ការព្រះគុណព្រះពុទ្ធ

**អហោ ពុទ្ធោ នមោ តស្ស   អហោ ពុទ្ធោ នមាមិហំ**

**អហោ ពុទ្ធោ នមេហំតំ   អហោ ពុទ្ធោ អហំ នមេ។**

ឱហ្ន៎! ព្រះពុទ្ធអស្ចារ្យក្រៃលែង ចិត្តខ្ញុំចាត់ចែង ក្រាបថ្វាយបង្គំឱនកាយសំពះ ថ្វាយចិត្តសន្សំសែនជ្រះថ្លាជុំដល់ព្រះសម្ពុទ្ធ។

## នមស្ការព្រះគុណព្រះធម៌

**អហោ ធម្មោ នមោ តស្ស   អហោ ធម្មោ នមាមិហំ**

**អហោ ធម្មោ នមេហំតំ   អហោ ធម្មោ អហំ នមេ។**

ឱហ្ន៎! ព្រះធម៌អស្ចារ្យវិសុទ្ធ ចិត្តខ្ញុំបរិសុទ្ធ ក្រាបថ្វាយបង្គំឱនកាយសំពះ ថ្វាយចិត្តសន្សំសែនជ្រះថ្លាជុំដល់ព្រះធម៌ថ្លៃ។

## នមស្ការព្រះគុណព្រះសង្ឃ

**អហោ សង្ឃោ នមោ តស្ស   អហោ សង្ឃោ នមាមិហំ**

**អហោ សង្ឃោ នមេហំតំ   អហោ សង្ឃោ អហំ នមេ។**

ឱហ្ន៎! ព្រះសង្ឃអស្ចារ្យប្រពៃ ចិត្តខ្ញុំអាល័យ ក្រាបថ្វាយបង្គំឱនកាយសំពះ ថ្វាយចិត្តសន្សំសែនជ្រះថ្លាជុំដល់ព្រះសង្ឃថ្លៃ។

ភិក្ខុ សីលសំវរោ **ឯក សំ**   **ធម៌នមស្ការ និង ធម្មបទ**   **ព.ស.២៥៧០**